វិទ្យាស្ថានបណ្តុះបណ្តាល និង
ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិន លើការកាត់បន្ថយភាពក្រីក្រនៅ មហាអនុតំបន់ទន្លេមេគង្គ៖ ករណីសិក្សាប្រទេសកម្ពុជា





អ៊ូច-ច័ន្ទតារ៉ានី សាំង-ច័ន្ទហង្ស និង ផាន់-ដាលីស

ឯកសារពិភាក្សាលេខ ៥២

ខែមិថុនា ២០១១

ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

# ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិន លើការកាត់បន្ថយភាពក្រីក្រនៅ មហាអនុតំបន់ទន្លេមេគង្គ៖ ករណីសិក្សាប្រទេសកម្ពុជា

ឯកសារពិភាក្សាលេខ ៥២

អ៊ូច ច័ន្ទតារ៉ានី
សាំង ច័ន្ទហង្ស
ផាន់ ដាលីស

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ខែមិថុនា ២០១១ ភ្នំពេញ កម្ពុជា

**បេសកកម្ម វបសអ**

ក្នុងលក្ខណៈជា វិទ្យាស្ថានកម្ពុជាឯករាជ្យផ្នែកស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វបសអ មានបេសកកម្មរួមចំណែកដល់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព។

វបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា។

© **រក្សាសិទ្ធិឆ្នាំ២០១១ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (**វបសអ**)

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ដែលអាចយកទៅចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង...។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ។

**ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិនលើការកាត់បន្ថយភាពក្រីក្រនៅមហាអនុតំបន់ទន្លេមេគង្គ៖ ករណីសិក្សាប្រទេសកម្ពុជា**

**Assessing China's Impact on Poverty Reduction in the Greater Mekong Sub-region: The Case of Cambodia**

ខែមិថុនា ឆ្នាំ២០១១

**អ៊ូច-ច័ន្ទតារ៉ានី សាំង-ច័ន្ទហេង និង ផាន់-ដាលីស**

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ។*

**វិទ្យាស្ថាន** CDRI

អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣

ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤

អ៊ីមែល៖ cdri@cdri.org.kh    http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ឹង-សុជាតិ អ៊ុំ-ចាន់ថា និង យូ-សិទ្ធីរិទ្ធ

បោះពុម្ពនៅប្រទេសកម្ពុជាដោយ រោងពុម្ព ធី អេន អេស រាជធានីភ្នំពេញ

# មាតិកា

បញ្ជីរូបភាព តារាង និងប្រអប់ ......... v
បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ ......... vii
សេចក្តីថ្លែងអំណរគុណ ......... ix
ខ្លឹមសារសង្ខេប ......... 1

**ជំពូក ១ សេចក្តីផ្តើម** ......... 3
១.១ សាវតារ ......... 3
១.២ គោលបំណងនៃការស្រាវជ្រាវ ......... 3

**ជំពូក ២ ការពិនិត្យឡើងវិញលើការសិក្សាមានស្រាប់ និងស្ថានភាពនៃភាពក្រីក្រ** ......... 5
២.១ ការពិនិត្យនូវការសិក្សានានាអំពីផលប៉ះពាល់របស់ប្រទេសចិនមកលើសេដ្ឋកិច្ចកម្ពុជា ......... 5
២.២ ស្ថានភាពក្រីក្រនៅកម្ពុជា ......... 7
២.៣ ក្របខ័ណ្ឌគោលនយោបាយ ......... 11

**ជំពូក ៣ ពាណិជ្ជកម្មចិន និងផលប៉ះពាល់** ......... 15
៣.១ ទំហំ និងការប្រែប្រួលពាណិជ្ជកម្ម ......... 15
៣.២ ក្របខ័ណ្ឌនៃការវិភាគ និងវិធីសាស្ត្រ ......... 21
៣.៣ លទ្ធផល ......... 21

**ជំពូក ៤ វិនិយោគចិន និងផលប៉ះពាល់** ......... 35
៤.១ ទំហំ និងការប្រែប្រួលវិនិយោគ ......... 35
៤.២ ក្របខ័ណ្ឌវិភាគ និងវិធីសាស្ត្រ ......... 38
៤.៣ ករណីសិក្សា ......... 40
៤.៣.១ ការពិនិត្យជាទូទៅលើវិស័យកាត់ដេរ ......... 40
៤.៣.២ លទ្ធផល ......... 41

**ជំពូក ៥ ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ចិន និងផលប៉ះពាល់** ......... 49
៥.១ ទំហំ និងការប្រែប្រួល ......... 49
៥.២ វិធីសាស្ត្រ និងក្របខ័ណ្ឌនៃការវិភាគ ......... 53

៥.៣ ករណីសិក្សា ........ 54

៥.៣.១ សាវតារករណីសិក្សា ........ 54

៥.៣.២ លទ្ធផលស្រាវជ្រាវ ........ 55

**ជំពូក ៦ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្នែកគោលនយោបាយ** ........ 63

៦.១ សេចក្តីសន្និដ្ឋាន ........ 63

៦.២ ការពិភាក្សាខាងគោលនយោបាយ ........ 66

**ឯកសារយោង** ........ 68

**ឧបសម្ព័ន្ធ** ........ 71

ឧបសម្ព័ន្ធ ១៖ ការបែងចែកផលិតផលលេខ ៣ខ្ទង់របស់ SITC ទៅតាមក្រុមអ្នកប្រើប្រាស់ និងក្រុមផលិតកម្ម ..... 71

ឧបសម្ព័ន្ធ ២៖ ចំណែកនៃផលិតផលនាំចេញនិងនាំចូលពីចិន (១៩៩២-២០០៨) នៅកម្រិតលេខ ៣ខ្ទង់ ........ 72

ឧបសម្ព័ន្ធ ៣៖ ការពិភាក្សាតាមក្រុមស្នូល៖ ODA របស់ចិន លើការស្តារផ្លូវជាតិលេខ៧ពីក្រចេះ ទៅត្រពាំងគ្រៀល ........ 82

ឧបសម្ព័ន្ធ ៤៖ ការពិភាក្សាតាមក្រុមស្នូល៖ សំណង់ស្ពានព្រែកតាមាក់ក្រោមមូលនិធិ ODA របស់ចិន ........ 96

បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI ........ 112

# បញ្ជីរូបភាព តារាង និងប្រអប់

## បញ្ជីរូបភាព


រូបភាព ២.១៖ ភាគរយប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្របែងចែកតាមតំបន់៥ ...... 10

រូបភាព ៣.១៖ ការនាំចេញរបស់កម្ពុជាទៅប្រទេសចិន និង ពិភពលោក ២០០០-២០០៨ ...... 17
រូបភាព ៣.២៖ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ចិន និង ជញ្ជីងពាណិជ្ជកម្ម ...... 18
រូបភាព ៣.៣៖ ក្របខ័ណ្ឌវិភាគពីផលប៉ះពាល់នៃពាណិជ្ជកម្មចិនលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ...... 21
រូបភាព ៣.៤៖ ចំណែកទីផ្សារសម្លៀកបំពាក់ពីអាស៊ីនៅក្នុងទីផ្សារសហរដ្ឋអាមេរិក ...... 29
រូបភាព ៣.៥៖ ចំណែកទីផ្សារនៃផលិតផលសម្លៀកបំពាក់នាំមុខគេ ១២មុខ របស់កម្ពុជា នៅក្នុងទីផ្សារសហរដ្ឋអាមេរិក ...... 31
រូបភាព ៣.៦៖ ចំណែកទីផ្សារសម្លៀកបំពាក់ពីអាស៊ី នៅក្នុងទីផ្សារអឺរ៉ុប ...... 32
រូបភាព ៣.៧៖ ចំណែកទីផ្សារនៃផលិតផលសម្លៀកបំពាក់នាំមុខគេរបស់កម្ពុជានៅក្នុងទីផ្សារអឺរ៉ុប ឆ្នាំ១៩៩០-២០០៩ ...... 34

រូបភាព ៤.១៖ វិនិយោគផ្ទាល់ពីបរទេសក្នុងប្រទេសកម្ពុជា ...... 35
រូបភាព ៤.២៖ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់តាមវិស័យ ពីឆ្នាំ១៩៩៨ ដល់ ២០០៨ ...... 37
រូបភាព ៤.៣៖ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់របស់ចិនតាមវិស័យជ្រើសរើស ពីឆ្នាំ១៩៩៨ ដល់ ២០០៨ ...... 38
រូបភាព ៤.៤៖ ក្របខ័ណ្ឌវិភាគពីវិនិយោគចិននៅកម្ពុជា ...... 39
រូបភាព ៤.៥៖ មុខរបរពីមុនរបស់កម្មករកាត់ដេរក្នុងគំរូតាង ...... 43
រូបភាព ៤.៦៖ ភាគរយកម្មករគំរូតាងបានផ្ញើប្រាក់ទៅផ្ទះ ...... 45
រូបភាព ៤.៧៖ ការប្រើប្រាស់ដោយក្រុមគ្រួសារនូវប្រាក់ផ្ញើទៅផ្ទះរបស់កម្មករ ...... 45
រូបភាព ៤.៨៖ កម្មវិធីបណ្តុះបណ្តាលរបស់រោងចក្រកាត់ដេរ ...... 46
រូបភាព ៤.៩៖ ការគាំទ្ររបស់រោងចក្រកាត់ដេរ ចំពោះការចូលរួមវគ្គបណ្តុះបណ្តាលនៅខាងក្រៅរោងចក្រ ...... 46
រូបភាព ៤.១០៖ ជំនាញ និង ចំណេះដឹងទទួលបានពីការងារបច្ចុប្បន្ន ...... 47
រូបភាព ៤.១១៖ ការប្រើប្រាស់ជំនាញ និង ចំណេះដឹងទទួលបានពីការងារបច្ចុប្បន្ន ...... 47
រូបភាព ៤.១២៖ ចំណាប់អារម្មណ៍របស់កម្មករគំរូតាង អំពីការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ចគ្រួសារ ...... 48

រូបភាព ៥.១៖ ការបើកផ្តល់ជំនួយក្នុងវិស័យដឹកជញ្ជូនដោយដៃគូសំខាន់ៗ ...... 51
រូបភាព ៥.២៖ ក្របខ័ណ្ឌវិភាគនៃគម្រោង ODA របស់ចិននៅកម្ពុជា ...... 53
រូបភាព ៥.៣៖ ផែនទីខេត្តក្រចេះ និង ស្ទឹងត្រែង ...... 56


## បញ្ជីតារាង


តារាង ២.១៖ បន្ទាត់ភាពក្រីក្រអាហារ ប្រាក់បន្ថែមសម្រាប់ទំនិញមិនមែនអាហារ និងបន្ទាត់ភាពក្រីក្រសរុប ...... 9

តារាង ៣.១៖ ពាណិជ្ជកម្មទ្វេភាគីកម្ពុជាជាមួយពិភពលោក ឆ្នាំ២០០០-២០០៨ ..... 16
តារាង ៣.២៖ ផលិតផលនាំមុខគេ ១០មុខ ដែលកម្ពុជានាំចេញទៅចិន នៅឆ្នាំ២០០០-២០០៨ ..... 19
តារាង ៣.៣៖ ផលិតផលឈានមុខទាំង១០ នាំចូលពីចិន នៅឆ្នាំ២០០៨ ..... 20
តារាង ៣.៤៖ ចំណែកនៃការនាំចេញផលិតផលជាក់លាក់ធៀបនឹងការនាំចេញសរុបទៅចិន ពីឆ្នាំ១៩៩២ ដល់ ២០០៨ នៅកម្រិតលេខ ៣ខ្ទង់ ..... 22
តារាង ៣.៥៖ ចំណែកនៃការនាំចេញផលិតផលជាក់លាក់ ធៀបនឹងការនាំចេញសរុបទៅចិន ពីឆ្នាំ១៩៩២ ដល់ ២០០៨ ..... 23
តារាង ៣.៦៖ ចំណែកនៃការនាំចូលផលិតផលជាក់លាក់ ធៀបនឹងការនាំចូលសរុបពីចិន ឆ្នាំ១៩៩២-២០០៨ នៅកម្រិតលេខ ៣ខ្ទង់ ..... 25
តារាង ៣.៧៖ ចំណែកនៃទំនិញសម្រាប់ជនក្រីក្រ នាំចូលពីចិននៅឆ្នាំ១៩៩២-២០០៨ ..... 27
តារាង ៣.៨៖ ចំណែកផលិតផលសម្រាប់ជនក្រីក្រ នៅក្នុងផលិតផលសរុបនាំចូលពីចិន ១៩៩២-២០០៨ ..... 27
តារាង ៣.៩៖ ភាពស្រដៀងគ្នាខាងការនាំចេញរវាងចិន និង កម្ពុជា ពីឆ្នាំ១៩៩២ ដល់ ២០០៨ ..... 28
តារាង ៣.១០៖ សម្លៀកបំពាក់នាំមុខគេ ១២មុខ ដែលកម្ពុជានាំចេញទៅទីផ្សារសហរដ្ឋអាមេរិក ពីឆ្នាំ១៩៩០-២០០៨ ..... 30
តារាង ៣.១១៖ សម្លៀកបំពាក់នាំមុខគេ ១២មុខ ដែលកម្ពុជានាំចេញទៅទីផ្សារអឺរ៉ុបពីឆ្នាំ១៩៩០-២០០៨ ..... 33

តារាង ៤.១៖ វិនិយោគិនឈានមុខទាំង ១២ ក្នុងប្រទេសកម្ពុជា ពីឆ្នាំ១៩៩៨ ដល់ ២០០៨ ..... 36
តារាង ៤.២៖ វិនិយោគរបស់ប្រទេសចិនក្នុងប្រទេសកម្ពុជា ពីឆ្នាំ១៩៩៨ ដល់ ២០០៩ ..... 36
តារាង ៤.៣៖ រោងចក្រកាត់ដេរចុះបញ្ជីជាសមាជិក GMAC ..... 41
តារាង ៤.៤៖ រោងចក្រជ្រើសរើសសម្រាប់ការសិក្សា និង ចំនួនកម្មករបានសម្ភាស ..... 42
តារាង ៤.៥៖ ចំនួនសរុបនៃកម្មករគំរូតាង និងការបែងចែកតាមភេទ ប្រភេទការងារ និង បទពិសោធន៍ការងារ ..... 43
តារាង ៤.៦៖ ប្រាក់ចំណូលរបស់កម្មករក្នុងគំរូតាង ..... 44
តារាង ៤.៧៖ ការវាយតម្លៃបរិយាកាសការងារតាមចម្លើយរបស់កម្មករគំរូតាង ..... 44

តារាង ៥.១៖ ការបើកផ្តល់ជំនួយរបស់ចិនពីឆ្នាំ២០០០-២០០៩ ..... 50
តារាង ៥.២៖ ការបើកផ្តល់ជំនួយរបស់ចិនតាមវិស័យឆ្នាំ២០០៥-២០០៩ ..... 51

**បញ្ជីប្រអប់**

ប្រអប់ ១៖ ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ចិន ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តមូលដ្ឋាននៅកម្ពុជាឆ្នាំ២០០៤-០៩ ..... 52

# បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| ACFTA | តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ASEAN-China Free Trade Area) |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) |
| AFTA | តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (ASEAN Free Trade Area) |
| AMK | អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជា (Angkor Mikroheranhvatho Kampuchea) |
| ARTNeT | បណ្ដាញបណ្ដុះបណ្ដាល និងស្រាវជ្រាវអាស៊ីប៉ាស៊ីហ្វិក ស្ដីពីពាណិជ្ជកម្ម (Asia-Pacific Research and Training Network on Trade) |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (Association of South East Asian Nations) |
| ASYCUDA | ប្រព័ន្ធទិន្នន័យគយស្វ័យប្រវត្តិ (Automated System of Customs Data) |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (Council for the Development of Cambodia) |
| CDRI | វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| CLMV | កម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម (Cambodia Laos Mayanmar Vietnam) |
| CMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (Cambodia Millennium Development Goals) |
| CNOOC | ក្រុមហ៊ុនជាតិចិនរកប្រេងក្នុងសមុទ្រ (China National Offshore Oil Corporation) |
| CNRS | មជ្ឈមណ្ឌលជាតិស្រាវជ្រាវវិទ្យាសាស្ត្រ (Centre National de la Recherche Scientifique) |
| CPI | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (Consumer Price Index) |
| CRDB | គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (Cambodian Rehabilitation and Development Board) |
| CSES | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (Cambodia Socio-Economic Survey) |
| DTIS | ការសិក្សាពីស្ថានភាពសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (Diagnostic Trade Integration Study) |
| EBA | គំនិតផ្ដួចផ្ដើមលើការនាំចូលទំនិញគ្រប់ប្រភេទក្រៅពីអាវុធ (Everything But Arms) |
| EHP | កម្មវិធីប្រមូលផលដើមដៃ (Early Harvest Programme) |
| EIC | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (Economic Institute of Cambodia) |
| ELC | ដីសម្បទានសេដ្ឋកិច្ច (Economic Land Concession) |
| FDI | វិនិយោគផ្ទាល់ពីបរទេស (Foreign Direct Investment) |
| FGD | ការពិភាក្សាតាមក្រុមស្នូល (Focus Group Discussion) |
| GDRP | អគ្គនាយកដ្ឋានចម្ការកៅស៊ូ (General Directorate of Rubber Plantations) |
| GMAC | សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (Garment Manufacturers Association in Cambodia) |
| GMS-DAN | មហាអនុតំបន់ទន្លេមេគង្គ-បណ្ដាញវិភាគអភិវឌ្ឍន៍ (Greater Mekong Sub-region - Development Analysis Network) |
| GSP | ប្រព័ន្ធអនុគ្រោះទូទៅ (Generalised System of Preference) |
| LCD | ប្រទេសលូតលាស់តិចជាងគេ (Least Developed Countries) |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture, Forestry and Fisheries) |
| MFN | លក្ខខណ្ឌអនុគ្រោះផ្នែកពាណិជ្ជកម្ម (Most Favoured Nation) |
| MoC | ក្រសួងពាណិជ្ជកម្ម (Ministry of Commerce) |
| NIS | វិទ្យាស្ថានជាតិស្ថិតិ (National Institute of Statistics) |
| NPRS | យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (National Poverty Reduction Strategy) |

| | | |
|---|---|---|
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ( National Strategic Development Plan ) |
| ODA | ជំនួយអភិវឌ្ឍន៍ផ្លូវការ ( Official Development Assistance ) |
| OECD | អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍<br>( Organisation for Economic Co-operation and Development ) |
| OGB | អង្គការអុកស្វាមអង់គ្លេស ( Oxfam Great Britain ) |
| RMB | ប្រាក់យ៉ុនចិន-រូបិយវត្ថុចិន ( Renminbi - currency of China ) |
| SEDP | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ( Socio-Economic Development Plan ) |
| SESC | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ( Socio-Economic Survey of Cambodia ) |
| SITC | ចំណាត់ថ្នាក់ស្តង់ដារពាណិជ្ជកម្មអន្តរជាតិ ( Standard International Trade Classification ) |
| Trade SWAp | អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ( Trade Sector-wide Approach ) |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ<br>( United States Agency for International Development ) |
| USITC | គណៈកម្មការពាណិជ្ជកម្មអន្តរជាតិសហរដ្ឋអាមេរិក ( United States International Trade Commission ) |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក ( World Trade Organisation ) |

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ សូមអរគុណជាអនេកប្បការចំពោះសហសេវិក បុគ្គល និងស្ថាប័ននានា ដែលបានរួមចំណែក និងឧបត្ថម្ភគាំទ្រដល់ការស្រាវជ្រាវនេះ។ សូមសម្តែងការដឹងគុណដ៏ជ្រាលជ្រៅជាពិសេសទៅដល់ មូលនិធិ Rockefeller ដែលបានផ្តល់ជំនួយហិរញ្ញវត្ថុដល់មហាអនុតំបន់ទន្លេមេគង្គ-បណ្តាញវិភាគអភិវឌ្ឍន៍ (GMS-DAN) សម្រាប់ការសិក្សានេះ។ GMS-DAN ទទួល បានការសម្របសម្រួលពីកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ (ETRC) នៃវិទ្យាស្ថាន CDRI និងមានដំណើរការក្រោមកិច្ចសហការរវាងគ្រឹះស្ថានអប់រំ និងវិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍ឈានមុខនៅប្រទេសកម្ពុជា ឡាវ ថៃ វៀតណាម និងខេត្តយុនណានប្រទេសចិន។

សូមថ្លែងអំណរគុណ ចំពោះលោក Larry Strange ជានាយកប្រតិបត្តិ និងបណ្ឌិត Rebeca F. Catalla ជាទីប្រឹក្សាស្រាវជ្រាវនៃ CDRI ដែលបានយកចិត្តទុកដាក់ និងជួយគាំទ្រយើងខ្ញុំ ហើយក៏សូមអរគុណចំពោះបណ្ឌិត Hossein Jalilian សម្រាប់ការជួយគាំទ្រយ៉ាងខ្លាំងក្លា និងជាប្រចាំ ទាំងខាងបច្ចេកទេស និងការសម្របសម្រួល។ សូមអរគុណផងដែរដល់សមាជិក GMS-DAN ទាំងអស់ ចំពោះការផ្តល់មតិស្ថាបនា និងមានប្រយោជន៍ក្នុងពេលធ្វើសិក្ខាសាលាពិភាក្សា។ យើងខ្ញុំក៏សូមសម្តែងការដឹងគុណ ចំពោះសមាជិកក្រុមស្រាវជ្រាវរបស់យើង គឺលោកស្រី ប៉ុន ដូរីណា ក្នុងការសម្របសម្រួលការងារដល់មូលដ្ឋាន កញ្ញា ផាន់ ដាលីស និងលោកស្រី ស្រ៊ី បុប្ផារ័ត្ន ក្នុងការជួយប្រមូលទិន្នន័យ និងជួយកិច្ចការចុះដល់មូលដ្ឋាន។ សូមថ្លែងអំណរគុណជាពិសេសដល់លោកស្រី Susan Watkins ចំពោះការជួយកែលម្អអត្ថបទនេះ និងអរគុណដល់លោក អ៊ឹង ស៊ានលី នាយកផ្នែកប្រតិបត្តិការ លោក តុង គឹមស៊ុន អ្នកសម្របសម្រួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្មនិងសហប្រតិបត្តិការក្នុងតំបន់ និងបុគ្គលិកជំនួយជាច្រើនទៀតនៅវិទ្យាស្ថាន CDRI។

ភ្នំពេញ ខែមិថុនា ឆ្នាំ២០១១

# ខ្លឹមសារសង្ខេប

ទំនាក់ទំនងពាណិជ្ជកម្មកាន់តែស៊ីជម្រៅរវាងកម្ពុជា និងចិន បាននាំមកនូវការរីកលូតលាស់ខ្លាំងនៃពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរ ប៉ុន្តែ ឱនភាពជញ្ជីងពាណិជ្ជកម្មរបស់កម្ពុជា នៅតែបន្តមានអត្រាកំណើនប្រចាំឆ្នាំជាមធ្យម ៣៤%។ ការសិក្សានេះ ប្រើក្របខ័ណ្ឌបង្កើតឡើងដោយ Jenkins និង Edwards (2004) ដើម្បីកំណត់អំពីពាណិជ្ជកម្មចិន-កម្ពុជា និងផលប៉ះពាល់ទៅលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា តាមរយៈទិដ្ឋភាពជាក់លាក់ ៣ គឺការនាំចេញទៅចិន ការនាំចូលពីចិន និងការនាំចេញទៅទីផ្សារទីបី។

លំនាំនៃការនាំចេញរវាងឆ្នាំ១៩៩២ និងឆ្នាំ២០០៨ មានការប្រែប្រួលគួរឲ្យកត់សម្គាល់។ ចំណែកនៃផលិតផលកសិកម្មអតិពលកម្ម ធ្លាក់ចុះយ៉ាងគំហុកពី ៥១,៤% ក្នុងឆ្នាំ១៩៩២ មកត្រឹម ៩,១% ក្នុងឆ្នាំ២០០០ បន្ទាប់មកងើបឡើងវិញដល់ ២៩,៦% ក្នុងឆ្នាំ២០០៨។ ចំណែកនៃការនាំចេញសត្វរស់ និងត្រី ក៏ឃើញមានការកើនឡើងពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៨។ ចំណែកនៃការនាំចេញទំនិញវាយនភ័ណ្ឌអតិពលកម្ម និងសម្លៀកបំពាក់ទៅប្រទេសចិន ក៏មានកំណើនខ្លាំងដែរ ពី ៣,២% ក្នុងឆ្នាំ១៩៩២ ដល់ ២៨,២% ក្នុងឆ្នាំ២០០៨។ កំណើនចំណែកនៃផលិតផលទាំងពីរនេះ ពិតជាបានរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដោយបានបង្កើតនូវការងារជាច្រើន។

ទិន្នន័យស្តីពីការនាំចូលពីប្រទេសចិន បង្ហាញនូវបរិមាណតិចតួច និងការថយចុះចំណែកនៃផលិតផលកសិកម្មអតិពលកម្ម នៅរវាងឆ្នាំ១៩៩២ និងឆ្នាំ២០០៨។ ប្រទេសទាំងពីរហាក់មិនមានការប្រកួតប្រជែងគ្នាខាងទីផ្សារផលិតផលកសិកម្មក្នុងស្រុកទេ។ ផលិតផលនាំចូលមួយចំនួនដែលកម្ពុជាមិនមានឯកទេសផលិតនោះ មានលក្ខណៈបំពេញឲ្យផលិតផលក្នុងស្រុក ប៉ុន្តែការកើនឡើងជាបន្តបន្ទាប់តតជាប់នៃចំណែកផលិតផលជាក់លាក់មួយចំនួនក្នុងប្រភេទនេះ ទោះក្នុងបរិមាណតិចតួចក្តី អាចបង្កការគំរាមកំហែងដល់ការប្រកួតប្រជែងរបស់ផលិតករកម្ពុជានាពេលអនាគត។ សំខាន់ជាងនេះទៀត ការកើនឡើងយ៉ាងគំហុកនៃចំណែកការនាំចូលសម្លៀកបំពាក់ និងទំនិញវាយនភ័ណ្ឌអតិពលកម្ម នៅរវាងឆ្នាំ១៩៩២ និងឆ្នាំ២០០៨ មិនបានប្រកួតប្រជែងជាមួយទីផ្សារក្នុងស្រុកទេ ព្រោះផលិតផលទាំងនេះត្រូវបានផ្គុំគ្នាឡើងសម្រាប់នាំចេញបន្តទៅទីផ្សារទីបី។ កំណើនចំណែកនៃការនាំចូលផលិតផលទាំងពីរខាងលើ ហាក់បានរួមចំណែកដល់ការបង្កើតការងារនៅកម្ពុជា ដូច្នេះវាមានឥទ្ធិពលវិជ្ជមានលើភាពក្រីក្រ ប៉ុន្តែក៏បានរាំងស្ទះដល់ការអភិវឌ្ឍទំនាក់ទំនងដើមខ្សែ* (backward linkage) នៃឧស្សាហកម្មនៅក្នុងសេដ្ឋកិច្ចក្នុងស្រុកផងដែរ។

ទាក់ទិននឹងផលចំណេញពីទំនិញប្រើប្រាស់ ទិន្នន័យបញ្ជាក់ថា ចំណែកនៃការនាំចូលទំនិញប្រើប្រាស់សម្រាប់ជនក្រីក្របានកើនឡើងពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០០០ ប៉ុន្តែធ្លាក់ចុះវិញពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៨។ ទិន្នន័យនេះបង្ហាញថា ផលចំណេញពីទំនិញប្រើប្រាស់គុណភាពទាប ដែលបានពីការនាំចូលផលិតផលប្រើប្រាស់តម្លៃទាបរបស់ចិន បានធ្លាក់ចុះបន្តិចនៅពាក់កណ្តាលទី២ នៃរយៈពេលនេះ ដែលធ្វើឲ្យការនាំចូលទំនិញពីចិនសម្រាប់ជនក្រីក្រ មិនសូវបានរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាទេ។ ផលិតផលនាំចូលជាប្រចាំសម្រាប់ជនក្រីក្រ រួមមាន ត្រី គ្រាប់ធញ្ញជាតិ បន្លែ ផ្លែឈើ ភេសជ្ជៈ សម្លៀកបំពាក់ និងសម្លៀកបំពាក់ប្រើរួច។

ការវិភាគការនាំចេញទៅកាន់ទីផ្សារប្រទេសទី៣ បង្ហាញថា កម្ពុជា និងចិន អាចជាគូប្រជែងខាងទំនិញកម្មន្តសាល តែមិនមែនទំនិញកសិកម្មនោះទេ។ ការពិនិត្យបន្ថែមលើការនាំចេញសម្លៀកបំពាក់នាំមុខគេទាំង ១២មុខ ទៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប បង្ហាញថា កម្ពុជាមានការប្រកួតប្រជែងខ្លាំងជាមួយចិនក្នុងទីផ្សារអាមេរិក តែមិនមែនក្នុងទីផ្សារអឺរ៉ុបទេ ព្រោះកម្ពុជាមានចំណែកតិចតួចប៉ុណ្ណោះ (ពី 0,0១ ទៅ ១0%) នៅក្នុងទីផ្សារអឺរ៉ុប។ ក្នុងចំណោមសម្លៀកបំពាក់ទាំង ១២មុខក្នុងទីផ្សារអាមេរិក ចំណែករបស់ចិន មានការធ្លាក់ចុះ សម្រាប់សម្លៀកបំពាក់ធ្វើពីក្រណាត់ចាក់ (SITC 8459) ស្របពេលដែលចំណែករបស់កម្ពុជាមានការកើនឡើង ដែលបង្កើតនូវឱកាសសម្រាប់អ្នកផ្គត់ផ្គង់ក្នុងស្រុក។ យ៉ាងណាមិញ

* ទំនាក់ទំនងរវាងអ្នកផលិត និងអ្នកផ្គត់ផ្គង់ធាតុចូល។

កំណើនយ៉ាងគំហុកនៃចំណែកទីផ្សាររបស់ចិនសម្រាប់សម្លៀកបំពាក់ដទៃទៀត អាចបង្កការគំរាមគំហែងធ្ងន់ធ្ងរដល់ផលិតករនៅកម្ពុជា។ បញ្ហានេះ អាចមានផលប៉ះពាល់អវិជ្ជមានដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

ស្របជាមួយនឹងការវិភាគពាណិជ្ជកម្មចិន ឥទ្ធិពលលើភាពក្រីក្រនៃវិនិយោគរបស់ចិននៅកម្ពុជា ក៏មានលើកមកពិនិត្យផងដែរ ដោយប្រើក្របខ័ណ្ឌ Jenkins និង Edwards's (2004)។ ការសិក្សាក៏បានពិនិត្យនូវវិនិយោគផ្ទាល់ពីបរទេស (FDI) លើផ្នែកអតិពលកម្ម ដែលមានសារៈសំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រ ដោយដើរតួជាប្រភពបង្កើតការងារដ៏ចំបងមួយនៅកម្ពុជា។ ករណីសិក្សាលើវិស័យកាត់ដេរដែលជាវិស័យទាក់ទាញការវិនិយោគខ្លាំងពីប្រទេសចិននោះ បានពិនិត្យពីផលប៉ះពាល់នៃវិនិយោគរបស់ចិននៅកម្ពុជា តាមរយៈ (១) កំណើនប្រាក់ចំណូលជនក្រីក្រនៅជនបទតាមរយៈការបង្កើតការងារ និងប្រាក់កម្រៃខ្ពស់ជាងមុន (២) ប្រាក់ផ្ញើទៅផ្ទះ និង (៣) ការអភិវឌ្ឍជំនាញរបស់ជនក្រីក្រនៅជនបទ។

ករណីសិក្សានេះបង្ហាញថា វិនិយោគរបស់ចិនក្នុងវិស័យកាត់ដេរនៅកម្ពុជា បានរួមចំណែកមួយកម្រិតដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារសម្រាប់ប្រជាជនជនបទ។ អង្កេតកម្មករកាត់ដេរចំនួន ៣០០នាក់ បានធ្វើឡើងនៅរាជធានីភ្នំពេញ (១៥០នាក់ពីរោងចក្រចិន និង ១៥០នាក់ទៀតក្រៅពីរោងចក្រចិន)។ អង្កេតបង្ហាញថា ៧០% នៃអ្នកឆ្លើយសម្ភាសន៍ ធ្លាប់ប្រកបមុខរបរខ្លួនឯង ហើយ ៤៥% ក្នុងនោះ កំពុងធ្វើការនៅរោងចក្រចិន។ កម្មករកាត់ដេរទាំងក្នុងរោងចក្រចិន និងមិនមែនចិន រកប្រាក់ចំណូលជាមធ្យមបាន ៨០ដុល្លារ/ខែ ឬ ២,៦៧ដុល្លារ/ថ្ងៃ (ឬ ២,០៣ដុល្លារ/ថ្ងៃ គិតតាមថ្លៃថេរឆ្នាំ២០០៦) គឺមានកម្រិតខ្ពស់ជាងបន្ទាត់ក្រីក្រមធ្យមនៅរាជធានីភ្នំពេញដែលមានចំនួន ០,៧៦ដុល្លារ/ថ្ងៃ (០,៧១ ដុល្លារ/ថ្ងៃ គិតជាថ្លៃថេរឆ្នាំ២០០៦)។ ប្រាក់ផ្ញើទៅផ្ទះរបស់កម្មករ ត្រូវប្រើសម្រាប់ម្ហូបអាហារប្រចាំថ្ងៃរបស់គ្រួសារ (៦៤%) និងសម្រាប់វិនិយោគលើវិស័យកសិកម្ម សងបំណុល និងសន្សំសម្រាប់កូនៗ។ ទាក់ទិននឹងការអភិវឌ្ឍជំនាញ ទាំងរោងចក្រចិន និងមិនមែនចិន ហាក់ដូចជាមិនមានកម្មវិធីបណ្តុះបណ្តាលច្បាស់លាស់ទេ។ គេឃើញមានតែកម្មករឆ្លើយសម្ភាសន៍ពីរនាក់ប៉ុណ្ណោះ (ធ្វើការនៅរោងចក្រចិន) ដែលទទួលបានការបណ្តុះបណ្តាលក្នុងការរចនាម៉ូតថ្មីៗ និងច្បាប់ការងារ។

សរុបមក វិនិយោគចិនក្នុងវិស័យកាត់ដេរ បានរួមចំណែកច្រើនណាស់ដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដោយផ្តល់នូវឱកាសការងារ និងជួយបង្កើតប្រាក់ចំណូលដល់ជនក្រីក្រនៅជនបទ។

ផលប៉ះពាល់នៃជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ចិនទៅលើការកាត់បន្ថយភាពក្រីក្រ ត្រូវបានវាយតម្លៃតាមរយៈករណីសិក្សាពីរ លើគម្រោងផ្តល់មូលនិធិក្នុងវិស័យដឹកជញ្ជូន គឺការជួសជុលផ្លូវជាតិលេខ៧ ពីខេត្តក្រចេះ ទៅត្រពាំងក្រៀល (ច្រកព្រំដែនទៅឡាវ) និងការសាងសង់ស្ពានព្រែកតាមាក់ នៅខេត្តកណ្តាល។ ករណីសិក្សានេះ ផ្តោតជាសំខាន់លើការវាយតម្លៃផលប៉ះពាល់នៃគម្រោងនីមួយៗទៅលើជីវភាពប្រជាជនមូលដ្ឋាន និងការអភិវឌ្ឍសង្គមរបស់សហគមន៍មូលដ្ឋាន ដោយផ្អែកជាចំបងលើទស្សនៈរបស់ប្រជាជនមូលដ្ឋាន។ ផ្លូវ និងស្ពានថ្មី សង់ដោយគម្រោងចំណាយរបស់ចិន ផ្តល់ផលប្រយោជន៍វិជ្ជមានឲ្យអ្នកភូមិ ច្រើនជាងផលអវិជ្ជមាន។ ឱកាសដាំដំណាំមានច្រើនជាងមុន និងលទ្ធភាពចូលទៅកាន់ទីផ្សារកាន់តែប្រសើរឡើង បានជួយលើកកម្ពស់ជីវភាពរស់នៅរបស់អ្នកភូមិ។ ពួកគាត់ក៏អាចទទួលបានការអប់រំងាយស្រួលជាងមុន សេវាថែទាំសុខភាពប្រសើរជាងមុន និងអាចធ្វើដំណើរបានឆ្ងាយជាងមុនដើម្បីរកការងារធ្វើ និងសិក្សាពីពិភពខាងក្រៅ តាមរយៈការធ្វើដំណើរទៅកាន់ទីរួមខេត្តផ្សេងៗ ឬ រាជធានីភ្នំពេញ។ លើសពីនេះទៀត ទីភ្នាក់ងារអភិវឌ្ឍន៍នានា អាចចូលទៅដល់ភូមិស្រុករបស់ពួកគាត់ ហើយនាំយកសេវាសង្គមកិច្ចទៅកាន់តំបន់ទាំងនោះ ព្រមទាំងបានជួយគ្រប់គ្រងធនធានព្រៃឈើនៅទីនោះទៀតផង។ សរុបមក គម្រោងទាំងពីរបាននាំមកនូវជម្រើសច្រើនជាងមុនសម្រាប់ការរកស៊ីចិញ្ចឹមជីវិតរបស់ប្រជាជនមូលដ្ឋាន។

## ជំពូក ១

# សេចក្តីផ្តើម

### ១.១ សាវតារ

ក្នុងរយៈពេល ៣ទសវត្សរ៍ចុងក្រោយនេះ ប្រទេសចិនមានការផ្លាស់ប្តូរយ៉ាងខ្លាំង ការអភិវឌ្ឍយ៉ាងលឿន និងការចូលរួមកាន់តែច្រើននៅក្នុងកិច្ចការនយោបាយ សេដ្ឋកិច្ចកម្រិតតំបន់ និងសាកលលោក។ សមិទ្ធផលដ៏សំខាន់នេះ បានក្លាយទៅជាប្រធានបទសម្រាប់ពិភាក្សាយ៉ាងខ្លាំងក្លា ដោយគេមើលឃើញប្រទេសចិនថាជាឱកាសល្អផង និងជាការគំរាមកំហែងខាងសេដ្ឋកិច្ចផង។

ប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ (GMS) មានទីតាំងភូមិសាស្ត្រនៅជិតចិន និងជាតំបន់មួយមានការប្រែប្រួល និងសក្តានុពលខ្លាំងសម្រាប់ការអភិវឌ្ឍ ហើយអាចក្លាយជាទីផ្សារយុទ្ធសាស្ត្រ និងផ្តល់នូវរបៀបរៀបចំស្ថាប័នមួយសម្រាប់ជួយពង្រឹងសមាហរណកម្មក្នុងតំបន់របស់ប្រទេសចិន។ ដូចគ្នាដែរ ចិនអាចក្លាយជាច្រកចេញចូល និងជាគោលដៅទីផ្សារដ៏សំខាន់សម្រាប់ប្រទេស GMS ដែលអាចជួយកាត់បន្ថយការពឹងផ្អែកទៅលើទីផ្សារអន្តរជាតិនៃការនាំចេញរបស់ពួកគេ។ តាមរយៈការតភ្ជាប់ជាមួយប្រទេស GMS ចិនបានកសាងទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគដ៏ធំសម្បើម និងបានផ្តល់ការគាំទ្រជាជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ជាពិសេសក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។

កម្ពុជា បានចាត់ទុកចិនជាដៃគូអភិវឌ្ឍន៍មានអនាគតល្អ ដែលអាចពន្លឿនការអភិវឌ្ឍប្រទេស និងកាត់បន្ថយគម្លាតជាមួយប្រទេសដទៃទៀតនៅតំបន់អាស៊ី។[១] ទម្ងន់វត្តមានរបស់ចិន កំពុងកើនឡើងយ៉ាងច្បាស់នៅកម្ពុជា ដែលនាំឲ្យមានការយកចិត្តទុកដាក់ខ្ពស់លើការរួមចំណែក និងផលប៉ះពាល់ផ្សេងៗ។ ក្នុងការពិភាក្សាបញ្ហាទាំងនេះ យើងគួរសិក្សាពីកំណើនតួនាទី និងផលប៉ះពាល់របស់ប្រទេសចិននៅកម្ពុជា។

### ១.២ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សានេះ ស្ថិតក្នុងស៊េរីនៃការសិក្សាតាមប្រទេសធ្វើឡើងដោយ GMS-DAN ក្រោមការឧបត្ថម្ភពី មូលនិធិ Rockefeller និងព្យាយាមវាយតម្លៃពីផលប៉ះពាល់ជាយថាហេតុរបស់ប្រទេសចិនមកលើជនក្រីក្រនៅប្រទេស GMS រួមមាន កម្ពុជា វៀតណាម ឡាវ និង ថៃ។ ឯកសារពិភាក្សានេះ ផ្តោតលើប្រទេសកម្ពុជា និងវិភាគពីឥទ្ធិពលលើភាពក្រីក្រនៃកំណើនវត្តមានរបស់ប្រទេសចិន តាមរយៈសមាសភាគសំខាន់ ៣ គឺ (១) ពាណិជ្ជកម្ម (២) វិនិយោគ និង (៣) ជំនួយអភិវឌ្ឍន៍ផ្លូវការ។ ការសិក្សានេះ ពិនិត្យពីទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា-ចិន និងផលប៉ះពាល់ទៅលើភាពក្រីក្រ ដោយសង្កេតមើលជាពិសេសពីតួនាទីនៃពាណិជ្ជកម្មចិន ក្នុងផ្នែកផលិតផលអតិពលកម្ម។ ការរួមចំណែកនៃវិនិយោគរបស់ប្រទេសចិននៅក្នុងជីវភាពជនក្រីក្រ បានលើកមកពិនិត្យតាមរយៈករណីសិក្សាលើវិស័យកាត់ដេរ។ ដោយទទួលស្គាល់ពីជំនួយទ្រទ្រង់របស់ប្រទេសចិន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា យើងបានអនុវត្តករណីសិក្សាពីរ លើគម្រោងដែលទទួលបានមូលនិធិ ODA របស់ចិនក្នុងវិស័យដឹកជញ្ជូន ដើម្បីពិនិត្យពីការរួមចំណែកនៃជំនួយរបស់ចិន ដល់ជីវភាព និងការអភិវឌ្ឍសង្គមរបស់ប្រជាជនមូលដ្ឋាន។

---

១ ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកឡើងនៅក្នុងបទសម្ភាសន៍ជាមួយសារព័ត៌មានចិន China Daily កាលពីថ្ងៃទី ១៨ កញ្ញា ២០១០។

អត្ថបទនេះសំដៅបង្កើនការយល់ដឹងរបស់អ្នកធ្វើគោលនយោបាយ អំពីផលប៉ះពាល់នៃវិនិយោគ ពាណិជ្ជកម្ម និង ODA របស់ចិន ដើម្បីស្វែងរកវិធីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន និងបង្កើនផលវិជ្ជមាន សំដៅជំរុញការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រទេស។ ផ្នែកទី១ ពិពណ៌នាពីសាវតា និងកម្មវត្ថុនៃការសិក្សា។ ផ្នែកទី២ ពិនិត្យមើលឯកសារដែលមានស្រាប់ និងស្ថានភាពក្រីក្រនៅកម្ពុជា និងរៀបរាប់ត្រួសៗអំពីគោលនយោបាយស្តីពីទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគកម្ពុជា-ចិន និងអំពីទំនាក់ទំនងជំនួយអភិវឌ្ឍន៍កម្ពុជា-ចិន។ ផ្នែកទី៣ ពិពណ៌នា និងវិភាគនិន្នាការពាណិជ្ជកម្មរវាងកម្ពុជា និងចិន ពន្យល់ពីក្របខណ្ឌវិភាគលើផលប៉ះពាល់ខាងពាណិជ្ជកម្ម និងស្រាវជ្រាវពីផលប៉ះពាល់ និងការរួមចំណែកនៃពាណិជ្ជកម្មចិនទៅលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ផ្នែកទី៤ ពិនិត្យពីនិន្នាការនៃវិនិយោគចិននៅកម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ពិពណ៌នាពីវិធីសាស្ត្រ និងក្របខ័ណ្ឌវិភាគនៃករណីសិក្សាមួយស្តីពីវិស័យកាត់ដេរ និងពិភាក្សាពីរបកគំហើញ និងឥទ្ធិពលទៅលើភាពក្រីក្រ ផ្អែកលើមូលដ្ឋាននៃការបង្កើតការងារ ប្រាក់ផ្ញើទៅផ្ទះ និងការអភិវឌ្ឍជំនាញ។ ផ្នែកទី៥ បង្ហាញពីការវិភាគ និងលទ្ធផលរកឃើញក្នុងករណីសិក្សាចំនួនពីរស្តីពី គម្រោងគមនាគមន៍ក្រោមមូលនិធិ ODA របស់ចិននៅកម្ពុជា និងផលប៉ះពាល់ជាយថាហេតុនៃគម្រោងទាំងនេះទៅលើប្រជាជនមូលដ្ឋាន។ នៅផ្នែកទី៦ មានការពិភាក្សាពីបញ្ហាសំខាន់ៗ និងឥទ្ធិពលនៃគោលនយោបាយ ដោយផ្អែកលើរបកគំហើញនៃការសិក្សា។

# ជំពូក ២

# ការពិនិត្យឡើងវិញលើការសិក្សាមានស្រាប់ និងស្ថានភាពនៃភាពក្រីក្រ

## ២.១ ការពិនិត្យនូវការសិក្សានានាអំពីផលប៉ះពាល់របស់ប្រទេសចិនមកលើសេដ្ឋកិច្ចកម្ពុជា

កំណើនឆាប់រហ័សរបស់ប្រទេសចិនក្នុងពីរបីទសវត្សរ៍កន្លងមកនេះ ពិតជាបានជំរុញបញ្ញវន្ត អ្នកស្រាវជ្រាវ និងអ្នកធ្វើគោលនយោបាយទាំងនៅប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍ ឲ្យចង់ដឹងចង់យល់ពីទំហំឥទ្ធិពលដែលចិនអាចជះមកលើប្រទេសលូតលាស់តិចជាងគេ (LDC) ទោះក្នុងលក្ខណៈបំពេញគ្នា ឬប្រកួតប្រជែងគ្នាក្តី។ ក្នុងឋានៈជាប្រទេសសេដ្ឋកិច្ចធំលំដាប់ទី៤ក្នុងពិភពលោក ផ្អែកលើ ផសស គិតតាមអត្រាប្តូរប្រាក់ផ្លូវការនោះ (Jenkins *et al.* 2007:235) ចិនបានរកឃើញមធ្យោបាយទាញយកធនធានផលិតកម្មក្នុងប្រទេសអន់ថយ ដើម្បីបង្កើនសមត្ថភាពផលិតកម្មរបស់ខ្លួន និងរក្សាល្បឿនរីកលូតលាស់ឲ្យទាន់កំណើនតម្រូវការក្នុងស្រុក និងសាកលលោក។ ចំណុចនេះចោទជាសំនួរថា តើចិនបានរួមចំណែកដល់ការអភិវឌ្ឍនៅប្រទេសជាម្ចាស់ផ្ទះ ឬក៏បង្កជាការរាំងស្ទះ?[២] ផ្នែកខាងក្រោមនេះ ពិនិត្យឡើងវិញនូវឯកសារសំខាន់ៗមួយចំនួនស្តីពីផលប៉ះពាល់នៃប្រទេសចិនទៅលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

ការសិក្សារបស់ Jenkins & Edwards (2004) ជាការស្រាវជ្រាវសំខាន់មួយពី ផលប៉ះពាល់របស់ចិនលើការកាត់បន្ថយភាពក្រីក្រនៅប្រទេសផ្សេងៗ មានទាំងកម្ពុជាផងដែរ។ តាមរយៈការគួបបញ្ចូលគ្នានូវ វិធីសាស្ត្របំបែកអង្គផ្សំ (disaggregated approach) សម្រាប់កំណត់ពីផលប៉ះពាល់របស់ចិនលើពាណិជ្ជកម្មរបស់ប្រទេសលូតលាស់តិចជាងគេនៅកម្រិត SITC លំដាប់បីខ្ទង់ ជាមួយនឹងក្របខ័ណ្ឌរបស់ Winters (2004) សម្រាប់ការវិភាគទំនាក់ទំនងពាណិជ្ជកម្ម និងភាពក្រីក្រ ដោយប្រើទិន្នន័យពីឆ្នាំ១៩៩០ ដល់ ២០០២ នោះ គេបានរកឃើញថា ទាក់ទិននឹងការនាំចេញទៅចិន កម្ពុជា (ក្នុងចំណោមប្រទេសនៅអាស៊ីខ្លះៗទៀត ដូចជា បង់ក្លាដែស និង ប៉ាគីស្ថាន) បាននាំចេញភាគច្រើននូវផលិតផលកម្មន្តសាលអតិពលកម្ម និងផលិតផលកសិកម្មអតិពលកម្ម[៣] ដែលមានផលប៉ះពាល់គួរឲ្យកត់សម្គាល់លើភាពក្រីក្រ។ ដោយប្រើប្រាស់សន្ទស្សន៍នាំចេញស្រដៀងគ្នាមួយ (export similarity index: បើតម្លៃសន្ទស្សន៍កាន់តែឡើងជិតដល់ ១ នោះចិន និងកម្ពុជាកាន់តែមានប្រូបាប៊ីច្រើន ក្លាយជាគូប្រកួតប្រជែងគ្នា) ការសិក្សានេះរកឃើញថា កម្ពុជា និងចិន មានការនាំចេញស្រដៀងគ្នាជាខ្លាំង ទាំងការនាំចេញទូទៅ និងការនាំចេញទំនិញកម្មន្តសាល។

ដោយសារទំនិញកម្មន្តសាលនាំចេញភាគច្រើនជាសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌអតិពលកម្ម ការសិក្សានេះបង្ហាញថា កំណើនភាពប្រកួតប្រជែងពីចិនក្នុងទីផ្សារប្រទេសទីបី អាចជះផលប៉ះពាល់អវិជ្ជមានដល់ជនក្រីក្រនៅកម្ពុជា។ ទោះបីការនាំចូលផលិតផលកម្មន្តសាលពីចិន មានចំនួនច្រើនក៏ដោយ ក៏វាមិនបានច្រានចេញនូវឧស្សាហកម្មក្នុងស្រុក ដែលផ្តល់ការងារដល់កម្មករគ្មានជំនាញនោះទេ ព្រោះទំនិញនាំចូលទាំងនោះ ភាគច្រើនជាអំបោះ និងក្រណាត់សម្រាប់ផលិតកម្ម

---

២ សម្រាប់ការវិភាគ និងលទ្ធផលសិក្សាពីផលប៉ះពាល់នៃកំណើនសេដ្ឋកិច្ចចិនលើប្រទេស LDC សូមមើលអត្ថបទរបស់ Jenkins & Edwards (2004); Jenkins *et al.* (2007); Kaplinsky & Messner (2007) និង Humphrey & Schmitz (2007)។

៣ ផ្អែកលើ Jenkins & Edwards (2004) ផលិតផលកសិកម្មអតិពលកម្ម ជាផលិតផល SITC-Rev2 មានលេខកូដ ០៣៧, ០៤២, ០៥, ០៦, ០៧ និង ២៣២។ ផលិតផលកម្មន្តសាលអតិពលកម្ម ជាផលិតផល SITC-Rev2 មានលេខកូដ ២៦៩, ៦១, ៦៣, ៦៦៥, ៦៦៦, ៨២១, ៨៣១, ៨៥១ និង ៨៩។ ផលិតផលសម្លៀកបំពាក់ និងវាយនភ័ណ្ឌ រួមមាន ផលិតផល SITC-Rev2 មានលេខកូដ ៦៥ និង ៨៤។

សម្លៀកបំពាក់បម្រើការនាំចេញ។ ដូច្នេះ ការនាំចូលពីប្រទេសចិន មិនបានបង្កការគំរាមកំហែងធ្ងន់ធ្ងរដល់ឧស្សាហកម្ម កម្មន្តសាលក្នុងស្រុកទេ ហើយមានផលប៉ះពាល់អវិជ្ជមានតិចតួចបំផុតដល់ជនក្រីក្រ។

Hing & Nou (2006) ដោយប្រើប្រាស់ការពិភាក្សាស៊ីជម្រៅជាមួយអ្នកពាក់ព័ន្ធផ្សេងៗ ដើម្បីរកមើលផលប៉ះពាល់ដល់ភាពក្រីក្រ នៃកម្មវិធីប្រមូលផលដើមដៃ (EHP) ក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន បានសន្និដ្ឋានថា EHP ផ្តល់ឲ្យកម្ពុជានូវឱកាសសម្រាប់អភិវឌ្ឍន៍កសិកម្មរបស់ខ្លួន ដែលជាប្រភពកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រីកការនាំចេញផលិតផល ដូចជា ផ្លែឈើស្រស់ សត្វចិញ្ចឹម ត្រី និងបង្គារ ទៅចិន។ Hing & Jalilian (2008) បានប្រើវិធីសាស្ត្រប៉ាន់ស្មានពីការបំពុលដោយឧស្សាហកម្មដែលបង្កើតឡើងដោយ Herttige *et al.* (1995) ដើម្បីតាមដានអំពីផលប៉ះពាល់របស់ចិនមកលើបរិស្ថានក្នុងតំបន់ ហើយបានរាយការណ៍ថា ក្នុងករណីកម្ពុជា កំណើនទំនិញនាំចូលក្នុងវិស័យបំពុលខ្លាំងពីប្រទេសចិន នៅរវាងឆ្នាំ២០០១ និងឆ្នាំ២០០៧ នាំឲ្យបរិស្ថានកម្ពុជាទទួលបានផលចំណេញច្រើនពីពាណិជ្ជកម្មនេះ ស្របពេលដែលបរិស្ថាននៅចិនត្រូវទទួលរងការខូចខាត។

វិនិយោគិនចិន មានពាក់ព័ន្ធខ្លាំងក្នុងវិស័យមួយចំនួននៃសេដ្ឋកិច្ចកម្ពុជា ដូចជា ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មយករ៉ែ កសិឧស្សាហកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ ការរួមចំណែកពីវិនិយោគិនចិន តាមរយៈវិនិយោគផ្ទាល់ក្នុងឧស្សាហកម្មកាត់ដេរ មានទំហំគួរឲ្យកត់សម្គាល់។ ទិន្នន័យពីសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC 2006) បង្ហាញថា រោងចក្រកាត់ដេរសរុបប្រហែល ២០,៧% ជារបស់វិនិយោគិនហុងកុង ២៤,៥% ជារបស់តៃវ៉ាន់ និង ១៣,១% ជារបស់ចិន ហើយមានតែ ៨,៦% ប៉ុណ្ណោះជារបស់វិនិយោគិនខ្មែរ (cited in USAID 2007:8)។ ដោយប្រើទិន្នន័យថ្នាក់ក្រុមហ៊ុនបានពី ១៦៤ក្រុមហ៊ុនដែលនៅឆ្នាំ២០០៣ មានបុគ្គលិកនារីសរុប ១៤៧.០០០នាក់ និង បុគ្គលិកបុរសសរុប ២១.០០០នាក់ លោក Yamagata (2006) អះអាងថា ឧស្សាហកម្មកាត់ដេរកម្ពុជារួមចំណែកយ៉ាងច្រើនដល់ការកាត់បន្ថយភាពក្រីក្រក្នុងប្រទេស តាមរយៈការផ្តល់ការងារដល់ជនក្រីក្រ និងការផ្តល់ប្រាក់កម្រៃខ្ពស់ច្រើនជាងបន្ទាត់ក្រីក្រ។ ដោយប្រើបន្ទាត់ក្រីក្រស្បៀងអាហារទូទៅ ស្មើនឹង ០,៦៣ដុល្លារ/ថ្ងៃ សម្រាប់រាជធានីភ្នំពេញ និង ០,៤៦ដុល្លារ/ថ្ងៃ សម្រាប់តំបន់ជនបទ ហើយនិងទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ១៩៩៩ អ្នកនិពន្ធប៉ាន់ស្មានថា បន្ទាត់ក្រីក្រទូទៅគិតក្នុងមនុស្សម្នាក់/ខែ នៅរាជធានីភ្នំពេញឆ្នាំ១៩៩៩ គឺ ១៨,៩ដុល្លារ ដែលទាបជាងចំណូលប្រចាំខែជាមធ្យម ៤៥ដុល្លាររបស់កម្មករកាត់ដេរ។

តួនាទីនៃក្រុមហ៊ុនគ្រប់គ្រងដោយឯកជន និងរដ្ឋរបស់ចិន ក្នុងវិស័យឧស្សាហកម្មយករ៉ែ កំពុងកើនឡើង។ ទោះបីជាផលប៉ះពាល់ពីសកម្មភាពទាំងនេះមិនទាន់មានការវាស់វែងក្តី ការសិក្សាមួយចំនួន បានបង្ហាញពីទិសដៅក្រុមហ៊ុនចិននៅកម្ពុជា។ ផែនទីមួយរៀបចំដោយ Oxfam America ក្នុងឆ្នាំ២០០៧ បង្ហាញថា មានក្រុមហ៊ុនចិនពីរ បានចូលរួមក្នុងវិស័យប្រេង និងឧស្ម័នក្នុងសមុទ្រកម្ពុជា (ផែនទីនេះមាននៅក្នុង Ngo 2007:10) ពោលគឺ ក្រុមហ៊ុនជាតិចិនរកប្រេងក្នុងសមុទ្រ (CNOOC) ក្នុងប្លុក F និង ក្រុមហ៊ុន China Petrotech ក្នុងប្លុក D។ Rutherford *et al.* (2008) បញ្ជាក់ថា ក្រុមហ៊ុនរ៉ែចិនចំនួន៦ ក្នុងនេះមានទាំងក្រុមហ៊ុន China Petrotech ផង កំពុងធ្វើប្រតិបត្តិការក្នុងវិស័យរ៉ែនៅកម្ពុជា ជាពិសេសរ៉ែលោហៈ រ៉ែមាស ប្រេង និងឧស្ម័ន (សម្រាប់ព័ត៌មានលម្អិត សូមមើល Rutherford *et al.* 2008:52)។

ទាក់ទិននឹងការចូលរួមរបស់ប្រទេសចិនក្នុងវិស័យកសិកម្ម Tong *et al.* (2009) រាយការណ៍ថា ចាប់តាំងពីថ្ងៃទី១១ មីនា ២០០៩ មក ក្រុមហ៊ុនចិនបានទទួលអាជ្ញាប័ណ្ណវិនិយោគក្នុងទម្រង់ជាសម្បទានដីសេដ្ឋកិច្ច (ELC) នៅភាគខាងជើង និងឦសានប្រទេស ដោយមានក្រុមហ៊ុន ៣ បានចាប់ផ្តើមដាំដំណាំហើយ (សម្រាប់ព័ត៌មានលម្អិតពីក្រុមហ៊ុនទាំងនេះ សូមមើល Ruthrford *et al.* 2008:48)។ Hem *et al.* (2009) តាមរយៈការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដូចជា មេឃុំ មេភូមិ អ្នកភូមិ និងអង្គការមិនមែនរដ្ឋាភិបាលនៅតាមតំបន់មានសម្បទានដីសេដ្ឋកិច្ច បានរកឃើញបញ្ហាមួយចំនួន ដែលកើតឡើងពីវត្តមានរបស់វិនិយោគិនចិន មានជាអាទិ៍ ការកាប់ព្រៃឈើច្រើនហួសកម្រិត ការបិទសិទ្ធិអ្នកភូមិមិនឲ្យប្រើផ្លូវដែលក្រុមហ៊ុនកសាង និងការហាមឃាត់មិនឲ្យប្រើប្រាស់អនុផលព្រៃឈើ។

Tong *et al.* (2009) បញ្ជាក់ថា គម្រោងអភិវឌ្ឍន៍វារីអគ្គិសនីមួយចំនួន បានផ្តល់ទៅឲ្យក្រុមហ៊ុនចិន ទាំងឯកជន និងរដ្ឋ។ គម្រោងទាំងនេះ មានដូចជា គម្រោងវារីអគ្គិសនីសេសានខាងក្រោមទី២ ស្រែពកខាងក្រោមទី២ និង ស្រែពកទី៤។ គម្រោងធំៗ ៤ បានដោះស្រាយស្រេចបាច់សម្រាប់ការសាងសង់គឺមាន កំចាយ ស្ទឹងអាតៃ ស្ទឹងតាតៃ និង ស្ទឹងឫស្សីជ្រុំ (សម្រាប់តារាងលម្អិតស្តីពីគម្រោងវារីអគ្គិសនីជាអាទិភាពនៅកម្ពុជា សូមមើល Hem *et al.* 2009:24)។ តាមការពិភាក្សាជាមួយអ្នកភូមិ Hem *et al.* (ibid) កត់សម្គាល់ថា ផ្លូវដែលក្រុមហ៊ុនចិនកសាងក្នុងតំបន់គម្រោងមួយចំនួន គេបិទមិនឲ្យប្រជាពលរដ្ឋប្រើប្រាស់ទេ ព្រោះក្រុមហ៊ុនខ្លាចពួកគាត់ធ្វើឲ្យខូចសំណង់ផ្សេងៗ។

Matthew (2007) បានពិនិត្យពីវិនិយោគរបស់ចិនលើសំណង់ផ្លូវ ស្ពាន នៅភាគកណ្តាល ភាគខាងជើង និងឦសានប្រទេស។ ការសិក្សារបស់គាត់ មានរាយការណ៍ពីការត៉ាវរបស់អ្នកភូមិជាច្រើនដែលត្រូវផ្លាស់ប្តូរទីតាំងរស់នៅ ព្រមទាំងការអនុម័ត និងយល់ព្រមពីអ្នកផ្សេងទៀតដែលទទួលប្រយោជន៍ពីគម្រោងទាំងនេះ ប៉ុន្តែគាត់មិនបានបង្ហាញភស្តុតាងជាក់លាក់ពីផលប៉ះពាល់នៃគម្រោងទាំងនេះមកលើសហគមន៍នៅតំបន់ជុំវិញនោះទេ។

សរុបមក ការសិក្សាខាងលើ បានផ្តល់ការយល់ដឹងមួយចំនួនពីផលប៉ះពាល់នៃកំណើនសេដ្ឋកិច្ចចិនមកលើសេដ្ឋកិច្ចកម្ពុជា។ ចិនដើរតួយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា តាមរយៈវិនិយោគផ្ទាល់យ៉ាងច្រើនៗនៅក្នុងឧស្សាហកម្មកាត់ដេរ។ ការពង្រីកការនាំចេញផលិតផលអតិពលកម្ម ទៅទីផ្សារចិន ក៏មានផលប៉ះពាល់ទៅលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាដែរ។ ទន្ទឹមគ្នានេះ គេនៅតែមានក្តីបារម្ភពីការចូលពាក់ព័ន្ធរបស់ចិនក្នុងការអភិវឌ្ឍកសិពាណិជ្ជកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជា វារីអគ្គិសនី ការយករ៉ែ ប្រេងកាត និងឧស្ម័ននៅតាមតំបន់ឆ្នេរ និងនៅក្នុងសមុទ្រ។

## ២.២ ស្ថានភាពក្រីក្រនៅកម្ពុជា

ការប្រយុទ្ធប្រឆាំងភាពក្រីក្រនៅប្រទេសកំពុងអភិវឌ្ឍ តែងតែជាបញ្ហាប្រឈមមួយដែលត្រូវចំណាយធនធានយ៉ាងច្រើន ហើយលទ្ធផលនៃកិច្ចប្រឹងប្រែងបែបនេះ តែងមានលក្ខណៈយឺតយ៉ាវ ដោយសារកត្តាមួយចំនួន ដូចជា សង្គ្រាមស៊ីវិល ទំនាស់ គ្រោះធម្មជាតិ ធនធានមានកម្រិត និងភាពទន់ខ្សោយក្នុងស្ថាប័នសាធារណៈ។ កត្តាទាំងអស់នេះ បានរាំងដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ក្នុងរយៈពេល ១៥ឆ្នាំកន្លងមក។ ផ្នែកនេះមិនបង្ហាញលម្អិតពីចំណងទាក់ទងរវាងវត្តមានភាពក្រីក្រ និងវិបត្តិ ឬហេតុការណ៍ដូចលើកឡើងនៅខាងលើទេ តែបង្ហាញពីនិន្នាការប្រែប្រួលនៃស្ថានភាពក្រីក្រក្នុងរយៈពេល១៥ឆ្នាំនេះ និងកត្តាផ្សេងៗដែលអាចជះឥទ្ធិពលទៅលើស្ថានភាពក្រីក្រនៅកម្ពុជា។ ផ្នែកនេះមានពិនិត្យត្រួសៗពីក្របខ័ណ្ឌនយោបាយសំដៅលុបបំបាត់ភាពក្រីក្រ ហើយផ្តល់និយមន័យទូទៅ និងជាក់ស្តែងនៃភាពក្រីក្រ ព្រមទាំងធ្វើការវាស់វែងភាពក្រីក្រនៅកម្ពុជា មុនពេលបកស្រាយបង្ហាញពីនិន្នាការនៃភាពក្រីក្រ។

គេទទួលស្គាល់ជាទូទៅថា ការលុបបំបាត់ភាពក្រីក្រស្ថិតនៅលំដាប់ខ្ពស់ក្នុងរបៀបវារៈអភិវឌ្ឍន៍របស់រដ្ឋាភិបាល ចាប់តាំងពីបានបង្ហើយផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចជំហានទី១ (SEDP I 1996-2000) ដែលផ្តោតលើកំណើន និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងការកាត់បន្ថយភាពក្រីក្រ និងចាប់តាំងពីពេលដំណើរការរដ្ឋាភិបាលអាណត្តិទី២ ឆ្នាំ១៩៩៨-២០០៣ ដែលនៅពេលនោះ មានការអនុវត្តយុទ្ធសាស្ត្រត្រីកោណ សំដៅកសាងសន្តិភាព ស្ថិរភាព សន្តិសុខ សមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម តាមរយៈកម្មវិធីផ្សេងៗ។ លទ្ធផលនៃ SEDP I បានផ្តល់ជាមូលដ្ឋានគ្រឹះ និងជួយកសាងទំនុកចិត្តចំពោះរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធមួយចំនួន ដូចជា ដៃគូអភិវឌ្ឍន៍របស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការបង្កើតយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិ (NPRS) នៅចុងឆ្នាំ២០០២ ដែលមានខ្លឹមសារស្របគ្នាជាមួយនឹង SEDP II ឆ្នាំ២០០១-២០០៥ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG)[៤] បានអនុម័តឡើងនៅខែកញ្ញា ឆ្នាំ២០០០។

---

៤ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDG) របស់កម្ពុជា គ្របដណ្តប់លើគោលដៅ/សូចនាករទូលំទូលាយចំនួន៩ ដែលក្នុងនោះ ការលុបបំបាត់ភាពអត់ឃ្លាន និងក្រីក្រខ្លាំង ត្រូវបានកំណត់ជា MDG ទី១ (MDG 1)។ MDG 1 មានគោលដៅកាត់បន្ថយឲ្យបានពាក់កណ្តាលនៅរវាងឆ្នាំ១៩៩៣ និង ២០១៥ នូវ អត្រាអ្នកមានចំណូលក្រោមបន្ទាត់ភាពក្រីក្រ។

ចាប់ពីពេលនោះមក រដ្ឋាភិបាលបានបន្តការប្តេជ្ញាចិត្តកាត់បន្ថយចំនួនប្រជាជនកម្ពុជារស់នៅក្នុងភាពក្រីក្រ ដោយរក្សាទុកការងារនេះនៅលំដាប់ខ្ពស់បំផុតក្នុងរបៀបវារៈនៃសកម្មភាពជាអាទិភាពរបស់រដ្ឋាភិបាល ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០០៦-២០១០ និងយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល។ យុទ្ធសាស្ត្រទាំងពីរនេះ បង្កើតឡើងក្នុងរដ្ឋាភិបាលអាណត្តិទី៣ ឆ្នាំ២០០៣-២០០៧។ ធនធាន និងកិច្ចប្រឹងប្រែងហាក់ដូចបានត្រៀមច្រើនណាស់សម្រាប់បម្រើគោលដៅកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតជាគោលនយោបាយផ្សេងៗ។ ដូច្នេះការពិនិត្យពីនិន្នាការប្រែប្រួលនៃភាពក្រីក្រនៅកម្ពុជាក្នុងមួយទសវត្សរ៍កន្លះកន្លងមក អាចមានប្រយោជន៍ច្រើន។

ដើម្បីយល់ច្បាស់ពីចរិតលក្ខណៈភាពក្រីក្រ យើងត្រូវយល់ដឹងពីទស្សនទាន និងការវាស់វែងភាពក្រីក្រដោយប្រើរង្វាស់ផ្សេងៗ។ ភាពក្រីក្រ មានន័យជាទូទៅថា "ការខ្វះខាតច្រើនៗខាងសុខុមាលភាព"។ ក្នុងន័យនេះ សុខុមាលភាពត្រូវបានវាស់វែងតាមលទ្ធភាពរបស់បុគ្គល ឬគ្រួសារណាមួយ ក្នុងការចាត់ចែងប្រើប្រាស់ធនធានផ្សេងៗ។ ហេតុដូច្នេះ ប្រជាជនកាន់តែមានសុខុមាលភាពល្អ ប្រសិនបើគាត់មានលទ្ធភាពកាន់តែច្រើនក្នុងការចាត់ចែងប្រើប្រាស់ធនធានផ្សេងៗ (World Bank 2008:11)។ មានរង្វាស់ទូទៅពីរ សម្រាប់វាស់វែងសុខុមាលភាព (និងភាពក្រីក្រ)៖ រង្វាស់ជារូបិយវត្ថុ និងរង្វាស់មិនមែនរូបិយវត្ថុ។ រង្វាស់ជារូបិយវត្ថុ ប្រើសូចនាករសំខាន់ពីរ គឺចំណូល និងចំណាយប្រើប្រាស់ ហើយភាពក្រីក្រគេវាស់វែងតាមការប្រៀបធៀបចំណូល ឬចំណាយប្រើប្រាស់របស់បុគ្គល ជាមួយនឹងចំណុចគោលមួយចំនួន (បន្ទាត់ក្រីក្រ) ដោយកំណត់ថា បើសិនបុគ្គលមានតួលេខទាបជាងចំណុចទាំងនោះ គឺត្រូវចាត់ទុកថាស្ថិតក្នុងភាពក្រីក្រ។ រង្វាស់មិនមែនរូបិយវត្ថុ ផ្តោតលើភាពចេះអក្សរ (ភាពក្រីក្រខាងការអប់រំ) និងអាហារូបត្ថម្ភ (ភាពក្រីក្រខាងសុខភាព និងអាហារូបត្ថម្ភ)។ ការអប់រំ ពាក់ព័ន្ធនឹងកម្រិតចេះអក្សររបស់បុគ្គលម្នាក់ៗ ធៀបនឹងចំណុចគោលនៃភាពមិនចេះអក្សរដែលគេចាត់ទុកជាបន្ទាត់ក្រីក្រ ហើយនិងចំនួនឆ្នាំបានសិក្សា ធៀបនឹងចំនួនឆ្នាំសិក្សាដែលបុគ្គលគួរបានបំពេញ។ អាហារូបត្ថម្ភ ផ្តោតលើស្ថានភាពអាហារូបត្ថម្ភរបស់កុមារ ចំនួនកើតជំងឺជាក់លាក់ផ្សេងៗ (រាគរូស គ្រុនចាញ់ និងជំងឺផ្លូវដង្ហើម) ឬ អាយុកាលមធ្យមនៃក្រុមមនុស្សខុសៗគ្នាក្នុងចំណោមប្រជាជន (Coudouel *et al*. 2002:30-33)។

ចំណាយប្រើប្រាស់ជាមធ្យមលើទំនិញអាហារ និងមិនមែនអាហារមួយក្រុមគិតក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃ ជាសូចនាករសុខុមាលភាពនៅកម្ពុជា ដែលគេបានប្រើចាប់ពីដើមទសវត្សរ៍១៩៩០។ ចំណាយប្រចាំថ្ងៃថ្នាក់ជាតិគិតក្នុងមនុស្សម្នាក់ និងសូចនាករសេដ្ឋកិច្ច-សង្គមកិច្ចជាច្រើនទៀត កន្លងមកគេទទួលបានតាមរយៈអង្កេតទ្រង់ទ្រាយធំៗលើគ្រួសារតំរូតាងនានាចាប់តាំងពីដើមទសវត្សរ៍១៩៩០ មានជាអាទិ៍ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (SESC) ឆ្នាំ១៩៩៣/៩៤ និងឆ្នាំ១៩៩៦ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ១៩៩៧ ១៩៩៩ ២០០៤ និង២០០៧ (World Bank 2006:19)។ ជាទូទៅ វត្តមាន គម្លាត និងភាពធ្ងន់ធ្ងរនៃភាពក្រីក្រ ព្រមទាំងបន្ទាត់ក្រីក្រសម្រាប់ចំណាយលើអាហារ ចំណាយលើទំនិញមិនមែនអាហារ និងចំណាយប្រើប្រាស់សរុប ត្រូវបានប៉ាន់ស្មានដោយធនាគារពិភពលោក។ ក្នុងការវិភាគខាងក្រោមនេះ មានផ្នែកជាច្រើនបានផ្អែកលើរបាយការណ៍របស់ធនាគារពិភពលោក (2006, 2007, 2008, 2009b)។

មុនពេលស្រាវជ្រាវពីនិន្នាការនៃភាពក្រីក្រ និងក្តាប់បាននូវរូបភាពច្បាស់លាស់ពីស្ថានភាពក្រីក្រនៅកម្ពុជា យើងគួរគូសបញ្ជាក់ពីរបៀបកំណត់បន្ទាត់ភាពក្រីក្រ។ បន្ទាត់ភាពក្រីក្រអាហារ ផ្អែកលើតម្លៃប៉ាន់ស្មាននៃទំនិញមួយក្រុមដែលផ្តល់នូវរបបអាហារហូបចុលសម្រាប់ទ្រទ្រង់ជីវិតកម្រិត ២១០០កាឡូរី/ថ្ងៃ ហើយប្រាក់បន្ថែមសម្រាប់ទំនិញមិនមែនអាហារ (ចំណាយប្រើប្រាស់អប្បបរមាលើទំនិញ និងសេវា) គេគណនាចេញពីចំណាយប្រើប្រាស់ទំនិញមិនមែនអាហាររបស់ប្រជាជនកម្ពុជា ដែលមានចំណាយប្រើប្រាស់សរុបគិតក្នុងសមាជិកគ្រួសារ១នាក់ ស្មើនឹងបន្ទាត់ភាពក្រីក្រខាងអាហារ (World Bank:20)។ តារាង ២.១ សង្ខេបនូវបន្ទាត់ក្រីក្រអាហារ បន្ទាត់ក្រីក្រមិនមែនអាហារ និងបន្ទាត់ក្រីក្រសរុប តាមពេលវេលាក្នុង ៣តំបន់ភូមិសាស្ត្រ។ តួលេខក្នុងតារាងបង្ហាញថា ចំណាយលើការរស់នៅ (ដើម្បីរក្សាកម្រិតជីវភាពសមរម្យ) ក្នុងតំបន់ទាំងនេះ បានកើនឡើងគួរឲ្យគត់សម្គាល់ពីឆ្នាំ១៩៩៤ ដល់ ២០០៧។

តារាង ២.១៖ បន្ទាត់ភាពក្រីក្រអាហារ ប្រាក់បន្ថែមសម្រាប់ទំនិញមិនមែនអាហារ និងបន្ទាត់ភាពក្រីក្រសរុប

| *តំបន់* | *1993/94* | *2004* | *2007* |
|---|---|---|---|
| *បន្ទាត់ភាពក្រីក្រអាហារ (រៀលគិតក្នុងមនុស្សម្នាក់/ថ្ងៃ)* | | | |
| ភ្នំពេញ | 1185 | 1782 | 2445 |
| តំបន់ទីក្រុងផ្សេងទៀត | 996 | 1568 | 2274 |
| តំបន់ជនបទ | 882 | 1389 | 1965 |
| *ប្រាក់បន្ថែមសម្រាប់ទំនិញមិនមែនអាហារ (រៀលគិតក្នុងមនុស្សម្នាក់/ថ្ងៃ)* | | | |
| ភ្នំពេញ | 393 | 569 | 647 |
| តំបន់ទីក្រុងផ្សេងទៀត | 269 | 384 | 430 |
| តំបន់ជនបទ | 236 | 364 | 302 |
| *បន្ទាត់ភាពក្រីក្រសរុប (រៀលគិតក្នុងមនុស្សម្នាក់/ថ្ងៃ)* | | | |
| ភ្នំពេញ | 1578 | 2351 | 3092 |
| តំបន់ទីក្រុងផ្សេងទៀត | 1265 | 1952 | 2704 |
| តំបន់ជនបទ | 1118 | 1753 | 2367 |

ប្រភព៖ SESC 93/94, CSES 04, CSES 07, ការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

កំណត់សម្គាល់៖ - តារាងនេះផ្អែកតាមឯកសារធនាគារពិភពលោក ឆ្នាំ២០០៦:២១ សម្រាប់ទិន្នន័យឆ្នាំ១៩៩៣/៩៤ និង ២០០៤ និង ធនាគារពិភពលោក ២០០៩:៧ និង ១២ សម្រាប់ទិន្នន័យឆ្នាំ២០០៧។

- អត្រាប្តូរប្រាក់ (NBC)៖ ២.៨៤៥,២រៀល/ដុល្លារ (១៩៩៤), ៤.០១៩រៀល/ដុល្លារ (២០០៤), ៤.០៦២,៧រៀល/ដុល្លារ (២០០៧)។

ជារួម អត្រាភាពក្រីក្រនៅកម្ពុជា បានធ្លាក់ចុះគួរគត់សម្គាល់ក្នុងរយៈពេល១៥ឆ្នាំចុងក្រោយ ពី ៤៧% នៅឆ្នាំ១៩៩៤ មកត្រឹម ៣២% នៅឆ្នាំ២០០៧។ ក្នុងអំឡុងពេលនេះ ភាពក្រីក្រធ្លាក់ចុះជាមធ្យមប្រហែល ១,១៥% ក្នុង១ឆ្នាំ ដែលបង្ហាញពីលទ្ធផលល្អគួរសមនៃកិច្ចប្រឹងប្រែងលុបបំបាត់ភាពក្រីក្ររបស់រដ្ឋាភិបាល។ នៅតាមតំបន់ភូមិសាស្ត្រនានា ដូចជា នៅភ្នំពេញ តំបន់ទីក្រុងផ្សេងទៀត និងតំបន់ជនបទ ភាពក្រីក្របានធ្លាក់ចុះក៏ពិតមែន ប៉ុន្តែមិនបានស្មើគ្នាល្អទេ។ ភាពក្រីក្រនៅតំបន់ជនបទមានអត្រាខ្ពស់នៅឡើយ បន្ទាប់មកទៀត គឺតំបន់ប្រជុំជនផ្សេងៗ ហើយរាជធានីភ្នំពេញមានអត្រាភាពក្រីក្រទាបជាងគេ (រូបភាព ២.១)។ ដោយសារប្រហែល ៤០% នៃប្រជាជនក្រីក្រទាំងអស់ រស់នៅតំបន់វាលទំនាប និង ៥០% រស់នៅតំបន់ទន្លេសាប តំបន់ភ្នំ/ខ្ពង់រាប ដូច្នេះ គេអាចសន្និដ្ឋានបានថា ភាពក្រីក្រនៅកម្ពុជាជាបាតុភូតនៅជនបទ (World Bank 2006:35)។

គួរកត់សម្គាល់ថា ការកាត់បន្ថយភាពក្រីក្រយឺតៗពីឆ្នាំ១៩៩៤ ដល់ ២០០៤ វាបង្កឡើងដោយកត្តាសំខាន់មួយ គឺ សង្គ្រាមស៊ីវិលរ៉ាំរ៉ៃរវាងកងទ័ពរដ្ឋាភិបាល និងកងទ័ពខ្មែរក្រហមដែលនៅចុងបញ្ចប់ត្រូវបានរំសាយ និងធ្វើសមាហរណកម្មចូលក្នុងកងទ័ពរដ្ឋាភិបាលនៅឆ្នាំ១៩៩៨។ ជម្លោះនេះបានរាំងស្ទះដល់ការផ្តល់សេវាសាធារណៈ ដូចជា ការថែទាំសុខភាព និងការអប់រំ នៅតាមតំបន់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម និងតំបន់ដែលតែងរងការរំខានពីទ័ពខ្មែរក្រហមតាមរយៈការលួចប្លន់ និងការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសហគមន៍នៅរវាងឆ្នាំ១៩៧៩ (ឆ្នាំដួលរលំរបបគ្រប់គ្រងប្រទេសផ្តាច់ការរបស់ខ្មែរក្រហម) និងឆ្នាំ១៩៩៨។ កត្តាមួយចំនួនទៀតនៃការធ្លាក់ចុះភាពក្រីក្រយឺតៗ រួមមាន លក្ខខណ្ឌអាកាសធាតុមិនទៀងទាត់ និងការគាំងទ្រឹងនៃវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធជនបទ ជាពិសេសប្រព័ន្ធធារាសាស្ត្រ។ និន្នាការធ្លាក់ចុះនៃភាពក្រីក្រ នៅបន្តពេញតំបន់ទាំងបី ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧ ប៉ុន្តែភាពក្រីក្រនៅតែបន្តឃើញមានច្រើននៅតំបន់ជនបទ។

រូបភាព ២.១៖ ភាគរយប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្របែងចែកតាមតំបន់[៥]







ប្រភព៖ SESC 93/94, CSES 04, CSES 07, ការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក, 2006-2009

៥ តួលេខ ត្រូវបានបង្ហាញក្នុងរូបភាព ២ផ្សេងគ្នា ដោយសារក្របខណ្ឌគំរូតាងខុសៗគ្នា ជាអាទិ៍ ទិន្នន័យឆ្នាំ១៩៩៤-២០០៤ និង ២០០៤-២០០៧ ត្រូវបានប្រើសម្រាប់ការប៉ាន់ស្មាន។

នៅឆ្នាំ២០០៧ គោលនយោបាយរដ្ឋាភិបាល ទំនងអនុវត្តបានល្អ ដោយនាំឲ្យមានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ក្នុងស្ថានភាពក្រីក្រ។ ប៉ុន្តែ វិសមភាព កាន់តែធ្ងន់ធ្ងរឡើង ដោយមេគុណ Gini (រង្វាស់វិសមភាពជាទូទៅមួយ មានតម្លៃប្រែប្រួលពី 0 ដែលបង្ហាញថាមានសមភាពល្អឥតខ្ចោះ ទៅដល់ ១ ដែលមានន័យថាមានវិសមភាពទាំងស្រុង) បានកើនឡើងពី 0,៣៥ ក្នុងឆ្នាំ១៩៩៣/៩៤ ដល់ 0,៤0 ក្នុងឆ្នាំ២០០៤ និង 0,៤៣ ក្នុងឆ្នាំ២០០៧ (World Bank 2007:iii; World Bank 2009:26)។ ចាប់តាំងពីត្រីមាសទី៤ ឆ្នាំ២០០៧ មក ស្ថានភាពក្រីក្របានយ៉ាប់យ៉ឺនមួយកម្រិតទៀត ដោយសារវិបត្តិធំពីរបានប៉ះទង្គិចដល់កម្ពុជា គឺមានការឡើងថ្លៃអាហារ និងថាមពលខ្ពស់ ពីពាក់កណ្តាលឆ្នាំ២០០៧ ដល់ពាក់កណ្តាលឆ្នាំ២០០៨ និងវិបត្តិហិរញ្ញវត្ថុសាកល ដែលបានប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជានៅត្រីមាសទី៤ ឆ្នាំ២០០៨។

វិបត្តិទី១ បានបង្កការប្រែប្រួលខ្លាំងក្នុងលំនាំចំណាយប្រើប្រាស់របស់គ្រួសារ។ ក្នុងអំឡុងពីខែកក្កដា ២០០៨ ដល់កក្កដា ២០០៩ អង្ករគ្រប់ប្រភេទឡើងថ្លៃ ១០០% សាច់ឡើងថ្លៃពី ៥០-៧០% ហើយបន្លែ និងត្រី ឡើងថ្លៃពី ២០-៣០%។ បញ្ហានេះជះឥទ្ធិពលអាក្រក់ទៅលើក្រុមជនក្រីក្របំផុត ៤០% ដោយពួកគេត្រូវចំណាយប្រហែល ៧០% នៃចំណូលរបស់ខ្លួនទៅលើអាហារ (CDRI 2008:9)។ វិបត្តិទី២ គឺការធ្លាក់ចុះសេដ្ឋកិច្ចប្រទេសជាច្រើន ដូចជា សហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងប្រទេសនៅតំបន់អាស៊ីដែលមានប្រាក់ចំណូលបង្គួរ ដូចជា ជប៉ុន និងកូរ៉េខាងត្បូង ជាដើម។ វិបត្តិនេះប៉ះពាល់ធ្ងន់ធ្ងរដល់សេដ្ឋកិច្ចកម្ពុជា ជាពិសេសផ្នែកកាត់ដេរដែលជាឧស្សាហកម្មផលិតកម្មទ្រទ្រង់ជនក្រីក្រ[៦] បានរងការប៉ះទង្គិចធ្ងន់ធ្ងរបំផុត ដោយសារការនាំចេញសម្លៀកបំពាក់ប្រហែល ៧០% មានទិសដៅទៅសហរដ្ឋអាមេរិក និង ២២% ទៅកាន់សហភាពអឺរ៉ុប។ នៅរវាងខែកញ្ញា ២០០៨ និងខែឧសភា ២០០៩ កម្មករ ៦២.០០០នាក់ (ភាគច្រើនជានារី) ត្រូវបានបញ្ឈប់ពីការងារ ដែលធ្វើឲ្យចំនួនកម្លាំងពលកម្មសរុបក្នុងផ្នែកនេះ ធ្លាក់មកត្រឹម ២៩០.០០០នាក់ (ក្រសួងពាណិជ្ជកម្ម ឆ្នាំ២០០៩)។ វិបត្តិទាំងពីរនេះ បានបណ្តាលឲ្យប្រជាជនកម្ពុជាជាច្រើនក្រុម ជាពិសេស ក្រុមជនមានប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះធ្លាក់ចុះក្នុងភាពក្រីក្រ ដែលធ្វើឲ្យលទ្ធផលលុបបំបាត់ភាពក្រីក្ររបស់រដ្ឋាភិបាលត្រូវចុះខ្សោយ នៅមួយទសវត្សរ៍កន្លះកន្លងទៅ (១៩៩៤-២០០៧)។

## ២.៣ ក្របខ័ណ្ឌគោលនយោបាយ

កំណែទម្រង់ច្បាប់ និងគោលនយោបាយជាច្រើន សំដៅលើកស្ទួយពាណិជ្ជកម្មនិងវិនិយោគ បានអនុវត្តឡើង ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រក្នុងប្រទេស។ យុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលផ្តោតជាពិសេសលើតម្រូវការទាក់ទាញវិនិយោគបរទេស និងបញ្ចូលការអភិវឌ្ឍពាណិជ្ជកម្មទៅក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រក្នុងប្រទេស។ គំនិតផ្តួចផ្តើម ដូចជា យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម (ដែលគេតែងហៅថា ការសិក្សាពីស្ថានភាពសមាហរណកម្មពាណិជ្ជកម្មកម្ពុជា៖ DTIS) និងអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) គេបានកំណត់ថា ជាយន្តការដ៏សំខាន់សម្រាប់អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្មរបស់កម្ពុជា។ ម្យ៉ាងទៀត ដោយសារការចូលរួមរបស់កម្ពុជាក្នុងអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ព្រមទាំងកិច្ចព្រមព្រៀងទ្វេភាគីជាច្រើនទៀត រដ្ឋាភិបាលបានកែតម្រូវក្របខ័ណ្ឌច្បាប់ នីតិវិធី និងរចនាសម្ព័ន្ធស្ថាប័ននានា ឲ្យស្របនឹងស្តង់ដារអន្តរជាតិ មានជាអាទិ៍ ប្រព័ន្ធធ្វើសុខដុមនីយកម្មមុខទំនិញគយ ប្រព័ន្ធពន្ធគយតាមកុំព្យូទ័រ និងការិយាល័យច្រកចេញចូលតែមួយសម្រាប់ពន្ធគយ។

### *ទំនាក់ទំនងវិនិយោគ និងពាណិជ្ជកម្មកម្ពុជា-ចិន*

ទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងកម្ពុជា និងចិន បានរីកធំធាត់ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ក្នុងឆ្នាំ១៩៩៦ កម្ពុជា និងចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្ម ការការពារ និងជំរុញវិនិយោគ ហើយក្នុងឆ្នាំ២០០០ បានបង្កើត

---

៦ វិស័យនេះ គេចាត់ទុកជាវិស័យទ្រទ្រង់ជនក្រីក្រ ព្រោះកម្មករកាត់ដេរភាគច្រើនមកពីតាមខេត្ត ហើយសាច់ញាតិរបស់ពួកគេត្រូវពឹងផ្អែកលើប្រាក់ដែលពួកគេផ្ញើទៅផ្ទះ។

គណៈកម្មាធិការសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម[៧]។ នៅថ្ងៃទី ២៧-២៩ មិថុនា ២០០៨ ស្ថានទូតចិនប្រចាំនៅកម្ពុជា ក្រសួងពាណិជ្ជកម្មកម្ពុជា (MoC) និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរួមគ្នាប្រារព្ធខួបលើកទី៥០ នៃសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មកម្ពុជា-ចិនប្រកបដោយជោគជ័យ ដោយបានរៀបចំការតាំងពិពណ៌ខ្នាតធំ និងមានការចូលរួមពីសហគ្រាសរដ្ឋ និងឯកជនរបស់ចិន អាជីវករក្នុងស្រុក និងក្រុមសហគមន៍ចិននៅកម្ពុជា ដើម្បីបង្កើតនូវឱកាសទំនាក់ទំនងកម្រិតខ្ពស់ និងពង្រីកវិនិយោគ ពាណិជ្ជកម្ម និងលើកទឹកចិត្តដល់គម្រោងវិនិយោគរួមគ្នា (joint venture)។

ការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA) ជាព្រឹត្តិការណ៍ដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងពាណិជ្ជកម្មអាស៊ាន-ចិន។ អាស៊ាន និងចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌមួយ នៅរាជធានីភ្នំពេញ នាខែវិច្ឆិកា ២០០២ ដោយប្ដេជ្ញាបង្កើត ACFTA ឲ្យបានក្នុងរយៈពេល១០ឆ្នាំ និងអនុវត្តពេញលេញនៅឆ្នាំ២០១០ ដោយប្រទេសអាស៊ានដំបូងចំនួន៦ (សិង្ហបុរី ថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ព្រុយណេ និង ហ្វីលីពីន) ហើយនៅឆ្នាំ២០១៥ នឹងបញ្ចូលប្រទេសអាស៊ាន៤ទៀត (ឡាវ កម្ពុជា ភូមា និង វៀតណាម)។ ក្របខ័ណ្ឌនេះបង្កើតនូវកិច្ចសហប្រតិបត្តិការ ពាណិជ្ជកម្ម និងវិនិយោគ និងកាត់បន្ថយរបាំងពាណិជ្ជកម្មរវាងអាស៊ាន និងចិន ព្រោះឯកសារនេះគ្របដណ្ដប់លើពាណិជ្ជកម្មទំនិញនិងសេវាកម្ម វិនិយោគ និងការពង្រីកកិច្ចសហប្រតិបត្តិការក្នុងវិស័យជាច្រើនទៀត ដូចជា ការសម្រួលដល់ពាណិជ្ជកម្ម ការផ្ទេរបច្ចេកវិទ្យា ការអភិវឌ្ឍធនធានមនុស្ស និងគម្រោងអភិវឌ្ឍន៍អនុតំបន់ (រួមទាំងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ាន[៨])។

សេចក្ដីថ្លែងដ៏សំខាន់មួយក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌខាងលើ គឺកម្មវិធីប្រមូលផលដើមដៃ (EHP) ដែលចាប់អនុវត្តនៅចន្លោះឆ្នាំ២០០៤ និង ២០០៦ សម្រាប់អាស៊ាន-៥ និង នៅឆ្នាំ២០១០ សម្រាប់សមាជិកថ្មី និងហ្វីលីពីន។ កម្ពុជារំពឹងថា នឹងទទួលបានផលចំណេញ ឱកាសសេដ្ឋកិច្ច ក៏ដូចជាបញ្ហាប្រឈមជាច្រើនអំពី ACFTA ឆ្លងតាម EHP នេះ។ ការសិក្សាមួយចំនួនបានពិនិត្យពីការរំពឹងទុកសម្រាប់ ACFTA ទាំងមូល។ ប៉ុន្តែគេមានព័ត៌មាន និងការស្រាវជ្រាវតិចតួចណាស់សម្រាប់ប្រទេសកម្ពុជា។ Hing & Nou (2006) បានស្រាវជ្រាវពីផលប៉ះពាល់ជាយថាហេតុនៃ EHP មកលើវិស័យកសិកម្មកម្ពុជា ហើយសន្និដ្ឋានថា កម្ពុជាអាចទទួលបានឱកាសល្អដើម្បីអភិវឌ្ឍកសិកម្មឲ្យក្លាយជាប្រភពនៃកំណើន និងការកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រីកការនាំចេញផលិតផល ដូចជា ផ្លែឈើស្រស់ សត្វចិញ្ចឹម ត្រី បង្គារ និងបង្កងទៅចិនជាដើម។ ប៉ុន្តែ អ្នកនិពន្ធបានដាស់តឿនថា អត្ថប្រយោជន៍ទាំងនេះមិនទាន់អាចកើតឡើងបានទេ ពីព្រោះកម្ពុជាត្រូវប្រឈមនឹងឧបសគ្គជាច្រើន ដូចជា បរិយាកាសអាជីវកម្មមិនល្អ ក្របខ័ណ្ឌច្បាប់មិនគ្រប់គ្រាន់ ហេដ្ឋារចនាសម្ព័ន្ធនៅខ្វះខាត និងស្ថាប័នសាធារណៈគ្មានប្រសិទ្ធភាព ជាដើម ក្នុងការបង្កើនសមត្ថភាពប្រកួតប្រជែងខាងកសិកម្ម និងសហគ្រាសអាជីវកម្មដើម្បីទាញយកប្រយោជន៍ពីឱកាសល្អពាក់ព័ន្ធនឹង EHP។

កម្មវិធីសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គ (GMS) ដែលធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានបង្កើតឡើងក្នុងឆ្នាំ១៩៩២ សម្រាប់ប្រទេសទាំង៦ នៅតាមដងទន្លេមេគង្គ (កម្ពុជា ឡាវ ភូមា ថៃ វៀតណាម និង ខេត្តយុនណានប្រទេសចិន) គឺជាទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដ៏សំខាន់មួយទៀតរវាងកម្ពុជា និងចិន។ របៀបវារៈរបស់ GMS ផ្ដោតលើ "ធាតុរឹង" (hardware) ក្នុងទម្រង់ជាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជាពិសេសហេដ្ឋារចនាសម្ព័ន្ធឆ្លងកាត់ព្រំដែន ដើម្បីជំរុញ ទំនាក់ទំនង និងការតភ្ជាប់ពាសពេញតំបន់។ កម្មវិធី GMS ក៏បានប្រឹងប្រែងដោះស្រាយបញ្ហា "ធាតុទន់" (software) ដែលត្រូវបំពេញឲ្យគ្នាដែរ ដូចជា ការសម្រួលពាណិជ្ជកម្ម និងវិនិយោគឆ្លងកាត់ព្រំដែន ដើម្បីគាំទ្រដល់សមាហរណកម្មសេដ្ឋកិច្ចក្នុង GMS។ កត្តាទាំងអស់នេះ បានបំពេញបន្ថែមលើវិធានការសេរីភាវូបនីយកម្មជាច្រើន ដែលជាលក្ខខណ្ឌមួយនៃសមាជិកភាពក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA)។

Menon (2005) រកឃើញថា "កម្មវិធី GMS កំពុងជួយសមាជិកខ្លួន ឲ្យធ្វើសមាហរណកម្មកាន់តែជិតស្និទ្ធជាមួយតំបន់អាស៊ាន និងតំបន់ឯទៀតក្នុងពិភពលោក។ ដោយកម្មវិធីនេះផ្ដែកលើទីផ្សារ ជាជាងលើការធ្វើសមាហរណកម្មស្ថាប័ន ដូច្នេះ

---

៧ http://www.mfa.gov.cn/eng/wjb/zzjg/yzs/gjlb/2696 (ព័ត៌មានទទួលបាននៅថ្ងៃទី២៦ ឧសភា ២០១០)។

៨ ការកសាងផ្លូវដែកពីសិង្ហបុរី ទៅ ខេត្តគុនមីង (Kunming) និង ផ្លូវថ្នល់ធំ (highway) តភ្ជាប់ពីទីក្រុងបាងកក ទៅខេត្តគុនមីង។

GMS កំពុងជំរុញទាំងគោលគំនិតតំបន់និយម និងពហុភាគីនិយម។ ទំនិញសាធារណៈនៃអនុតំបន់ ដែលផ្តល់តាមរយៈកម្មវិធីនេះ កំពុងរីកដុះដាលនៅទូទាំងសាកលលោក មិនមែនត្រឹមនៅក្នុងតំបន់ប៉ុណ្ណោះទេ"។

ចិន ដើរតួនាទីសកម្មមួយ ជាអ្នកទទួលប្រយោជន៍ និងអ្នករួមវិភាគទានក្នុងកម្មវិធី GMS។ ចិនផ្តល់ជំនួយហិរញ្ញវត្ថុ និងជំនួយអភិវឌ្ឍន៍ធនធានមនុស្ស ដល់កម្មវិធី GMS និងសមាជិកនៃកម្មវិធីនេះ ព្រោះចិនមានបំណងបង្កើតឱកាសសេដ្ឋកិច្ច និងការរីកចម្រើននៅភាគខាងត្បូងនៃប្រទេសខ្លួន (Yunnan និង Guangxi) និងជំរុញឲ្យមានវិនិយោគចិនកាន់តែច្រើនក្នុងប្រទេស GMS។

កម្ពុជា ក៏ទទួលបានផលប្រយោជន៍ដែរ តាមរយៈការចូលរួមក្នុងការអភិវឌ្ឍគម្រោង GMS ក្នុងវិស័យជាច្រើន រួមមាន បរិស្ថាន ទេសចរណ៍ ថាមពល និងការអភិវឌ្ឍធនធានមនុស្ស។

### *ទំនាក់ទំនងជំនួយបរទេសកម្ពុជា-ចិន*

ចិនបានផ្តល់ជំនួយបរទេសដល់កម្ពុជា ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍១៩៥០។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ កម្ពុជា និងចិន បានពង្រីកកិច្ចសហប្រតិបត្តិការជាបន្តបន្ទាប់ខាងវប្បធម៌ ទេសចរណ៍ និងកសិកម្ម ហើយក៏មានការផ្លាស់ប្តូរទស្សនកិច្ចរវាងមន្ត្រីសភា កងទ័ព អ្នកសារព័ត៌មាន និងមន្ត្រីសុខាភិបាលនៃប្រទេសទាំងពីរផងដែរ។[៩]

ជំនួយបរទេសរបស់ចិនមកកម្ពុជា ចាត់ទុកជាច្រកដ៏សំខាន់មួយសម្រាប់ជំរុញពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ។

ជំនួយអភិវឌ្ឍន៍ចិន មានប្រជាប្រិយភាពកាន់តែច្រើននៅកម្ពុជា ព្រោះមិនសូវមានដាក់សម្ពាធខាងនយោបាយ និងលក្ខខណ្ឌសេដ្ឋកិច្ចមកលើកម្ពុជា ដូចជំនួយប្រទេសឯទៀត (Phou Sambath ND)។ ឆ្លងតាមបទពិសោធន៍របស់ខ្លួនជាមួយជំនួយបរទេស និងដោយមិនចង់ជាន់ដានអ្វីដែលខ្លួនចាត់ទុកថាជាឥរិយាបថមិនល្អរបស់អ្នកផ្តល់ជំនួយអន្តរជាតិនោះ រដ្ឋាភិបាលចិនបានដាក់ចេញនូវគោលនយោបាយជំនួយអភិវឌ្ឍន៍ ឬជំនួយបរទេសជាផ្លូវការមួយ សម្រាប់ប្រទេសទទួលជំនួយដូចជាកម្ពុជាជាដើម និងបានបង្កើតគោលការណ៍ចំនួន៨ សម្រាប់ណែនាំពីរបៀបបែងចែកប្រាក់បើកផ្តល់របស់ខ្លួន ដែលហាក់ដូចជាបានបន្ធូរបន្ថយសម្ពាធលើប្រទេសទទួលជំនួយនានា។ គោលការណ៍ទាំងនោះ រួមមាន (Chin & Frolic 2007)៖

- ទាំងប្រទេសម្ចាស់ជំនួយ និងប្រទេសទទួលជំនួយ ត្រូវធានាឲ្យមានសមភាព និងប្រយោជន៍ទៅវិញទៅមក
- គោរពអធិបតេយ្យភាព និងមិនដាក់លក្ខខណ្ឌអ្វីឡើយ
- ផ្តល់កម្ចីមិនមានការប្រាក់ ឬមានការប្រាក់ទាប ក្នុងនាមអ្នកក្រជួយអ្នកក្រ
- លើកទឹកចិត្តដល់ប្រទេសទទួលជំនួយឲ្យធ្វើការអភិវឌ្ឍប្រកបដោយឯករាជ្យ និងមិនសូវពឹងផ្អែកលើជំនួយបរទេស
- គាំទ្រដល់គម្រោងដែលទាមទារវិនិយោគតិច និងអាចសម្រេចបានក្នុងរយៈពេលខ្លី
- បែងចែកឧបករណ៍ និងបរិក្ខារមានគុណភាពល្អ និងមានថ្លៃសមរម្យស្របតាមទីផ្សារ
- ផ្តល់ជំនួយបច្ចេកវិទ្យាដែលមានប្រសិទ្ធភាព
- ផ្តល់កម្រៃឈ្នួលសមរម្យដល់ជំនាញការ ស្របតាមថ្លៃទីផ្សារ

---

៩ http://www.mfa.gov.cn/eng/wjb/zzjg/yzs/gjlb/2696/ (ព័ត៌មានទទួលបាននៅថ្ងៃទី២៦ ឧសភា ២០១០)

ជាការឆ្លើយតប រដ្ឋាភិបាលកម្ពុជា ក៏បានប្តេជ្ញាចិត្តធានាឲ្យមានការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវជំនួយអន្តរជាតិទាំងអស់ដែលបានផ្តល់មក ដូចជា ការប្រើប្រាស់ជំនួយប្រកបដោយតម្លាភាព និងគណនេយ្យភាព ការពង្រឹងតួនាទីបុគ្គលសំខាន់ៗ ភាពពាក់ព័ន្ធល្អជាមួយនឹងការធ្វើផែនការ និងអនុវត្តកម្មវិធី ព្រមទាំងការវាយតម្លៃពីផលប៉ះពាល់នៃ NASP (Chan Sophal *et al*. 2008)។

ជំពូក ៣

# ពាណិជ្ជកម្មចិន និងផលប៉ះពាល់

## ៣.១ ទំហំ និងការប្រែប្រួលពាណិជ្ជកម្ម

ភាពរីកចម្រើនខ្លាំងក្នុងទំនាក់ទំនងសេដ្ឋកិច្ចកម្ពុជា-ចិន បានលេចចេញច្បាស់នៅពាក់កណ្ដាលទសវត្សរ៍១៩៩០ នៅពេលមានវិនិយោគិនចិនជាច្រើន ចូលមកបណ្ដាក់ទុនក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជា ដើម្បីទាញយកផលចំណេញពីសិទ្ធិទទួលបានការអនុគ្រោះពិសេសរបស់កម្ពុជា ដូចជា លក្ខខណ្ឌអនុគ្រោះផ្នែកពាណិជ្ជកម្ម (MFN) ផ្ដល់ដោយសហភាពអឺរ៉ុប និងប្រព័ន្ធអនុគ្រោះទូទៅ (GSP) ផ្ដល់ដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក។ កំណើនទំនាក់ទំនងនេះ ក៏ជាលទ្ធផលនៃការអនុវត្តកិច្ចព្រមព្រៀងកម្ពុជា-ចិនលើកិច្ចការពារ និងជំរុញវិនិយោគ ដែលធ្វើឡើងក្នុងខែកក្កដា ១៩៩៦ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី ដែលធ្វើឡើងក្នុងខែកក្កដា ១៩៩៧ (Hing 2006:17)។ ទំនាក់ទំនងប្រទេសទាំងពីរ កាន់តែរីកចម្រើនស៊ីជម្រៅជាងមុន តាមរយៈក្របខ័ណ្ឌកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីនៃអាស៊ាន-ចិន (ACFTA) ជាពិសេសកម្មវិធីប្រមូលផលដើមដៃ (EHP) ដែលមានគោលដៅពន្លឿនសេរីភាវូបនីយកម្មពាណិកម្មកសិកម្ម។ ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) និងការហូរចូលមូលធនពីប្រទេសចិន ក៏ដើរតួសំខាន់បំផុតដែរក្នុងការជំរុញការអភិវឌ្ឍប្រទេសកម្ពុជាក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ។ ការពិនិត្យពីទំនាក់ទំនងរវាងកម្ពុជាជាមួយនឹងដៃគូពាណិជ្ជកម្មសំខាន់ៗក្នុងតំបន់ និងលើពិភពលោកនៅទសវត្សរ៍ចុងក្រោយនេះ អាចមានប្រយោជន៍ច្រើនដល់ការកំណត់ពីពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ចិន ឲ្យបានកាន់តែលម្អិតថែមទៀត។

### *ពាណិជ្ជកម្មកម្ពុជាជាមួយពិភពលោក*

អត្រាកំណើនការនាំចូលពីពិភពលោក តំបន់អាស៊ាន និង GMS-5 មានកម្រិតខ្ពស់ជាខ្លាំងនៅចន្លោះឆ្នាំ២០០០ និង ២០០៨។ គិតតាមតម្លៃពាណិជ្ជកម្មទីផ្សារ កម្ពុជាមានទំនោរធ្វើការនាំចូលភាគច្រើនពីដៃគូពាណិជ្ជកម្មយូរឆ្នាំរបស់ខ្លួន ដែលមានជាអាទិ៍ប្រទេសជិតខាង ថៃ និង វៀតណាម ហើយបន្ទាប់មកមាន ចិន សិង្ហបុរី កូរ៉េ ជប៉ុន ម៉ាឡេស៊ី និងតិចជាងគេពីប្រទេសឥណ្ឌា។ ចំណុចគួរកត់សម្គាល់ គឺការនាំចូលពីប្រទេសទាំងនោះ មាននិន្នាការកើនឡើងទាំងអស់ ដែលបំផុសសំណួរថា តើការនាំចូលជាការប្រកួតប្រជែង ឬបំពេញឲ្យទីផ្សារក្នុងស្រុក។

ក្នុងអំឡុងឆ្នាំ២០០០-២០០៨ ការនាំចេញកើនឡើងយឺតជាងការនាំចូល ដែលឆ្លុះបញ្ចាំងពីឱនភាពជាបន្តនៃជញ្ជីងពាណិជ្ជកម្មកម្ពុជា។ នៅឆ្នាំ២០០៨ ឱនភាពជញ្ជីងពាណិជ្ជកម្មកម្ពុជា ជាមួយពិភពលោក មានជិតដល់ ២ពាន់លានដុល្លារ ហើយឱនភាពជាមួយតំបន់អាស៊ាន ក៏មានសភាពធ្ងន់ធ្ងរដែរនៅរវាងឆ្នាំ២០០០ និង ២០០៨ ដែលបង្ហាញពីការពឹងផ្អែកខ្លាំងរបស់កម្ពុជាទៅលើការនាំចូលពីពិភពលោក និងតំបន់អាស៊ាន។ បើពិនិត្យតាមដៃគូពាណិជ្ជកម្មនីមួយៗ យើងអាចឃើញច្បាស់នូវឱនភាពខ្លាំងនៃជញ្ជីងពាណិជ្ជកម្មកម្ពុជា ជាមួយនឹងថៃ វៀតណាម ចិន សិង្ហបុរី និងកូរ៉េខាងត្បូង។ ការសិក្សាពីឥទ្ធិពលនៃស្ថានភាពជញ្ជីងពាណិជ្ជកម្មនេះ ដូចជា ឥទ្ធិពលច្រានចេញនូវផលិតករក្នុងស្រុកជាដើម ត្រូវតែអនុវត្តឡើង មុននឹងសម្រេចធ្វើអន្តរាគមន៍តាមខ្សែផ្ដេក ឬខ្សែបញ្ឈរ ជួយការពារដល់មូលដ្ឋានសេដ្ឋកិច្ច ឬឧស្សាហកម្មក្នុងស្រុកនោះ។

តារាង ៣.១៖ ពាណិជ្ជកម្មទ្វេភាគីកម្ពុជាជាមួយពិភពលោក ឆ្នាំ២០០០-២០០៨ (តម្លៃទីផ្សារ ជាលានដុល្លារ)

| *ប្រទេស* | *2000* | *2001* | *2002* | *2003* | *2004* | *2005* | *2006* | *2007* | *2008* |
|---|---|---|---|---|---|---|---|---|---|
| *នាំចូល* | | | | | | | | | |
| ពិភពលោក | 1762.71 | 1862.3 | 2045.59 | 2347.71 | 2840.69 | 3420.35 | 4558.02 | 5324.97 | 6934.63 |
| អាស៊ាន-9 | 1038.63 | 1119.39 | 1177.93 | 1418.6 | 1616.11 | 1984.58 | 2712.49 | 3101.09 | 4412.61 |
| សហភាពអឺរ៉ុប-15 | 106.57 | 93.6 | 111.39 | 103.57 | 125.76 | 145.82 | 155.19 | 199.14 | 211.99 |
| GMS-5 | 651.58 | 819.1 | 945.66 | 1254.54 | 1558.35 | 2006.66 | 2730.07 | 3281.52 | 4641.17 |
| ចិន | 164.06 | 205.65 | 251.56 | 294.65 | 451.77 | 536.03 | 697.76 | 883.59 | 1095.54 |
| ឥណ្ឌា | 7.89 | 10.54 | 16.97 | 20.27 | 16.75 | 21.35 | 48.09 | 44.83 | 53.85 |
| ជប៉ុន | 51.98 | 50.43 | 69.95 | 54.55 | 79.87 | 78.11 | 81.82 | 111.04 | 184.04 |
| កូរ៉េខាងត្បូង | 95.91 | 101.54 | 115.23 | 105.56 | 126.32 | 144.28 | 205.09 | 281.43 | 294.38 |
| មីយ៉ាន់ម៉ា | 71.33 | 60.26 | 55.01 | 64.74 | 83.54 | 109.28 | 108.33 | 134.12 | 165.13 |
| សិង្ហបុរី | 425.75 | 370.02 | 352.25 | 307.61 | 348.76 | 303.04 | 459.63 | 438.66 | 520.45 |
| ថៃ | 345.9 | 467.44 | 515.69 | 692.61 | 722.6 | 914.99 | 1251.69 | 1356.85 | 2014.03 |
| សហរដ្ឋអាមេរិក | 23.06 | 28.05 | 28.47 | 56.3 | 57.24 | 67.19 | 70.87 | 137.53 | 150.27 |
| វៀតណាម | 141.62 | 146 | 178.41 | 267.29 | 383.97 | 555.64 | 780.61 | 1041.07 | 1531.6 |
| *នាំចេញ* | | | | | | | | | |
| ពិភពលោក | 1529.75 | 1778.26 | 2013.67 | 2384.22 | 2950.36 | 3150.85 | 4019.03 | 4605.79 | 4955.64 |
| អាស៊ាន-9 | 138.35 | 112.24 | 182.84 | 192.95 | 218.07 | 302.47 | 338.88 | 362.24 | 438.86 |
| សហភាពអឺរ៉ុប-15 | 342.43 | 479.41 | 522.1 | 621.39 | 824.17 | 724.89 | 928.18 | 1045.7 | 1249.58 |
| GMS-5 | 104.65 | 69.91 | 101.15 | 132.98 | 188.15 | 219.08 | 239.2 | 305.33 | 343.24 |
| ចិន | 59.49 | 34.8 | 24.55 | 26 | 29.93 | 27.3 | 35.09 | 51.07 | 38.83 |
| ឥណ្ឌា | 1.27 | 1.11 | 0.68 | 0.31 | 0.23 | 0.42 | 1.48 | 1.24 | 4.27 |
| ជប៉ុន | 52.18 | 66.01 | 74.92 | 89.43 | 99.76 | 105.46 | 120.23 | 138.99 | 121.01 |
| កូរ៉េខាងត្បូង | 2.31 | 7.1 | 3.03 | 4.2 | 6.95 | 5.96 | 5.46 | 8.87 | 14.38 |
| មីយ៉ាន់ម៉ា | 16.84 | 19.01 | 19.36 | 8.32 | 9.03 | 8 | 20.27 | 21.31 | 14.38 |
| សិង្ហបុរី | 74.84 | 54.64 | 84.03 | 74.48 | 48.35 | 100.42 | 112.35 | 84.87 | 116.58 |
| ថៃ | 7.86 | 12.27 | 11.22 | 12.26 | 27.64 | 31.56 | 34.65 | 48.77 | 90.12 |
| សហរដ្ឋអាមេរិក | 879.95 | 1016.77 | 1145.81 | 1335.84 | 1591.48 | 1766.6 | 2328.27 | 2599.41 | 2545.83 |
| វៀតណាម | 37.3 | 22.83 | 65.39 | 94.71 | 130.58 | 160.22 | 169.45 | 205.5 | 214.28 |

ប្រភព៖ UNComTrade 2009

## ពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ចិន

ទំនាក់ទំនងពាណិជ្ជកម្មយ៉ាងជ្រាលជ្រៅរវាងកម្ពុជា និង ចិន ដូចជាតាមរយៈ ACFTA-EHP បាននាំមកនូវការផ្លាស់ប្តូរយ៉ាងសំខាន់ក្នុងលំនាំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរ ក្នុងទសវត្សរ៍ចុងក្រោយនេះ។ ជាទូទៅ ពាណិជ្ជកម្មសរុប (ការ

នាំចូលបូកនឹងការនាំចេញ) រវាងប្រទេសទាំងពីរ កើនឡើងជាខ្លាំងដោយមានអត្រាកំណើនប្រចាំឆ្នាំជាមធ្យម ២៣,១% នៅចន្លោះឆ្នាំ២០០១ និង ២០០៨។ ទោះយ៉ាងនេះក្តី រូបភាព ៣.១ បង្ហាញថា តម្លៃនៃការនាំចេញរបស់កម្ពុជាទៅចិន នៅចន្លោះឆ្នាំ២០០០ និង ២០០៨ នៅមានទំហំតូច ប្រមាណ ៣៦,៣៤លានដុល្លារជាមធ្យម ឬស្មើនឹង ១% នៃចំណែកការនាំចេញសរុបរបស់កម្ពុជា ទៅពិភពលោកក្នុងអំឡុងពេលនោះ។

រូបភាព ៣.១៖ ការនាំចេញរបស់កម្ពុជាទៅប្រទេសចិន និង ពិភពលោក ២០០០-២០០៨ (លានដុល្លារ)




ប្រភព៖ UNComTrade 2009

តម្លៃនៃការនាំចេញទៅចិនមានកម្រិតទាប និងឡើងចុះមិនទៀងទាត់ពីមួយឆ្នាំទៅមួយឆ្នាំ (មានកំណើនជាមធ្យម ០,៣% ក្នុងចន្លោះឆ្នាំ២០០១ និង ២០០៨) គួបផ្សំនឹងកំណើនការនាំចូលពីចិនកម្រិតខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ (ជាមធ្យម ២៧,២% ក្នុងចន្លោះឆ្នាំ២០០១ និង ២០០៨) ធ្វើឲ្យជញ្ជីងពាណិជ្ជកម្មកម្ពុជា (ការនាំចេញដកការនាំចូល) ជាមួយចិន កាន់តែមានឱនភាពខ្លាំងឡើង (រូបភាព ៣.២)។ មានការធ្លាក់ចុះខ្លាំងៗពីរលើក ធ្វើឲ្យអត្រាកំណើនការនាំចេញក្លាយជាអវិជ្ជមាន គឺ -៥៨,៧% នៅឆ្នាំ២០០២ និង -២៤,៥% នៅឆ្នាំ២០០៨។ ការធ្លាក់ចុះការនាំចេញទាំងពីរលើក និងកំណើនជាបន្តបន្ទាប់នៃការនាំចូលពីចិន ធ្វើឲ្យឱនភាពជញ្ជីងពាណិជ្ជកម្មកម្ពុជារីកធំគួរឲ្យកត់សម្គាល់តាំងពីដើមទសវត្សរ៍២០០០ គឺ -១៤៦លានដុល្លារ នៅឆ្នាំ២០០១ និង -១.០៥៧លានដុល្លារ នៅឆ្នាំ២០០៨។ ដូច្នេះ ការពិនិត្យពីលំនាំ និងលក្ខណៈពាណិជ្ជកម្មរវាងប្រទេសទាំងពីរ វាមានប្រយោជន៍សម្រាប់ការវាយតម្លៃពីផលចំណេញ ឬកំហាតបង់ដែលអាចកើតមានពី ACFTA និង កម្មវិធីប្រមូលផលដើមដៃ។ ឯកសារនេះមិនព្យាយាមវិភាគពីផលប៉ះពាល់នៃកិច្ចព្រមព្រៀង ACFTA ទេ ប៉ុន្តែនឹងពិនិត្យពីឥទ្ធិពលនៃកំណើនការរួមចំណែករបស់ប្រទេសចិន ដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា តាមរយៈច្រកពាណិជ្ជកម្មដែលអាចឆ្លុះបញ្ចាំងពីផលចំណេញ ឬការខាតបង់នៃការអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌ។

រូបភាព ៣.២៖ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ចិន និង ជញ្ជីងពាណិជ្ជកម្ម




ប្រភព៖ UNComTrade 2009

មុននឹងសិក្សាលម្អិតពីលំនាំពាណិជ្ជកម្ម យើងគួរពិនិត្យពីផលិតផលនាំចេញនាំមុខគេទាំង១០ របស់កម្ពុជាទៅប្រទេសចិន ក្នុងទសវត្សរ៍ចុងក្រោយនេះ។ ក្នុងឆ្នាំ២០០៨ ផលិតផលសំខាន់ៗ៣ គឺកៅស៊ូឆៅ និងកៅស៊ូសំយោគ ឈើ្បក្សានិងឈើ (cork and wood)[១០] (SITC 24) និងវាយនភ័ណ្ឌនិងគ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់ ត្រូវបាននាំចេញទៅចិន ដោយរួមចំណែកជិត ៨៩% នៃការនាំចេញទៅប្រទេសចិនសរុប (តារាង ៣.២)។ ការនាំចេញផលិតផលផ្សេងទៀត រួមមាន ផលិតផលកសិកម្ម ដូចជា ត្រីស្រស់/ត្រាំទឹកកក សត្វវង្គសត្វ/សិប្បិសត្វ និងគ្រឿងសង្ហារឹម។ បើពិនិត្យក្នុង១០ឆ្នាំកន្លងមកនេះ យើងអាចមើលឃើញពីការធ្លាក់ចុះយ៉ាងខ្លាំងក្នុងការនាំចេញ (៥៩,២%) ក្នុងចន្លោះឆ្នាំ២០០០ និង២០០២ ដែលបង្ហាញពីការផ្លាស់ប្តូរយ៉ាងសំខាន់ក្នុងលំនាំពាណិជ្ជកម្មទ្វេភាគីរវាងចិន និងកម្ពុជា។

ការធ្លាក់ចុះយ៉ាងខ្លាំងក្នុងការនាំចេញសរុបនៅដើមទសវត្សរ៍២០០០ បង្កជាចំបងដោយសារការនាំចេញផលិតផលកម្មន្តសាលត្បក្សា និងឈើ[១១] (SITC 63) បានធ្លាក់ចុះអស់ ៧១% ពី ៤៨,៦៤លានដុល្លារ ក្នុងឆ្នាំ២០០០ មកត្រឹម ១៤,០៥ លានដុល្លារ ក្នុងឆ្នាំ២០០២ ដោយសាររដ្ឋាភិបាលបានលុបចោលសម្បទានព្រៃឈើ ៤០% ដែលជិតស្មើនឹងពាក់កណ្តាលនៃតំបន់សម្បទានទាំងអស់ និងដោយសាររដ្ឋាភិបាលបានផ្អាកការកាប់ឈើនៅតំបន់សម្បទាននិងការដឹកជញ្ជូនឈើហ៊ុប នៅខែមករា ២០០២។ វិធានការប្រឆាំងនឹងការកាប់ឈើទាំងនេះ បានដាក់ចេញ បន្ទាប់ពីរដ្ឋាភិបាលបានរកឃើញពីផលអវិជ្ជមានធ្ងន់ធ្ងរនៃការកាប់ឈើ និងកង្វះសមត្ថភាពនៃវិនិយោគិនក្នុងការបំពេញកាតព្វកិច្ចតាមកិច្ចសន្យា (World Bank 2004:19, 76)។ គួរកត់សម្គាល់ជាសំខាន់ថា ទោះផលិតផលកម្មន្តសាលត្បក្សានិងឈើ (SITC 63) បានថយចុះក្តី ប៉ុន្តែត្បក្សាធម្មជាតិ និងឈើ (SITC 24) បានកើនឡើងគួរកត់សម្គាល់ក្នុងអំឡុងពេលនោះ។

---

១០ បើតាម SITC Rev. 3 ត្បក្សានិងឈើ រួមមាន ត្បក្សាធម្មជាតិ/ត្បក្សាមិនទាន់ច្នៃ/កំទេចត្បក្សា ឧស/ធ្យូងឈើ ចំណាំង/កំទេចឈើ ឈើមិនទាន់ច្នៃ ឈើឡាំង និងឈើសម្រាប់ការងារទូទៅ ដូចជា ឈើកំណល់ផ្លូវរថភ្លើង ឈើទន់ច្នៃរួច/លកបង្អួរ និងឈើរឹងអាររួច។

១១ បើតាម SITC Rev 3 ផលិតផលកម្មន្តសាលត្បក្សា និងឈើ (SITC 63) រួមមាន ត្បក្សា និងឆ្នុកដប សន្លឹកវីនៀរ ក្តារបន្ទះធ្វើពីកំទេចក្តារបន្ទះ ក្តារសរសៃឈើ និងឈើច្នៃរួច។

តារាង ៣.២៖ ផលិតផលនាំមុខគេ ១០មុខ ដែលកម្ពុជានាំចេញទៅចិន នៅឆ្នាំ២០០០-២០០៨

| SITC Rev.3 | មុខផលិតផល | តម្លៃជាលានដុល្លារ | | | | | ចំណែក (%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | 2000 | 2002 | 2004 | 2006 | 2008 | 2000 | 2002 | 2004 | 2006 | 2008 |
| 23 | កៅស៊ូឆៅ និងកៅស៊ូសំយោគ | 5.4 | 7.5 | 2.5 | 8.7 | 11.5 | 9.1 | 30.9 | 8.5 | 25.8 | 31.6 |
| 24 | ឈើ និងឈើ | 1.6 | 1.1 | 10.1 | 12.1 | 10.6 | 2.7 | 4.4 | 33.6 | 35.8 | 29.2 |
| 84 | សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់ | 2.5 | 0.1 | 0.8 | 3 | 10.3 | 4.2 | 0.2 | 2.5 | 9 | 28.4 |
| 00 | សសៃអំបោះវាយនភ័ណ្ឌ | - | - | 0.1 | 0.7 | 1.2 | - | - | 0.3 | 2.2 | 3.3 |
| 26 | អំបោះ/ក្រណាត់/វត្ថុធាតុវាយនភ័ណ្ឌ | 0 | 0.2 | 9.1 | 7 | 0.6 | 0 | 0.6 | 30.6 | 20.9 | 1.7 |
| 03 | ត្រីរស់/ស្រស់/ត្រាំទឹកកក/បង្កក | 0.5 | 1.1 | 0.5 | 0.6 | 0.5 | 0.8 | 4.4 | 1.7 | 1.8 | 1.3 |
| 65 | សត្វវង្គសត្វ/សិប្បសត្វ | 0.6 | 0.2 | 0.8 | 0.4 | 0.4 | 1 | 0.9 | 2.6 | 1.1 | 1 |
| 85 | ស្បែកជើង | - | 0.1 | 0 | 0.1 | 0.4 | - | 0.2 | 0.1 | 0.4 | 1 |
| 82 | សង្ហារឹម/គ្រឿងផ្គត់ផ្គង់សង្ហារឹម | - | 0 | 0 | 0 | 0.3 | - | 0.1 | 0.1 | 0 | 0.9 |
| 89 | ទំនិញកម្មន្តសាលផ្សេងៗ | 0 | 0 | 0 | 0.2 | 0.2 | 0 | 0 | 0.1 | 0.5 | 0.4 |
| | ផ្សេងៗ | 48.7 | 14.1 | 5.9 | 0.9 | 0.4 | 82.1 | 58.3 | 19.9 | 2.7 | 1.2 |
| | *សរុប* | *59.3* | *24.2* | *29.9* | *33.7* | *36.4* | *100* | *100* | *100* | *100* | *100* |

ប្រភព៖ UN ComTrade 2009

កំណត់សម្គាល់៖ ការរៀបចំណាត់ថ្នាក់ដោយអ្នកនិពន្ធផ្អែកលើតម្លៃការនាំចេញទំនិញនៅឆ្នាំ២០០៨

ថ្វីបើការនាំចេញសរុបទៅចិន មានការធ្លាក់ចុះខ្លាំងភ្លាមៗនៅដើមទសវត្សរ៍២០០០ ប៉ុន្តែវាមាននិន្នាការកើនឡើងសន្សឹមៗវិញនៅឆ្នាំ២០០៨ ទោះក្នុងកម្រិតមួយដែលមានតួលេខទាបជាងក្នុងឆ្នាំ២០០០ក្តី។ លើសពីនេះទៀត ទំនិញនាំចេញដែលមានមកជាយូរផ្សេងទៀត ដូចជា កៅស៊ូឆៅ និងកៅស៊ូសំយោគ សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់ ផលិតផលត្រី ស្បែកជើង និងគ្រឿងសង្ហារឹម កើនឡើងបង្គួរក្នុងអំឡុងពេលដូចគ្នានេះ។ ផលិតផលកម្ពុជា ហាក់ទទួលបានឱកាសកាន់តែច្រើនដើម្បីចូលទៅកាន់ទីផ្សារចិន ហើយការកាត់បន្ថយការនាំចេញឈើ ឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរគតិយាបថពាណិជ្ជកម្ម និងជំហររបស់រដ្ឋាភិបាលចំពោះការអភិរក្សបរិស្ថាន និងការការពារធនធានធម្មជាតិ។

ការនាំចូលពីចិន កើនលឿនជាខ្លាំង ជាងការនាំចេញ។ នៅចន្លោះឆ្នាំ២០០១ និង ២០០៨ កំណើនការនាំចូលជាមធ្យមពីមួយឆ្នាំទៅមួយឆ្នាំគឺ ២៧,២%។ ក្នុងចំណោមផលិតផលនាំចូលនាំមុខគេទាំង១០ អំបោះ/ក្រណាត់/វត្ថុធាតុវាយនភ័ណ្ឌ ឈរនៅលំដាប់ខ្ពស់បំផុត ដោយរួមចំណែកប្រហែល ៥០,៣% នៃការនាំចូលសរុបពីចិន ក្នុងឆ្នាំ២០០៨ (តារាង ៣.៣)។ គួរកត់សម្គាល់ថា ផលិតផលលំដាប់ខ្ពស់បំផុតនេះ នាំចូលមកជាចំបងសម្រាប់ផលិតកម្មក្នុងស្រុក និងការនាំចេញបន្តទៅទីផ្សារទី៣ ដូចជា ជប៉ុន កាណាដា តំបន់អឺរ៉ុប និងសហរដ្ឋអាមេរិក ព្រោះប្រមាណ ២០,៧% នៃរោងចក្រទាំងអស់ក្នុងឧស្សាហកម្មសម្រាប់ការនាំចេញនេះ មានប្រភពមកពីហុងកុង និងប្រហែល ១៣,១% មកពីចិនដីគោក ហើយទទួលបានធាតុចូលសម្រាប់ការផលិត ពីរោងចក្រមេនៅប្រទេសដើមរបស់ខ្លួន (GMAC 2006 cited in USAID 2007:8)។

តារាង ៣.៣៖ ផលិតផលឈានមុខទាំង១០ នាំចូលពីចិន នៅឆ្នាំ២០០៨

| SITC Rev.3 | មុខផលិតផល | តម្លៃជាលានដុល្លារ | | | | | ចំណែក (%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | 2000 | 2002 | 2004 | 2006 | 2008 | 2000 | 2002 | 2004 | 2006 | 2008 |
| 65 | អំបោះ/ក្រណាត់/វត្ថុធាតុវាយនភណ្ឌ | 76 | 146.4 | 286 | 434.1 | 550.1 | 46.3 | 58.2 | 63.3 | 62.2 | 50.2 |
| 76 | ឧបករណ៍ទូរគមនាគមន៍ | 11.4 | 5.9 | 11 | 23.1 | 59.7 | 6.9 | 2.3 | 2.4 | 3.3 | 5.4 |
| 66 | ផលិតផលខនិជអលោហៈ | 4.3 | 9.2 | 16.1 | 28.4 | 50.2 | 2.6 | 3.7 | 3.6 | 4.1 | 4.6 |
| 84 | សម្លៀកបំពាក់/គ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់ | 8.2 | 8.2 | 11.9 | 30 | 48.4 | 5 | 3.2 | 2.6 | 4.3 | 4.4 |
| 71 | ឧបករណ៍ផលិតថាមពល | 4.3 | 8.1 | 11.6 | 17 | 47.4 | 2.6 | 3.2 | 2.6 | 2.4 | 4.3 |
| 77 | ឧបករណ៍អគ្គិសនី | 1.3 | 2.5 | 2.7 | 11.2 | 37 | 0.8 | 1 | 0.6 | 1.6 | 3.4 |
| 67 | ដែក និង ដែកថែប | 12.9 | 6.8 | 15.2 | 13.7 | 36.8 | 7.9 | 2.7 | 3.4 | 2 | 3.4 |
| 69 | ផលិតផលលោហៈ | 4.9 | 14.8 | 10.7 | 9.5 | 29.6 | 3 | 5.9 | 2.4 | 1.4 | 2.7 |
| 72 | ម៉ាស៊ីនសម្រាប់ឧស្សាហកម្មពិសេស | 6.5 | 11.4 | 7.7 | 21.6 | 29.1 | 3.9 | 4.6 | 1.7 | 3.1 | 2.7 |
| 74 | បរិក្ខាររោងចក្រ | 1.5 | 2.5 | 4.7 | 17.1 | 28 | 0.9 | 1 | 1 | 2.5 | 2.6 |
| | ផ្សេងៗ | 32.8 | 35.3 | 73.9 | 91.8 | 176.4 | 20 | 14 | 16.4 | 13.2 | 16.1 |
| | *សរុប* | *164.1* | *251.1* | *451.7* | *697.5* | *1092.9* | *100* | *100* | *100* | *100* | *100* |

ប្រភព៖ UN ComTrade 2009

ក្រៅពីការនាំចូលអំបោះនិងក្រណាត់ គឺការនាំចូលឧបករណ៍ទូរគមនាគមន៍ដែលស្ថិតនៅលំដាប់ទី២ ហើយបន្ទាប់មកគឺផលិតផលរ៉ែអលោហធាតុ សម្លៀកបំពាក់និងគ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់ ឧបករណ៍ផលិតថាមពលអគ្គិសនី ឧបករណ៍អគ្គិសនី ដែកនិងដែកថែប ផលិតផលលោហធាតុ និងគ្រឿងចក្រឧស្សាហកម្ម។ ការប្រកួតប្រជែងពីប្រទេសចិនក្នុងទីផ្សារកម្ពុជា ហាក់មិនកើតមានឡើយ ព្រោះផលិតផលនាំចូលលំដាប់ខ្ពស់បំផុត ត្រូវប្រើជាចំបងក្នុងផលិតកម្មសម្រាប់នាំចេញ ហើយកម្ពុជាក៏មិនមានទំនាក់ទំនងដើមខ្សែនៃឧស្សាហកម្មនៅក្នុងសេដ្ឋកិច្ចក្នុងស្រុកដែរ។ ម៉្យាងទៀត ផលិតផល ៦មុខ ក្នុងចំណោមផលិតផលនាំចូលនាំមុខគេ ៩មុខ មិនមានផលិតនៅកម្ពុជាទេ ផលិតផល ៣មុខផ្សេងទៀត ដូចជា សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់ ផលិតផលលោហធាតុ និងផលិតផលមិនមែនលោហធាតុ ក៏មិនមានសកម្មភាព និងទំហំផលិតកម្មធំដុំអ្វីដែរនៅក្នុងស្រុក។

សរុបមក ទំនាក់ទំនងពាណិជ្ជកម្មកាន់តែរឹងមាំរវាងកម្ពុជា និងចិន ជាពិសេសតាមរយៈ ACFTA-EHP បានផ្តល់ឱកាសទូលំទូលាយសម្រាប់ការបង្កើនពាណិជ្ជកម្មទ្វេភាគីក្នុងទំនិញប្រពៃណី ដូចជា ផលិតផលឈើ ត្រី ឧបករណ៍ទូរគមនាគមន៍ អំបោះនិងក្រណាត់ គ្រឿងចក្រអគ្គិសនី ដែកនិងដែកថែប លោហធាតុ និងផលិតផលមិនមែនលោហធាតុ ព្រមទាំងផលិតផលកសិកម្ម និងកម្មន្តសាលថ្មីៗជាច្រើនប្រភេទ។ ដោយសារជញ្ជីងពាណិជ្ជកម្មកម្ពុជាមានឱនភាពខ្លាំងក្នុងទសវត្សរ៍ចុងក្រោយនេះ ដូច្នេះគួរចោទសំណួរថា តើកម្ពុជាទទួលបានផលចំណេញពីពាណិជ្ជកម្មជាមួយចិនឬទេ ហើយបើសិនជាបាន តើវាមានទំហំប៉ុណ្ណា? ផ្នែក ៣.៣ ព្យាយាមឆ្លើយបំភ្លឺសំណួរទាំងនេះ។

## ៣.២ ក្របខ័ណ្ឌនៃការវិភាគ និងវិធីសាស្ត្រ

ការសិក្សានេះប្រើប្រាស់ក្របខ័ណ្ឌ Jenkins និង Edwards's (២០០៤) ដើម្បីវិភាគពីផលប៉ះពាល់នៃពាណិជ្ជកម្មចិនលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដោយប្រើទិន្នន័យពាណិជ្ជកម្មនៅកម្រិតលេខ ៣ខ្ទង់។ ផលប៉ះពាល់នៃពាណិជ្ជកម្មចិនអាចពិនិត្យបាននៅ ៣កម្រិត គឺកម្រិតទី១ រួមមាន ការនាំចេញទៅចិន ការនាំចូលពីចិន និងការនាំចេញទៅទីផ្សារទី៣។ កម្រិតទី២ ពាក់ព័ន្ធនឹងទំហំនៃការនាំចេញផលិតផលអតិពលកម្មទៅចិន ទំហំនៃការនាំចូលពីចិននូវផលិតផលចូលមកប្រកួតប្រជែង និងផលិតផលប្រើប្រាស់សម្រាប់ជនក្រីក្រ និងទំហំនៃការនាំចេញផលិតផលអតិពលកម្មទៅទីផ្សារទី៣។ កម្រិតទី៣ ផ្តោតលើឥទ្ធិពលលើភាពក្រីក្រនៃកំណើន ឬការថយចុះចំនួនការងារដែលបម្រើការនាំចេញផលិតផលអតិពលកម្មទៅចិន កំណើនការប្រកួតប្រជែងអំពីការនាំចូលពីចិន និងកម្រិតនៃការប្រកួតប្រជែងក្នុងផលិតផលអតិពលកម្មនៅទីផ្សារទី៣។ ក្របខ័ណ្ឌខាងក្រោម បង្ហាញពីយន្តការនៃការវិភាគ។

រូបភាព ៣.៣៖ ក្របខ័ណ្ឌវិភាគពីផលប៉ះពាល់នៃពាណិជ្ជកម្មចិនលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា




ប្រភព៖ កែសម្រួលចេញពី Jenkins and Edwards (2004)

## ៣.៣ លទ្ធផល[១២]

### *ការនាំចេញទៅចិន*

តារាង ៣.៤ បង្ហាញពីបម្រែបម្រួលគួរកត់សម្គាល់ក្នុងរចនាសម្ព័ន្ធនៃការនាំចេញពីកម្ពុជាទៅចិន ក្នុងអំឡុងពីរទសវត្សរ៍ចុងក្រោយនេះ។ ពីដើមទសវត្សរ៍១៩៩០ ដល់ឆ្នាំ២០០០ ចំណែកនៃការនាំចេញគ្រប់ក្រុមផលិតផល បានធ្លាក់ចុះយ៉ាងខ្លាំង លើកលែងតែផលិតផលកម្មន្តសាលអតិពលកម្ម និងផលិតផលព្រៃឈើ (មិនអាចរកទិន្នន័យបានសម្រាប់ឆ្នាំ១៩៩២) និងផលិតផលសម្លៀកបំពាក់និងវាយនភ័ណ្ឌអតិពលកម្មផ្សេងទៀត។ ការធ្លាក់ចុះយ៉ាងខ្លាំងក្នុងចំណែកការនាំចេញផលិតផលកសិកម្មអតិពលកម្មនៅដើមទសវត្សរ៍២០០០ នាំឲ្យមានការខាតបង់យ៉ាងធំក្នុងចំណូលពីការនាំចេញ ហើយអាចមានទាំងការបាត់បង់ការងារក្នុងវិស័យនេះផងដែរ។ ក្នុងអំឡុងពេលដដែល ចំណែកនៃការនាំចេញផលិតផលកសិកម្មផ្សេងទៀត និងកម្មន្តសាលផ្សេងទៀត បានធ្លាក់ចុះច្រើន ដែលធ្វើឲ្យចំណូលពីការនាំចេញថយចុះ ប៉ុន្តែហាក់មិនជះឥទ្ធិពលលើភាពមានការងារធ្វើទេ ដោយសារវិស័យទាំងនោះមិនមែនអតិពលកម្ម។ ចំណុចគួរចាប់អារម្មណ៍ គឺចំណែកនៃការនាំចេញសម្លៀកបំពាក់ និងទំនិញវាយនភ័ណ្ឌអតិពលកម្ម បានកើនឡើងតិចតួចណាស់ក្នុងអំឡុងពេលនោះ។

---

១២ ផ្នែកនេះ កែសម្រួលចេញពី Jenkins និង Edwards (2004) ដែលក្នុងនោះ ផលិតផលត្រូវបានបែងចែកជាក្រុមទៅតាមកម្រិតអតិពលកម្មសម្រាប់ការនាំចេញទៅប្រទេសចិន និងប្រភេទផលិតផលប្រើប្រាស់សម្រាប់ជនក្រីក្រដែលនាំចូលពីចិន ដើម្បីស្វែងយល់ពីឥទ្ធិពលនៃពាណិជ្ជកម្មទ្វេភាគីលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

តារាង ៣.៤៖ ចំណែកនៃការនាំចេញផលិតផលជាក់លាក់ធៀបនឹងការនាំចេញសរុបទៅចិន ពីឆ្នាំ១៩៩២ ដល់ ២០០៨ នៅកម្រិតលេខ ៣ខ្ទង់

| *ក្រុមផលិតផល* | *ផលិតផល* | *1992 (%)* | *2000 (%)* | *2007 (%)* | *2008 (%)* |
|---|---|---|---|---|---|
| *1* | ផលិតផលកសិកម្មអតិពលកម្ម | 51.38 | 9.11 | 21.8 | 29.63 |
| *2* | ផលិតផលកសិកម្មផ្សេងៗ | 14.46 | 2.16 | 4.43 | 8.43 |
| *3* | ផលិតផលព្រៃឈើ | | 2.73 | 47.06 | 27.42 |
| *4* | រ៉ែ និង ប្រេងកាត | | | 0.02 | 0.32 |
| *5* | សម្លៀកបំពាក់ និងវាយនភ័ណ្ឌអតិពលកម្ម | 3.26 | 4.21 | 19.34 | 28.19 |
| *6* | ផលិតផលអតិពលកម្មផ្សេងៗ | | 81.77 | 3.69 | 5.57 |
| *7* | ផលិតផលកម្មន្តសាលផ្សេងៗ | 30.9 | 0.02 | 3.67 | 0.43 |
| | *សរុប* | *100* | *100* | *100* | *100* |

ប្រភព៖ UN ComTrade 2009

កំណត់សម្គាល់៖ ចំណាត់ថ្នាក់ផលិតផលមានចុះក្នុងឧបសម្ព័ន្ធ ១

ចាប់ពីឆ្នាំ២០០០ ដល់ ២០០៨ ក្រុមផលិតផលខាងលើ មាននិន្នាការប្រែប្រួលខុសគ្នា (តារាង ៣.៤)។ ចំណែកនៃការនាំចេញផលិតផលកសិកម្មអតិពលកម្ម ទំនិញវាយនភ័ណ្ឌ និងសម្លៀកបំពាក់ កើនឡើងយ៉ាងខ្លាំង ប៉ុន្តែចំណែកការនាំចេញផលិតផលអតិពលកម្មផ្សេងៗ បានធ្លាក់ចុះធ្ងន់ធ្ងរ ដែលផ្តល់រូបភាពចម្រុះមួយមិនដឹងថា តើរឿងនេះអាចបញ្ជាក់នូវការថយចុះចំណូលពីការនាំចេញ និងចំនួនការងារធ្វើក្នុងវិស័យទាំងនោះឬយ៉ាងណា? ម្យ៉ាងទៀត ចំណែកនៃការនាំចេញផលិតផលកសិកម្មមិនមែនអតិពលកម្ម ព្រៃឈើ រ៉ែ និងផលិតផលកម្មន្តសាលផ្សេងទៀត ក៏កើនឡើងដែរ ដែលបានជួយប៉ះប៉ូវដល់ការធ្លាក់ចុះនៃការនាំចេញផលិតផលអតិពលកម្មផ្សេងៗ។

ការពិនិត្យស្រាវជ្រាវលើបញ្ជីវាយមុខផលិតផលកម្រិតលេខ ៣ខ្ទង់ក្នុងក្រុមផលិតផលខាងលើ បានបង្ហាញលទ្ធផលកាន់តែគួរឲ្យចាប់អារម្មណ៍ (តារាង ៣.៥)។ ការធ្លាក់ចុះយ៉ាងខ្លាំងក្នុងការនាំចេញផលិតផលកសិកម្មអតិពលកម្ម មានឫសគល់ជាបឋមមកពី ការថយចុះចំណែកនៃការនាំចេញផ្លែឈើស្រស់/ស្ងួត និងគ្រាប់ផ្លែឈើ (SITC 057) ពី ១៦,៨% នៅឆ្នាំ១៩៩២ មកដល់សូន្យនៅឆ្នាំ២០០០ និងការធ្លាក់ចុះចំណែកនៃការនាំចេញជ័រកៅស៊ូ/កៅស៊ូធម្មជាតិ (SITC 231) ពី ៣៤,៥% នៅឆ្នាំ១៩៩២ មកត្រឹម ៩,១% នៅឆ្នាំ២០០០។ គួរកត់សម្គាល់ថា នៅអំឡុងពេលនោះ មិនមានការនាំចេញស្រូវប្រភេទណាមួយទេ។ ក្នុងចំណោម ផ្លែឈើស្រស់/ស្ងួត និងគ្រាប់ផ្លែឈើ មានតែផ្លែឈើស្ងួត (SITC 05799) ប៉ុណ្ណោះដែលបាននាំចេញទៅចិនក្នុងឆ្នាំ១៩៩២ និងគ្រាប់ស្វាយចន្ទី (SITC 05773) ក្នុងឆ្នាំ១៩៩៥។ ការធ្លាក់ចុះយ៉ាងខ្លាំងក្នុងការនាំចេញកៅស៊ូធម្មជាតិ បណ្តាលជាសំខាន់មកពីការកាត់បន្ថយតំបន់ដាំដុះកៅស៊ូយកជ័រពី ៥០.៨៩១ហិកតា ក្នុងឆ្នាំ១៩៩២ មកត្រឹម ២៩.១១៩ហិកតា ក្នុងឆ្នាំ២០០២ ហើយដើមកៅស៊ូចាស់ៗ (អាយុ ២៥-៣០ឆ្នាំ) ដែលមិនសូវឲ្យផល ក៏ត្រូវកាប់ចេញ ដែលនាំឲ្យថយចុះផលិតកម្មសរុបនៃកៅស៊ូធម្មជាតិ/ជ័រកៅស៊ូ និងការនាំចេញទាំងមូល (MAFF 2010)[១៣]។

នៅចន្លោះឆ្នាំ២០០០ និង ២០០៨ កំណើនចំណែកនៃការនាំចេញកៅស៊ូធម្មជាតិ ជាកត្តាតែមួយគត់ដែលបង្កកំណើនចំណែកនៃការនាំចេញផលិតផលកសិកម្មអតិពលកម្ម។ គួរកត់សម្គាល់ដែរថា អង្ករពីរប្រភេទ គឺប្រភេទអង្ករសគ្លី (SITC 0422) និងអង្ករគ្រាប់ល្អគ្មានបាក់ (SITC 04231) ឃើញមាននាំចេញក្នុងឆ្នាំ២០០៥ និង ២០០៨ ប៉ុន្តែក្នុងទំហំតូចមួយប្រមាណជា ២០០ដុល្លារ ទៅ ៣០០ដុល្លារ។ ការនាំចេញកៅស៊ូធម្មជាតិ បានកើនឡើងគួរឲ្យកត់សម្គាល់ក្នុងទសវត្សរ៍ចុងក្រោយនេះ ដោយសារកម្មវិធីដាំដើមកៅស៊ូឡើងវិញរបស់រដ្ឋាភិបាលដែលបានចាប់ផ្តើមក្នុងឆ្នាំ១៩៩៣ និងការពង្រីកការដាំដុះទាំងចម្ការកៅស៊ូឯកជន និងចម្ការកៅស៊ូតាមគ្រួសារតូចៗ។ ជាលទ្ធផល ផ្ទៃដីដាំកៅស៊ូសរុបទាំងរដ្ឋ ឯកជន និងតាមគ្រួសារតូចៗ

១៣ សូមមើលគេហទំព័រខាងស្ថិតិរបស់ MAFF៖ http://www.maff.gov.kh/eng/statistics/rubber/html#a2

ក្នុងឆ្នាំ២០០៨ បានកើនដល់ ១០៨.៦៥៦ហិកតា ក្នុងនេះ ៣១,៥៨% មានដើមកៅស៊ូគ្រប់អាយុអាចចៀរជ័របាន (GDRP 2009)។ ដើមកៅស៊ូគ្រប់អាយុអាចចៀរជ័របាន ក្រោយពេលដាំចំនួន ៥ឆ្នាំ។

ការនាំចេញកៅស៊ូធម្មជាតិ អាចជះឥទ្ធិពលយ៉ាងខ្លាំងទៅលើភាពមានការងារធ្វើ និងការកាត់បន្ថយភាពក្រីក្រ។ ការសិក្សាមួយរបស់ SOFRACO នៅឆ្នាំ២០០៥ បានប៉ាន់ស្មានថា កម្លាំងពលកម្មសរុបក្នុងវិស័យនេះ មានប្រមាណ ២៦.៣០០នាក់ ក្នុងឆ្នាំ២០០២ ហើយការសិក្សាបន្ទាប់របស់ UNDP (2007) ប៉ាន់ស្មានថា កម្លាំងពលកម្មក្នុងវិស័យនេះ មានប្រមាណ ៤០.០០០នាក់ ក្នុងឆ្នាំ២០០៧។ ក្នុងការសិក្សាអំពីសមត្ថភាពប្រកួតប្រជែងនៃវិស័យកៅស៊ូកម្ពុជាក្នុងការនាំចេញ Saing (2009a) បង្ហាញថា ប្រាក់ឈ្នួលប្រចាំថ្ងៃមធ្យមនៃកម្មករកៅស៊ូក្នុងឆ្នាំ២០០៨ គឺ ១៥.០០០រៀល ស្មើនឹង ៩៨១៤,៨រៀល គិតតាមថ្លៃថេរឆ្នាំ២០០៦ ដែលខ្ពស់ជាងបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ (ការប៉ាន់ស្មានពីចំណាយប្រើប្រាស់លើអាហារ និងទំនិញមិនមែនអាហារប្រចាំថ្ងៃ ធ្វើឡើងដោយធនាគារពិភពលោក) នៅឆ្នាំ២០០៧ ដែលមានកម្រិត ២.៣៦៧រៀល ឬស្មើនឹង ២.២០៣,៩រៀល បើគិតតាមថ្លៃនៅឆ្នាំ២០០៦[១៤]។

តារាង ៣.៥៖ ចំណែកនៃការនាំចេញផលិតផលជាក់លាក់ ធៀបនឹងការនាំចេញសរុបទៅចិន ពីឆ្នាំ១៩៩២ ដល់ ២០០៨

| SITC 3 | ប្រភេទផលិតផល | 1992 (%) | 2000 (%) | 2007 (%) | 2008 (%) |
|---|---|---|---|---|---|
| 001 | សត្វរស់ក្រៅពីត្រី | | 0.352 | 2.012 | 6.223 |
| 034 | ត្រី រស់/ស្រស់/ត្រាំទឹកកក/បង្កក | | 0.78 | 1.623 | 1.25 |
| 036 | សត្វវង្គ(ក្តាម បង្កង) សិប្បសត្វ (ខ្យង គ្រំ) ជាដើម | | 1.025 | 0.672 | 0.945 |
| 231 | កៅស៊ូធម្មជាតិ/ជ័រឈើ ជាដើម | 34.551 | 9.099 | 21.569 | 29.606 |
| 247 | ឈើមិនទាន់ច្នៃ/ឈើឡាំង | | 0.568 | 31.605 | 13.027 |
| 248 | ឈើច្នៃធម្មតា | | 2.167 | 15.452 | 13.669 |
| 292 | វត្ថុធាតុជាបន្លែនៅ | 14.455 | | 0.08 | 0.016 |
| 634 | សន្លឹកវីនៀរ/ក្តារបន្ទះ ជាដើម | | 79.439 | 0.051 | |
| 635 | ផលិតផលឈើ ដែលពុំបានចែងនៅកន្លែងផ្សេង | | 2.329 | 0.043 | 0.226 |
| 657 | ក្រណាត់/សរសៃអំបោះពិសេស | | 0 | 0.02 | 0.046 |
| 661 | ផលិតផលស្បែកសម្លាប់ | | 0 | 0.001 | 0.005 |
| 841 | សម្លៀកបំពាក់ត្បាញសម្រាប់ក្មេងប្រុស/បុរស | | 4.185 | 1.154 | 5.074 |
| 845 | សម្លៀកបំពាក់ប្រហាក់ប្រហែល ដែលពុំបានចែងនៅកន្លែងផ្សេង | | 0 | 4.623 | 17.022 |
| 846 | គ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់ | | 0.021 | 0.003 | 0.004 |
| 848 | ក្រណាត់មិនមែនវាយនភណ្ឌ/គ្រឿងសម្រាប់ពាក់លើក្បាល | | 0 | 0.001 | 0.001 |
| 893 | វត្ថុធ្វើពីជាតិប្លាស្ទិក ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.001 | 0.036 | 0.058 |
| 899 | ស្នាដៃវត្ថុផ្សេងៗ ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.001 | 0.135 | 0.33 |

ប្រភព៖ UN ComTrade 2009

កំណត់សម្គាល់៖ តារាងលម្អិតមាននៅក្នុងឧបសម្ព័ន្ធ ២

១៤ ការគណនារបស់អ្នកនិពន្ធដោយប្រើទិន្នន័យសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ($CPI_{2006}$=100) ទទួលបានពីវិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា។

គួរកត់សម្គាល់ថា វិស័យដំណាំកៅស៊ូ អាចមានឥទ្ធិពលរឹតតែខ្លាំងជាងនេះទៀតទៅលើចំនួនការងារ ព្រោះមួយភាគធំនៃកៅស៊ូធម្មជាតិកម្ពុជា ត្រូវបាននាំចេញជាផ្លូវការ ឬមិនផ្លូវការទៅប្រទេសវៀតណាម ដើម្បីធ្វើការកែច្នៃ ហើយជ័រកៅស៊ូកែច្នៃរួចមួយភាគ ត្រូវបាននាំចេញបន្តទៅប្រទេសចិន។ ថ្លៃកៅស៊ូនៅទីផ្សារប្រទេសវៀតណាម ថោកជាងនៅទីផ្សារប្រទេសសិង្ហបុរី និង ម៉ាឡេស៊ី ប៉ុន្តែផលិតករកៅស៊ូនៅកម្ពុជា ច្រើនចូលចិត្តទីផ្សារវៀតណាម ព្រោះអស់ចំណាយតិចក្នុងការដឹកជញ្ជូនទៅព្រំដែនវៀតណាម ហើយវៀតណាមទទួលយកកៅស៊ូធម្មជាតិគុណភាពអន់ (Saing 2009a: 13)។

ផលិតផលកសិកម្មផ្សេងៗទៀត មាននិន្នាការស្រដៀងគ្នានឹងផលិតផលកសិកម្មអតិពលកម្ម នៅចន្លោះឆ្នាំ ១៩៩២ និង ២០០០។ ការធ្លាក់ចុះផលិតផលកសិកម្ម នៅចុងទសវត្សរ៍១៩៩០ និងដើមទសវត្សរ៍២០០០ បណ្តាលមកពីការធ្លាក់ចុះយ៉ាងខ្លាំងក្នុងការនាំចេញបន្លែឆៅ (SITC 292) ហើយការរើបឡើងវិញនៅពាក់កណ្តាលទសវត្សរ៍២០០០ បណ្តាលមកពីកំណើនការនាំចេញសត្វរស់ (SITC 001) និងត្រីរស់/ស្រស់/ត្រាំទឹកកក (SITC 034)។ ពីឆ្នាំ២០០០ ដល់ ២០០៨ ការនាំចេញផលិតផលឈើ កើនឡើងគួរឲ្យកត់សម្គាល់ ដោយសារកំណើននៃការនាំចេញឈើមិនទាន់ច្នៃ ឈើឡាំង និងឈើសម្រាប់ការងារទូទៅ។ ការនាំចេញផលិតផលរ៉ែ បានផុសឡើងក្នុងឆ្នាំ២០០៧-០៨ និងមានជាអាទិ៍ កាកសំណល់/កំទេចដែកស្អិត (SITC 282) និងរ៉ែលោហធាតុធម្មតា (SITC 287) ប៉ុន្តែមានបរិមាណតិចតួចណាស់។

ចំណែកនៃការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌអតិពលកម្ម មាននិន្នាការកើនឡើងយ៉ាងទៀងទាត់នៅចន្លោះឆ្នាំ១៩៩២ និង ២០០៨ ដោយសារកំណើនការនាំចេញអំបោះ ក្រណាត់ត្បាញមានជាតិកប្បាស ក្រណាត់ត្បាញសិប្បកម្ម វាយនភ័ណ្ឌតម្បាញ ក្រណាត់ចាក់ ស្បៃ/គ្រឿងជរ/គ្រឿងប៉ាក់ ក្រណាត់/អំបោះពិសេស (SITC 651-657) និងសម្លៀកបំពាក់បុរស/ក្មេងប្រុស សម្លៀកបំពាក់ប៉ាក់សម្រាប់ស្ត្រី/ក្មេងស្រី សម្លៀកបំពាក់ចាក់ដោយម្ជុលសម្រាប់បុរស/ក្មេងប្រុស សម្លៀកបំពាក់ចាក់ដោយម្ជុលសម្រាប់ស្ត្រី/ក្មេងស្រី សម្លៀកបំពាក់ គ្រឿងបន្ទាប់បន្សំ និងគ្រឿងសម្រាប់ពាក់លើក្បាល/សម្លៀកបំពាក់មិនមែនវាយនភ័ណ្ឌ (SITC 841-848)។

ដោយសារកង្វះទិន្នន័យ និងការសិក្សាពីចំនួនរោងចក្រកាត់ដេរដែលផលិតសម្រាប់នាំចេញទៅទីផ្សារចិន គេពិបាកដឹងបានពីឥទ្ធិពលនៃកំណើនការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌ ទៅលើភាពក្រីក្រ និងចំនួនការងារ។ ទោះយ៉ាងណាក្តី កំណើនការនាំចេញផលិតផលខាងលើ ប្រហែលជាប់ទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ ព្រោះប្រាក់កម្រៃអប្បបរមាប្រចាំខែនៅក្នុងវិស័យ គឺ ៥០ដុល្លារ (ប្រមាណ ២,២៧ដុល្លារ/ថ្ងៃ គិតតាមថ្លៃថេរឆ្នាំ២០០៨) ដែលខ្ពស់ជាងបន្ទាត់ភាពក្រីក្រជាតិនៅក្រុងភ្នំពេញឆ្នាំ២០០៧ (០,៧៦ដុល្លារ/ថ្ងៃ)។[១៥]

ផ្ទុយទៅវិញ ការនាំចេញទំនិញកម្មន្តសាលអតិពលកម្ម បានធ្លាក់ចុះយ៉ាងខ្លាំងនៅចន្លោះឆ្នាំ២០០០ និង ២០០៨ ដោយសារការធ្លាក់ចុះខ្លាំងនូវការនាំចេញសន្លឹកវីនៀរ/ក្តារបន្ទះ (SITC 634) និងទំនិញផ្សេងៗធ្វើពីឈើ ពីព្រោះរដ្ឋាភិបាលបានបញ្ឈប់ការកាប់ឈើនៅតំបន់ដីសម្បទាន និងការដឹកជញ្ជូនឈើហ៊ុបក្នុងខែមករា ២០០២។ ការធ្លាក់ចុះផលិតកម្មក្តារបន្ទះបានកាត់បន្ថយចំនួនការងារក្នុងវិស័យនេះ។ កង្វះខាតទិន្នន័យលើការកាត់បន្ថយការងារ និងប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករក្នុងវិស័យនេះ នាំឲ្យយើងមិនអាចធ្វើសេចក្តីសន្និដ្ឋានបានជាក់លាក់ពីឥទ្ធិពលលើភាពក្រីក្រ។ ការធ្លាក់ចុះផលិតផលខាងលើ ក៏បង្ហាញច្បាស់ពីការផ្លាស់ប្តូរយ៉ាងសំខាន់ក្នុងគោលនយោបាយពាណិជ្ជកម្មរបស់រដ្ឋាភិបាល ដែលគាំទ្រកាន់តែច្រើនដល់ការអភិរក្សបរិស្ថាន។

---

១៥ ការកែតម្រូវតាមអតិផរណា ដោយប្រើ CPI អនុវត្តឡើងដោយវិទ្យាស្ថានជាតិស្ថិតិ៖ ប្រាក់កម្រៃពិតប្រចាំថ្ងៃគឺ ២,២៧/១,៥១=១,៥០ដុល្លារ តាមកម្រិតថ្លៃឆ្នាំ២០០៦ ($CPI_{2008}$=151)។ ចំណាយប្រើប្រាស់ប្រចាំថ្ងៃក្នុងមនុស្សម្នាក់គឺ ០,៧៦/១,០៧=០,៧១ដុល្លារ តាមកម្រិតថ្លៃឆ្នាំ២០០៦ ($CPI_{2007}$=107)។

### ការនាំចូលពីចិន (ផ្នែកផលិតករ)

តារាង ៣.៦ បង្ហាញថា ផលិតផលកសិកម្មបានរួមចំណែកតែមួយភាគតូចនៅក្នុងការនាំចូលសរុបពីចិន ក្នុងចន្លោះឆ្នាំ ១៩៩២ និង ២០០៨។ ដូច្នេះ ការនាំចូលទំនិញកសិកម្មពីចិន ហាក់មិនបានគំរាមកំហែង ឬធ្វើការប្រកួតប្រជែងអ្វីតឹងតែងចំពោះផលិតករវិស័យកសិកម្មក្នុងស្រុកទេ។ មានផលិតផលកសិកម្មផ្សេងៗ ជាច្រើនដែលនាំចូលពីចិន ប៉ុន្តែភាគច្រើនបានចូលមកមិនទៀងទាត់ទេ ពោលគឺផលិតផលមួយអាចឃើញមាននាំចូលនៅឆ្នាំខ្លះ និងមិនឃើញមាននៅឆ្នាំខ្លះទៀត។ ផលិតផលទាំងនេះ មានដូចជា ប្រភេទត្រីស្រស់/ត្រាំទឹកកក/រក្សាទុកក្នុងកំប៉ុងមួយចំនួន (SITC 034 & 035) ស្រូវ (ជាប់សំបក) និងអង្ករកិនគ្មានបាក់ (SITC 0421 & 04231) ម្សៅដំឡូងឈើ/ជ្រៃ (SITC 05645) បន្លែក្រៀម (SITC 05619) ផ្លែម៉ឺឡុង/ល្ហុង (SITC 05791) ម្នាស់ច្នៃរួច (SITC 05893) និងផ្លែអាព្រីកូត/ផ្លែសឺរីហ្ស (SITC 05895)។

តារាង ៣.៦៖ ចំណែកនៃការនាំចូលផលិតផលជាក់លាក់ ធៀបនឹងការនាំចូលសរុបពីចិន ឆ្នាំ១៩៩២-២០០៨ នៅកម្រិតលេខ ៣ខ្ទង់

| ក្រុមផលិតផល | ផលិតផល | 1992 (%) | 2000 (%) | 2007 (%) | 2008 (%) |
|---|---|---|---|---|---|
| 1 | ផលិតផលកសិកម្មអតិពលកម្ម | 1.95 | 0.3 | 0.29 | 0.25 |
| 2 | ផលិតផលកសិកម្មផ្សេងៗ | 0.08 | 4.8 | 1.03 | 0.82 |
| 3 | ផលិតផលព្រៃឈើ | | 0 | 0.01 | 0.01 |
| 4 | រ៉ែ និង ឥន្ធនៈ | | 0.44 | 0.73 | 1.66 |
| 5 | សម្លៀកបំពាក់ និងវាយនភ័ណ្ឌអតិពលកម្ម | 0.06 | 51.33 | 60.22 | 54.63 |
| 6 | ផលិតផលអតិពលកម្មផ្សេងៗ | 6.42 | 7.6 | 3.19 | 3.66 |
| 7 | ផលិតផលកម្មន្តសាលផ្សេងៗ | 91.48 | 35.54 | 34.49 | 38.74 |
| | សរុប | 100 | 100 | 100 | 100 |

ប្រភព៖ UN ComTrade 2009

កំណត់សម្គាល់៖ តារាងលម្អិតមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ២

គួរកត់សម្គាល់ថា ផលិតផលផ្សេងទៀតបាននាំចូលជាទៀងទាត់ ប៉ុន្តែមិនមែនជាផលិតផលឯកទេសរបស់កម្ពុជាទេ ជាអាទិ៍ បន្លែបង្កក (SITC 05459) ផ្លែប៉ោមស្រស់ (SITC 0574) ទំពាំងបាយជូរក្រៀម (SITC 05752) ផ្លែព័រ/ក្វីនស៍ស្រស់ (SITC 05792) និងប៉ាស្តា (SITC 09891)។ ផលិតផលនាំចូលទាំងនេះ ជួយបំពេញបន្ថែមដល់ផលិតកម្មក្នុងស្រុក។

ផលិតផលខ្លះនាំចូលពីចិនក្នុងបរិមាណតិចតួច ប៉ុន្តែអាចបង្កើតជាការប្រកួតប្រជែងដល់ផលិតករក្នុងស្រុក ដោយសារកំណើនជាទៀងទាត់របស់វាចូលមកក្នុងទីផ្សារកម្ពុជា ហើយចិនជាប្រទេសឈានមុខគេក្នុងចំណោមផលិតករទំនិញមានថ្លៃទាបនៅក្នុងតំបន់។ ផលិតផលទាំងនោះ មានដូចជា សាច់ជ្រូកកំប៉ុង/កែច្នៃរួច (SITC 0175) ខ្ទឹមបារាំង/គល់ខ្ទឹម (SITC 05451) ខ្ទឹមស/ខ្ទឹមសយកគល់ (SITC 05452) ផ្សិតដុះក្នុងដី/ផ្សិតក្រៀម ឬកំប៉ុង (SITC 05679) ប៉េងប៉ោះកិន (SITC 05673) បន្លែរក្សាទុកផ្សេងទៀត (SITC 05679) ដំណាប់ផ្លែឈើ (SITC 0581) គ្រាប់ផ្លែឈើ (SITC 0581) ផ្លែឈើ/គ្រាប់ផ្លែឈើរក្សាទុក (SITC 05896) ទឹកឃ្មុំធម្មជាតិ (SITC 0616) នំផ្អែម-ស្ករគ្រាប់ (SITC 06229) តែបៃតង (SITC 07411) តែខ្មៅ (SITC 07413) ចំណីសត្វ (SITC 08199) ទឹកសៀង (SITC 09841) និងទឹកជ្រលក់មានគ្រឿងទេសផ្សំចូលគ្នា (SITC 09849)។

នៅមុនពាក់កណ្ដាលទសវត្សរ៍១៩៩០ សម្លៀកបំពាក់ និងវាយនភ័ណ្ឌអតិពលកម្ម រួមចំណែកតិចតួចក្នុងការនាំចូលសរុប ខណៈដែលផលិតផលកម្មន្តសាលផ្សេងទៀត រួមចំណែកយ៉ាងច្រើន។ បន្ទាប់ពីនោះមក ការនាំចូលសម្លៀកបំពាក់ និងវាយនភ័ណ្ឌ កើនយ៉ាងរហ័ស ដល់ប្រហែលជាពាក់កណ្ដាលនៃការនាំចូលសរុបពីចិន ដោយសារការរីកលូតលាស់យ៉ាង

លឿននៃវិស័យនេះក្នុងសេដ្ឋកិច្ចក្នុងស្រុក នៅចន្លោះពាក់កណ្តាលទសវត្សរ៍១៩៩០ និងឆ្នាំ២០០៨។ ក្នុងចំនួនរោងចក្រសរុប នៅក្នុងឧស្សាហកម្មនេះ មានប្រហែល ២០,៧% ជារបស់វិនិយោគិនមកពី ហុងកុង និង ១៣,១% មកពីចិន (GMAC 2006 cited in USAID 2007:8)។ រោងចក្រចិនទាំងនេះ (ស្ទើរតែទាំងអស់សម្រាប់បម្រើការនាំចេញ) តែងប្រើធាតុចូលសម្រាប់ផលិតកម្ម ដែលយកមកពីសហគ្រាសមេរបស់ខ្លួននៅប្រទេសចិន និង ហុងកុង។[១៦] ដូច្នេះ កំណើនចំណែកនៃការនាំចូលផលិតផលទាំងនោះ មិនគំរាមកំហែងដល់ផលិតករក្នុងស្រុកទេ ប៉ុន្តែរាំងស្ទះដល់ការអភិវឌ្ឍចំណងទាក់ទងដើមខ្សែនៃឧស្សាហកម្មក្នុងស្រុក។

ចំណែកការនាំចូលនៃទំនិញកម្មន្តសាលអតិពលកម្មផ្សេងៗ ធៀបនឹងការនាំចូលសរុបពីចិន មានតិចតួចណាស់ និងបានធ្លាក់ចុះពី ៧,៦% ក្នុងឆ្នាំ២០០៦ មកត្រឹម ៣,៦% ក្នុងឆ្នាំ២០០៨។ ការនាំចូលនេះហាក់មិនមានផលប៉ះពាល់អ្វីធំដុំទេ ព្រោះផលិតផលនាំចូលមួយចំនួន ដូចជា ស្បែកសត្វ ដូចជា ជ្រូក ចៀម ពពែ គោ (SITC 6112-6118) សន្លឹកវីនៀរ ក្តារបន្ទះ និងក្តារសរសៃឈើ (SITC 6341-6345) ឧបករណ៍ធ្វើពីឈើ (SITC 6351-6359) ពូក ស្រោមពូក និងគ្រឿងគ្រែ (SITC 89997) គ្រឿងសង្ហារឹមធ្វើពីលោហធាតុ និងប្លាស្ទិក (SITC 82139 & 82171) កាបូបដៃ ហិបធ្វើពីស្បែក វ៉ាលីធ្វើពីប្លាស្ទិក (SITC 8311-8312) ព្រមទាំងប្រដាប់ប្រដារក្មេងលេង (SITC 89421-89429) និងបំពង់ទឹកក្តៅ (SITC 89997) ជាដើម មិនមានការប្រកួតប្រជែងនៅក្នុងទីផ្សារក្នុងស្រុកទេ ដោយសារផលិតកម្មទំនិញខាងលើនេះ គ្មាន ឬមានសកម្មភាពតិចតួចនៅកម្ពុជា។

កំណើនជាទៀងទាត់នៃការនាំចូលទំនិញកម្មន្តសាលអតិពលកម្មផ្សេងទៀត អាចបង្កើតជាការប្រកួតប្រជែងចំពោះផលិតករក្នុងស្រុក។ ផលិតផលទាំងនោះ មានដូចជា ដប/ក្រឡកែវ កែវទឹក និងវត្ថុធ្វើពីកែវសម្រាប់តុអាហារ/ផ្ទះបាយ ព្រមទាំងគ្រឿងតុបតែងធ្វើពីកែវ (SITC 66511, 66522, 66523, 66529, 66593) សម្ភារៈផ្ទះបាយ/តុអាហារធ្វើពីប៉ុសឺឡែន (SITC 66611) សម្ភារៈការិយាល័យ ចង្ក្រាន និងសង្ហារឹមបន្ទប់គេងធ្វើពីឈើ (SITC 82151-82159) សង្ហារឹមធ្វើពីឫស្សី (SITC 82179) ក្រដាសឃីហោ និងក្រដាសកាតុង (SITC 89281) កាបូប/កញ្ចប់ និងកំប៉ុងធ្វើពីប្លាស្ទិក សម្ភារៈការិយាល័យ និងសម្ភារៈធ្វើពីប្លាស្ទិកដទៃទៀត (SITC 89311, 89319, 89394, 89399) ប៊ិកគ្រប់ប្រភេទ (SITC 89521) និងច្រាស/អំបោស/ឧបករណ៍ជូត (SITC 89972)។

ការនាំចូលផលិតផលកម្មន្តសាលផ្សេងៗ មានចំណែកប្រហែលមួយភាគបីនៃការនាំចូលពីចិនសរុប នៅចន្លោះឆ្នាំ១៩៩២ និង ២០០៨។ ទំហំនៃការនាំចូលផលិតផលទាំងនេះ ប្រហែលមិនមានផលប៉ះពាល់ធ្ងន់ធ្ងរលើភាពមានការងារធ្វើក្នុងសេដ្ឋកិច្ចក្នុងស្រុកទេ ព្រោះក្រុមផលិតផលទាំងនេះមិនមែនជាផលិតផលអតិពលកម្ម ប៉ុន្តែ វានៅតែអាចរារាំងដល់កំណើន ឬការលូតលាស់នៃឧស្សាហកម្មក្នុងស្រុកប្រភេទស្រដៀងគ្នា។

ផលិតផលខ្លះ អាចប្រកួតប្រជែងជាមួយផលិតផលក្នុងស្រុក ជាអាទិ៍ ភេសជ្ជៈមាន ឬគ្មានជាតិស្រវឹង (SITC 111-112) ផលិតផលឱសថ (SITC 541-542) ជី (SITC 56211) ផលិតផលក្រដាស/ក្រដាសកាតុង/ក្រដាសកាត់ (SITC 641-642) ស៊ីម៉ងត៍ (SITC 66122)។ ផលិតផលដទៃទៀត ដូចជា គីមីសរីរាង្គ និងអសរីរាង្គ (SITC511-516, 522-524) ផលិតផលប្លាស្ទិកកែច្នៃ និងផលិតផល/សម្ភារៈនៃឧស្សាហកម្មគីមី (SITC 581-583, 591-598) ព្រមទាំង ដែក ដែកថែប និងកម្មន្តសាលលោហធាតុ (SITC 673-679, 682-686, 691-699) និងប្រភេទផ្សេងទៀតនៃគ្រឿងយន្តកសិកម្ម និងឧស្សាហកម្ម (SITC 75-79, 81-83, 87-89) មិនមានការគំរាមកំហែងដល់ផលិតករក្នុងស្រុកឡើយ ដោយសារកម្ពុជាមិនមានឧស្សាហកម្មបែបនេះ។

---

១៦ នៅខែកុម្ភៈ ២០០៥ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC) បានធ្វើអង្កេតមួយលើរោងចក្រចំនួន ៧០ ជ្រើសរើសចេញពី ២៣៨រោងចក្រសម្រាប់ការនាំចេញ ដែលជាសមាជិកនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ហើយបានបង្ហាញថា ៧៩% នៃចំនួនរោងចក្រសរុបក្នុងគំរូតាង នាំចូលក្រណាត់ពីចិន និង ១៤% នាំចូលក្រណាត់ពី ហុងកុង ខណៈដែល ៧១% នាំចូលគ្រឿងវាយនភ័ណ្ឌបន្ទាប់បន្សំ ពីចិន និង ២៤% នាំចូលវាពីហុងកុង (USAID 2005:13)។

## *ការនាំចូលពីចិន (ផ្នែកអ្នកប្រើប្រាស់)*

ក្រៅពីការពិនិត្យពី ផលប៉ះពាល់ដែលអាចកើតមានលើភាពមានការងារធ្វើ និងការប្រកួតប្រជែងកើតចេញពីការនាំចូលពីប្រទេសចិននោះ យើងក៏គួរស្រាវជ្រាវមើលដែរថា តើអ្នកប្រើប្រាស់នៅកម្ពុជាអាចទទួលបានផលចំណេញពីផលិតផលមានថ្លៃទាបនាំចូលពីចិនឬយ៉ាងណា។ តារាង ៣.៧ បង្ហាញពីកំណើនបន្តិចនៃចំណែកការនាំចូលទំនិញប្រើប្រាស់សម្រាប់ជនក្រីក្រនៅវាងឆ្នាំ១៩៩២ និង ២០០០ ប៉ុន្តែធ្លាក់ចុះបន្តិចវិញ មកត្រឹម ៥,៥% ក្នុងឆ្នាំ២០០៨។ ផលចំណេញសម្រាប់អ្នកប្រើប្រាស់ ហាក់មិនមានលក្ខណៈធំដុំទេ។

តារាង ៣.៧៖ ចំណែកនៃទំនិញសម្រាប់ជនក្រីក្រ នាំចូលពីចិននៅឆ្នាំ១៩៩២-២០០៨ (%)

| *ឈ្មោះក្រុមផលិតផល* | *1992* | *2000* | *2007* | *2008* |
|---|---|---|---|---|
| ទំនិញសម្រាប់អ្នកក្រ | 2.27 | 9.55 | 4.82 | 5.49 |
| ក្រុមទំនិញផ្សេងៗ | 97.73 | 90.45 | 95.18 | 94.51 |

ប្រភព៖ UN ComTrade, 2009 ។ កំណត់សម្គាល់៖ ចំណាត់ថ្នាក់ផលិតផល មានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ១

តារាង ៣.៨៖ ចំណែកផលិតផលសម្រាប់ជនក្រីក្រ នៅក្នុងផលិតផលសរុបនាំចូលពីចិន ១៩៩២-២០០៨ (%)

| SITC 3 | *ក្រុមផលិតផល* | *1992* | *2002* | *2007* | *2008* |
|---|---|---|---|---|---|
| *001* | សត្វរស់ លើកលែងត្រី | | | | 0.0095 |
| *037* | ត្រី/ សត្វវង្គ(ក្ដាម បង្កង) ឬសិប្បសត្វ (ខ្យង គ្រំ) កែច្នៃ/រក្សាទុក | | 0.002 | 0.021 | 0.049 |
| *042* | អង្ករ | | 0.008 | | |
| *048* | គ្រាប់ធញ្ញជាតិ/ម្សៅ | | 0.013 | 0.094 | 0.337 |
| *054* | បន្លែ ស្រស់/ត្រាំទឹកកក/បង្កក | | 0.001 | 0.013 | 0.001 |
| *056* | មើម/ឫសបន្លែ កែច្នៃ/រក្សាទុក | 0.013 | 0.144 | 0.095 | 0.032 |
| *057* | ផ្លែឈើ/គ្រាប់ផ្លែឈើ ស្រស់/ស្ងួត | | 0.077 | 0.016 | 0.054 |
| *061* | ជាតិស្ករ/រង្វ/ទឹកឃ្មុំ | 1.84 | 0.005 | 0.012 | 0 |
| *062* | នំផ្អែម/ស្ករគ្រាប់ | 0.095 | 0.023 | 0.102 | 0.096 |
| *081* | ចំណីសត្វ | | 0.026 | 0.001 | 0.006 |
| *098* | ផលិតផលសម្រាប់ហូប ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.318 | 0.091 | 0.042 |
| *111* | វត្ថុរាវគ្មានជាតិស្រវឹង ដែលពុំបានចែងនៅកន្លែងផ្សេង | 0.663 | 0.107 | 0.037 | 0.067 |
| *269* | សម្លៀកបំពាក់ចាស់ៗ ជាដើម | | | 0.004 | 0.009 |
| *841* | សម្លៀកបំពាក់ត្បាញសម្រាប់ក្មេងប្រុស/បុរស | | 0.009 | 0.008 | 0.05 |
| *842* | សម្លៀកបំពាក់ត្បាញសម្រាប់ក្មេងស្រី/ស្ត្រី | | 0.097 | 0.001 | 0 |
| *843* | អាវសឺមិសសម្រាប់បុរសក្មេងប្រុស ដែលចាក់ដោយម្ជុល | | 0.27 | 0.07 | 0.652 |
| *844* | អាវសឺមិសសម្រាប់ស្ត្រីក្មេងស្រី ដែលចាក់ដោយម្ជុល | | 0.129 | 0.165 | 0.733 |
| *845* | សម្លៀកបំពាក់ប្រហាក់ប្រហែល ដែលពុំបានចែងនៅកន្លែងផ្សេង | | 3.188 | 2.448 | 2.034 |
| *846* | គ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់ | | 0.78 | 0.959 | 0.845 |
| *848* | សម្លៀកបំពាក់មិនមែនវាយនភ័ណ្ឌ/គ្រឿងសម្រាប់ពាក់លើក្បាល | 0.065 | 0.506 | 0.19 | 0.116 |
| *851* | ស្បែកជើង | 0.171 | 3.902 | 0.488 | |

ប្រភព៖ UN ComTrade 2009

តារាង ៣.៨ មានរាយនូវប្រភេទទំនិញប្រើប្រាស់សម្រាប់ជនក្រីក្រ គិតជាភាគរយធៀបនឹងទំនិញនាំចូលសរុបពីចិន។ ផលិតផលកសិកម្ម មានចំណែកតូចក្នុងក្រុមផលិតផលសម្រាប់ជនក្រីក្រ។ ជាក់ស្តែង សត្វរស់ និងត្រី/ខ្ទង មានចំណែកតិចតួច រីឯអង្ករមាននាំចូលតែម្តងម្កាលប៉ុណ្ណោះ។ ម្យ៉ាងទៀត ចំណែកនៃការនាំចូលបន្លែ បានធ្លាក់ចុះចន្លោះឆ្នាំ២០០០ និង ២០០៨។ ទាំងអស់នេះ សុទ្ធតែជាផលិតផលចាំបាច់ដែលគ្រួសារកម្ពុជាមានចំណូលមធ្យម និងទាប តែងប្រើប្រាស់ជាទូទៅ ជាពិសេសជនក្រីក្រ។ ចំណែកការនាំចូលស្ករ និងសារជាតិផ្អែម ក៏ធ្លាក់ចុះដែរ ក្នុងអំឡុងពេលដដែលនេះ។

ផ្ទុយមកវិញ ចំណែកនៃការនាំចូលចំណីសត្វ ផលិតផលអាចបរិភោគបាន និងភេសជ្ជៈគ្មានជាតិស្រវឹង កើនឡើងតិចតួច ហើយសម្លៀកបំពាក់ចាស់ៗ បានលេចឡើងជាផលិតផលនាំចូលថ្មីមួយទៀតក្នុងឆ្នាំ២០០៧ និង ២០០៨។ ចំណែកនៃការនាំចូលសម្លៀកបំពាក់ប្រភេទផ្សេងៗ ដូចជា សម្លៀកបំពាក់បុរស/ក្មេងប្រុស សម្លៀកបំពាក់ស្ត្រី/ក្មេងស្រី សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់ ដែលជាផលិតផលចំបងក្នុងក្រុមនេះ មានកំណើនបន្តិចបន្តួចនៅចន្លោះឆ្នាំ២០០០ និង ២០០៨។ ផលចំណេញសម្រាប់អ្នកប្រើប្រាស់ ហាក់គ្មានអ្វីធំដុំទេ ព្រោះភាគច្រើននៃទំនិញនាំចូលពីចិនទាំងនោះ ជាធាតុចូលសម្រាប់វិស័យកាត់ដេរ និងវាយនភ័ណ្ឌក្នុងស្រុកដែលសំដៅបម្រើការនាំចេញ។

### *ការនាំចេញទៅទីផ្សារទី៣*

ការសិក្សាអង្កេតពីភាពស្រដៀងគ្នាក្នុងរចនាសម្ព័ន្ធការនាំចេញនៃប្រទេសកម្ពុជា និងចិន ជាចំណុចសំខាន់ មុននឹងពិនិត្យពីការប្រកួតប្រជែងរវាងប្រទេសទាំងពីរនៅក្នុងទីផ្សារទី៣។ ការសិក្សានេះ ប្រើវិធីសាស្ត្ររបស់ Jenkins & Edwards (2004) និង Okamoto (2005)។ វិធីសាស្ត្រ Spearman correlation ranking ត្រូវបានយកមកអនុវត្ត ដើម្បីពិនិត្យពីទំនាក់ទំនងរវាងចំណែកនៃការនាំចេញតាមចំណាត់ថ្នាក់ SITC ៣ខ្ទង់ របស់កម្ពុជា ធៀបនឹងការនាំចេញសរុបរបស់ខ្លួនទៅសាកលលោក ហើយនិងចំណែកដូចគ្នារបស់ចិន។ កាលណាតម្លៃកាន់តែខិតជិត ១ គឺមានន័យថា រចនាសម្ព័ន្ធការនាំចេញរបស់ប្រទេសទាំងពីរកាន់តែស្រដៀងគ្នាខ្លាំង ដូច្នេះប្រទេសទាំងពីរកាន់តែប្រកួតប្រជែងគ្នាខ្លាំងនៅក្នុងទីផ្សារទី៣។

តារាង ៣.៩៖ ភាពស្រដៀងគ្នាខាងការនាំចេញរវាងចិន និង កម្ពុជា ពីឆ្នាំ១៩៩២ ដល់ ២០០៨

| *ឆ្នាំ* | *កសិកម្ម †* | *p-value* | *ផលិតកម្ម †* | *p-value* | *ទំនិញនាំចេញសរុប †* | *p-value* |
|---|---|---|---|---|---|---|
| 1992 | -0.1125 | 0.66 | 0.1293 | 0.24 | -0.0618 | 0.54 |
| 1995 | -0.0455 | 0.84 | 0.2287 | 0.02** | 0.0756 | 0.4 |
| 1998 | 0.0614 | 0.8 | 0.326 | 0.00*** | 0.1079 | 0.24 |
| 2001 | -0.0818 | 0.69 | 0.3593 | 0.00*** | 0.2642 | 0.00*** |
| 2004 | -0.0557 | 0.77 | 0.4731 | 0.00*** | 0.2388 | 0.00*** |
| 2007 | -0.1921 | 0.32 | 0.4646 | 0.00*** | 0.2501 | 0.00*** |
| 2008 | -0.1504 | 0.48 | 0.4685 | 0.00*** | 0.1771 | 0.03** |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យបានពី UNComTrade 2009។ កំណត់សម្គាល់៖ កម្រិតសារៈសំខាន់ស្ថិតិ៖ * កម្រិត ១០% ** កម្រិត ៥% *** កម្រិត ១% † ៖ គណនាតាមវិធីសាស្ត្រ Spearman correlation ranking រវាងចំណែកនៃទំនិញនាំចេញរបស់កម្ពុជា និងរបស់ចិន។

តារាង ៣.៩ បង្ហាញថា នៅចន្លោះឆ្នាំ២០០១ និង ២០០៨ សម្រាប់ទំនិញនាំចេញគ្រប់មុខ កម្ពុជា និងចិន មានភាពស្រដៀងគ្នាតិចតួច ដែលមានសារៈសំខាន់ស្ថិតិ (statistically significant) នៅកម្រិត ១% សម្រាប់ឆ្នាំ២០០១-០៧ និង ៥% សម្រាប់ឆ្នាំ២០០៨។ បើគិតតាមចំណាត់ថ្នាក់ក្រុមផលិតផល រចនាសម្ព័ន្ធនៃការនាំចេញផលិតផលកសិកម្មរបស់កម្ពុជា មានភាពខុសគ្នាជាមួយនឹងចិន ប៉ុន្តែកម្រិតនៃភាពស្រដៀងគ្នាបានកើនឡើងនៅក្នុងរចនាសម្ព័ន្ធនៃការនាំចេញផលិតផលកម្មន្តសាល ដែលមានសារៈសំខាន់ស្ថិតិនៅកម្រិត ៥% សម្រាប់ឆ្នាំ១៩៩៥ និង ១% សម្រាប់ឆ្នាំ១៩៩៨-២០០៨។ ចំណុចនេះបង្ហាញពីកំណើនការប្រកួតប្រជែងពីប្រទេសចិនក្នុងផលិតផលកម្មន្តសាលក្នុងទីផ្សារទី៣។

ការនាំចេញផលិតផលកម្មន្តសាលរបស់កម្ពុជា ផ្តោតជាចំបងលើផលិតផលវាយនភ័ណ្ឌ និង សម្លៀកបំពាក់ (ជាពិសេស SITC Rev.3 84) ដូច្នេះ ប្រទេសទាំងពីរទំនងជាដៃគូប្រកួតប្រជែងក្នុងផលិតផលទាំងនោះនៅទីផ្សារទី៣។ គួរកត់សម្គាល់ថា មេគុណទំនាក់ទំនងជាក់ច្បាស់នៃរចនាសម្ព័ន្ធការនាំចេញរបស់ប្រទេសទាំងពីរក្នុងផលិតផលកម្មន្តសាល អាចសន្មតថា បណ្តាលមកពីភាពស្រដៀងគ្នាខ្លាំងក្នុងរចនាសម្ព័ន្ធការនាំចេញផលិតផលវាយនភ័ណ្ឌ និងសម្លៀកបំពាក់ ព្រោះប្រទេសកម្ពុជា នៅមានមូលដ្ឋានផលិតទំនិញកម្មន្តសាលតូចចង្អៀត។ ចាប់តាំងពីការបង្កើតឧស្សាហកម្មនេះនៅពាក់កណ្តាលទសវត្សរ៍ ១៩៩០ ផលិតផលសម្លៀកបំពាក់របស់កម្ពុជា តែងតែតម្រង់ទិសទៅទីផ្សារសំខាន់ៗ ៣ គឺសហរដ្ឋអាមេរិក (ប្រមាណ ៧០%) សហភាពអឺរ៉ុប (២៣%) និង កាណាដា (៥%) (MoC 2009 cited in Saing 2009b: 2)។ ដូច្នេះ គួរមានការសិក្សាពិនិត្យពី ស្ថានភាពប្រកួតប្រជែងរវាងប្រទេសទាំងពីរនៅក្នុងទីផ្សារសហរដ្ឋអាមេរិក និងអឺរ៉ុប។

## ***ការប្រកួតប្រជែងក្នុងទីផ្សារសហរដ្ឋអាមេរិក***

រូបភាព ៣.៤ បង្ហាញថា ចំណែកទីផ្សារចិន កើនឡើងជាខ្លាំងក្នុងទីផ្សារសម្លៀកបំពាក់សហរដ្ឋអាមេរិកនៅអំឡុងទសវត្សរ៍ចុងក្រោយ ជាពិសេសនៅចន្លោះដើមទសវត្សរ៍២០០០ និងឆ្នាំ២០០៨ ដែលអាចបង្កការគំរាមកំហែងដល់ប្រទេសមានឯកទេសកម្មក្នុងផលិតផលទាំងនោះ ដូចជា បង់ក្លាដេស កម្ពុជា ឥណ្ឌូនេស៊ី ថៃ និងវៀតណាម។ ថ្វីបើមានវិបត្តិពីរ គឺៈ ការឡើងថ្លៃថាមពល និងការធ្លាក់ចុះសេដ្ឋកិច្ចសាកលក៏ដោយ ក៏ចំណែកទីផ្សាររបស់ប្រទេសចិនបានរីកធំគួរឲ្យកត់សម្គាល់ ចាប់ពីចុងឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ ខណៈដែលចំណែកទីផ្សាររបស់កម្ពុជាបានលូតលាស់យឺតៗ។ ក្នុងពេលនេះដែរ កំណើន ចំណែកទីផ្សាររបស់ប្រទេសវៀតណាម និងបង់ក្លាដេស បានដាក់សម្ពាធបន្ថែមមកលើផលិតករសម្លៀកបំពាក់របស់កម្ពុជា។

រូបភាព ៣.៤៖ ចំណែកទីផ្សារសម្លៀកបំពាក់ពីអាស៊ីនៅក្នុងទីផ្សារសហរដ្ឋអាមេរិក (SITC 841-848)




ប្រភព៖ USITC 2010

តារាង ៣.១០ បង្ហាញពីសម្លៀកបំពាក់នាំមុខគេ ១២មុខ ដែលកម្ពុជានាំចេញទៅទីផ្សារសហរដ្ឋអាមេរិក ចាប់តាំងពីការបង្កើតឧស្សាហកម្មនេះនៅដើមទសវត្សរ៍១៩៩០ និងគូសបញ្ជាក់ពីបណ្តាផលិតផលជាឯកទេសកម្មរបស់កម្ពុជា ដូចជា សម្លៀកបំពាក់ចាក់ដោយអំបោះទ្បេន ខោជើងវែងបុរស/ស្ត្រី សម្លៀកបំពាក់ក្រៅ/ខោអាវទ្រនាប់/សម្លៀកបំពាក់គេងយប់

បុរស/ស្ត្រី អាវយឺត អាវរលុងនារី និងសម្លៀកបំពាក់ទារក។ ពីឆ្នាំ១៩៩០ ដល់ ២០០៨ ផលិតផលភាគច្រើនមានកំណើនការនាំចេញតាមតម្លៃទីផ្សារបច្ចុប្បន្ន ហើយខ្លះទៀតមានកំណើនយ៉ាងខ្លាំង ដូចជា អាវចាក់ ខោជើងវែងស្ត្រី/ក្មេងស្រី/បុរស/ក្មេងប្រុស និងអាវក្រៅស្ត្រី/ក្មេងស្រី។

តារាង ៣.១០៖ សម្លៀកបំពាក់នាំមុខគេ ១២មុខ ដែលកម្ពុជានាំចេញទៅទីផ្សារសហរដ្ឋអាមេរិក ពីឆ្នាំ១៩៩០-២០០៨ (គិតជាលានដុល្លារ)

| *No.* | *SITC* | *ឈ្មោះផលិតផល* | *1990* | *1994* | *1997* | *2000* | *2003* | *2006* | *2008* |
|---|---|---|---|---|---|---|---|---|---|
| *1* | 8453 | សម្លៀកបំពាក់ចាក់ដោយអំបោះទ្បែន | - | 0.001 | 25.92 | 200.65 | 182.64 | 456.08 | 591.75 |
| *2* | 8426 | ខោជើងវែងស្ត្រី/ក្មេងស្រី | - | - | 11.4 | 139.66 | 273.21 | 350.95 | 373.5 |
| *3* | 8414 | ខោជើងវែងបុរស/ក្មេងប្រុស | - | - | 34.73 | 163.42 | 140.79 | 195.9 | 236.69 |
| *4* | 8442 | សម្លៀកបំពាក់ក្រៅស្ត្រី/ក្មេងស្រី ចាក់ដោយម្ជុល | - | 0.001 | 4.06 | 18.64 | 29.56 | 142.7 | 230.57 |
| *5* | 8448 | សម្លៀកបំពាក់ក្នុង ឬ សម្លៀកបំពាក់គេងយប់សម្រាប់ស្ត្រី/ក្មេងស្រី ចាក់ដោយម្ជុល | - | - | 1.32 | 27.23 | 123.86 | 185.63 | 160.00 |
| *6* | 8454 | អាវយឺតដៃខ្លី/អាវកីឡា ចាក់ដោយម្ជុល | - | - | 0.70 | 12.74 | 13.33 | 107.62 | 136.82 |
| *7* | 8437 | អាវសឺមិបុរស/ក្មេងប្រុស ចាក់ដោយម្ជុល | 0.073 | - | 2.64 | 20.97 | 31.23 | 90.98 | 93.69 |
| *8* | 8447 | អាវរលុងសម្រាប់ស្ត្រី/ក្មេងស្រី ចាក់ដោយម្ជុល | - | 0.012 | 4.99 | 16.67 | 34.75 | 117.56 | 91.46 |
| *9* | 8438 | សម្លៀកបំពាក់ក្នុងបុរស/ក្មេងប្រុស ចាក់ដោយម្ជុល | - | - | 2.39 | 11.45 | 74.54 | 76.13 | 73.18 |
| *10* | 8459 | សម្លៀកបំពាក់ចាក់ដោយម្ជុលដែលមិនបានចែងនៅកន្លែងផ្សេងទៀត | - | - | 0.42 | 3.26 | 6.23 | 60.98 | 72.62 |
| *11* | 8451 | សម្លៀកបំពាក់ទារក | - | - | 0.08 | 21.03 | 16.91 | 35.24 | 66.47 |
| *12* | 8432 | អាវធំបុរស/ក្មេងប្រុស ចាក់ដោយម្ជុល | - | - | 1.21 | 3.59 | 4.78 | 35.75 | 50.32 |

ប្រភព៖ UN ComTrade 2009

ដោយសារកំណើនតម្លៃនាំចេញនៃផលិតផលនាំមុខគេទាំង ១២មុខ របស់កម្ពុជា ដូចនេះ កំណើននៃចំណែកការនាំចេញសម្លៀកបំពាក់សរុបរបស់ចិនទៅសហរដ្ឋអាមេរិក ហាក់មិនបង្កការព្រួយបារម្ភធ្ងន់ធ្ងរចំពោះផលិតផលកម្ពុជាទេ។ ប៉ុន្តែការពិនិត្យលម្អិតពីទំនាក់ទំនងរវាងចំណែកទីផ្សារនៃប្រទេសទាំងពីរនៅកម្រិតផលិតផល ៤ខ្ទង់ បានផ្តល់រូបភាពយ៉ាងច្បាស់ពីការប្រកួតប្រជែងដែលអាចកើតមានរវាងប្រទេសទាំងពីរ។ រូបភាព ៣.៥ បង្ហាញថា កម្ពុជាអាចប្រឈមនឹងការគំរាមកំហែងពីផលិតករចិនក្នុងផលិតផលសម្លៀកបំពាក់មួយចំនួន ដូចជា សម្លៀកបំពាក់ទារក អាវចាក់ ខោអាវទ្រនាប់បុរស/ក្មេងប្រុស ក្រណាត់ប៉ាក់/សូត្រ ខោជើងវែងបុរស/ក្មេងប្រុស អាវក្រៅស្ត្រី/ក្មេងស្រី ខោអាវទ្រនាប់/សម្លៀកបំពាក់គេងយប់ស្ត្រី/ក្មេងស្រី អាវបុរស/ស្ត្រី ក្រណាត់ប៉ាក់/សូត្រ និងខោជើងវែងស្ត្រី/ក្មេងស្រី ជាដើម។ ប៉ុន្តែដោយសារចំណែកផលិតផលចិនដទៃទៀតបានធ្លាក់ចុះ ជាពិសេសសម្លៀកបំពាក់ប៉ាក់/សូត្រ ដូច្នេះ កម្ពុជាក៏អាចចាប់យកឱកាសថ្មីៗបានដែរ។

រូបភាព ៣.៥៖ ចំណែកទីផ្សារនៃផលិតផលសម្លៀកបំពាក់នាំមុខគេ ១២មុខ របស់កម្ពុជា នៅក្នុងទីផ្សារសហរដ្ឋអាមេរិក ឆ្នាំ១៩៩០-២០០៨[១៧]




Source: UN ComTrade 2009

## ***ការប្រកួតប្រជែងក្នុងទីផ្សារអឺរ៉ុប***

រូបភាព ៣.៦ បង្ហាញពីកំណើនយ៉ាងខ្លាំងនៃចំណែកទីផ្សារសម្លៀកបំពាក់ចិន នៅតំបន់អឺរ៉ុប ក្នុងទសវត្សរ៍ចុងក្រោយ ហើយវាមានល្បឿនលឿននៅចន្លោះឆ្នាំ២០០០ និង ២០០៨ ដែលអាចគំរាមកំហែងដល់ប្រទេសមានឯកទេសកម្មក្នុងផលិតផលដូចគ្នា ដូចជា បង់ក្លាដេស កម្ពុជា ឥណ្ឌូនេស៊ី ថៃ និងវៀតណាម។ ថ្វីបើមានវិបត្តិពីរគឺ៖ ការឡើងថ្លៃថាមពល និងការធ្លាក់ចុះសេដ្ឋកិច្ចសាកលក៏ដោយ ក៏ចំណែកទីផ្សារប្រទេសចិនបានរីកធំគួរឲ្យកត់សម្គាល់ចាប់ពីចុងឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ ខណៈដែលចំណែកទីផ្សាររបស់កម្ពុជាបានធ្លាក់ចុះ។ ប៉ុន្តែដោយសារផលិតផលកម្ពុជាមានចំណែកតូចក្នុងទីផ្សារអឺរ៉ុប គឺប្រមាណ ០,០១% ទៅ ១% នៅចន្លោះឆ្នាំ១៩៩០ និង ២០០៨ ដូច្នេះកំណើនចំណែកទីផ្សារផលិតផលចិន និងបង់ក្លាដេស មិនទំនងជាមានផលប៉ះពាល់មកលើផលិតផលកម្ពុជាទេ។

---

១៧ សម្លៀកបំពាក់ជាប់ចំណាត់ថ្នាក់កំពូល ១២មុខរបស់កម្ពុជា ក្នុងចំណោមសម្លៀកបំពាក់នាំចេញទៅសហរដ្ឋអាមេរិកទាំងអស់ (SITC 84) ផ្អែកតាមតម្លៃនាំចេញក្នុងឆ្នាំ២០០៨។

រូបភាព ៣.៦៖ ចំណែកទីផ្សារសម្លៀកបំពាក់ពីអាស៊ី នៅក្នុងទីផ្សារអឺរ៉ុប (SITC 841-848)




ប្រភព៖ UN ComTrade 2010

តារាង ៣.១១ បញ្ជាក់ពីការនាំចេញផលិតផលសម្លៀកបំពាក់នាំមុខគេទាំង ១២មុខរបស់កម្ពុជា ទៅទីផ្សារអឺរ៉ុប នៅចន្លោះឆ្នាំ១៩៩០ និង ២០០៨ ដែលមានរចនាសម្ព័ន្ធស្រដៀងទៅនឹងទីផ្សារសហរដ្ឋអាមេរិក។ ផលិតផលនាំចេញចំបង គឺខោជើងវែងបុរស/ក្មេងប្រុស ខោជើងវែងស្ត្រី/ក្មេងស្រី អាវសឺមិសម្រាប់បុរស/ក្មេងប្រុស សម្លៀកបំពាក់ចាក់ដោយអំបោះទ្បែន អាវសឺមិសម្រាប់បុរស/ក្មេងប្រុសចាក់ដោយម្ជុល និងអាវធំបុរស/ក្មេងប្រុស ស្របពេលដែលផលិតផលដទៃទៀតរួមមានអាវម៉ង់តូ និងអាវក្រៅសម្រាប់ស្ត្រី/ក្មេងស្រី សម្លៀកបំពាក់ចាក់ដោយម្ជុល អាវយឺតដៃខ្លី និងអាវរលុងស្ត្រី/ក្មេងស្រី។ តម្លៃសម្លៀកបំពាក់នាំចេញនាំមុខគេ ៦មុខដំបូង កើនឡើងខ្លាំង លើកលែងតែសម្លៀកបំពាក់ចាក់ដោយអំបោះទ្បែន និងអាវសឺមិសម្រាប់បុរស/ក្មេងប្រុស ហើយក្រុមផលិតផលនាំមុខគេដទៃទៀត ក៏មាននិន្នាការស្រដៀងនេះដែរ។

ដោយសារកំណើនតម្លៃនាំចេញនៃផលិតផលនាំមុខគេទាំង ១២មុខ របស់កម្ពុជា ដូច្នេះកំណើននៃចំណែកការនាំចេញសម្លៀកបំពាក់សរុបរបស់ចិនទៅទីផ្សារអឺរ៉ុប ហាក់មិនមានបង្កការគំរាមកំហែងអ្វីដល់ផលិតផលកម្ពុជាទេ។ ផ្អែកតាមការធ្វើចំណាត់ថ្នាក់លេខ ៤ខ្ទង់ កំណើនចំណែកទីផ្សារផលិតផលចិន បានបង្ហាញរូបភាពកាន់តែច្បាស់ឡើង។ ចំណែកទីផ្សារនៃសម្លៀកបំពាក់នាំចេញនាំមុខគេមួយមុខៗ ក្នុងចំណោមទាំង ១២មុខរបស់ចិន បានកើនឡើងយ៉ាងលឿនដែលអាចបង្កគ្រោះថ្នាក់ដល់ផលិតផលកម្ពុជា។ ប៉ុន្តែដោយសារចំណែកទីផ្សារនៃសម្លៀកបំពាក់នាំមុខគេមួយមុខៗក្នុងចំណោមទាំង ១២មុខរបស់កម្ពុជា មានទំហំតូច ដូច្នេះផលប៉ះពាល់អវិជ្ជមានហាក់គ្មានអ្វីធំដុំទេ។

តារាង ៣.១១៖ សម្លៀកបំពាក់នាំមុខគេ ១២មុខ ដែលកម្ពុជានាំចេញទៅទីផ្សារអឺរ៉ុបពីឆ្នាំ១៩៩០-២០០៨ (លានដុល្លារ)

| No. | SITC | ឈ្មោះផលិតផល | 1990 | 1994 | 1997 | 2000 | 2003 | 2006 | 2008 |
|---|---|---|---|---|---|---|---|---|---|
| 1 | 8414 | ខោជើងវែងបុរស/ក្មេងប្រុស | 0.01 | 3.36 | 53.37 | 139.69 | 282.83 | 433.89 | 548.86 |
| 2 | 8426 | ខោជើងវែងស្ត្រី/ក្មេងស្រី | 0.00 | 3.58 | 14.6 | 25.65 | 37.42 | 86.05 | 92.11 |
| 3 | 8415 | អាវសឺមិសម្រាប់បុរស/ក្មេងប្រុស | 0.00 | 0.16 | 3.36 | 5.04 | 11.01 | 15.53 | 54.23 |
| 4 | 8453 | សម្លៀកបំពាក់ចាក់ដោយអំបោះទ្បែន | 0.21 | 0.87 | 13.8 | 31.12 | 54.67 | 49.42 | 43.31 |
| 5 | 8437 | អាវសឺមិបុរស/ក្មេងប្រុសចាក់ដោយម្ជុល | - | 0.51 | 2.88 | 19.43 | 57.49 | 43.27 | 42.28 |
| 6 | 8432 | អាវធំបុរស/ក្មេងប្រុសចាក់ដោយម្ជុល | - | 0.13 | 0.51 | 5.33 | 9.11 | 18.97 | 30.85 |
| 7 | 8442 | សម្លៀកបំពាក់ក្រៅសម្រាប់ស្ត្រី/ក្មេងស្រីចាក់ដោយម្ជុល | - | 0.57 | 6.06 | 5.84 | 21.85 | 31.9 | 24.89 |
| 8 | 8441 | អាវម៉ង់តូស្ត្រី/ក្មេងស្រីចាក់ដោយម្ជុល | - | 1.78 | 3.41 | 2.57 | 6.51 | 8.25 | 17.52 |
| 9 | 8459 | សម្លៀកបំពាក់ចាក់ដោយម្ជុលដែលមិនបានចែងនៅកន្លែងផ្សេងទៀត | - | 5.64 | 4.19 | 0.91 | 8.79 | 11.5 | 16.66 |
| 10 | 8454 | អាវយឺតដៃខ្លី/អាវកីឡាចាក់ដោយម្ជុល | - | 0.71 | 4.56 | 2.86 | 0.65 | 3.31 | 15.72 |
| 11 | 8447 | អាវរលុងសម្រាប់ស្ត្រី/ក្មេងស្រី ចាក់ដោយម្ជុល | - | 0.35 | 4.95 | 5.11 | 6.76 | 11.1 | 13.15 |
| 12 | 8458 | សម្លៀកបំពាក់មិនមែនចាក់ដោយម្ជុលដែលមិនបានចែងនៅកន្លែងផ្សេងទៀត | - | 0.21 | 1.39 | 0.37 | 3.13 | 3.65 | 9.69 |

ប្រភព៖ UN ComTrade 2009

រូបភាព ៣.៧៖ ចំណែកទីផ្សារនៃផលិតផលសម្លៀកបំពាក់នាំមុខគេរបស់កម្ពុជានៅក្នុងទីផ្សារអឺរ៉ុប ឆ្នាំ១៩៩០-២០០៩




ប្រភព៖ UN ComTrade 2009

សរុបមក តាមការពិនិត្យចំណែកទីផ្សារនៃផលិតផលសម្លៀកបំពាក់សំខាន់ៗរបស់កម្ពុជាក្នុងទីផ្សារទី៣ ដូចជា ទីផ្សារសហរដ្ឋអាមេរិក និងទីផ្សារអឺរ៉ុបជាដើម ការសិក្សានេះអាចសន្និដ្ឋានបានថា ចិនអាចក្លាយជាដៃគូប្រកួតប្រជែងចំពោះផលិតផលសម្លៀកបំពាក់កម្ពុជាមួយចំនួន ប៉ុន្តែមិនមែនក្នុងទីផ្សារអឺរ៉ុបទេ ដោយសារតែផលិតផលកម្ពុជាមានចំណែកតូចណាស់ក្នុងទីផ្សារនេះ។ ទោះយ៉ាងនេះក្តី ក៏គួរពិចារណាឲ្យបានម៉ត់ចត់ថា តើកម្ពុជាអាចប្រកួតប្រជែងនឹងចិនឬទេ ក្នុងទីផ្សារសហរដ្ឋអាមេរិក និងទីផ្សារអឺរ៉ុប ពីព្រោះ ១៣,១% នៃឧស្សាហកម្មកាត់ដេរនៅកម្ពុជាជារបស់ប្រទេសចិន និង ២០,៧% ជារបស់ហុងកុង ហើយកម្ពុជាមានចំណែកតិចតួចត្រឹមតែ ៨,៦% ប៉ុណ្ណោះ (GMAC 2006 cited in USAID 2007: 8)។

## ជំពូក ៤

# វិនិយោគចិន និងផលប៉ះពាល់

### ៤.១ ទំហំ និងការប្រែប្រួលវិនិយោគ

ដោយសារប្រាក់សន្សំក្នុងស្រុកមានកម្រិតទាប ដូចនេះ FDI គឺជាសមាសធាតុដ៏សំខាន់មួយក្នុងសេដ្ឋកិច្ចកម្ពុជា។ ពីឆ្នាំ១៩៩៨ ដល់ ២០០៨ កម្រិតនៃ FDI គិតជាអនុមតិទ្រព្យសកម្មជាប់លាប់ បានរួមចំណែកជាមធ្យមប្រមាណ ១៥% នៃ ផសស និង ៥៦% នៃអនុមតិវិនិយោគសរុប (រូបភាព ៤.១)។ FDI ប្រមូលផ្តុំជាចំបងក្នុងវិស័យទេសចរណ៍ សំណង់ និងកាត់ដេរ។ ទិន្នន័យបានពីសៀវភៅស្ថិតិប្រចាំឆ្នាំ២០០៨ របស់វិទ្យាស្ថានជាតិស្ថិតិ (NIS) បង្ហាញថា ជាមធ្យម ៦០% នៃអនុមតិទ្រព្យសកម្មជាប់លាប់សរុប ត្រូវបានអនុវត្តក្នុងអំឡុងឆ្នាំ១៩៩៤ ដល់ ២០០៧។

រូបភាព ៤.១៖ វិនិយោគផ្ទាល់ពីបរទេស (អនុមតិវិនិយោគសរុបគិតជាទ្រព្យសកម្មជាប់លាប់) ក្នុងប្រទេសកម្ពុជា
(លានដុល្លារ និង % នៃ ផសស)




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងទិន្នន័យចក្ខុវិស័យសេដ្ឋកិច្ចពិភពលោករបស់ IMF (ខែមេសា ២០១០)

ប្រទេសចិន ជាវិនិយោគិនចំបងមួយក្នុងប្រទេសកម្ពុជា។ តារាង ៤.១ បង្ហាញពីវិនិយោគិនឈានមុខទាំង ១២ ក្នុងប្រទេសកម្ពុជា ចាប់ពីឆ្នាំ១៩៩៨ ដល់ ២០០៩។ ចិនជាវិនិយោគិននាំមុខគេ ដោយរួមចំណែកប្រមាណ ៤៥,៦% នៃ វិនិយោគបរទេសសរុប បន្ទាប់មក មានកូរ៉េខាងត្បូង (១៧,៦%) និងសហរដ្ឋអាមេរិក (៩,៥%)។ វិនិយោគរបស់ចិន មានទំហំ

ជាមធ្យមប្រមាណ ២៥លានដុល្លារ ដែលទាបជាងវិនិយោគរបស់រុស្ស៊ី (៦២លានដុល្លារ) សហរដ្ឋអាមេរិក (៣៧,២លានដុល្លារ) និង កូរ៉េខាងត្បូង (៣០,៩លានដុល្លារ)។

តារាង ៤.១៖ វិនិយោគិនឈានមុខទាំង ១២ ក្នុងប្រទេសកម្ពុជា ពីឆ្នាំ១៩៩៨ ដល់ ២០០៨

| *ប្រទេស* | *ចំនួនគម្រោង* | *អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ (លានដុល្លារអាមេរិក)* | *តម្លៃវិនិយោគជាមធ្យម (លានដុល្លារអាមេរិក)* | *% នៃ FDI សរុប* |
|---|---|---|---|---|
| ចិន | 278 | 6940.9 | 25.0 | 45.6 |
| កូរ៉េខាងត្បូង | 87 | 2686.1 | 30.9 | 17.6 |
| សហរដ្ឋអាមេរិក | 39 | 1452.5 | 37.2 | 9.5 |
| ថៃ | 43 | 596.1 | 13.9 | 3.9 |
| ម៉ាឡេស៊ី | 51 | 534.6 | 10.5 | 3.5 |
| វៀតណាម | 33 | 447.0 | 13.5 | 2.9 |
| តៃវ៉ាន់ | 117 | 436.2 | 3.7 | 2.9 |
| រុស្ស៊ី | 7 | 434.0 | 62.0 | 2.8 |
| សិង្ហបុរី | 46 | 403.8 | 8.8 | 2.7 |
| ហុងកុង | 47 | 171.6 | 3.7 | 1.1 |
| ជប៉ុន | 15 | 135.4 | 9.0 | 0.9 |
| បារាំង | 15 | 114.8 | 7.7 | 0.8 |

ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

តារាង ៤.២៖ វិនិយោគរបស់ប្រទេសចិនក្នុងប្រទេសកម្ពុជា ពីឆ្នាំ១៩៩៨ ដល់ ២០០៩

| *ឆ្នាំ* | *ចំនួនគម្រោង* | | | *អនុមតិទ្រព្យសកម្មជាប់លាប់ (លានដុល្លារ)* | | |
|---|---|---|---|---|---|---|
| | *សរុប* | *ចិន* | *% នៃចិន* | *សរុប* | *ចិន* | *% នៃចិន* |
| 1998 | 212 | 40 | 18.9 | 555.5 | 104.7 | 18.9 |
| 1999 | 135 | 27 | 20.0 | 196.2 | 46.0 | 23.5 |
| 2000 | 83 | 7 | 8.4 | 160.2 | 28.4 | 17.7 |
| 2001 | 47 | 5 | 10.6 | 139.5 | 5.0 | 3.6 |
| 2002 | 44 | 8 | 18.2 | 143.6 | 24.1 | 16.8 |
| 2003 | 58 | 10 | 17.2 | 64.7 | 32.9 | 50.9 |
| 2004 | 75 | 21 | 28.0 | 154.7 | 83.1 | 53.7 |
| 2005 | 123 | 41 | 33.3 | 682.4 | 452.0 | 66.2 |
| 2006 | 119 | 31 | 26.1 | 2300.6 | 717.1 | 31.2 |
| 2007 | 166 | 32 | 19.3 | 1344.6 | 180.3 | 13.4 |
| 2008 | 125 | 28 | 22.4 | 7620.8 | 4374.6 | 57.4 |
| 2009 | 122 | 28 | 23.0 | 1871.3 | 892.7 | 47.7 |
| 1998-2009 | 1309 | 278 | 21.2 | 15,234.0 | 6940.9 | 45.6 |

ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

តារាង ៤.២ បង្ហាញពីការរីកលូតលាស់នៃវិនិយោគផ្ទាល់ពីចិនមកក្នុងប្រទេសកម្ពុជា ចាប់ពីឆ្នាំ១៩៩៨ និងវិនិយោគប្រកបដោយនិរន្តរភាពពីបណ្តាសហគ្រាសចិនមកក្នុងប្រទេសកម្ពុជាពីឆ្នាំ២០០៤ ដល់ ២០០៩។

របាយតាមវិស័យនៃវិនិយោគរបស់ចិនក្នុងប្រទេសកម្ពុជា បង្ហាញថា ចិនចាប់អារម្មណ៍ខ្លាំងទៅលើវិស័យអភិវឌ្ឍន៍ធនធានធម្មជាតិ ដូចជា ប្រេងកាត រ៉ែ និងថាមពល (រួមទាំងរោងចក្រវារីអគ្គិសនី) ព្រមទាំងវិស័យទេសចរណ៍ និងកាត់ដេរ។

ពីឆ្នាំ១៩៩៨ ដល់ ២០០៩ មាន ៩៩,៨% នៃ FDI សរុប ក្នុងវិស័យប្រេងកាត ៩១,៧% នៃ FDI សរុប ក្នុងវិស័យរ៉ែ និង ៨៣,៥% នៃ FDI សរុប ក្នុងវិស័យថាមពល ជាវិនិយោគរបស់ចិន (រូបភាព ៤.៣)។ វិនិយោគរបស់ចិនក្នុងវិស័យទេសចរណ៍ (៦០,៧%) កាត់ដេរ (៤០,១%) ឧស្សាហកម្មផ្សេងៗ (៣៨,១%) និងកសិកម្ម (២៥,៦%) ក៏មានទំហំធំដែរ ធៀបនឹង FDI សរុប ក្នុងវិស័យនីមួយៗទាំងនោះ។

រូបភាព ៤.២៖ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់តាមវិស័យ ពីឆ្នាំ១៩៩៨ ដល់ ២០០៨
(ជា % នៃអនុមតិ FDI សរុប គិតជាទ្រព្យសកម្មជាប់លាប់)




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

វិនិយោគចិននៅកម្ពុជា បានរីកធំជាបណ្តើរៗពីក្រុមហ៊ុនកម្មន្តសាលខ្នាតតូច ជាពិសេសក្នុងវិស័យកាត់ដេរ ទៅជាក្រុមហ៊ុនអភិវឌ្ឍន៍ធនធានខ្នាតមធ្យម និងខ្នាតធំ ដែលបានធ្វើវិនិយោគយ៉ាងសំខាន់បំផុតក្នុងផ្នែកធនធានធម្មជាតិ កសិកម្ម សំណង់ និងរោងចក្រវារីអគ្គិសនី។ ដោយឡែកក្នុងឆ្នាំ២០០៨ ចិនបានវិនិយោគយ៉ាងច្រើនក្នុងវិស័យទេសចរណ៍នៅកម្ពុជា ជាពិសេស ក្នុងការអភិវឌ្ឍតំបន់កំសាន្តឆ្នេរសមុទ្រនៅកោះកុង (គីរីសាគរ និងបុទុមសាគរ) ដែលមានទឹកប្រាក់ដល់ទៅ ៣៨០៥លានដុល្លារ ឬស្មើនឹង ៩៨% នៃវិនិយោគសរុបរបស់ចិនក្នុងវិស័យនេះ ចាប់ពីឆ្នាំ១៩៩៨ ដល់ ២០០៩។

Wu និង Chen (2001) បង្ហាញថា ការស្ទុះឡើងនៃវិនិយោគក្រៅប្រទេសរបស់ចិន គឺផុសចេញពីផលប្រយោជន៍ខាងនយោបាយ ការស្វែងរកទីផ្សារ បំណងទាញយកចំណេញពីតម្លៃពលកម្មទាប ព្រមទាំងវត្ថុមាន និងកម្រិតថ្លៃនៃ

ធនធានធម្មជាតិ។ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ធនធានមនុស្ស ព្រមទាំងស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងរចនាសម្ព័ន្ធស្ថាប័ននៃប្រទេសម្ចាស់ផ្ទះ ក៏ដើរតួនាទីសំខាន់ណាស់ដែរក្នុងវិនិយោគរបស់ចិន ដូចបានឃើញជាក់ស្តែងនៅកម្ពុជា។

រូបភាព ៤.៣៖ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់របស់ចិនតាមវិស័យជ្រើសរើស ពីឆ្នាំ១៩៩៨ ដល់ ២០០៨
(ជា % នៃអនុមតិ FDI សរុប គិតជាទ្រព្យសកម្មជាប់លាប់ក្នុងវិស័យនីមួយៗ)




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

វិនិយោគចិនយ៉ាងច្រើនក្នុងវិស័យកាត់ដេរសម្រាប់ការនាំចេញក្នុងទសវត្សរ៍១៩៩០ មានដើមហេតុជាចំបងអំពីលក្ខខណ្ឌអនុគ្រោះផ្នែកពាណិជ្ជកម្ម (MFN) របស់កម្ពុជា និងផលចំណេញពីសិទ្ធិនាំចេញរបស់កម្ពុជាក្រោមប្រព័ន្ធអនុគ្រោះទូទៅ (GSP) ផ្តល់ដោយសហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងប្រទេសអភិវឌ្ឍន៍ដទៃទៀត។ វិនិយោគិនចិនទាញយកផលចំណេញទាំងពីរយ៉ាង គឺលទ្ធភាពចូលទៅទីផ្សារ និងថ្លៃទាបនៃកម្លាំងពលកម្ម។ ថ្មីៗនេះ ចិនបានវិនិយោគក្នុងការអភិវឌ្ឍធនធានធម្មជាតិ ដូចជា ថាមពល (រោងចក្រវារីអគ្គិសនី) រ៉ែ កសិឧស្សាហកម្ម និងសំណង់ ជាដើម។

Wu និង Chen (2001) បង្ហាញទៀតថា គុណភាពអន់នៃកម្លាំងពលកម្ម និងកម្រិតបច្ចេកទេសទាបក្នុងប្រទេសកំពុងអភិវឌ្ឍ បានលើកទឹកចិត្តជាខ្លាំងដល់ការបង្កើតទីផ្សារកិច្ចសន្យា (contract market) (ហើយចិនអាចឈានចូលក្នុងទីផ្សារនេះ ដោយផ្អែកលើបទពិសោធន៍របស់ខ្លួន) ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានតាមរយៈការផ្តល់ជំនួយបរទេស។ ម្យ៉ាងទៀត វិធីនេះក៏បានជួយជំរុញការលក់ផលិតផលនាំចេញរបស់ចិនដែរ។ ជាក់ស្តែង ក្រុមហ៊ុនសំណង់ផ្សេងៗរបស់ចិនបានជួយជំរុញការនាំចេញសម្ភារៈសំណង់ បរិក្ខារសម្រួល បច្ចេកទេស និងកម្លាំងពលកម្មរបស់ចិន។ ចំណុចនេះ នឹងមានពិភាក្សានៅផ្នែកបន្ទាប់ ស្តីពីជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ចិនចំពោះកម្ពុជា។

## ៤.២ ក្របខណ្ឌវិភាគ និងវិធីសាស្ត្រ

ក្នុងការវាយតម្លៃពីឥទ្ធិពលនៃ FDI លើការកាត់បន្ថយភាពក្រីក្រ ចំណុចសំខាន់គឺត្រូវញែកចេញពីគ្នានូវផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលរបស់ FDI។ FDI អាចរួមចំណែកដោយផ្ទាល់ជាចំបងតាមរយៈការបង្កើតការងារ និងប្រាក់ចំណូល។ ផលចំណេញដោយប្រយោលនៃ FDI អាចផ្ទេរតាមរយៈចំណងទាក់ទងដើមខ្សែ និងចុងខ្សែ (backward and forward kinkages) ចំណេះដឹងទទួលបានដោយប្រយោល និងឥទ្ធិពលការបង្ហាញឲ្យឃើញជាក់ស្តែង។ ទោះយ៉ាងនេះក្តី ការវាស់វែងពីឥទ្ធិពលទាំងនោះ មានការលំបាកបន្តិច។

ឥទ្ធិពលលើភាពក្រីក្រនៃ FDI ប្រភេទផ្សេងៗ ជាអាទិ៍ FDI ក្នុងវិស័យអតិពលកម្ម ឬអតិមូលធន ជាដើម ក៏អាចសម្គាល់បានដែរ។ ដូចនេះ កម្ពុជាចាំបាច់ត្រូវបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រដើម្បីទាក់ទាញ FDI មកក្នុងវិស័យទាំងនោះដែលចូលរួមចំណែកជួយកាត់បន្ថយភាពក្រីក្រ។ FDI ក្នុងវិស័យអតិពលកម្ម ជាប្រភពបង្កើតការងារដ៏ចំបងនៅក្នុងប្រទេសមួយដូចជាកម្ពុជាយើង ដូច្នេះសំខាន់ជាខ្លាំងសម្រាប់ការកាត់បន្ថយភាពក្រីក្រ។

គេតែងគិតថា វិនិយោគចិនក្នុងវិស័យអតិពលកម្មនេះ ជួយបង្កើតការងារយ៉ាងច្រើនសម្រាប់ពលករគ្មានជំនាញដែលជះឥទ្ធិពលវិជ្ជមានដល់ជនក្រីក្រនៅទីជនបទ។ ដូច្នេះ ក្រុមស្រាវជ្រាវបានធ្វើករណីសិក្សាមួយលើវិស័យកាត់ដេរដែលជាឧស្សាហកម្មអតិពលកម្មមួយទាក់ទាញវិនិយោគយ៉ាងច្រើនពីប្រទេសចិន។ ករណីសិក្សានេះ ព្យាយាមវាយតម្លៃពីឥទ្ធិពលនៃលំហូរចូល FDI របស់ចិន លើការកាត់បន្ថយភាពក្រីក្រដោយពិនិត្យទៅលើ៖ (១) ឱកាសបង្កើនចំណូលសម្រាប់ជនក្រីក្រនៅជនបទ តាមរយៈការបង្កើតការងារ និងប្រាក់កម្រៃខ្ពស់ជាងមុន (២) ប្រាក់ផ្ញើទៅផ្ទះ និង (៣) ផលចំណេញជាប្រយោលដល់ការអភិវឌ្ឍជំនាញរបស់ជនក្រីក្រនៅតំបន់ជនបទ និងការផ្ទេរបច្ចេកវិទ្យាមកសហគ្រាសក្នុងស្រុក។ ឥទ្ធិពលនៃវិនិយោគចិនក្នុងវិស័យកាត់ដេរ មកលើសេដ្ឋកិច្ច ក៏មានពិភាក្សាដោយត្រួសៗផងដែរ។

រូបភាព ៤.៤៖ ក្របខ័ណ្ឌវិភាគពីវិនិយោគចិននៅកម្ពុជា




ចិន ក៏បានវិនិយោគច្រើនដែរក្នុងវិស័យធនធានធម្មជាតិ (កសិកម្ម កសិឧស្សាហកម្ម រ៉ែ ប្រេងនិងឧស្ម័ន និងវារីអគ្គិសនី) ជាពិសេសតាមរយៈសម្បទានដីសេដ្ឋកិច្ច។ វិនិយោគទុនប្រភេទនេះ មានផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានខ្លាំងទៅលើការកាត់បន្ថយភាពក្រីក្រ ជីវភាពនៅមូលដ្ឋាន និងបរិស្ថាន ប៉ុន្តែការសិក្សានេះ មិនបានផ្ដោតលើទិដ្ឋភាពនេះទេ។ កន្លងមកមានការសិក្សាជាច្រើនបានពិនិត្យ និងធ្វើការទិតៀនពីបញ្ហាមូលដ្ឋាននានានៃការចូលរួមរបស់ក្រុមហ៊ុនចិនក្នុងវិស័យធនធានធម្មជាតិនៅកម្ពុជា។

*វិធីសាស្ត្រ និងព្រំដែននៃករណីសិក្សាលើវិស័យកាត់ដេរនៅកម្ពុជា*

អង្កេតមួយបានរៀបចំឡើង ដើម្បីស្វែងយល់ពីផលប៉ះពាល់ជាក់លាក់នានានៃវិនិយោគចិនក្នុងវិស័យកាត់ដេរ ជាពិសេសក្នុង ៣ចំណុចដូចបានលើកឡើងខាងលើ។ អង្កេតបានធ្វើឡើងនៅរាជធានីភ្នំពេញ លើកម្មករកាត់ដេរ ៣០០នាក់ ក្នុងនេះ ១៥០នាក់ធ្វើការក្នុងរោងចក្ររបស់ចិន និង ១៥០នាក់ទៀត ក្នុងរោងចក្រមិនមែនជារបស់ចិន។ ការជ្រើសយកគំរូតាងពីក្រុមហ៊ុនជារបស់ចិន និងមិនមែនជារបស់ចិនបែបនេះ គឺដើម្បីស្វែងយល់ថា តើវិនិយោគចិនជះឥទ្ធិពលទៅលើភាពក្រីក្រខុសប្លែកពីវិនិយោគរបស់ប្រទេសផ្សេងទៀតឬយ៉ាងណា និងខុសប្លែកយ៉ាងដូចម្ដេច។ គំរូតាងត្រូវបានជ្រើសរើសដោយមានគោលដៅ និងដោយមិនគិតពីទំហំរោងចក្រ (ចំនួនកម្មករសរុប) ទេ។

ដោយសារគំរូតាងមានចំនួនតិច ដូច្នេះលទ្ធផលនៃអង្កេតនេះមិនអាចប្រើប្រាស់ដើម្បីធ្វើការសន្និដ្ឋានជាទូទៅទេ។ ម្យ៉ាងទៀត លទ្ធផលអង្កេតនេះ ផ្ដោតជាចំបងលើការយល់ឃើញរបស់កម្មករដោយមិនមានការប្រៀបធៀបថ្លឹងថ្លែងជាមួយនឹងទស្សនៈរបស់អ្នកពាក់ព័ន្ធដទៃទៀតទេ ដោយសារភាពពិបាកក្នុងការស្វែងរកព័ត៌មានពីវិនិយោគិនចិន និងទីភ្នាក់ងារពាក់ព័ន្ធផ្សេងៗ។ ជាពិសេស ការស្រាវជ្រាវនេះមិនមានបំណងធ្វើវិភាគស៊ីជម្រៅពីទំហំអត្ថប្រយោជន៍សុទ្ធនៃវិនិយោគចិនក្នុងវិស័យកាត់ដេរ ចំពោះការកាត់បន្ថយភាពក្រីក្រទេ។

## ៤.៣ ករណីសិក្សា

### *៤.៣.១ ការពិនិត្យជាទូទៅលើវិស័យកាត់ដេរ*

វិស័យកាត់ដេរមានចំណែកប្រមាណ ១០,៥% នៃ ផសស ហើយបានចូលរួមយ៉ាងធំធេងក្នុងកំណើនសេដ្ឋកិច្ច ក្នុងទសវត្សរ៍កន្លងទៅ។ ទិន្នន័យកត់ត្រាដោយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា បង្ហាញថា វិស័យកាត់ដេរបានបង្កើនចំណែក ២% ជារៀងរាល់ឆ្នាំ ទៅក្នុង ផសស ចាប់តាំងពីឆ្នាំ១៩៩៥ ប៉ុន្តែនិន្នាការនេះហាក់ធ្លាក់ចុះវិញក្នុងប៉ុន្មានឆ្នាំថ្មីៗ។ វិស័យកាត់ដេរបានផុសឡើងឆ្លងតាមការទទួលបានលក្ខខណ្ឌអនុគ្រោះពាណិជ្ជកម្មពីសហរដ្ឋអាមេរិក។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសហរដ្ឋអាមេរិក-កម្ពុជាលើផលិតផលវាយនភ័ណ្ឌ និងសម្លៀកបំពាក់ (១៩៩៩-២០០៤) ដែលចងភ្ជាប់លទ្ធភាពចូលទីផ្សារ (កំណើនកូតា) ទៅនឹងស្តង់ដារពលកម្ម ត្រូវបានចុះហត្ថលេខាក្នុងឆ្នាំ១៩៩៨-១៩៩៩។ កិច្ចព្រមព្រៀងផលិតផលវាយនភ័ណ្ឌរយៈពេលបីឆ្នាំកន្លះរវាងសហភាពអឺរ៉ុប-កម្ពុជា បានបង្កើតឡើងនៅឆ្នាំ១៩៩៩ ដោយបានលើកលែងពន្ធ និងកូតា ចំពោះផលិតផលសម្លៀកបំពាក់កម្ពុជាដោយគោរពតាមវិធានប្រភពដើមទំនិញ។ ម្យ៉ាងវិញទៀត នៅឆ្នាំ២០០១ សហភាពអឺរ៉ុបបានចាប់អនុវត្តគំនិតផ្តួចផ្តើមលើ "ការនាំចូលទំនិញគ្រប់ប្រភេទក្រៅពីអាវុធ" (EBA) ដែលអនុញ្ញាតការលើកលែងពន្ធ និងកូតាលើរាល់ការនាំចេញរបស់កម្ពុជាទៅទីផ្សារសហភាពអឺរ៉ុប។

មកទល់បច្ចុប្បន្ន ចំណែកនៃខ្សែចង្វាក់កំណត់តម្លៃ និងតម្លៃបន្ថែមនៃវិស័យកាត់ដេររបស់កម្ពុជា នៅមានកម្រិតតូចនៅឡើយ។ កម្ពុជាគ្រាន់តែចូលរួមក្នុងដំណាក់កាល "កាត់ និងតម្រឹម" ប៉ុណ្ណោះ នៅក្នុងខ្សែចង្វាក់កំណត់តម្លៃ (World Bank 2009)។ កម្ពុជាមិនមានឧស្សាហកម្មវាយនភ័ណ្ឌពេញលេញទេ ហើយធាតុចូលភាគច្រើនសម្រាប់វិស័យនេះ បានមកពីការនាំចូល ឬក៏សហគ្រាសផលិតទទួលបានការផ្គត់ផ្គង់វត្ថុធាតុដើមពីអតិថិជនរបស់ខ្លួន ហើយទទួលបានប្រាក់កម្រៃក្នុងលក្ខណៈជាប្រាក់ឈ្នួលសម្រាប់ដំណើរការកែច្នៃប៉ុណ្ណោះ។ រោងចក្រកាត់ដេរជាង ៩០% ជាកម្មសិទ្ធិរបស់បរទេស ដូច្នេះប្រាក់ចំណេញយ៉ាងច្រើនម្ចាស់រោងចក្របានបញ្ជូនត្រឡប់ទៅប្រទេសដើមខ្លួនវិញ។ ការរួមចំណែកដោយផ្ទាល់ទៅក្នុងថវិការដ្ឋាភិបាលក៏មានកម្រិតដែរ ដោយសារវិស័យនេះទទួលបានការលើកលែងពន្ធនាំចូល និងការកាត់បន្ថយ ឬការលើកលែងពន្ធលើប្រាក់ចំណេញ។

ទោះយ៉ាងនេះក្តី វិស័យកាត់ដេរផ្តល់ផលចំណេញយ៉ាងច្រើនដល់ប្រទេសកម្ពុជា តាមការជំរុញកំណើន ផសស ជារួម ការបង្កើតប្រាក់ចំណូល និងការកាត់បន្ថយភាពក្រីក្រ។ សម្លៀកបំពាក់រួមចំណែកដល់ទៅ ៨០% នៃផលិតផលនាំចេញសរុប។ ឧស្សាហកម្មកាត់ដេរមិនត្រឹមតែរួមចំណែកក្នុងការបង្កើតការងារទេ ប៉ុន្តែថែមទាំងជួយបង្កើនការផ្ញើប្រាក់ទៅក្រុមគ្រួសារកម្មករនៅតំបន់ជនបទទៀតផង។ កម្មករជាច្រើនជានារីវ័យក្មេងធ្វើចំណាកស្រុកពីតំបន់ជនបទក្រីក្រ ទៅរាជធានីភ្នំពេញដែលជាទីតាំងនៃឧស្សាហកម្មកាត់ដេរ។ ដូច្នេះ ប្រជាជនភាគច្រើនដែលទទួលផលប្រយោជន៍ពីឧស្សាហកម្មនេះ ជានារីវ័យក្មេងគ្មានជំនាញ និងមានការអប់រំទាប មកពីតំបន់ជនបទ ដែលស្ថិតក្នុងចំណោមជនងាយរងគ្រោះបំផុតក្នុងទីផ្សារការងារ។ បញ្ហាប្រឈមគឺ តើមានប្រជាជនកម្ពុជាប៉ុន្មាននាក់ បម្រើការងារជាបុគ្គលិកផ្នែកបច្ចេកទេស និង/ឬ ជាអ្នកគ្រប់គ្រងរោងចក្រ? តាមការប៉ាន់ស្មាន ទីភ្នាក់ងារជ្រើសរើសការងារចិន បានបញ្ជូនអ្នកត្រួតការ និងអ្នកបច្ចេកទេសផ្នែកកាត់ដេរជាជនជាតិចិនប្រហែល ៥០០០នាក់ ឲ្យមកធ្វើការក្នុងរោងចក្រកាត់ដេរនៅកម្ពុជា។ ការកសាងសមត្ថភាពធនធានមនុស្សក្នុងស្រុកសំខាន់ខ្លាំងណាស់ ដូច្នេះ គួរបង្កើតឲ្យមានបរិយាកាសមួយដែលជួយឲ្យសហគ្រិនក្នុងស្រុកទទួលបានបទពិសោធន៍ពីសហគ្រាសបរទេស។ ក្នុងពេលជាមួយគ្នា ការបង្កើតការងារដោយប្រយោល ដូចជា ក្នុងផ្នែកដឹកជញ្ជូន ពាណិជ្ជកម្ម ភោជនីយដ្ឋាន សេវាកម្ម និងអាជីវកម្មខ្នាតតូចផ្សេងៗ ក៏ឃើញមានជាក់ស្តែងដែរ។

### ៤.៣.២ លទ្ធផល

ករណីសិក្សានេះ បានផ្តល់ព័ត៌មានជាមូលដ្ឋានពីចំណាប់អារម្មណ៍របស់កម្មករកាត់ដេរ លើការរួមចំណែកនៃឧស្សាហកម្មកាត់ដេរដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារនិងប្រាក់ចំណូល ប្រាក់ផ្ញើទៅផ្ទះ និងឱកាសកសាងសមត្ថភាព និងជំនាញ។

*រោងចក្រជ្រើសរើសសម្រាប់ការសិក្សា*

តារាង ៤.៣ បង្ហាញពីចំនួនរោងចក្រកាត់ដេរជាសមាជិកនៃ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងការបែងចែកតាមសញ្ជាតិរបស់ម្ចាស់រោងចក្រ ព្រមទាំងចំនួនកម្មករសរុបធ្វើការក្នុងរោងចក្រនៅខែមករា ២០១០។

សហគ្រាសគំរូតាង និង ចំនួនកម្មករកាត់ដេរបានសម្ភាស មានរាយលម្អិតក្នុង តារាង ៤.៤ ក្នុងនោះមាន សហគ្រាសរបស់ចិនដីគោក (ចំនួន១០) ហុងកុង (២) កូរ៉េ (២) ម៉ាឡេស៊ី (២) សិង្ហបុរី (១) តៃវ៉ាន់ (៣) និង សហរដ្ឋអាមេរិក (១)។

តារាង ៤.៣៖ រោងចក្រកាត់ដេរចុះបញ្ជីជាសមាជិក GMAC (ខែមករា ២០១០)

| *ប្រទេស* | *ចំនួនរោងចក្រ* | *ចំនួនកម្មករសរុប* | *ប្រទេស* | *ចំនួនរោងចក្រ* | *ចំនួនកម្មករសរុប* |
|---|---|---|---|---|---|
| តៃវ៉ាន់ | 61 | 77,245 | តៃវ៉ាន់ + សហរដ្ឋអាមេរិក | 3 | 3657 |
| ចិន | 41 | 40,394 | ចិន + ហុងកុង | 4 | 3632 |
| ហុងកុង | 37 | 45,838 | ចិន + តៃវ៉ាន់ | 2 | 2635 |
| កូរ៉េ | 31 | 26,014 | ចិន + កម្ពុជា | 3 | 2529 |
| ម៉ាឡេស៊ី | 13 | 26,733 | កូរ៉េ +កម្ពុជា | 1 | 1213 |
| កម្ពុជា | 12 | 6701 | ម៉ាឡេស៊ី + តៃវ៉ាន់ | 1 | 1093 |
| សិង្ហបុរី | 10 | 20,575 | ហុងកុង + កាណាដា | 1 | 546 |
| សហរដ្ឋអាមេរិក | 8 | 4916 | ហុងកុង + ម៉ាកាវ | 1 | 478 |
| ម៉ាកាវ | 3 | 7747 | ចិន + អង់គ្លេស | 1 | 399 |
| ប៉ង់ក្លាដេស | 1 | 2126 | តៃវ៉ាន់ + កម្ពុជា | 1 | 356 |
| អង់គ្លេស | 1 | 1400 | | | |
| កាណាដា | 1 | 1113 | | | |
| អូស្ត្រាលី | 1 | 713 | | | |
| ឥណ្ឌូនេស៊ី | 1 | 546 | | | |
| ហ្វីលីពីន | 1 | 425 | | | |
| អេស្ប៉ាញ | 1 | 350 | | | |
| ថៃ | 1 | 306 | | | |
| *សរុប* | *224* | *263,142* | | *18* | *16,557* |

ប្រភព៖ GMAC ឆ្នាំ២០១០

តារាង ៤.៤៖ រោងចក្រជ្រើសរើសសម្រាប់ការសិក្សា និង ចំនួនកម្មករបានសម្ភាស

| *លេខ* | *ឈ្មោះរោងចក្រ* | *សញ្ជាតិម្ចាស់រោងចក្រ* | *ចំនួនកម្មករកាត់ដេរបានសម្ភាស* |
|---|---|---|---|
| 1 | (Cambodia) Hongmei Imp & Exp Co., Ltd | ចិន (ចិនដីគោក) | 15 |
| 2 | GDM Enterprise Co., Ltd | ចិន (ចិនដីគោក) | 15 |
| 3 | GHG (Cambodia) Ltd | ចិន (ចិនដីគោក) | 15 |
| 4 | Kimsheng Garment Co., Ltd | ចិន (ចិនដីគោក) | 15 |
| 5 | Legend Garment (Cambodia) Co., Ltd | ចិន (ចិនដីគោក) | 15 |
| 6 | New Orient (Cambodia) Garment Co., Ltd | ចិន (ចិនដីគោក) | 15 |
| 7 | Pine Great (Cambodia) Garment Co., Ltd | ចិន (ចិនដីគោក) | 15 |
| 8 | Shen Zhou (Cambodia) Co., Ltd | ចិន (ចិនដីគោក) | 15 |
| 9 | Star Knitting & Garment Factory Ltd | ចិន (ចិនដីគោក) | 15 |
| 10 | Su Tong Gang Group Ying kan (Cam) Garment | ចិន (ចិនដីគោក) | 15 |
| 11 | Gennon (Cambodia) Garment Manufacturing Ltd | ហុងកុង | 15 |
| 12 | Supertex., Ltd | ហុងកុង | 15 |
| 13 | Evergreen Garment Co., Ltd | កូរ៉េ | 15 |
| 14 | Gawon Apparel Co., Ltd | កូរ៉េ | 15 |
| 15 | June Textile Co., Ltd | ម៉ាឡេស៊ី | 15 |
| 16 | PCCS Garment Limited | ម៉ាឡេស៊ី | 15 |
| 17 | 8 Star Sportswear Ltd | សិង្ហបុរី | 15 |
| 18 | Chean Ping Garment Co., Ltd | តៃវ៉ាន់ | 15 |
| 19 | Phong Wan Enterprise Co., Ltd | តៃវ៉ាន់ | 10 |
| 20 | Kin Tai Garment Co., Ltd | តៃវ៉ាន់ | 5 |
| 21 | Sky High (Cambodia) Co., Ltd | សហរដ្ឋអាមេរិក | 15 |
| *សរុប* | | | *300* |

ប្រភព៖ អង្កេតរបស់ CDRI ក្នុងខែមេសា ២០១០

*ការបង្កើតការងារ*

តារាង ៤.៥ បង្ហាញលម្អិតពីចំនួនកម្មករជ្រើសរើសសម្រាប់ការសិក្សា ដោយបែងចែកតាមភេទ ប្រភេទការងារ និងបទពិសោធន៍ការងារ។ កម្មករកាត់ដេរបានសម្ភាស ៨៨% ជានារី ហើយ ៨២% បានចូលធ្វើការក្នុងរោងចក្របច្ចុប្បន្នចំនួន ៣ឆ្នាំ ឬតិចជាងនេះ។ ឧស្សាហកម្មកាត់ដេរ មានលក្ខណៈពឹងផ្អែកខ្លាំងលើពលកម្មនារី ដូច្នេះ ការអភិវឌ្ឍឧស្សាហកម្មនេះផ្តល់អំណាចខាងសេដ្ឋកិច្ចដល់នារី តាមរយៈការបង្កើតឱកាសការងារទ្រង់ទ្រាយធំសម្រាប់ពួកគេ។ ក្នុងចំណោមគំរូតាង មាន ៥៨% ជាយន្តការីផ្នែកដេរ និងមានតែ ១,៦% ប៉ុណ្ណោះ ជាបុគ្គលិកការិយាល័យ។

តារាង ៤.៥៖ ចំនួនសរុបនៃកម្មករគំរូតាង និងការបែងចែកតាមភេទ ប្រភេទការងារ និង បទពិសោធន៍ការងារ

| *ប្រភេទការងារ* \ *បទពិសោធន៍* | *< 1ឆ្នាំ* | | *1-3 ឆ្នាំ* | | *> 3-5 ឆ្នាំ* | | *> 5-15 ឆ្នាំ* | | *សរុប* |
|---|---|---|---|---|---|---|---|---|---|
| | *បុរស* | *នារី* | *បុរស* | *នារី* | *បុរស* | *នារី* | *បុរស* | *នារី* | |
| កម្មករទូទៅ | 0 | 2 | | | | | | 1 | 3 |
| កម្មករផ្នែកកាត់ | 1 | 5 | 2 | 3 | 0 | 2 | | 2 | 15 |
| កម្មករផ្នែកដេរ | 9 | 42 | 4 | 68 | 0 | 27 | | 25 | 175 |
| កម្មករត្រួតពិនិត្យគុណភាព | 0 | 13 | 0 | 13 | | | | 1 | 27 |
| កម្មករ (បោក អ៊ុត ខ្ចប់....) | 11 | 8 | 2 | 19 | 0 | 4 | | 3 | 47 |
| កម្មករមើលឃ្លាំង | 0 | 3 | 0 | 5 | 0 | 2 | | | 10 |
| អ្នកសំអាត/សន្តិសុខ/ចុងភៅ/អ្នកបើកបរ | 0 | 1 | 2 | 5 | 1 | 0 | | 1 | 10 |
| អ្នកត្រួតពិនិត្យគុណភាព | 0 | 1 | | | 0 | 2 | | | 3 |
| អ្នកត្រួតពិនិត្យចុងក្រោយ | | | | | | | | 2 | 2 |
| យន្តការី | 1 | 0 | 1 | 0 | | | | | 2 |
| ជំនួយការធានាគុណភាព | 0 | 1 | | | | | | | 1 |
| បុគ្គលិកការិយាល័យ | | | 0 | 2 | 1 | 1 | | 1 | 5 |
| *សរុប* | *22* | *76* | *11* | *115* | *2* | *38* | | *36* | *300* |

ប្រភព៖ អង្កេតរបស់ CDRI ក្នុងខែមេសា ២០១០

តាមការស្នើឲ្យកម្មករកាត់ដេរដែលជាគំរូតាង បានរំលឹកពីការងារចុងក្រោយបង្អស់ដែលខ្លួនបានបម្រើការអស់រយៈពេលយ៉ាងតិចបីខែ អង្កេតបានរកឃើញថា ៦៣% នៃកម្មករមកពីរោងចក្រចិន និង ៧៧% មកពីរោងចក្រមិនមែនរបស់ចិន ធ្លាប់ជាអ្នកប្រកបមុខរបរខ្លួនឯងពីមុនមក ដូចជា៖ (១) កសិករនៅកសិដ្ឋានផ្ទាល់ខ្លួន (២) សិស្ស (៣) មេផ្ទះ ឬជួយធ្វើការងារផ្ទះ (៤) គ្មានការងារធ្វើ (៥) ប្រកបមុខរបរខ្លួនឯងផ្សេងៗនៅផ្ទះ (រូបភាព ៤.៥)។

រូបភាព ៤.៥៖ មុខរបរពីមុនរបស់កម្មករកាត់ដេរក្នុងគំរូតាង




ប្រភព៖ អង្កេតរបស់ CDRI ក្នុងខែមេសា ២០១០

ក្នុងអំឡុងឆ្នាំ១៩៩៨ ដល់ ២០០៨ វិនិយោគចិនក្នុងវិស័យកាត់ដេររួមចំណែក ៤០% នៃទឹកប្រាក់វិនិយោគសរុបក្នុងឧស្សាហកម្មនេះ និង ៣៤% នៃ FDI សរុបក្នុងឧស្សាហកម្មនេះ។ គំរូតាងត្រូវបានជ្រើសយកដោយមិនគិតពីទំហំរោងចក្រ (ចំនួនកម្មករបម្រើការក្នុងរោងចក្រ) ទេហើយការសិក្សាបានបញ្ជាក់ថាវិនិយោគចិនក្នុងវិស័យកាត់ដេរនៅកម្ពុជាបានរួមចំណែក

ក្នុងការបង្កើតការងារសម្រាប់ប្រជាជនជនបទ។ គួរកត់សម្គាល់ថា ការសិក្សានេះមិនបានធ្វើការប្រៀបធៀបអត្ថប្រយោជន៍រវាងការងារមុន និងការងារបច្ចុប្បន្ន នោះទេ។

ក្នុងអំឡុងពេលធ្វើអង្កេតនៅខែមេសា ២០១០ ប្រាក់ឈ្នួលទាបបំផុតតាមច្បាប់សម្រាប់កម្មករកាត់ដេរគឺ ៥០ដុល្លារ/ខែ (ចាប់ពីឆ្នាំ២០០៦ មក)។ តារាង ៤.៦ បង្ហាញពីទិន្នន័យប្រាក់ឈ្នួលប្រចាំខែបានពីការសម្ភាស។ កម្មករក្នុងគំរូតាងភាគច្រើនរកចំណូលបានប្រមាណ ៨០ដុល្លារ/ខែ ឬប្រហែល ២,៦៧ដុល្លារ/ថ្ងៃ។ ពួកគេធ្វើការពី ៨-១០ម៉ោង/ថ្ងៃ និង ៦ថ្ងៃ/សប្តាហ៍។ ប៉ុន្តែ ប្រហែល ៧៦% នៃកម្មករកាត់ដេរមកពីរោងចក្រមិនមែនរបស់ចិន ធ្វើការ ១០ម៉ោង/ថ្ងៃ ធៀបនឹងកម្មករក្នុងរោងចក្ររបស់ចិន ត្រឹមតែ ៣៦,៧% ប៉ុណ្ណោះ។

តារាង ៤.៦៖ ប្រាក់ចំណូលរបស់កម្មករក្នុងគំរូតាង

| | *គំរូតាងទាំងអស់* | *រោងចក្រចិន (1)* | *រោងចក្រមិនមែនចិន (2)* | *ភាពខុសគ្នារវាង (1) & (2)* |
|---|---|---|---|---|
| មធ្យម | 81.9 | 83.8 | 80.1 | 3.7 |
| មេដ្យាន | 80.0 | 82.0 | 77.5 | 4.5 |
| ម៉ូត | 80.0 | 80.0 | 80.0 | 0.0 |
| គម្លាតស្តង់ដារ | 21.5 | 21.0 | 22.0 | -1.0 |
| អប្បបរមា | 14.0 | 14.0* | 40.0 | -26.0 |
| អតិបរមា | 200.0 | 150.0 | 200.0 | -50.0 |

កំណត់សម្គាល់៖ ប្រាក់ចំណូល (ក្នុងខែមករា ២០១០) រួមមាន ចំណូលពីការងារថែមម៉ោង និងប្រាក់ឧបត្ថម្ភផ្សេងទៀត។

*កម្មករកាត់ដេរម្នាក់ធ្វើការត្រឹមតែពីរបីថ្ងៃប៉ុណ្ណោះក្នុងខែមករា ២០១០ ដោយសារមានជំងឺ។ ប្រភព៖ អង្កេតរបស់ CDRI ក្នុងខែមេសា ២០១០

សរុបមក បន្ទាត់ភាពក្រីក្រសរុបនៅរាជធានីភ្នំពេញក្នុងឆ្នាំ២០០៧ ប៉ាន់ស្មានដោយធនាគារពិភពលោកគឺ ០,៧៦ដុល្លារ/ថ្ងៃ។ កម្មករកាត់ដេររកចំណូលបានជាមធ្យម ២,០៣ដុល្លារ/ថ្ងៃ (ថ្លៃថេរឆ្នាំ២០០៦) ដែលខ្ពស់ជាងបន្ទាត់ភាពក្រីក្រសរុបក្នុងរាជធានីភ្នំពេញ (០,៧១ដុល្លារ) ហើយចំណុចនេះបង្ហាញថា ការងារក្នុងឧស្សាហកម្មកាត់ដេរជួយកាត់បន្ថយភាពក្រីក្រ។

*បរិយាកាសការងារ*

កម្មករនៅរោងចក្រមិនមែនរបស់ចិន មានច្រើននាក់ជាងកម្មករក្នុងរោងចក្រចិន ដែលបានប្រាប់ថា ខ្លួនមានបរិយាកាសការងារល្អ។

តារាង ៤.៧៖ ការវាយតម្លៃបរិយាកាសការងារតាមចម្លើយរបស់កម្មករគំរូតាង

| | | *ការថែទាំសុខភាព* | *កន្លែងធ្វើការ* | *អនាម័យ* | *ការសុំឈប់សម្រាកប្រចាំឆ្នាំ* | *ការសុំឈប់សម្រាកដោយសារជំងឺ* |
|---|---|---|---|---|---|---|
| *រោងចក្រមិនមែនរបស់ចិន* | ល្អ | 31% | 31% | 35% | 29% | 34% |
| | មធ្យម | 53% | 64% | 31% | 42% | 38% |
| | មិនល្អ | 14% | 4% | 28% | 21% | 17% |
| *រោងចក្រចិន* | ល្អ | 45% | 45% | 36% | 63% | 66% |
| | មធ្យម | 51% | 51% | 49% | 23% | 21% |
| | មិនល្អ | 4% | 4% | 13% | 13% | 13% |

ប្រភព៖ អង្កេតរបស់ CDRI ក្នុងខែមេសា ២០១០

*ប្រាក់ផ្ញើទៅផ្ទះ*

តបនឹងសំណួរថា តើអ្នកធ្លាប់ផ្ញើប្រាក់ទៅផ្ទះឬទេ កម្មករមកពីរោងចក្រមិនមែនរបស់ចិន ៤៧% និងកម្មករមកពីរោងចក្ររបស់ចិន ៥៣% និយាយថា ខ្លួនធ្លាប់ផ្ញើ។ គ្រួសាររបស់កម្មករប្រើប្រាស់ប្រាក់ផ្ញើនោះជាចំបងសម្រាប់៖ (១) ចំណាយលើអាហារប្រចាំថ្ងៃ (២) វិនិយោគក្នុងការងារកសិកម្ម (៣) ផ្គត់ផ្គង់ការសិក្សារបស់សមាជិកគ្រួសារ (៤) សងបំណុល (៥) សន្សំសម្រាប់កូនៗ និង (៦) ទិញដីកសិកម្ម (រូបភាព ៤.៧)។

រូបភាព ៤.៦៖ ភាគរយកម្មករគំរូតាងបានផ្ញើប្រាក់ទៅផ្ទះ




ប្រភព៖ អង្កេតរបស់ CDRI ក្នុងខែមេសា ២០១០

រូបភាព ៤.៧៖ ការប្រើប្រាស់ដោយក្រុមគ្រួសារនូវប្រាក់ផ្ញើទៅផ្ទះរបស់កម្មករ (មុខចំណាយសំខាន់ៗ)




ប្រភព៖ អង្កេតរបស់ CDRI ក្នុងខែមេសា ២០១០

*ការអភិវឌ្ឍជំនាញ*

ដូចមានបង្ហាញក្នុងរូបភាព ៤.៨ ទាំងរោងចក្ររបស់ចិន និងរោងចក្រមិនមែនរបស់ចិន មិនមានផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេស ឬជំនាញជាលក្ខណៈប្រព័ន្ធអ្វីឡើយ។ ក្នុងចំណោមគំរូតាងទាំង ៣០០នាក់ មានតែអ្នកឆ្លើយសម្ភាសន៍ ៤នាក់ប៉ុណ្ណោះ (២នាក់មកពីរោងចក្រចិន) ដែលបានទទួលការបណ្តុះបណ្តាលអំពី ការថែ្មម៉ូដ និងច្បាប់ស្តីពីការងារ។

ស្រដៀងគ្នាដែរ ចំពោះសំណួរថា តើរោងចក្រដែលពួកគេធ្វើការ មានផ្តល់ឱកាសឲ្យចូលរួមវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្រៅរោងចក្រដែរឬទេ កម្មករភាគច្រើនឆ្លើយថា "មិនដឹង ឬ មិនមានទេ" (រូបភាព ៤.៩)។

រូបភាព ៤.៨៖ កម្មវិធីបណ្តុះបណ្តាលរបស់រោងចក្រកាត់ដេរ




ប្រភព៖ អង្កេតរបស់ CDRI ក្នុងខែមេសា ២០១០

រូបភាព ៤.៩៖ ការគាំទ្ររបស់រោងចក្រកាត់ដេរ ចំពោះការចូលរួមវគ្គបណ្តុះបណ្តាលនៅខាងក្រៅរោងចក្រ







ប្រភព៖ អង្កេតរបស់ CDRI ក្នុងខែមេសា ២០១០

រូបភាព ៤.១០ បង្ហាញថា កម្មករ ៤១% នៅរោងចក្ររបស់ចិន និង ៦៣% នៅរោងចក្រមិនមែនរបស់ចិន យល់ឃើញថា ពួកគេទទួលបានចំណេះដឹង ឬជំនាញជាក់លាក់ពីការងារបច្ចុប្បន្ន ទោះបីភាគច្រើនទទួលបានត្រឹមតែជំនាញមូលដ្ឋាន តាមរយៈការងារប្រចាំថ្ងៃក្តី។ ពួកគេរំពឹងថា នឹងអាចប្រើប្រាស់ជំនាញ និងចំណេះដឹងទាំងនេះដើម្បី (១) ស្វែងរកការងារនៅរោងចក្រស្រដៀងគ្នាដទៃទៀតក្នុងប្រទេស (២) ស្វែងរកការងារនៅរោងចក្រស្រដៀងគ្នាដទៃទៀតនៅបរទេស (កូរ៉េ ម៉ាឡេស៊ី ថៃ) និង (៣) បើកមុខរបរដោយខ្លួនឯង ដូចជា ហាងកាត់ដេរជាដើម (រូបភាព ៤.១១)។ មានតែ ១០% នៃកម្មករបានសម្ភាសប៉ុណ្ណោះ ដែលបានស្វែងរក និងចំណាយប្រាក់លើការសិក្សាអភិវឌ្ឍជំនាញផ្ទាល់ខ្លួន ដូចជាខាងកាត់ដេរ និងថ្នៃម៉ូត និងថ្នៃសម្លៀកបំពាក់អាពាហ៍ពិពាហ៍ ជាដើម។

រូបភាព ៤.១០៖ ជំនាញ និង ចំណេះដឹងទទួលបានពីការងារបច្ចុប្បន្ន




ប្រភព៖ អង្កេតរបស់ CDRI ក្នុងខែមេសា ២០១០

រូបភាព ៤.១១៖ ការប្រើប្រាស់ជំនាញ និង ចំណេះដឹងទទួលបានពីការងារបច្ចុប្បន្ន




ប្រភព៖ អង្កេតរបស់ CDRI ក្នុងខែមេសា ២០១០

*ការផ្លាស់ប្តូរជីវភាពរស់នៅ*

ប្រហែល ៥០% នៃអ្នកឆ្លើយសម្ភាសន៍ ទាំងមកពីរោងចក្ររបស់ចិន និងមិនមែនរបស់ចិនជឿថា ស្ថានភាពសេដ្ឋកិច្ចគ្រួសាររបស់ខ្លួនមានការរីកចម្រើន ហើយមូលហេតុចំបងៗ រួមមាន៖ (១) វិនិយោគ (ការទិញដី ទូកម៉ាស៊ីន សត្វចិញ្ចឹម) (២) ប្រាក់ចំណូលទៀងទាត់ (ប្រាក់ឈ្នួលពីរោងចក្រ) (៣) ប្រភពប្រាក់ចំណូលគ្រួសារច្រើនជាងមុន (៤) ទិន្នផលស្រូវប្រសើរជាងមុន និង (៥) ជីវភាពរស់នៅប្រសើរជាងមុននៅក្នុងភូមិ។

រូបភាព ៤.១២៖ ចំណាប់អារម្មណ៍របស់កម្មករគំរូតាង អំពីការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ចគ្រួសារ




ប្រភព៖ អង្កេតរបស់ CDRI ក្នុងខែមេសា ២០១០

# ជំពូក ៥

# ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ចិន និង ផលប៉ះពាល់

## ៥.១ ទំហំ និងការប្រែប្រួល

ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ដើរតួយ៉ាងសំខាន់ក្នុងការផ្តល់ហិរញ្ញប្បទានក្នុងទម្រង់ជាធនធានសាធារណៈបន្ថែម សម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា ដោយគាំទ្រដល់ការផ្តល់សេវាសាធារណៈ និងជួយទាក់ទាញវិនិយោគឯកជន តាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវាសេដ្ឋកិច្ច។[១៨]

មូលដ្ឋានទិន្នន័យ ODA របស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CRDB-CDC) ដែលជាស្ថាប័នកណ្តាលថ្នាក់ជាតិសម្រាប់ការសម្របសម្រួលជំនួយ បានកត់ត្រានូវកំណើនចំណាយហិរញ្ញវត្ថុជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០០០ មក។ ពីឆ្នាំ២០០០ ដល់ ២០០៩ មូលនិធិសម្រាប់ចំណាយជាមធ្យមផ្តល់ដោយដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគីជាផ្លូវការ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងទម្រង់ជាជំនួយឥតសំណង និងប្រាក់កម្ចី មានសរុប ៦៦២,៣លានដុល្លារ។ នៅឆ្នាំ២០០០ ODA ក្នុងមនុស្សម្នាក់ មាន ៣៧ដុល្លារ ហើយនៅឆ្នាំ២០០៩ កើនដល់ ៧០,៧ដុល្លារ/នាក់។ វិស័យផ្តោតសំខាន់ រួមមាន សុខាភិបាល អប់រំ កសិកម្ម អភិវឌ្ឍន៍ជនបទ វប្បធម៌និងសិល្បៈ ថាមពលនិងអគ្គិសនី អភិបាលកិច្ច និងរដ្ឋបាល គមនាគមន៍ និងសុខុមាលភាពសង្គមនិងសហគមន៍ ដែលស្របតាមអាទិភាពនៃការអភិវឌ្ឍប្រទេសកម្ពុជា នៅក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP)។ ក្នុងឆ្នាំនីមួយៗចាប់តាំងពីឆ្នាំ២០០០ ដល់២០០៩ ប្រមាណ ៣៥% នៃមូលនិធិចំណាយសរុប ត្រូវបានលៃចែកទៅឲ្យផ្នែកសហប្រតិបត្តិការបច្ចេកទេស ប្រមាណ ៦០% ទៅឲ្យកម្មវិធីនិងគម្រោងវិនិយោគ ហើយមានត្រឹម ២,៥% ដែលផ្តល់ទៅឲ្យផ្នែកជំនួយជាស្បៀងអាហារ និងសង្គ្រោះបន្ទាន់។

ទាក់ទិននឹងចំណាយមូលនិធិ ទំនុកចិត្តគ្នាទៅវិញទៅមក និងគណនេយ្យភាព ត្រូវមានជាចាំបាច់ ដើម្បីកសាងភាពជាដៃគូអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព។ ទស្សនវិស័យនេះ ហាក់ដើរតាមអនុសាសន៍ក្នុងរបាយការណ៍ស្តីពីប្រសិទ្ធភាពជំនួយ ក្នុងឆ្នាំ២០០៦ និង ២០០៧ ដែលសង្កត់ធ្ងន់ថា កំណើនទំនុកចិត្ត និងការយោគយល់គ្នាទៅវិញទៅមក រវាងកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ជាកត្តាដ៏ចាំបាច់ដើម្បីធានាឲ្យការអភិវឌ្ឍកាន់តែមានប្រសិទ្ធភាពឡើង។[១៩]

តាមសាវតារ កម្ពុជាទទួលបានជំនួយសម្រាប់ការអភិវឌ្ឍប្រទេសពីដៃគូអភិវឌ្ឍន៍ផ្សេងៗជាច្រើន ក្នុងនោះ ចិនកំពុងលេចឡើងជាអ្នកផ្តល់ជំនួយដ៏សំខាន់មួយ។ ចាប់តាំងពីទសវត្សរ៍១៩៩០ នៅពេលកម្ពុជាអាចធានាបាននូវសន្តិសុខ និងស្ថិរភាពនយោបាយនោះ ប្រទេសទាំងពីរបានរក្សានូវការទាក់ទង និងការផ្លាស់ប្តូរទស្សនកិច្ចជាញឹកញាប់ ជាបន្ថែមលើទំនាក់ទំនងការទូតដ៏រឹងមាំដែលបង្កើតឡើងបានចំនួន៥០ឆ្នាំមកហើយ។ រដ្ឋាភិបាលប្រទេសទាំងពីរ បានជ្រើសរើសយកឆ្នាំ២០០៨ ជាឆ្នាំអបអរសាទរមិត្តភាពចិន-កម្ពុជា ដើម្បីពង្រឹងមិត្តភាពរវាងប្រទេសទាំងពីរ និងបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី។

ចិនជាប្រភពជំនួយបរទេសដ៏សំខាន់មួយដល់កម្ពុជា។ ពីឆ្នាំ២០០០ ដល់ ២០០៩ ODA របស់ចិន ដល់កម្ពុជា មានសរុប ៤៦៥លានដុល្លារ ស្មើនឹង ៧% នៃជំនួយសរុបពីដៃគូអភិវឌ្ឍន៍ទាំងអស់របស់កម្ពុជា។ ការផ្តល់ហិរញ្ញប្បទានរបស់ចិន បន្តកើនឡើងជារៀងរាល់ឆ្នាំ ដូចអាចឃើញច្បាស់តាមកំណើនពីត្រឹម ២,៦លានដុល្លារក្នុងឆ្នាំ២០០០ ដល់ ៣២,៥លានដុល្លារ ក្នុងឆ្នាំ២០០៤ និង ១១៤,៧លានដុល្លារក្នុងឆ្នាំ២០០៩ (តារាង ៥.១)។ នៅឆ្នាំ២០០៩ ចិនបានបង្កើន ២០% បន្ថែមលើ

---

១៨ របាយការណ៍ស្តីពីប្រសិទ្ធភាពជំនួយនៅកម្ពុជាឆ្នាំ២០០៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ទំព័រ ១ និង ៣។

១៩ ibid

ហិរញ្ញប្បទានសរុបដែលខ្លួនផ្ដល់ឲ្យកម្ពុជាក្នុងឆ្នាំ២០០៨ តាមនេះប្រទេសចិនឈរនៅលំដាប់ទីពីរ បន្ទាប់ពីប្រទេសជប៉ុន ក្នុងចំណោមប្រទេសដែលផ្ដល់ហិរញ្ញប្បទានច្រើនៗបំផុតមកកម្ពុជា ដោយបានរួមចំណែក ១១,៦% នៃហិរញ្ញប្បទានសរុបដែលកម្ពុជាទទួលបាន។

តារាង ៥.១៖ ការបើកផ្ដល់ជំនួយរបស់ចិនពីឆ្នាំ២០០០-២០០៩ (លានដុល្លារ)

| | *ទម្រង់* | *2000* | *2001* | *2002* | *2003* | *2004* | *2005* | *2006* | *2007* | *2008* | *2009 est.* |
|---|---|---|---|---|---|---|---|---|---|---|---|
| ការបើកផ្ដល់ប្រាក់សរុបដោយដៃគូអភិវឌ្ឍន៍ទាំងអស់ | ជំនួយឥតសំណង | - | 347 | 347.7 | 373.4 | 367.2 | 438.8 | 458.6 | 567.3 | 681.7 | 699.1 |
| | កម្ចី | - | 124.9 | 183.2 | 166.1 | 188.2 | 171.2 | 136.1 | 223.1 | 273.9 | 290.3 |
| | សរុប | 466.8 | 471.9 | 530.9 | 539.5 | 555.4 | 610 | 594.7 | 790.4 | 955.6 | 989.4 |
| ចិន | ជំនួយឥតសំណង | - | - | - | - | - | 13.1 | 6.7 | 0.4 | 0.2 | 3 |
| | កម្ចី | - | - | - | - | - | 33.5 | 46.5 | 92 | 95.2 | 111.7 |
| | សរុប | 2.6 | 16.3 | 5.7 | 5.6 | 32.5 | 46.6 | 53.2 | 92.4 | 95.4 | 114.7 |
| ជាភាគរយនៃការបើកផ្ដល់សរុប | | | | | | | | | | | |
| ចិន | ជំនួយឥតសំណង | - | - | - | - | - | 3 | 1.5 | 0.1 | 0 | 0.4 |
| | កម្ចី | - | - | - | - | - | 19.6 | 34.2 | 41.2 | 34.8 | 38.5 |
| | សរុប | 0.6 | 3.5 | 1.1 | 1 | 5.8 | 7.6 | 9 | 11.7 | 10 | 11.6 |

ប្រភព៖ របាយការណ៍ស្ដីពីប្រសិទ្ធភាពជំនួយនៅកម្ពុជា ឆ្នាំ២០០៧ ២០០៨ ២០០៩

ការបើកផ្ដល់ពីចិន ជាជំនួយទ្វេភាគី ៣ប្រភេទ គឺជំនួយឥតសំណង កម្ចីឥតការប្រាក់ និង កម្ចីសម្បទាន។ ជំនួយឥតសំណង និងកម្ចីឥតការប្រាក់ ភាគច្រើនផ្ដល់តាមរយៈគម្រោងផ្សេងៗ ជាពិសេស គម្រោងផ្ដោតលើសុខុមាលភាពសង្គម ជំនួយជាសម្ភារៈនិងបច្ចេកទេស និងការបណ្ដុះបណ្ដាលផ្ទាល់ខ្លួន ស្របតាមសំណើរបស់ប្រទេសទទួលជំនួយ។ កម្ចីសម្បទានឃើញមានជាចំបងក្នុងគម្រោងដើម្បីប្រាក់ចំណេញ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ តាមរយៈកិច្ចសន្យាផ្គត់ផ្គង់សម្ភារៈ បច្ចេកវិទ្យា និងសេវាកម្ម ពីក្រុមហ៊ុនរដ្ឋរបស់ចិន (Martyn 2008)។

ទាក់ទិននឹងការចំណាយតាមវិស័យ ពីឆ្នាំ២០០៥-២០០៩ ប្រាក់ដែលចិនផ្ដល់ឲ្យ ត្រូវបានបែងចែកជាចំបងទៅវិស័យដឹកជញ្ជូនដែលមាននិន្នាការកើនឡើងជារៀងរាល់ឆ្នាំ តាំងពីឆ្នាំ២០០៦ ដល់ ២០០៩ (តារាង៥.២)។ ធៀបនឹងដៃគូអភិវឌ្ឍន៍សំខាន់ៗផ្សេងទៀត ចិនជាអ្នករួមចំណែកធំបំផុតក្នុងវិស័យនេះនៅអំឡុងឆ្នាំ២០០៧-២០០៩ បន្ទាប់មកទៀត មានជប៉ុន និងកូរ៉េខាងត្បូង (រូបភាព ៥.១)។

តារាង ៥.២៖ ការបើកផ្ដល់ជំនួយរបស់ចិនតាមវិស័យឆ្នាំ២០០៥-២០០៩ (លានដុល្លារ)

| *វិស័យ* | *2005* | *2006* | *2007* | *2008* | *2009* | *សរុប* |
|---|---|---|---|---|---|---|
| សុខាភិបាល | | 0.13 | | | | 0.13 |
| អប់រំ | | 0.38 | | | 0.08 | 0.46 |
| កសិកម្ម | 1.71 | 0.07 | | | | 1.78 |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | 0.05 | | | | | 0.05 |
| ព័ត៌មាន និងទំនាក់ទំនង | | | 8.85 | | | 8.85 |
| ប្រៃសណីយ៍ និង ទូរគមនាគមន៍ | | 8.46 | | | | 8.46 |
| គមនាគមន៍ | 25.83 | 12.68 | 42.31 | 87.12 | 114.62 | 282.56 |
| សេវាសហគមន៍ និង សុខុមាលភាពសង្គម | 18.53 | 19.04 | 26.22 | | | 63.79 |
| វប្បធម៌ និងសិល្បៈ | | 0.28 | 0.3 | | | 0.58 |
| បរិស្ថាន និងការអភិរក្ស | | 0.02 | 0.02 | | | 0.04 |
| អភិបាលកិច្ច និងរដ្ឋបាល | 0.52 | 12.18 | 14.75 | 8.29 | | 35.75 |
| សរុប | 46.64 | 53.24 | 92.45 | 95.41 | 114.7 | 402.43 |

ប្រភព: របាយការណ៍ស្ដីពីប្រសិទ្ធភាពជំនួយនៅកម្ពុជា

រូបភាព ៥.១៖ ការបើកផ្ដល់ជំនួយក្នុងវិស័យដឹកជញ្ជូនដោយដៃគូសំខាន់ៗ (លានដុល្លារ)




ប្រភព៖ របាយការណ៍ស្ដីពីប្រសិទ្ធភាពជំនួយនៅកម្ពុជា

ចិនមិនដែលស្ទាក់ស្ទើរទេ ក្នុងការគាំទ្រកម្ពុជាក្នុងវិស័យដែលអ្នកផ្ដល់កម្ចី និងអ្នកផ្ដល់ជំនួយឯទៀតៗបោះបង់ចោល ដោយសារមានបញ្ហាពាក់ព័ន្ធ ដូចជា សិទ្ធិមនុស្ស កង្វះចម្លើយតបរបស់រដ្ឋាភិបាលទៅលើនីតិវិធីរដ្ឋបាល អំពើពុករលួយ កំណែទម្រង់យោធានិងរដ្ឋបាល និងគម្រោងមានហានិយភ័យខ្ពស់។ លើសពីនេះទៀត ចិនជំរុញឲ្យមានអាជីវកម្មយ៉ាងសកម្ម

រវាងវិនិយោគិនរបស់ខ្លួន និងដៃគូនៅកម្ពុជា។ រឿងនេះបង្ហាញច្បាស់តាមរយៈកិច្ចសហប្រតិបត្តិការប្រមាណ ៩០% រវាងក្រុមហ៊ុនឯកជន និងពាក់កណ្តាលឯកជនកម្ពុជា និងចិន (Phou Sambath ND cited in Marks 2000)។ ក្រៅពីនេះ ជំនួយពីចិនផ្តោតជាចំបងលើតម្រូវការជាក់ស្តែងរបស់កម្ពុជា និងគ្មានផ្សារភ្ជាប់នឹងលក្ខខណ្ឌ ឬសំណងអ្វីទេ (ជំនួយគ្មានចំណង)។ ដូច្នេះជំនួយអភិវឌ្ឍន៍ចិន កាន់តែមានភាពទាក់ទាញ និងមានសំណើពីកម្ពុជាកាន់តែច្រើន។

ប្រអប់ ១៖ ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ចិន ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តមូលដ្ឋាននៅកម្ពុជាឆ្នាំ២០០៤-០៩

កំណើនគួរឲ្យកត់សម្គាល់នៃជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) របស់ចិន អាចកត់ត្រាបានជាសំខាន់ តាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តមូលដ្ឋាន ដូចមានបង្ហាញក្នុងកម្មវិធីជំនួយសំខាន់ៗមួយចំនួន៖

- ក្នុងឆ្នាំ២០០៤ ចិនបានយល់ព្រមផ្តល់ ២០០លានដុល្លារ ជាឥណទានរបស់អ្នកទិញដើម្បីកសាងស្ពានឆ្លងទន្លេមេគង្គ និងទន្លេសាប និងផ្លូវធំៗចំនួន២ គឺ ផ្លូវជាតិលេខ៧៦ និង លេខ៧៨។ ក្រុមហ៊ុនទទួលសាងសង់ គឺ Shanghai Construction Group of China។

- ក្នុងឆ្នាំ២០០៦ ទឹកប្រាក់ ៣០០លានRMB (រូបិយវត្ថុចិន) បានផ្តល់ជាជំនួយឥតសំណង ដើម្បីកសាងវិមានរដ្ឋាភិបាលកម្ពុជា ដោយមានក្រុមហ៊ុន Yunnan Construction Engineering Group ជាអ្នកទទួលសាងសង់។ បន្ទាប់មក ក្រោមកម្មវិធី GMS ចិនបានបើកផ្តល់ប្រាក់កម្ចីសម្បទានបន្ថែមទៀត ដើម្បីកសាង Information Super Expressway។ ចិនក៏បានយល់ព្រមលើការផ្តល់កម្ចីគ្មានការប្រាក់ ១០០លានRMB សម្រាប់សកម្មភាពអភិវឌ្ឍន៍កម្ពុជា។

- ក្នុងឆ្នាំ២០០៧ ចិនបានផ្តល់ប្រាក់ ២០៧លានដុល្លារ ជាកម្ចីឥណទានរបស់អ្នកទិញមានលក្ខខណ្ឌអនុគ្រោះ សម្រាប់កសាងផ្លូវជាតិលេខ៨ ផ្លូវលេខ៧៦មួយកំណាត់ ស្ពានព្រែកតាមាក់ និងស្ពានព្រែកក្តាម។ ចិនបានផ្តល់ម៉ាស៊ីនបូមទឹកប្រើម៉ាស៊ូតធុនតូច ២០០គ្រឿង សម្រាប់ប្រើក្នុងវិស័យកសិកម្ម និងចូលរួមជាមួយអ្នកផ្តល់ជំនួយពហុភាគីនានា ដើម្បីផ្តល់មូលនិធិសម្រាប់លើកកម្ពស់ការអប់រំ ការថែទាំសុខភាព ហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍជនបទ និងកសិកម្ម។ ប្រាក់ដែលចិនបើកផ្តល់ តំណាងឲ្យ ១៣% នៃទឹកប្រាក់សរុប ៦៩០លានដុល្លារ ដែលជាចំនួនដ៏ច្រើនមួយសម្រាប់ដំណើរការអភិវឌ្ឍន៍នៅកម្ពុជា។ ក្នុងឋានៈជាអ្នកផ្តល់ជំនួយទ្វេភាគី ចិនបានបន្តផ្តល់មូលនិធិដល់កម្ពុជា ដូចឃើញជាក់ស្តែង ទឹកប្រាក់ ៦២.៥០០ដុល្លារ ដែលផ្តល់ដល់ក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច សម្រាប់រៀបចំការិយាល័យ និងបរិក្ខារដឹកជញ្ជូន ការផ្តល់អាហារូបករណ៍ឲ្យទាហានកម្ពុជា ៦០នាក់ ទៅទទួលការបណ្តុះបណ្តាលនៅចិន ការផ្តល់នាវាល្បាតសមុទ្រ ៩គ្រឿង ដើម្បីការពារសំណង់ និងសម្ភារៈផ្សេងៗសម្រាប់យកប្រេងក្នុងឈូងសមុទ្រថៃ (Xinhua ប្រែសម្រួលពីរស្មីកម្ពុជាឆ្នាំ២០០៧)។

- នៅឆ្នាំ២០០៨ ចិនសន្យាផ្តល់កម្ចីមានការប្រាក់ទាបចំនួន ៥៥លានដុល្លារ និងអនុញ្ញាតឲ្យកម្ពុជានាំចេញទំនិញច្រើនជាងមុនទៅប្រទេសចិនដោយមិនជាប់ពន្ធ។ បន្ទាប់មកទៀត ចិនបានសន្យាផ្តល់កម្ចី ២៨០លានដុល្លារ សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន សំណង់ធារាសាស្ត្រក្នុងខេត្តបាត់ដំបង បណ្តាញបញ្ជូនថាមពលអគ្គិសនីមកភ្នំពេញ ការជួសជុលផ្លូវតភ្ជាប់ពីខេត្តកំពង់ធំទៅព្រះវិហារ និងផ្លូវពីខេត្តស្ទឹងត្រែងទៅបានឡុង (Xinhua ប្រែសម្រួលពីរស្មីកម្ពុជាឆ្នាំ២០០៨)។

- នៅខែឧសភា ២០០៩ ចិនបានផ្តល់កម្ចីសម្បទានប្រមាណ ៧៣លានដុល្លារ សម្រាប់កសាងកំណាត់ផ្លូវសំខាន់មួយនៅភាគឦសានប្រទេស ដើម្បីជួយអភិវឌ្ឍតំបន់នោះទៅជាតំបន់សេដ្ឋកិច្ចថ្មីមួយ។ ផ្លូវនោះសម្រាប់សម្រួលពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ការដឹកជញ្ជូន និងទេសចរណ៍ជាមួយប្រទេសជាប់ព្រំដែនក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ត្រីកោណ GMS។ ក្នុងខែកក្កដា ទឹកប្រាក់ប្រហែល ៦៦,៨លានដុល្លារ ត្រូវបានអនុម័តសម្រាប់ការស្តារជួសជុលផ្លូវក្នុងខេត្តកំពង់ធំ កំពងចាម និង មណ្ឌលគិរី (Xinhua ប្រែសម្រួលពីរស្មីកម្ពុជាឆ្នាំ២០០៩)។

ទាំងកម្ពុជា និងចិន បន្តពង្រឹងទំនាក់ទំនង តាមរយៈការផ្លាស់ប្តូរទស្សនកិច្ចគ្នាទៅវិញទៅមកជារឿយៗ។ ចិនមានបំណងពង្រីកចំណងទាក់ទងពាណិជ្ជកម្ម និងផ្តល់ជំនួយបន្ថែមដល់កម្ពុជា សម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការកែលម្អវិស័យកសិកម្ម (Deum Ampil 2010)។ ក្នុងអំឡុងពេលទស្សនកិច្ចរបស់ឧបនាយករដ្ឋមន្ត្រីចិន Hui Liangy នៅខែមីនា ២០១០ ចិនបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ (MOU) ចំនួន៣ ជាមួយកម្ពុជា ប្រកាសពីបំណងចង់ជំរុញផលិតកម្មស្រូវ និងកែលម្អប្រព័ន្ធទូរគមនាគមន៍នៅកម្ពុជា (Ek Madra 2010)។

## ៥.២ វិធីសាស្ត្រ និងក្របខ័ណ្ឌនៃការវិភាគ

ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ហាក់ដើរតួនាទីបំពេញបន្ថែមយ៉ាងសំខាន់ចំពោះប្រភពហិរញ្ញប្បទានអភិវឌ្ឍន៍ ជាពិសេសក្នុងប្រទេសមានប្រាក់ចំណូលទាបដូចជាកម្ពុជា។ ODA ក៏ជាយានចំបងមួយសម្រាប់ការផ្ទេរមូលធន និងចំណេះដឹងបច្ចេកទេសពីប្រទេសអភិវឌ្ឍន៍ មកប្រទេសកំពុងអភិវឌ្ឍន៍ដែរ។

គួរគត់សម្គាល់ថា ការវាយតម្លៃផលប៉ះពាល់នៃ ODA ជាទូទៅ ឬក្នុងវិស័យជាក់លាក់ណាមួយ ជាការងារស្មុគស្មាញ ដោយសារលទ្ធផលនៃការអភិវឌ្ឍ និងការប្រែប្រួលភាពក្រីក្រ ទទួលរងឥទ្ធិពលពីកត្តាជាច្រើនទៀត ក្រៅពី ODA។ លើសពីនេះទៀត ការកំណត់ជាបរិមាណនៃឥទ្ធិពល ODA ក៏ពិបាកលើសគេដែរ។

ដូចបានគូសបញ្ជាក់ក្នុងផ្នែកមុននេះស្តីពីទំហំនៃ ODA របស់ចិន ការផ្តល់ហិរញ្ញប្បទានពីប្រទេសចិនបានកើនឡើងគួរឲ្យកត់សម្គាល់ ហើយបានបែងចែកជាចំបងសម្រាប់ការកែលម្អហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅកម្ពុជា។ ដូច្នេះ ផលប៉ះពាល់នៃ ODA របស់ចិន លើការកាត់បន្ថយភាពក្រីក្រ ត្រូវវាយតម្លៃតាមរយៈករណីសិក្សាជ្រើសរើសមួយចំនួនលើគម្រោងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្តល់មូលនិធិដោយចិន។

រូបភាព ៥.២៖ ក្របខ័ណ្ឌវិភាគនៃគម្រោង ODA របស់ចិននៅកម្ពុជា




គេតែងយល់ឃើញជាយូរមកហើយថា ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ជួយរួមចំណែកដោយផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ។ ការសិក្សាជាច្រើនដែលប្រើវិធីសាស្ត្រខុសៗគ្នា អនុវត្តនៅតាមទីកន្លែង និងនៅពេលខុសៗគ្នា បានផ្តល់ភស្តុតាងជាក់ស្តែងច្រើនណាស់ បញ្ជាក់ពីផលប៉ះពាល់នៃការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនទៅលើភាពក្រីក្រ។ Setboonsarng (2006)

បានពិនិត្យពីលទ្ធផលជាក់ស្តែងដែលមានស្រាប់ សង្ខេបខ្លឹមសារសិក្ខាសាលា ADBI ឆ្នាំ២០០៥ ស្តីពី ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការកាត់បន្ថយភាពក្រីក្រ[២០] ហើយបានបង្ហាញពីផលប៉ះពាល់នៅកម្រិតម៉ាក្រូ និងមីក្រូនៃហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននេះ។ *នៅកម្រិតម៉ាក្រូ* ចំណងទាក់ទងរវាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការកាត់បន្ថយភាពក្រីក្រ វាស្តែងឡើងតាមរយៈកំណើនសេដ្ឋកិច្ច។ *នៅកម្រិតមីក្រូ* ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការជះឥទ្ធិពលទៅលើធាតុផ្សំជាប្រាក់ចំណូល និងមិនមែនប្រាក់ចំណូល នៃភាពក្រីក្រ។ ទាក់ទិននឹង*ភាពក្រីក្រខាងប្រាក់ចំណូល* ហេដ្ឋារចនាសម្ព័ន្ធផ្តល់ឱកាសឲ្យអ្នកក្របង្កើនផលិតភាពនៃធនធានមានកម្រិតរបស់ខ្លួន (ឧទាហរណ៍ បញ្ចុះតម្លៃធាតុចូល ជួយសម្រួលដល់ការទទួលបានឥណទាន សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ទីផ្សារមានកម្រិតថ្លៃល្អ និងការធ្វើពិពិធកម្មកសិកម្ម)។ ដូចគ្នានេះដែរ ទាក់ទិននឹង*ភាពក្រីក្រមិនមែនប្រាក់ចំណូល* ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន អាចជះឥទ្ធិពលតាមរយៈការបញ្ចុះថ្លៃសេវាកម្មដែលជនក្រីក្រត្រូវការ និងជួយបំពេញបន្ថែមលើអន្តរាគមន៍នានាដែលសំដៅលើកកម្ពស់លទ្ធភាពទទួលបានសេវាថែទាំសុខភាព សេវាអប់រំ និងសេវាសង្គមផ្សេងៗទៀត។

ផ្អែកលើស្ថានភាពដូចខាងលើ មានការវិភាគពីឥទ្ធិពលនៃ ODA របស់ចិនទៅលើភាពក្រីក្រ តាមរយៈផលប៉ះពាល់កម្រិតមីក្រូនៃគម្រោងអភិវឌ្ឍន៍ខាងដឹកជញ្ជូនចំនួន២ នៅកម្ពុជា។ ក្របខ័ណ្ឌវិភាគ មានបង្ហាញក្នុងរូបភាព ៥.២។

*វិធីសាស្ត្រ និងកំហិត*

ករណីសិក្សាចំនួន២ លើគម្រោងផ្តល់មូលនិធិដោយ ODA របស់ចិន ក្នុងវិស័យដឹកជញ្ជូន ដែលបានធ្វើឡើង ដើម្បីយល់ដឹងស៊ីជម្រៅពីបញ្ហាជាក់លាក់ និងផលប៉ះពាល់ផ្សេងៗ គឺមានការស្តារកំណាត់ផ្លូវជាតិលេខ៧ ពីក្រចេះទៅត្រពាំងក្រៀល (ព្រំដែនឡាវ) ដែលបានបញ្ចប់រួចរាល់ ហើយនិងការកសាងស្ពានព្រែកតាមាក់ នៅខេត្តកណ្តាលដែលកំពុងដំណើរការនៅពេលសិក្សា។

ការពិភាក្សាតាមក្រុមស្នូល (FGDs) ជាមួយអ្នកតំណាងរបស់ក្រុមគោលដៅ និងអ្នកទទួលផលដោយផ្ទាល់ និងដោយប្រយោល ព្រមទាំងអង្កេតរបស់ក្រុមអ្នកស្រាវជ្រាវ បានអនុវត្តឡើងដើម្បីប្រមូលព័ត៌មានបែបគុណភាពសំខាន់ៗដោយផ្អែកជាចំបងលើចំណាប់អារម្មណ៍របស់ប្រជាជនមូលដ្ឋាន។ ចំណុចសំខាន់ៗដែលបានពិភាក្សាក្នុង FGDs មានបង្ហាញក្នុងរូបភាព ៥.២។ កំហិតចំបងៗក្នុងការវាយតម្លៃនេះ គឺកង្វះទិន្នន័យបែបបរិមាណ (ការធ្វើអង្កេតអាចត្រូវចំណាយច្រើនពេកធៀបនឹងថវិកាសម្រាប់ការសិក្សានេះ) និងភាពមិនស្មើសាច់នៃទិន្នន័យតាមពេលវេលា លើសូចនាករសង្គមតាមភូមិ (ឧទាហរណ៍ អត្រាបោះបង់ការសិក្សានៅសាលារៀន អត្រាមរណៈមុន និងក្រោយពេលមានផ្លូវថ្មល់ និងស្ពាន)។

## ៥.៣ ករណីសិក្សា

### *៥.៣.១ សាវតារករណីសិក្សា*

*ករណីសិក្សាទី១៖ ការស្តារកំណាត់ផ្លូវជាតិលេខ៧ ពីក្រចេះទៅត្រពាំងក្រៀល (ព្រំដែនឡាវ)*

ផ្លូវជាតិលេខ៧ ជាផ្លូវធំមានប្រវែង ៥០៩គីឡូម៉ែត្រ ឆ្លងកាត់ខេត្តក្រចេះ និងស្ទឹងត្រែង ដោយតភ្ជាប់ពីស្គន់នៅខេត្តកំពង់ចាម ទៅវ៉ឺនសៃ នៅព្រំដែនឡាវ ហើយបន្ទាប់មកតភ្ជាប់ទៅ ផ្លូវលេខ១៣ របស់ឡាវ និងឆ្ពោះទៅភាគខាងជើងតាមបណ្តោយទន្លេមេគង្គ ទៅកាន់លួងប្រាបាង។

---

២០ សិក្ខាសាលានេះ ធ្វើឡើងនៅទីក្រុង ម៉ានីល ពីថ្ងៃទី ១៨ ដល់ ២២ កក្កដា ២០០៥។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅគេហទំព័រៈ http://www.adbi.org/event/851.transport.infrastructure.poverty.reduciton/

ការស្តារជួសជុលផ្លូវនេះ (រូបភាព ៥.៣) ទទួលហិរញ្ញប្បទានពីកម្ចីសម្បទានចំនួន ៦០,៩៨លានដុល្លារ និងជំនួយឥតសំណង ២,៤៣លានដុល្លារ ពីរដ្ឋាភិបាលចិន និងទទួលសាងសង់ដោយក្រុមហ៊ុន Shanghai Construction Group of China។ ការស្តារជួសជុល ចាប់ផ្តើមនៅខែវិច្ឆិកា ២០០៤ និងចប់សព្វគ្រប់នៅខែធ្នូ ២០០៧។ ផ្លូវជាតិលេខ៧ ជាចំណែកមួយនៃផ្លូវតភ្ជាប់ប្រទេសអាស៊ាន ហើយក៏បំពេញឲ្យផ្លូវអាស៊ានលេខ១១ ផងដែរ។ ប្រជាជននៅខេត្តក្រចេះ និងស្ទឹងត្រែង តែងហៅផ្លូវនេះជាទូទៅថា ផ្លូវធំអាស៊ាន។

*ករណីសិក្សាទី២៖ ការកសាងស្ពានព្រែកតាមាក់នៅខេត្តកណ្តាល (១០៦០ម៉ែត្រ)*

ស្ពានព្រែកតាមាក់ មានប្រវែង ១០៦០ម៉ែត្រ ទទឹង ១៣,៥ម៉ែត្រ និងស្ថិតនៅចម្ងាយ ៤០គីឡូម៉ែត្រខាងជើងរាជធានីភ្នំពេញ។ គម្រោងនេះចាប់ផ្តើមនៅខែមិថុនា ២០០៧ ហើយគ្រោងបញ្ចប់នៅខែកញ្ញា ២០១០។ ដោយជួយសម្រួលចរាចរឆ្លងកាត់ទន្លេមេគង្គ គម្រោងនេះបង្កើតនូវច្រកមួយទៀតដែលតភ្ជាប់ភាគខាងកើតទៅភាគខាងលិចប្រទេសកម្ពុជា។ ការសាងសង់នេះអនុវត្តឡើងដោយប្រើកម្ចីសម្បទានចំនួន ៤៣,៥លានដុល្លារ ពីរដ្ឋាភិបាលចិន និងកិច្ចសន្យាម៉ៅការសាងសង់ឲ្យក្រុមហ៊ុន Shanghai Construction Group របស់ចិន។

### *៥.៣.២ លទ្ធផលស្រាវជ្រាវ*

*ករណីសិក្សាទី១៖ ការស្តារជួសជុលផ្លូវជាតិលេខ៧ ពីក្រចេះ ទៅត្រពាំងក្រៀល (ច្រកព្រំដែនទៅឡាវ)*

ការពិភាក្សាតាមក្រុមស្នូល (FGDs) បានធ្វើឡើងពីថ្ងៃទី២៣ ដល់ ២៥ មីនា ២០១០ នៅខេត្តស្ទឹងត្រែង និងក្រចេះ ព្រោះផ្លូវជាតិលេខ៧ ឆ្លងកាត់ខេត្តទាំងពីរ និងតភ្ជាប់ច្រករបៀងសេដ្ឋកិច្ចកម្ពុជា និងឡាវ។

ក្នុងខេត្តនីមួយៗខាងលើ ភូមិចំនួន ៣ ដែលនៅតាមបណ្តោយផ្លូវជាតិលេខ៧ ហើយកៀកនឹងព្រំដែន ត្រូវបានជ្រើសរើសសម្រាប់ការពិភាក្សាតាមក្រុមស្នូល ដើម្បីរកមើលផលប៉ះពាល់នៃសំណង់នេះទៅលើជីវភាពអ្នកភូមិ។ ប្រជាជននៅភូមិអូរស្វាយ អូរឫស្សីកណ្តាល និងរាជានុកូល ក្នុងខេត្តស្ទឹងត្រែង និងនៅភូមិអូរតាណឹង កសាង និងស្រែរនាម ក្នុងខេត្តក្រចេះ ត្រូវបានជ្រើសរើសសម្រាប់ការពិភាក្សានេះ។

អ្នកចូលរួមពី ៦ ទៅ ១១នាក់ ក្នុង FGD នីមួយៗ ត្រូវបានជ្រើសរើសដោយមានការជ្រោមជ្រែងពីមេភូមិ ដើម្បីឲ្យមានសមភាពខាងយេនឌ័រ ប្រភពចំណូលចម្រុះ និង ខ្ទង់អាយុប្រែប្រួលពី២០-៦០ឆ្នាំ។ ចំណុចសំខាន់ដែលបានលើកឡើង រួមមានស្ថានភាពភូមិនៅមុននិងក្រោយពេលផ្លូវជួសជុលរួច ផលប៉ះពាល់ទំនងកើតមានទៅលើអ្នកភូមិ និងទំនាក់ទំនងរវាងអ្នកភូមិនិងអ្នកខាងក្រៅភូមិ ក្នុងអំឡុងពេលស្តារជួសជុលផ្លូវ។ ចំណុចបន្ទាប់ៗ រួមមានរយៈពេល និងចំណាយលើការធ្វើដំណើរ ការប្រែប្រួលលំនាំជីវភាពរស់នៅ លទ្ធភាពចូលទីផ្សារ លទ្ធភាពទទួលបានសេវាសង្គមកិច្ច តម្លៃដីនិងវិនិយោគអភិវឌ្ឍន៍ដី សុវត្ថិភាព ការផ្លាស់ប្តូរទៅរស់នៅកន្លែងថ្មី និងការស្តារជីវភាព និងផលប៉ះពាល់ដែលអាចកើតមានលើសកម្មភាពដទៃទៀត។

លទ្ធផលនៃការពិភាក្សា ពឹងផ្អែកមួយភាគធំលើព័ត៌មានរាយការណ៍ដោយអ្នកចូលរួមក្នុង FGDs និងការសង្កេតរបស់ក្រុមអ្នកស្រាវជ្រាវ។ ដូច្នេះ លទ្ធផលនេះមិនអាចយកទៅប្រើ ដើម្បីធ្វើការសន្និដ្ឋានជាទូទៅពីផលប៉ះពាល់នៃ ODA របស់ចិនមកលើប្រទេសកម្ពុជាទាំងមូលនោះទេ។

រូបភាព ៥.៣៖ ផែនទីខេត្តក្រចេះ និង ស្ទឹងត្រែង



សាវតារសហគមន៍

ភូមិជ្រើសរើសទាំង៦ ស្ថិតនៅចម្ងាយ ១២-៦០គីឡូម៉ែត្រ ពីទីរួមខេត្តស្ទឹងត្រែង និងក្រចេះ (របាយការណ៍ FGD ស្តីពីភូមិនីមួយៗ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ)។ បន្ទាប់ពីផ្លូវថ្មីបានកសាងរួចហើយ ភូមិទាំងនេះ ក៏រីកចម្រើនឡើង ដោយសារមានអ្នកចំណូលថ្មីចូលមករស់នៅ។ ប្រជាជនថ្មីចូលមកដើម្បីរកបានដីដាំដុះកាន់តែច្រើន ហើយពួកអ្នកគ្មានដីធ្លី គេចូលមក ដើម្បីរកកន្លែងជ្រកកោន។

ការផ្លាស់ប្តូរក្នុងមុខរបរអ្នកភូមិ អាចសម្គាល់ឃើញ តាមការប្រៀបធៀបស្ថានភាពក្នុងភូមិ នៅមុនពេល និងក្រោយពេលកែលម្អផ្លូវ។ អ្នកភូមិមានឱកាសច្រើនជាងមុនដើម្បីរកប្រាក់ចំណូល ដោយសារមានមធ្យោបាយដឹកជញ្ជូន និងលទ្ធភាពចូលទីផ្សារងាយស្រួលជាងមុនច្រើន ហើយមានអំណាចច្រើនជាងមុនក្នុងការចរចាថ្លៃនៅពេលលក់ចេញផលិតផល។ កូនចៅរបស់ពួកគាត់ អាចធ្វើដំណើរទៅក្រៅភូមិដើម្បីរកការងារ និងបន្តការសិក្សា។ ប្រជាជនភាគច្រើនដាំដំណាំច្រើនមុខ ដូចជា អំពៅ ពោត ហើយដំណាំពេញនិយមជាងគេ គឺដំឡូងឈើ ដែលអ្នកចំណូលថ្មីនាំដាំមុនគេ។ អ្នកភូមិមានប្រភពប្រាក់ចំណូលជាច្រើន ដូចជា ការដាំដំណាំ ការចិញ្ចឹមសត្វ ការងារកសិកម្មយកប្រាក់ឈ្នួល ការកាប់ឈើ ការនេសាទ ការបើកហាងលក់គ្រឿងទេស និងការប្រមូលជ័រឈើ។ ទោះយ៉ាងនេះក្តី ប្រភពប្រាក់ចំណូលសំខាន់ គឺការដាំស្រូវ លើកលែងតែប្រជាជននៅភូមិរាជានុកូល ក្នុងខេត្តស្ទឹងត្រែង ដែលភាគច្រើនចូលបម្រើការក្នុងកងទ័ព ហើយធ្វើការដាំដុះតែតិចតួចប៉ុណ្ណោះ ដោយសារខ្វះដីមានជីជាតិ ខ្វះប្រព័ន្ធធារាសាស្ត្រ ឬក៏ពុំមានដីសម្រាប់ដាំដុះ។

លទ្ធផល និងផលប៉ះពាល់

ផ្លូវកសាងថ្មី ផ្តល់លទ្ធផលទាំងវិជ្ជមាន និងអវិជ្ជមាន ដល់ប្រជាជនរស់នៅតាមដងផ្លូវ និងនៅជិតនោះ។

*ផ្នែកវិជ្ជមាន*

ក្នុងអំឡុងពេលធ្វើ FGDs មានរាយការណ៍ស្រដៀងគ្នាអំពីផលប្រយោជន៍បានពីការកសាងផ្លូវនេះ ដោយសារតំបន់ភូមិសាស្ត្រ និងទីតាំងនៃភូមិជ្រើសរើស មានលក្ខណៈស្រដៀងគ្នា។ ផ្លូវនេះកាត់បន្ថយចំណាយ និងរយៈពេលធ្វើដំណើររបស់អ្នកភូមិ ទៅកាន់ទីរួមខេត្ត និងទីផ្សារ។ វាបានពង្រីកលទ្ធភាពទទួលបានការអប់រំ សេវាសុខាភិបាល និងឥណទានជួយបង្កើនថ្លៃផលិតផលនិងដីធ្លី ព្រមទាំងនាំមកនូវគំនិតថ្មីៗផ្នែកបច្ចេកទេសដាំដុះ និងអាជីកម្មកសិកម្ម តាមរយៈការចូលមកដល់នៃអង្គការអភិវឌ្ឍន៍នានា។ ប៉ុន្តែសម្រាប់អ្នកភូមិរាជាមង្គល ផ្លូវនេះនាំមកត្រឹមតែឱកាសឲ្យប្រជាជនរកបានការងារធ្វើនៅក្នុងភូមិ ឬនៅក្រៅភូមិ ដោយសារពួកគេមានដីតិចតួចពេកមិនអាចដាំដុះបានច្រើនទេ។

*១) រយៈពេល និងចំណាយលើការធ្វើដំណើរ៖* ក្នុងភូមិចំនួន៦ មានការប្រែប្រួលរយៈពេល និងចំណាយលើការធ្វើដំណើរ។ អ្នកភូមិអូរស្វាយកាលពីមុន ត្រូវធ្វើដំណើរទៅទីរួមខេត្តស្ទឹងត្រែងតាមទូក ដោយត្រូវចំណាយប្រាក់អស់ ១០.០០០រៀល និងត្រូវសម្រាកមួយយប់នៅទីនោះ។ ឥឡូវនេះគាត់អាចជិះម៉ូតូរបស់ខ្លួនឯង ឬជិះរថយន្តឈ្នួល ហើយចំណាយពេលធ្វើដំណើរតែ ២ម៉ោងប៉ុណ្ណោះ។ ថ្លៃធ្វើដំណើរចម្ងាយ ៥៥គ.ម ពីភូមិអូរតាណឹង ទៅទីរួមខេត្តក្រចេះ ថយចុះពី ៧០០០រៀល មកត្រឹម ៤០០០រៀល ហើយចំណាយពេលតែ ១ម៉ោងប៉ុណ្ណោះតាមរថយន្តក្រុងតូច ឬរថយន្តឈ្នួល ធៀបនឹង ៣ម៉ោងកាលពីមុន។

> *"ពីមុន គ្មានហេតុផលអ្វីត្រូវទិញម៉ូតូទេ ព្រោះយើងគ្មានផ្លូវ។ ពេលយើងចង់ទៅកន្លែងណាមួយ យើងត្រូវចាំឲ្យរថយន្តឈ្នួលមកយកយើង ឬសុំដោយសាររថយន្តកងទ័ព។ ឥឡូវនេះមានផ្លូវល្អហើយ ដូច្នេះយើងអាចទិញម៉ូតូ ដោយប្រើលុយសន្សំពីការលក់ដី និងលក់ផលដំណាំ ហើយយើងអាចធ្វើដំណើរបានងាយស្រួល និងរហ័សជាងមុន....... អ្នកលក់គ្រឿងទេសមួយចំនួន គេឡើងទៅផ្សារនៅឯទីរួមខេត្តស្ទើររៀងរាល់ថ្ងៃ។"*

*២. លទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាព៖* សាលារៀននៅក្នុងភូមិទាំងនោះ បានកកើតឡើងតាំងពីមុនពេលមានផ្លូវ ប៉ុន្តែមានត្រឹមថ្នាក់ទី៦ ប៉ុណ្ណោះ។ ការអប់រំក្មេងៗត្រូវបញ្ចប់នៅពេលពួកគេរៀនចប់ថ្នាក់ទាំងនោះ ហើយសិស្សខ្លះបានបោះបង់ការសិក្សាបន្ទាប់ពីចូលរៀនបាន ២-៣ឆ្នាំ។ រឿងនេះកើតឡើងដោយសារកង្វះគ្រូ និងសម្ភារៈសម្រួលការសិក្សា ព្រមទាំងបញ្ហាសុវត្ថិភាពពេលធ្វើដំណើរទៅមកសាលារៀន។ ចាប់តាំងពីមានផ្លូវថ្មីនេះមក ក្មេងកាន់តែច្រើនបានចូលសាលារៀន ព្រោះមានគ្រូ និងសម្ភារៈសម្រួលការសិក្សា (ឧទាហរណ៍ តុ កៅអី សៀវភៅពុម្ព)។ នាបច្ចុប្បន្ន សាលារៀនមានដល់ថ្នាក់ទី៩ ហើយសិស្សអាចបន្តការសិក្សានៅតាមវិទ្យាល័យក្នុងស្រុកក្បែរៗនោះ ឬក្នុងខេត្ត (ចម្ងាយ៨-៥៥គ.ម)។ ការធ្វើដំណើរទៅមកតាមម៉ូតូឌុបត្រូវចំណាយប្រាក់អស់ ៣០០០រៀល ហើយគ្រួសារខ្លះដែលមានលទ្ធភាព គេជួលផ្ទះឲ្យកូនស្នាក់នៅរៀនសូត្រនៅជិតសាលារៀនតែម្តង។

ក្នុងគ្រប់ FGDs គេបានលើកឡើងពីការលំបាកក្នុងការទទួលបានសេវាសុខភាព មុនពេលផ្លូវធ្វើរួច។ អ្នកភូមិប្រើថ្នាំ និងការព្យាបាលបែបបុរាណនៅពេលឈឺថ្កាត់។ នៅពេលឆ្លងទន្លេ ស្ត្រីត្រូវប្រើថ្នាំឫសឈើ និងពឹងលើឆ្មបបុរាណដែលអាចធ្វើឲ្យពួកគេងាយរងគ្រោះបំផុត។ អ្នកជំងឺធ្ងន់ធ្ងរអាចស្លាប់នៅផ្ទះ ឬនៅតាមផ្លូវទៅមណ្ឌលសុខភាព ជាពិសេស បើសិនមណ្ឌលសុខភាពស្ថិតនៅឆ្ងាយពីភូមិ។ តាំងពីផ្លូវបានកសាងរួច អ្នកផ្តល់សេវាសុខភាពឯកជន បានចាប់អារម្មណ៍នឹងភូមិជាច្រើន ហើយអ្នកភូមិក៏មានលទ្ធភាពធ្វើដំណើរទៅមណ្ឌលសុខភាពសាធារណៈបានយ៉ាងងាយដែរ។ ឆ្មបបុរាណក៏បានទទួលការបណ្តុះបណ្តាលនៅមណ្ឌលសុខភាព អំពីវិធីសាស្ត្រមានសុវត្ថិភាពល្អសម្រាប់ជួយដល់ស្ត្រីក្នុងពេលសម្រាលកូន។ ទោះយ៉ាងនេះក្តី សេវាសុខភាពនៅតាមភូមិ មានការកែលម្អយឺតយ៉ាវណាស់ ហើយអាចដោះស្រាយតែបញ្ហាសុខភាពស្រាលៗប៉ុណ្ណោះ។ ជាលទ្ធផល អ្នកភូមិនៅតែត្រូវធ្វើដំណើរទៅស្រុកក្បែរៗនោះដែលផ្តល់សេវាបានប្រសើរ ឬទៅខេត្ត ឬទៅរាជធានីភ្នំពេញ ប៉ុន្តែទោះយ៉ាងណាក៏ពួកគេនៅតែធ្វើដំណើរបានងាយស្រួល និងលឿនជាងមុនដែរ។

*៣. ថ្លៃដី៖* ថ្លៃដីប្រែប្រួល អាស្រ័យលើទីតាំង។ នៅភូមិអូរឫស្សីកណ្តាល ដីតាមបណ្តោយផ្លូវឡើងថ្លៃជាខ្លាំងពីស្ទើរស្មើសូន្យ រហូតដល់ ១០០ដុល្លារ/ប្លង់ (៣ម x ៤០០ម) ហើយដីដាំដុះមានតម្លៃពី ២០០០-៣០០០ដុល្លារ/ហិកតា។ នៅភូមិរាជានុកូលវិញ ដីមួយប្លង់ថ្លៃ ៦០០ដុល្លារ (១ម x ៣០០ម) ហើយដីដាំដុះថ្លៃ ១០០០ដុល្លារ/ហិកតា។ ថ្លៃដីកើនឡើងជាលំដាប់ចាប់ពីជំហានដំបូងនៃការកសាងផ្លូវ ដែលជួនពេលគ្នាជាមួយនឹងការស្ទុះឡើងនៃទីផ្សារដីធ្លីនៅកម្ពុជា។ អ្នកទិញមានប្រភពមកពីខេត្តផ្សេងៗ ដូចជា កំពង់ចាម តាកែវ ព្រៃវែង កំពង់ធំ និងភ្នំពេញ។ ពួកគេទិញដីសម្រាប់ដាំដុះ និងវិនិយោគ ដោយប្រាថ្នាកេញយកចំណេញពីការឡើងថ្លៃដីនៅពេលអនាគត។

*៤. លទ្ធភាពចូលទៅកាន់ទីផ្សារ៖* ថ្លៃផលិតផលកសិកម្ម កើនឡើងដោយសារផ្លូវថ្នល់ដែលនាំអ្នកទិញបានកាន់តែច្រើនជាងមុនពីតំបន់ផ្សេងៗ ឲ្យចូលដល់ភូមិ។ ផ្លូវថ្នល់ក៏អាចឲ្យអ្នកភូមិដឹកជញ្ជូនផលិតផលស្រស់ៗទៅទីផ្សារដោយខ្លួនឯង ហើយបង្កើនកម្លាំងចរចាកំណត់ថ្លៃលក់។ ការពិភាក្សាបានឲ្យដឹងថា ថ្លៃផលដំណាំកើនឡើងពី ២០០រៀល/គីឡូក្រាម ដល់ ៨០០-១០០០រៀល/គីឡូក្រាម ធ្វើឲ្យកសិករមានទឹកចិត្តបង្កើនផលិតកម្មរបស់ខ្លួន ខុសពីពេលមុនដែលពួកអ្នកភូមិតែងធ្លាប់ទុកផលិតផលឲ្យរលួយចោល ដោយសារគ្មានអ្នកមកទិញ ឬការដឹកជញ្ជូនទៅទីផ្សារមានការលំបាក និងត្រូវចំណាយខ្ពស់។

*"ឈ្មួញកណ្តាលមកដល់ផ្ទះយើងស្ទើររៀងរាល់ថ្ងៃ មិនដូចពីមុនដែលគេមកតែមួយដងក្នុងមួយខែ...... ទោះបីគេមិនមករកយើង ក៏យើងអាចយកផលិតផលទៅទីផ្សារខេត្តដោយខ្លួនឯងបានដែរ។"*

*៥. ផលប្រយោជន៍ផ្សេងទៀត៖*

- *ផលប្រយោជន៍ទូទៅ៖* អ្នកភូមិពេញចិត្តនឹងកម្រិតជីវភាពរបស់ខ្លួន ដោយមានម៉ូតូ និងផ្ទះជួសជុលថ្មី តាមរយៈការលក់ដី និងផលដំណាំផ្សេងៗ។ កូនចៅរបស់ពួកគេអាចចេញទៅរកការងារធ្វើ និងរៀនជំនាញវិជ្ជាជីវៈថ្មីៗ ដូចជាសិប្បកម្ម ឬជួសជុលម៉ូតូនៅក្រៅភូមិ។

- *ចំណងទាក់ទងជាមួយទីភ្នាក់ងារអភិវឌ្ឍន៍៖* ផ្លូវថ្នល់តភ្ជាប់អ្នកភូមិជាមួយនឹងបណ្តាទីភ្នាក់ងារអភិវឌ្ឍន៍ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងភ្ញៀវទេសចរណ៍។ ការតភ្ជាប់នេះមានបង្ហាញក្នុងសកម្មភាពរបស់អង្គការ Oxfam និង Danida ដូចជា ការជីកអណ្តូង ការផ្តល់កម្ចីសម្រាប់ការចិញ្ចឹមសត្វរកចំណូលទ្រទ្រង់ជីវភាព និងការជួយកសាងផ្លូវលំក្នុងភូមិជាច្រើន។ ស្ថាប័នមីក្រូហិរញ្ញវត្ថុ ដូចជា អេស៊ីលីដា អម្រិត និងធនាគារភូមិ ផ្តល់ឱកាសឲ្យប្រជាជនបង្កើនការប្រើប្រាស់ធាតុចូលកសិកម្ម។ CIVO បានបង្រៀនជំនាញសិប្បកម្មដល់អ្នកភូមិ។ ផ្លូវថ្នល់បានទាក់ទាញភ្ញៀវទេសចរណ៍ច្រើនជាងមុន មកទស្សនាតំបន់ទេសចរណ៍ធម្មជាតិដ៏មានសក្តានុពលនៅជិតភូមិទាំងនោះ (ភូមិអូរឫស្សីកណ្តាល)។

*ផ្នែកអវិជ្ជមាន*

ក្រៅពីលទ្ធផលជាវិជ្ជមាន ក៏មានសេចក្តីរាយការណ៍ពីការបារម្ភធំៗមួយចំនួនទាក់ទងនឹងការកសាងផ្លូវនេះដែរ។

*១. ឱកាសការងារក្នុងអំឡុងពេលកសាងផ្លូវ៖* គម្រោងស្តារកសាងនេះ បានត្រៀមសព្វគ្រប់នូវពលកម្ម បច្ចេកទេស និងសម្ភារៈ ហើយបានជ្រើសរើសប្រជាជនមូលដ្ឋានតិចនាក់ណាស់ឲ្យចូលធ្វើការ និងឲ្យធ្វើការតែត្រឹម ២-៣សប្តាហ៍ប៉ុណ្ណោះ។

*២. ការត្រូវផ្លាស់ប្តូរទៅរស់នៅកន្លែងថ្មី និងការស្តារជីវភាព៖* ក្នុងជំហានដំបូង ផ្ទះអ្នកភូមិមួយចំនួនត្រូវរងការខូចខាត ឬត្រូវរុះរើចេញ ដើម្បីធ្វើផ្លូវ។ ការបង់សំណងប៉ះប៉ូវ គឺ ១០០០-២៥០០ដុល្លារសម្រាប់ផ្ទះនីមួយៗដែលមានស្ថានភាពល្អ និង ៣០០-៦០០ដុល្លារសម្រាប់ផ្ទះមានស្ថានភាពមិនសូវល្អ ដែលជាចំនួនមួយមិនច្រើនទេ ព្រោះអ្នកភូមិត្រូវទៅសង់លំនៅថ្មីដែលកាន់តែចូលជ្រៅក្នុងព្រៃ។

*៣. សុវត្ថិភាពផ្លូវ និងសន្តិសុខសហគមន៍៖* ផ្លូវនេះនាំឲ្យកើតគ្រោះថ្នាក់ចរាចរណ៍ច្រើនជាងមុន ដោយសារកង្វះផ្លាកសញ្ញាចរាចរណ៍ត្រឹមត្រូវ និងផ្ទៃផ្លូវងាយខូចខាត។ ម្យ៉ាងទៀត ដោយសារឥទ្ធិពលភូមិងាយចូលដល់ ដូច្នេះអំពើចោរកម្មក៏កើនឡើងដែរ។

*៤. បញ្ហាទំនាស់ និងបរិស្ថាន៖* ផ្លូវនេះ បានទាក់ទាញក្រុមហ៊ុនវិនិយោគមួយចំនួន ដែលភាគច្រើនជាក្រុមហ៊ុនចិនវិនិយោគផ្នែកអាជីវកម្មរ៉ែ និងចម្ការដំណាំ។ ក្រុមហ៊ុនទាំងនេះទទួលបានដីសម្បទានពីរដ្ឋាភិបាល ដែលប៉ះពាល់ដល់ដីដាំដុះរបស់អ្នកភូមិ នាំឲ្យមានជម្លោះរវាងអ្នកភូមិ និងក្រុមហ៊ុន។ ផលប៉ះពាល់មួយទៀត គឺការបាត់បង់ឈើប្រណិតដែលក្រុមហ៊ុនបានកាប់ចេញដើម្បីដាំដំណាំកសិឧស្សាហកម្ម។

សរុបសេចក្តីមក ផ្លូវថ្មីកសាងក្រោមគម្រោងថវិការបស់ចិន ផ្តល់ផលវិជ្ជមានឲ្យអ្នកភូមិ ច្រើនជាងផលអវិជ្ជមាន។ ឱកាសដាំដុះដំណាំច្រើនជាងមុន និងការរៀនសូត្រពីបទពិសោធន៍របស់អ្នកចំណូលថ្មី និងអ្នកដំណើរឆ្លងកាត់ បានកែលម្អកម្រិតជីវភាពរបស់អ្នកភូមិ។ ផ្លូវថ្នល់ល្អជាធាតុចូលបន្ថែមមួយដែលជួយបង្កើនឱកាសទទួលបានការអប់រំ និងសេវាសុខភាពកាន់តែប្រសើរ។ អ្នកភូមិអាចសិក្សាពីពិភពខាងក្រៅ តាមការចេញទៅទីរួមខេត្ត ឬរាជធានីភ្នំពេញ។ ពួកគេអាចធ្វើដំណើរបានឆ្ងាយ និងងាយស្រួលជាងមុន ដើម្បីរកការងារធ្វើ។ ទីភ្នាក់ងារអភិវឌ្ឍន៍នានាក៏អាចចូលមកដល់ភូមិ ហើយអាចផ្តល់សេវាសង្គមដល់អ្នកភូមិ ព្រមទាំងជួយថែរក្សាធនធានព្រៃឈើ។ សរុបមក ផ្លូវនេះនាំឲ្យមានជម្រើសជីវភាពច្រើនជាងមុន។

អ្នកចូលរួមក្នុងការពិភាក្សា FGD បានស្នើថា ផ្លូវល្អគួរមានផ្លាកសញ្ញាគ្រប់គ្រាន់ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងគួរមានគុណភាពជាប់បានយូរ។

*ករណីសិក្សាទី២៖ សំណង់ស្ពានព្រែកតាមាក់នៅខេត្តកណ្តាល (១០៦០ម)*

សាវតារសហគមន៍

ការពិភាក្សា FGDs ចំនួនពីរ បានធ្វើឡើង គឺមួយនៅភូមិកំពង់ដំរី ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និងមួយទៀតនៅភូមិស្វាយអាត់លើ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ ការពិភាក្សា FGDs បានអនុវត្តនៅខែធ្នូ ២០០៩ នៅពេលការសាងសង់ស្ពានកំពុងដំណើរការ ហើយអ្នកភូមិកំពុងប្រើប្រាស់សាឡាង ដើម្បីឆ្លងទន្លេនៅឡើយ។ ដូច្នេះ អ្នកចូលរួមក្នុងការពិភាក្សា FGDs បានឆ្លើយប្រាប់ពីផលប្រយោជន៍ដែលពួកគេរំពឹងទទួលបានពីស្ពានថ្មីនេះ។

ភូមិកំពង់ដំរី មាន ២៧៤គ្រួសារ។ លោកមេភូមិបានជួយជ្រើសរើសប្រជាជន ៨នាក់ (ប្រុស ១នាក់ ស្រី ៧នាក់) ឲ្យចូលរួមក្នុង FGD ដោយផ្អែកលើការកំណត់កម្រិតជីវភាពរបស់ពួកគេថាជាអ្នកក្រីក្រ។ អ្នកចូលរួមម្នាក់ជាសមាជិកក្រុមប្រឹក្សាឃុំ និងជាមេភូមិ។

ស្រុកស្វាយអាត់លើ មាន ២០៧គ្រួសារ។ អ្នកស្រុក ៧នាក់ ត្រូវបានជ្រើសរើសដោយមានគោលដៅសម្រាប់ការពិភាក្សា FGD ផ្អែកតាមមុខរបរជាអ្នកដើរលក់អីវ៉ាន់នៅកំពង់ចម្លង (សាឡាង)។ ប៉ុន្តែជាក់ស្តែងមានមនុស្សច្រើនជាងការរំពឹងទុកមកចូលរួមក្នុង FGD ព្រោះនៅទីបំផុតមានរហូតដល់ ១៧នាក់ ដែលមានមុខរបរ ឬមានសមាជិកគ្រួសារដែលប្រកបរបរជាអ្នកដើរលក់ (ទឹកអំពៅ លៀស អាហារ ផ្លែឈើ និងភេសជ្ជៈ) នៅកំពង់ចម្លង។

លទ្ធផលរំពឹងទុក និងផលប៉ះពាល់

*ផ្នែកវិជ្ជមាន*

*១. រយៈពេល និងចំណាយលើការធ្វើដំណើរ៖* សម្រាប់អ្នកចូលរួមពិភាក្សាយល់ឃើញថា មានស្ពានប្រសើរជាងគ្មាន។ នៅពេលស្ពានធ្វើរួច ពួកគេអាចឆ្លងទៅត្រើយម្ខាងនៅគ្រប់ពេលតាមចំណង់ ឯតឡូវនេះ ត្រូវតែរង់ចាំសាឡាង ហើយសាឡាងមិនបម្រើសេវាកម្មនៅពេលយប់ទេ។ ពួកគាត់នឹងចំណាយតិចជាងមុនក្នុងការធ្វើដំណើរ។ ឧទាហរណ៍ នាបច្ចុប្បន្ន ការធ្វើដំណើរទៅមកពីភូមិទៅភ្នំពេញ ត្រូវចំណាយអស់ ៤០.០០០រៀល។ លើសពីនេះទៀត នៅពេលឆ្លងសាឡាង ពួកគេត្រូវចំណាយ ៥០០រៀលសម្រាប់ម៉ូតូមួយ និង ៣០០រៀលសម្រាប់មនុស្សម្នាក់។ ប្រសិនបើជិះរថយន្តឈ្នួល ការធ្វើដំណើរទៅមកនេះ ត្រូវចំណាយអស់ ២០.០០០រៀល។ គេត្រូវចំណាយពេលពី ១ម៉ោង ទៅ ១ម៉ោងកន្លះ ដើម្បីឆ្លងទន្លេ។ ពេលស្ពានបើក ពួកគេនឹងមិនមានបង់ចំណាយបន្ថែមទាំងនេះទៀតទេ។ ចំណុចសំខាន់មួយទៀត សាឡាងដំណើរការពីម៉ោង ៥ព្រឹក ដល់ ៥ល្ងាច ដូច្នេះ ការធ្វើដំណើរ គឺមានកម្រិត។ ក្នុងករណីបន្ទាន់ ពួកគេត្រូវតែចំណាយលុយច្រើនឲ្យសាឡាង។

*២. បម្រែបម្រួលជីវភាពរស់នៅ៖* ប្រជាជនរំពឹងថា នឹងអាចចូលទៅកាន់ទីផ្សារស្រួលជាងមុន ព្រោះអាចធ្វើដំណើរបានគ្រប់ពេលវេលា។ លើសពីនេះទៀត ថ្លៃផលិតផលក្នុងភូមិនឹងកើនឡើង ដោយសារពួកគាត់អាចលក់ផ្ទាល់ទៅឲ្យអ្នកលក់រាយ ជាជាងឈ្មួញកណ្តាល។ តួយ៉ាង ក្នុងអំឡុងពេលនៃការសិក្សា អ្នកភូមិលក់ឥដ្ឋមួយដុំថ្លៃ ១៥០រៀល ហើយប្រសិនបើមិនមានបង់ថ្លៃសាឡាងទេ ពួកគាត់អាចលក់ឥដ្ឋនោះបានថ្លៃ ២០០រៀល/ដុំ។ ម្យ៉ាងទៀត អ្នកភូមិអាចទទួលបានការងារនៅភ្នំពេញ ព្រោះអាចធ្វើដំណើរទៅមកបានយ៉ាងងាយ ដោយមិនចាំបាច់ចំណាយប្រាក់ទៅជួលផ្ទះនៅទីក្រុង។ ក្រៅពីនេះ ពួកគាត់រំពឹងថានឹងមានភោជនីយដ្ឋានថ្មីៗបើកដំណើរការក្នុងភូមិគាត់ ដូច្នេះនឹងមានការងារធ្វើកាន់តែច្រើនក្នុងមូលដ្ឋាន។ ពួកគាត់ក៏រំពឹងថា ភូមិគាត់នឹងបានតភ្ជាប់បណ្តាញអគ្គិសនីជាតិក្នុងពេលឆាប់ៗ។ នាបច្ចុប្បន្ន អ្នកភូមិត្រូវប្រើអគ្គិសនីឯកជនថ្លៃដល់ ២៨០០រៀល/គីឡូវ៉ាត់ម៉ោង។ អគ្គិសនីមានតាំងពីដើមឆ្នាំ២០០៩ ហើយប្រជាជនប្រហែល ៧០% បានតភ្ជាប់នឹងការផ្គត់ផ្គង់នេះ។

អ្នកចូលរួមពិភាក្សា បានប្រាប់ពីការលំបាកនៃការបាត់បង់ចំណូលគ្រួសារ ជាពិសេសអ្នកមានប្រភពចំណូលពីការលក់ដូរនៅជិតកំពង់ចម្លង។ ប៉ុន្តែពួកគាត់នៅតែគិតថា មានស្ពានប្រសើរជាងគ្មាន ព្រោះប្រាក់ចំណូលបានពីការលក់អីវ៉ាន់នៅកំពង់ចម្លង មានបរិមាណតិចតួច និងមិនទៀងទាត់ទេ ហើយវាគ្រាន់តែជាប្រាក់ចំណូលបន្ថែមប៉ុណ្ណោះ។

*៣. លទ្ធភាពទទួលបានសេវាសង្គម៖* អ្នកភូមិសង្ឃឹមថា ពួកសិស្សនិស្សិតដែលទៅសិក្សានៅក្រុងភ្នំពេញនឹងអាចត្រឡប់មកផ្ទះវិញក្នុងថ្ងៃតែមួយដោយមិនចាំបាច់ជួលកន្លែងស្នាក់នៅ ដូច្នេះនឹងមានអ្នកភូមិកាន់តែច្រើននាក់ដែលអាចទៅរៀនបាន។ ក្នុងករណីមានជំងឺធ្ងន់ធ្ងរ ពួកគាត់ក៏អាចទៅដល់មន្ទីរពេទ្យទាន់ពេលដែរ។

*៤. ថ្លៃដី និងវិនិយោគ៖* ដីធ្លីរំពឹងថានឹងឡើងថ្លៃនៅពេលស្ពានដំណើរការ ដោយសារលទ្ធភាពធ្វើដំណើរចេញចូលស្រួលជាងមុន។ ថ្លៃដីនៅជុំវិញការដ្ឋានកើនឡើងយ៉ាងខ្លាំង នៅដំណាក់កាលដំបូងនៃការសាងសង់។ ទោះជាដីឡើងថ្លៃឥតឈប់ ក៏អ្នកភូមិមិនលក់ដីលំនៅដ្ឋានរបស់ខ្លួនដែរ ដោយសារមិនដឹងរើផ្ទះទៅនៅទីណា បន្ទាប់ពីនោះមក។ ការពិភាក្សា FGDs បង្ហាញទៀតថា អ្នកភូមិមិនបានប្រមើលឃើញថា ត្រូវមានធ្វើវិនិយោគអ្វីភ្លាមៗទេ ប៉ុន្តែពួកគាត់រំពឹងថា មាននៅពេលអនាគត។

*៥. ការត្រូវផ្លាស់ប្តូរទៅរស់នៅកន្លែងថ្មី និងការស្តារជីវភាព៖* ស្ពាននេះប៉ះពាល់ដី ឬផ្ទះប្រជាជនជិត ១០០គ្រួសារ ហើយរដ្ឋាភិបាល ផ្តល់សំណងប៉ះប៉ូវ ១៨ដុល្លារ/ម² សម្រាប់ដីនិងផ្ទះនៅជិតស្ពាន ១៥ដុល្លារ/ម² សម្រាប់ដីលំនៅដ្ឋានផ្សេងទៀត ៨ដុល្លារ/ម² សម្រាប់ដីកសិកម្ម ៥,៣ដុល្លារ/ម² សម្រាប់ដីផ្សេងទៀត។ ប្រជាជនភាគច្រើនដែលរងការប៉ះពាល់ពីសំណង់នេះ បានផ្លាស់ទីទៅតាំងលំនៅនៅកន្លែងផ្សេងក្នុងភូមិដដែល។

*ផ្នែកអវិជ្ជមាន*

ស្ពាននេះមានផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានលើប្រជាជនដែលរស់នៅក្បែរនោះ។ ប្រជាជនមូលដ្ឋានដែលប្រកបរបរលក់ដូរតូចតាចនៅក្បែរកំពង់ចម្លង អាចបាត់បង់ប្រភពចំណូលបន្ថែមរបស់ខ្លួនពេលស្ពានសង់រួចក៏ពិតមែន ប៉ុន្តែពួកគេនៅតែមានទស្សនៈសុទិដ្ឋិនិយមចំពោះស្ពាននេះ។ សរុបមក ពួកគាត់រំពឹងថានឹងទទួលបានផលចំណេញពីស្ពាន ដូចជា ចំណេញពេលវេលានិងប្រាក់កាសលើការធ្វើដំណើរ ឱកាសរកបានការងារធ្វើនៅកន្លែងឆ្ងាយៗជាងមុន លទ្ធភាពកាន់តែប្រសើរចូលទៅកាន់ទីផ្សារនៅក្រៅភូមិ និងការលក់ផលិតផលគាត់បានកាន់តែថ្លៃ។

ទោះបីជាមានស្ពានកំពុងសាងសង់ក្នុងឃុំក្តី ក៏គ្មានប្រជាជនមូលដ្ឋានណាទទួលបានការងារក្នុងសំណង់នេះទេ។ កម្មករសំណង់ភាគច្រើនជាជនជាតិចិន។

**ជំពូក ៦**

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្នែកគោលនយោបាយ

## ៦.១ សេចក្តីសន្និដ្ឋាន

ផ្នែកខាងក្រោម បង្ហាញនូវកស្តុតាងបានពីសមាសភាគនីមួយៗក្នុងការវិភាគពីផលប៉ះពាល់នៃពាណិជ្ជកម្ម វិនិយោគ និង ODA ទៅលើភាពក្រីក្រ។ គួរចងចាំថា លទ្ធផលទាំងនេះ ដកស្រង់ជាចំបងពីករណីសិក្សានានាដូចរៀបរាប់ខាងលើ។

*ទិដ្ឋភាពពាណិជ្ជកម្ម*

ក្នុងមួយទសវត្សរ៍កន្លះចុងក្រោយនេះ ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា-ចិន រីកលូតលាស់ជាខ្លាំង ប៉ុន្តែ ជញ្ជីងពាណិជ្ជកម្មអវិជ្ជមានរបស់កម្ពុជា នៅតែបន្តរីកធំ តាមអត្រាកំណើនប្រចាំឆ្នាំជាមធ្យម ៣៤%។ ដោយប្រើប្រាស់ក្របខ័ណ្ឌបង្កើតដោយ Jenkins និង Edwards (2004) ការសិក្សានេះបានកំណត់ពីឥទ្ធិពលនៃប្រទេសចិនលើភាពក្រីក្រនៅកម្ពុជា តាមរយៈទិដ្ឋភាពជាក់លាក់ចំនួនបី គឺការនាំចេញទៅចិន ការនាំចូលពីចិន និងការនាំចេញទៅទីផ្សារទី៣។ លទ្ធផលវិភាគមានខ្លឹមសារសង្ខេបដូចខាងក្រោម។

ចំណែកតាមមុខទំនិញនាំចេញទៅចិន មានលំនាំប្រែប្រួលគួរឲ្យកត់សម្គាល់ពីឆ្នាំ១៩៩២-២០០៨។ ចំណែកនៃការនាំចេញផលិតផលកសិកម្មអតិពលកម្ម ធ្លាក់ចុះខ្លាំងពី ៥១,៤% ក្នុងឆ្នាំ១៩៩២ មកត្រឹម ៩,១% ក្នុងឆ្នាំ២០០០ បន្ទាប់មកស្ទុះឡើងវិញដល់ ២៩,៦% ក្នុងឆ្នាំ២០០៨។ ការធ្លាក់ចុះនេះ បណ្តាលមកពីការថយចុះការនាំចេញជ័រកៅស៊ូធម្មជាតិដោយសារការកាប់យកចេញនូវដើមកៅស៊ូចាស់ៗគ្មានផលិតភាព ឯការស្ទុះឡើងវិញបណ្តាលពីកំណើនការនាំចេញជ័រកៅស៊ូធម្មជាតិ ដោយសារដើមកៅស៊ូរាប់ម៉ឺនដើមដែលដាំឡើងវិញបានលូតលាស់ធំល្មមអាចយកជ័របាន គួបផ្សំនឹងកំណើនការនាំចេញសត្វរស់ និងត្រី ពីឆ្នាំ២០០០-២០០៨។ ការនាំចេញសម្លៀកបំពាក់ និងទំនិញវាយនភ័ណ្ឌអតិពលកម្ម ទៅចិន ក៏មាននិន្នាការកើនឡើងគួរឲ្យកត់សម្គាល់ដែរ ពី ៣,២% ក្នុងឆ្នាំ១៩៩២ ដល់ ២៨,២% ក្នុងឆ្នាំ២០០៨។ កំណើនចំណែកផលិតផលទាំងពីរក្រុមនេះ អាចជួយរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដោយសារវាបានបង្កើតការងារជាច្រើន។ ប៉ុន្តែនៅរវាងឆ្នាំ២០០០ និង ២០០៨ ការនាំចេញទំនិញកម្មន្តសាលអតិពលកម្មធ្លាក់ចុះជាខ្លាំង ប៉ុន្តែមានការប៉ះប៉ូវមកវិញដោយសារកំណើនគួរឲ្យកត់សម្គាល់ក្នុងការនាំចេញផលិតផលព្រៃឈើក្នុងពេលជាមួយគ្នានោះ។

ទិន្នន័យស្តីពីការនាំចូលពីចិនមកកម្ពុជាបង្ហាញថា ផ្នែកផលិតផលកសិកម្មអតិពលកម្មមានទំហំតូច និងបានធ្លាក់ចុះពីឆ្នាំ១៩៩២-២០០៨។ ការប្រកួតប្រជែងរវាងប្រទេសទាំងពីរក្នុងទីផ្សារកសិកម្មក្នុងស្រុក មិនទំនងកើតមានឡើងទេ។ ផលិតផលមួយចំនួនដែលមិនមែនជាឯកទេសរបស់កម្ពុជា ដូចជា ផ្លែប៉ោមស្រស់ ទំពាំងបាយជូរក្រៀម ផ្លែព័រ និង ផ្លែ quinces ជាដើម សុទ្ធតែជាផលិតផលនាំចូលដើម្បីបំពេញបន្ថែម។ ការនាំចូលផលិតផលកសិកម្មអតិពលកម្មមានទំហំតូច ប៉ុន្តែកំណើនជាទៀងទាត់នៃចំណែកនាំចូលផលិតផលមួយចំនួនក្នុងក្រុមនេះ អាចគំរាមកំហែងដល់ការប្រកួតប្រជែងនៅពេលអនាគត។ កំណើនចំណែកនៃការនាំចូលសម្លៀកបំពាក់ និងវាយនភ័ណ្ឌអតិពលកម្ម ពីឆ្នាំ១៩៩២-២០០៨ មិនបង្កើតជាការប្រកួតប្រជែងក្នុងទីផ្សារក្នុងស្រុកទេ ព្រោះផលិតផលទាំងនេះគេត្រៀមរៀបចំសម្រាប់នាំចេញទៅទីផ្សារទី៣។ កំណើនចំណែកនៃការនាំចូលផលិតផលដូចបានរៀបរាប់ខាងលើ ហាក់ដូចជាបានបង្កើតការងារនៅប្រទេសកម្ពុជា ដូច្នេះវាមានឥទ្ធិពលវិជ្ជមានលើភាពក្រីក្រ ប៉ុន្តែវាក៏រាំងដល់ឱកាសអភិវឌ្ឍទំនាក់ទំនងដើមខ្សែនៃឧស្សាហកម្មផ្សេងៗនៅក្នុងសេដ្ឋកិច្ចក្នុងស្រុកផងដែរ។

ទាក់ទិននឹងផលចំណេញសម្រាប់អ្នកប្រើប្រាស់ ទិន្នន័យបង្ហាញថា ចំណែកនៃការនាំចូលទំនិញប្រើប្រាស់សម្រាប់ប្រជាជនក្រីក្រ បានកើនឡើងពីឆ្នាំ១៩៩២-២០០០ ប៉ុន្តែធ្លាក់ចុះវិញពីឆ្នាំ២០០០-២០០៨។ និន្នាការនេះ បង្ហាញថា ផលចំណេញនៃទំនិញប្រើប្រាស់គុណភាពអន់ បានពីការនាំចូលផលិតផលប្រើប្រាស់ថោកៗរបស់ចិន បានធ្លាក់ចុះបន្តិចនៅពាក់កណ្តាលទី២ នៃអំឡុងពេលនោះ ដែលធ្វើឲ្យតួនាទីជួយរួមចំណែករបស់ប្រទេសចិន ក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា កាន់តែចុះខ្សោយ។ ផលិតផលសម្រាប់ប្រជាជនក្រីក្រដែលនាំចូលជាប្រចាំ រួមមាន ត្រី គ្រាប់ធញ្ញជាតិ បន្លែ ផ្លែឈើ ភេសជ្ជៈ គ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់ និងខោអាវចាស់ៗ។

ការវិភាគការនាំចេញទៅទីផ្សារទី៣ បង្ហាញថា កម្ពុជានិងចិន អាចប្រកួតប្រជែងគ្នាក្នុងទីផ្សារទី៣ សម្រាប់មុខទំនិញកម្មន្តសាល ប៉ុន្តែមិនមែនផលិតផលកសិកម្មនោះទេ។ ការពិនិត្យលម្អិតថែមទៀតពីការនាំចេញសម្លៀកបំពាក់ឈានមុខទាំង ១២មុខ ទៅកាន់សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប បង្ហាញពីការប្រកួតប្រជែងដែលអាចកើតមានជាមួយចិន ក្នុងទីផ្សារសហរដ្ឋអាមេរិក ប៉ុន្តែមិនមែនក្នុងសហភាពអឺរ៉ុបទេ ដោយសារចំណែកទីផ្សារសម្លៀកបំពាក់របស់កម្ពុជានៅសហភាពអឺរ៉ុបមានកម្រិតទាបត្រឹម 0,0១% ទៅ ១%។ ក្នុងចំណោមផលិតផលឈានមុខទាំង ១២មុខក្នុងទីផ្សារសហរដ្ឋអាមេរិក ការធ្លាក់ចុះចំណែករបស់ចិន និងការកើនចំណែករបស់កម្ពុជា ក្នុងមុខទំនិញសម្លៀកបំពាក់ចាក់ដោយម្ជុល (SITC 8459) បានបង្កើតឱកាសសម្រាប់ផលិតកម្ពុជា ខណៈដែលកំណើនខ្ពស់នៃចំណែកផលិតផលចិន ចំនួន ១១មុខទៀតនៅក្នុងទីផ្សារនោះ វាអាចបង្កការគំរាមកំហែងដល់កម្ពុជា និងអាចជះឥទ្ធិពលអវិជ្ជមានដល់ការកាត់បន្ថយភាពក្រីក្រ។

*ទិដ្ឋភាពវិនិយោគ*

ចិនជាវិនិយោគិនចំបងមួយនៅកម្ពុជា។ វិនិយោគរបស់ចិន បានកើនឡើងយ៉ាងច្រើនចាប់ពីឆ្នាំ២០០៤ ដោយផ្តោតលើការអភិវឌ្ឍធនធានធម្មជាតិ (ប្រេងកាត រ៉ែ ថាមពល រោងចក្រវារីអគ្គិសនី) ទេសចរណ៍ និងវិស័យកាត់ដេរ។ វិនិយោគិនចិនចូលមកកម្ពុជា ដោយគេសម្លឹងឃើញថ្លៃពលកម្មទាប ស្ថិរភាពនយោបាយ គ្រឿងលើកទឹកចិត្តសម្រាប់វិនិយោគ និងទីផ្សារផុសឡើងថ្មីជាច្រើនសម្រាប់កម្ពុជាដែលទទួលបានលក្ខខណ្ឌអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម (MFN)។

ការរួមចំណែកនៃវិនិយោគចិនក្នុងវិស័យកាត់ដេរនៅកម្ពុជា គេបានពិនិត្យតាមរយៈករណីសិក្សាទាក់ទិននឹងការងារ និងការបង្កើតប្រាក់ចំណូល ប្រាក់ផ្ញើទៅផ្ទះ និងឱកាសសម្រាប់ការផ្ទេរជំនាញនិងកសាងសមត្ថភាព។ វិនិយោគចិនក្នុងវិស័យនេះ បានបង្ហាញពីការរួមចំណែកជាវិជ្ជមានដល់ការបង្កើតការងារ (៦៣% នៃកម្មករឆ្លើយសម្ភាសន៍បានប្រកបរបរខ្លួនឯង មុនពេលចូលមកធ្វើការក្នុងរោងចក្រចិន)។ កម្មកររោងចក្រចិន មានចំណូលជាមធ្យម ច្រើនជាងពីរដងនៃបន្ទាត់ក្រីក្រនៅក្រុងភ្នំពេញ គិតតាមថ្លៃថេរឆ្នាំ២០០៦។ ប៉ុន្តែបរិមាណចំណេញសុទ្ធ តាមការប្រៀបធៀបរវាងការប្រកបរបរខ្លួនឯងពីមុន និងការងារបច្ចុប្បន្ន មិនមែនជាកម្មវត្ថុនៃការសិក្សានេះទេ។

ករណីសិក្សានេះ ក៏បង្ហាញដែរថា ប្រាក់ផ្ញើទៅផ្ទះរបស់កម្មករកាត់ដេរ ត្រូវបានប្រើប្រាស់ជាចំបងសម្រាប់ចំណាយលើអាហារប្រចាំថ្ងៃ និងលើការសិក្សាអប់រំរបស់សមាជិកគ្រួសារ ការសងបំណុល និងការទិញដីកសិកម្ម ហើយទាំងអស់នេះ អាចជួយគ្រួសារឲ្យងើបផុតពីភាពខ្វះខាតក្នុងរយៈពេលខ្លី និងរយៈពេលវែង។ ចំណុចនេះ ឆ្លុះបញ្ចាំងពីទស្សនៈរបស់កម្មករស្តីពីស្ថានភាពសេដ្ឋកិច្ចកាន់តែប្រសើរឡើងរបស់ក្រុមគ្រួសារ ចាប់តាំងពីពួកគេចូលធ្វើការនៅរោងចក្រកាត់ដេរជាអាទិ៍ ពួកគេអាចវិនិយោគក្នុងការទិញដី ទូកប្រើម៉ាស៊ីន និងសត្វចិញ្ចឹម ដើម្បីរកប្រាក់ចំណូលជាទៀងទាត់ ឬបង្កើនប្រភពប្រាក់ចំណូល។ ប៉ុន្តែកម្មករភាគច្រើនបានបង្ហាញពីការមិនពេញចិត្តនឹងបរិយាកាសការងារនៅរោងចក្រ ដូចជា ការថែទាំសុខភាព កន្លែងធ្វើការ អនាម័យ និងការទទួលបានច្បាប់ឈប់សម្រាកប្រចាំឆ្នាំ និងនៅពេលមានជំងឺ។ ឱកាសនិងការគាំទ្រការអភិវឌ្ឍសមត្ថភាពនិងជំនាញ នៅមានកម្រិតទាប ហើយជំនាញ និងចំណេះដឹងដែលពួកគេទទួលបានពីការងារបច្ចុប្បន្ន គឺជាជំនាញមូលដ្ឋានរៀនពីការងារប្រចាំថ្ងៃ។ ដោយឡែក ការផ្ទេរចំណេះដឹង និងជំនាញ គឺជាកង្វះខាតដ៏ធំមួយក្នុងគម្រោងវិនិយោគចិននៅកម្ពុជា ជាពិសេសក្នុងវិស័យកាត់ដេរ។ ទោះបីវិស័យនេះមិនតម្រូវឲ្យមានជំនាញច្រើនក៏ដោយ ក៏ឱកាស និងការគាំទ្រឲ្យមានការអភិវឌ្ឍជំនាញ គួរតែជាសមាសភាគមួយដែលវិនិយោគបរទេសនៅកម្ពុជាត្រូវគោរពតាម។

*ទិដ្ឋភាពជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA)*

ចិនជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់មួយសម្រាប់ការបញ្ជូនមូលនិធិ ក៏ដូចជាការកៀងគរវិនិយោគសម្រាប់កម្ពុជា។ ODA របស់ចិន ដើរតួនាទីយ៉ាងសំខាន់ជាធនធានសាធារណៈបន្ថែម ដោយផ្តល់ហិរញ្ញប្បទានដល់របៀបវារៈអភិវឌ្ឍន៍របស់កម្ពុជា តាមរយៈការគាំទ្រការផ្តល់សេវាសាធារណៈ។ ចិនផ្តល់ជំនួយឲ្យកម្ពុជា ដោយដាក់លក្ខខណ្ឌតិចតួចណាស់ទាក់ទិននឹងតម្លាភាព និងបែបបទនៃវិនិយោគ (Chan Sophal *et al.* 2008) និងមានតាំងពីផ្នែកទំនាក់ទំនងការទូតដល់អន្តរាគមន៍វិនិយោគ និងសេដ្ឋកិច្ច។ ប៉ុន្តែភាគច្រើន ចិនផ្តល់នូវកម្ចីសម្បទាន ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេស ការកសាង និងជួសជុលផ្លូវ។ ការសិក្សានេះ បានពិនិត្យលើការរួមចំណែកនៃគម្រោងចំនួន២ ខាងដឹកជញ្ជូនដែលផ្តល់មូលនិធិដោយ ODA របស់ចិន ចំពោះជីវភាពប្រជាជនមូលដ្ឋាន និងការអភិវឌ្ឍសង្គមកិច្ចរបស់សហគមន៍មូលដ្ឋាន។

វិស័យដឹកជញ្ជូន សំខាន់ជាខ្លាំងសម្រាប់ការអភិវឌ្ឍសហគមន៍មូលដ្ឋាន និងប្រទេសជាតិទាំងមូល។ បើសិនពុំមានលទ្ធភាពចូលទៅដល់ ធនធាន ទីផ្សារ សេវាសុខាភិបាល ការអប់រំ និងសេវាកម្មសង្គមផ្សេងៗទៀតនោះ គុណភាពជីវិតនឹងត្រូវធ្លាក់ចុះ កំណើនត្រូវស្ទឹកគាំង ហើយការកាត់បន្ថយភាពក្រីក្រមិនអាចមានចីរភាពទេ។ ផ្លូវទ្រុឌទ្រោម កាត់បន្ថយតួនាទីដឹកជញ្ជូនក្នុងការជួយសម្រួលដល់ផលិតកម្ម និងសកម្មភាពប្រើប្រាស់។

ការរួមចំណែកនៃគម្រោងផ្តល់មូលនិធិដោយប្រទេសចិន ដើម្បីកែលម្អផ្លូវជាតិលេខ៧ និងសង់ស្ពានព្រែកតាមាក់ ចំពោះការប្រែប្រួលជីវភាព និងការអភិវឌ្ឍសង្គមក្នុងតំបន់គម្រោង ក៏ត្រូវបានពិនិត្យដោយផ្អែកតាមទស្សនៈរបស់ប្រជាជនមូលដ្ឋាន ស្តីពីរយៈពេលនិងថ្លៃធ្វើដំណើរ លទ្ធភាពចូលទៅដល់ទីផ្សារ សេវាសង្គមកិច្ច វិនិយោគ ការអភិវឌ្ឍអាជីវកម្ម សុវត្ថិភាព និងផលប៉ះពាល់ជាយថាហេតុដទៃទៀត។ ករណីសិក្សាទាំងពីរបង្ហាញថា អ្នកភូមិមានចំណាប់អារម្មណ៍ថាពួកគាត់ទទួលបានផលវិជ្ជមានច្រើនជាងផលអវិជ្ជមាន។ សរុបមក ផ្លូវល្អជាងមុន និងស្ពានថ្មី ហាក់ដូចជាធាតុចូលបំពេញបន្ថែមសម្រាប់ការអភិវឌ្ឍ ឬទាក់ទាញទាំងឱកាសរកប្រាក់ចំណូល និងអត្ថប្រយោជន៍មិនមែនប្រាក់ចំណូល ដែលរួមចំណែកលើកកម្ពស់ជីវភាពប្រជាជន វឌ្ឍនភាពសង្គម និងការកាត់បន្ថយភាពក្រីក្រ។

អ្នកឆ្លើយសម្ភាសន៍ក្នុងករណីសិក្សា សង្កត់ធ្ងន់ថា ផ្លូវ និងស្ពាន បានកាត់បន្ថយរយៈពេលធ្វើដំណើរ និងថ្លៃដឹកជញ្ជូនយ៉ាងច្រើន។ លក្ខណៈនេះ នាំឲ្យមានធាតុចូល និងទំនិញប្រើប្រាស់ច្រើនជាងមុន។ កសិផលនៅមូលដ្ឋាន អាចលក់បានថ្លៃខ្ពស់ជាងមុន ដោយសារលទ្ធភាពចូលទៅកាន់ទីផ្សារស្រួលជាងមុន និងមានឈ្មួញកណ្តាលកាន់តែច្រើនចូលមកដល់ភូមិ។ ពិពិធកម្មដំណាំ ជាកត្តាសំខាន់មួយទៀត ដោយសារអ្នកចំណូលថ្មី និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម បាននាំយកព័ត៌មាន និងបច្ចេកទេសថ្មីៗចូលមកក្នុងភូមិ។ ករណីសិក្សា ក៏បានបង្ហាញពីកំណើនការប្រើប្រាស់សេវាអប់រំ និងសុខាភិបាលរបស់អ្នកភូមិ ដោយសារការកែលម្អផ្លូវ ព្រមទាំងអន្តរាគមន៍ផ្សេងៗ ជាអាទិ៍ បុគ្គលិកជំនាញមានឆន្ទៈខ្ពស់ជាងមុនក្នុងការធ្វើការនៅតំបន់អាចចេញចូលបានជានិច្ច និងមានការផ្តល់សម្ភារៈផ្គត់ផ្គង់គួរឲ្យទុកចិត្ត។ លើសពីនេះទៀត ផ្លូវថ្មីលើកទឹកចិត្តឲ្យមានការផ្តល់សេវាជាលក្ខណៈពាណិជ្ជកម្ម។ ឥទ្ធិពលវិជ្ជមានសំខាន់ៗផ្សេងទៀតដែលអ្នកភូមិបានលើកឡើង រួមមានទំនាក់ទំនងជាមួយទីភ្នាក់ងារអភិវឌ្ឍន៍ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងទេសចរ ដែលបង្កើតឱកាសអាជីវកម្ម និងការងារសម្រាប់ប្រជាជនមូលដ្ឋាន។

ការយល់ឃើញថា ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនអាចកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារ មិនមានការបញ្ជាក់គាំទ្រពីប្រជាជនមូលដ្ឋានក្នុងករណីសិក្សាទាំងពីរទេ។ ការកសាង និងថែទាំផ្លូវ ត្រូវប្រើពលកម្មច្រើន ហើយអាចផ្តល់ឱកាសការងារដល់ប្រជាជនមូលដ្ឋាន ទោះជាវាកើតមានយូរៗម្តងក៏ដោយ។ ដូច្នេះ វាមិនអាចជាយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់កាត់បន្ថយភាពក្រីក្រនោះទេ។ សកម្មភាពសាងសង់អនុវត្តតាមកិច្ចសន្យាជាមួយក្រុមហ៊ុនចិន ទាំងសម្ភារៈ បច្ចេកវិទ្យា និងពលកម្ម រួមទាំងកម្មករគ្មានជំនាញផង។ មានតែប្រជាជនប៉ុន្មាននាក់ប៉ុណ្ណោះ ដែលបានការងារធ្វើក្នុងអំឡុងពេលសាងសង់ ហើយបានតែ ២-៣សប្តាហ៍ប៉ុណ្ណោះ។ ការបារម្ភមួយទៀតដែលអ្នកចូលរួមក្នុងការពិភាក្សា និងអាជ្ញាធរមូលដ្ឋាន បានលើកឡើង គឺចាប់តាំងពីផ្លូវបានកែលម្អឡើង ក្រុមហ៊ុនវិនិយោគខាងធនធានរ៉ែ និងចម្ការដំណាំរបស់ចិនជាច្រើន ទទួលបានដី

សម្បទានក្នុងតំបន់ទាំងនោះ ដែលនាំឲ្យមានទំនាស់រវាងអ្នកភូមិនិងក្រុមហ៊ុន ការកាប់ឈើ ការបាត់បង់លទ្ធភាពប្រើប្រាស់ដី និងធនធានព្រៃឈើរបស់អ្នកភូមិ។ ផ្លូវថ្មីក៏មានបញ្ហាសុវត្ថិភាពដែរ ដោយសារមិនមានផ្លាកសញ្ញាគ្រប់គ្រាន់។ អំពើចោរកម្មក្នុងភូមិ ក៏បានកើនឡើងដែរ។

អ្នកលក់ដូរតូចតាចនៅក្បែរកំពង់ចម្លងក្នុងអំឡុងពេលធ្វើអង្កេត នឹងត្រូវបាត់បង់ប្រភពចំណូលបន្ថែមរបស់ខ្លួន នៅពេលស្ពានបើកដំណើរការ ទោះបីជាពួកគេមានអារម្មណ៍សុទិដ្ឋិនិយមពីការមានស្ពានក៏ដោយ។

## ៦.២ ការពិភាក្សាខាងគោលនយោបាយ

ការពិភាក្សាក្នុងផ្នែកមុន គូសបញ្ជាក់នូវលទ្ធផលសំខាន់ៗបានពីការវិភាគលើទិដ្ឋភាពពាណិជ្ជកម្ម វិនិយោគ និង ODA របស់ចិន ជាមួយនឹងផលប៉ះពាល់នានាទាក់ទងនឹងភាពក្រីក្រ។ ដើម្បីទទួលបានលទ្ធផលកាន់តែល្អប្រសើរ យើងគួរពិចារណាពីជំហានខ្លះៗថែមទៀត។

*ផ្នែកពាណិជ្ជកម្ម*

លទ្ធផលរកឃើញជាក់ស្តែង បង្ហាញច្បាស់ថា ការពង្រឹងទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគឲ្យកាន់តែស៊ីជម្រៅជាមួយចិន អាចរួមចំណែកជួយកាត់បន្ថយភាពក្រីក្រនៅកម្ពុជា តាមរយៈការបង្កើតការងារក្នុងវិស័យអតិពលកម្ម និងការនាំចូលទំនិញប្រើប្រាស់ពីចិនសម្រាប់អ្នកក្រ ក្នុងលក្ខណៈជាផលិតផលបំពេញបន្ថែមឲ្យទីផ្សារក្នុងស្រុក។ ដើម្បីរួមចំណែកបានកាន់តែប្រសើរក្នុងការកាត់បន្ថយភាពក្រីក្រ ត្រូវអនុវត្តជំហាននានាដូចតទៅ៖

- ទាញផលចំណេញពីឱកាសនាំចេញផលិតផលកសិកម្មអតិពលកម្មដែលកម្ពុជាមានជំនាញ ដូចជា ត្រី សត្វចិញ្ចឹម ស្រូវ កៅស៊ូ និងផលិតផលកម្មន្តសាលធុនស្រាល ដោយប្រើប្រព័ន្ធអនុគ្រោះទទួលបានពីប្រទេសចិន ក្រោមក្របខ័ណ្ឌនៃ ACFTA ដែលអាចជួយកាត់បន្ថយឱនភាពជញ្ជីងពាណិជ្ជកម្ម និងជំរុញការកាត់បន្ថយភាពក្រីក្រ។
- ជំរុញ និងបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុពាណិជ្ជកម្មសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ដោយសារពួកគេចូលរួមដោយប្រយោលក្នុងសកម្មភាពនាំចេញ។
- ជំរុញផលិតផលកសិកម្មកម្ពុជា តាមរយៈពិពណ៌ពាណិជ្ជកម្ម ឬបេសកកម្មពាណិជ្ជកម្មទៅចិន។
- បញ្ចុះបញ្ចូលផលិតករសម្លៀកបំពាក់ចិន ឲ្យប្រើប្រាស់ធាតុចូលផលិតដោយផលិតករនៅកម្ពុជា ឬបង្កើតទំនាក់ទំនងដើមខ្សែនៃឧស្សាហកម្មកម្ពុជា។
- លើកទឹកចិត្ត និងគាំទ្រផលិតករក្នុងស្រុក ឲ្យចូលរួមក្នុងផ្នែកទំនាក់ទំនងដើមខ្សែនៃឧស្សាហកម្មកាត់ដេរ។
- អនុម័តប្រើប្រព័ន្ធគយប្រើកុំព្យូទ័រ ដើម្បីកាត់បន្ថយចំនួនឯកសារ ចំនួនហត្ថលេខា និងចំណាយក្រៅផ្លូវការ តួយ៉ាងដូចជា ប្រព័ន្ធ ASYCUDA នៅកំពង់ផែក្រុងព្រះសីហនុ ដែលនឹងកាត់បន្ថយភាពមិនអាចប៉ាន់ស្មានបាន និងបង្កើនទំនុកចិត្តរបស់វិនិយោគិន។

*ផ្នែកវិនិយោគ*

ភាពសម្បូរទៅដោយធនធានធម្មជាតិ ឈើ សក្តានុពលរ៉ែនិងវារីអគ្គិសនី ធនធានប្រេងកាត ព្រមទាំងថ្លៃពលកម្មទាប ធ្វើឲ្យកម្ពុជាអាចទាក់ទាញវិនិយោគ និងជំនួយអភិវឌ្ឍន៍របស់ចិន និងទទួលបានតវិយាបថវិជ្ជមានពីចិន។ ដូចបានពិនិត្យឃើញក្នុងករណីសិក្សាលើវិស័យកាត់ដេរ វិនិយោគរបស់ចិន មានផលប៉ះពាល់វិជ្ជមានទៅលើការងារ និងការបង្កើតប្រាក់ចំណូល ប៉ុន្តែមិនមែនលើការអភិវឌ្ឍជំនាញនោះទេ។ បញ្ហាសំខាន់ គឺក្នុងទំនាក់ទំនងស្អិតរមួតនេះ តើអត្ថប្រយោជន៍បានពីវិនិយោគរបស់ចិន ហូរចូលក្នុងវិស័យក្នុងស្រុកបានកម្រិតណា។ ដូច្នេះត្រូវមានអន្តរាគមន៍ខាងគោលនយោបាយ ដើម្បីបង្កើត

លក្ខខណ្ឌចាំបាច់សម្រាប់ការហូរចូលជាវិជ្ជមាន និងទាក់ទាញវិនិយោគចិន និងបរទេសផ្សេងទៀតមកក្នុងវិស័យទាំងឡាយដែលមានសក្តានុពលក្នុងការផ្ទេរជំនាញ និងបច្ចេកវិទ្យា ហើយនាំឲ្យមានគំនិតកែប្រែបែបថ្មី កំណើនផលិតភាព ការលើកកម្ពស់គុណភាពនិងផលិតកម្មក្នុងស្រុក និងទំនាក់ទំនងដើមខ្សែ និងចុងខ្សែនៃផលិតកម្មក្នុងស្រុក។

*ផ្នែកជំនួយអភិវឌ្ឍន៍ផ្លូវការ*

ក្រៅពីផលប៉ះពាល់ជាវិជ្ជមាននៃផ្លូវល្អ និងស្ពានថ្មីនោះ សកម្មភាពមួយចំនួនទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ក៏គួរគិតគូរពិចារណាផងដែរ ដូចជា៖

- ពិពិធកម្ម និងការបង្កើនឱកាសដោះស្រាយជីវភាព សម្រាប់អ្នកដើរលក់ឥវ៉ាន់ និងអាជីករមួយចំនួន ដែលនឹងត្រូវបាត់បង់ប្រាក់ចំណូលពីការធ្វើអាជីវកម្មនៅកំពង់ចម្លង និងអ្នកដែលបានបាត់បង់លទ្ធភាពប្រើប្រាស់ដី និងធនធានព្រៃឈើ។
- ការផ្សព្វផ្សាយណែនាំពីព័ត៌មានចរាចរណ៍ និងការយល់ដឹងពីសុវត្ថិភាពតាមដងផ្លូវ ទៅដល់អ្នកភូមិតាមរយៈក្រុមប្រឹក្សាឃុំ។
- ការចរចាជាមួយរដ្ឋាភិបាលចិន ឲ្យមានការជួលកម្លាំងពលកម្មកម្ពុជា ក្នុងគម្រោង ODA របស់ចិន ដើម្បីជំរុញការផ្ទេរបច្ចេកវិទ្យា និងជំនាញដល់កម្ពុជា។
- ការលើកស្ទួយកម្មវិធីកសាងសមត្ថភាពនៅកម្រិតមូលដ្ឋាន គួរតែជាលក្ខខណ្ឌមួយសម្រាប់ឲ្យគម្រោង ODA របស់ចិនគោរព និងអនុវត្តតាម។

*ការស្រាវជ្រាវនាពេលអនាគត*

ដោយសារការសិក្សានេះនៅមានកម្រិត ដូច្នេះគួរមានការវិភាគជាក់ស្តែងឲ្យកាន់តែច្រើន និងស៊ីជម្រៅ អំពីទំនាក់ទំនងរវាងវិនិយោគបរទេស និងការកាត់បន្ថយភាពក្រីក្រ និងអំពីគោលគំនិតនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការកាត់បន្ថយភាពក្រីក្រសម្រាប់ប្រទេសកម្ពុជា ទាំងកម្រិតម៉ាក្រូ និងកម្រិតមីក្រូ។

# ឯកសារយោង

Carl, Middleton & Sam, Chanthy (2008), "Cambodia's Hydropower Development and China's Involvement" (Phnom Penh: RCC)

CDC (2007, 2008 & 2009), "The Cambodia Aid Effectiveness Report" (Phnom Penh: CDC)

CDRI (2008), Impact of High Food Prices in Cambodia, Survey Report (Phnom Penh: CDRI)

Chan, Sophal, Mangahas, Joel, Pham Thi, Thanh An & Wood, Bernard (2008), Cambodia Evaluation of Aid Effectiveness, Final Report

Chin, T, Gregory & B. Michael, Frolic (2007), "Emerging Donors in International Development Assistance: The China Case", (PBDD: Partnership & Business Development Division, York University)

Coudouel, Aline, Hentschel, Jesko S., Wodon, Quentin T. (2002), Poverty Measurement and Analysis (Washington: World Bank)

Crespo, Nuno & Paula Fontoura, Maria (ND), Determinant Factors of FDI Spill-overs: What Do We Really Know? ISEG-Universidade Techica de Lisboa

Cuyvers, Ludo, Soeng, Reth & Bulcke, Daniel Van Den (2006), Foreign Direct Investment of Least Developed Countries: The Case of Cambodia's Textile, Garment, Furniture, Transportation and Tourism Industries, CAS Discussion Paper No. 09

Cuyvers, Ludo, Plasmans, Joseph, Soeng, Reth & Bulcke, Daniël Van Den (2008), Determinants of Foreign Direct Investment in Cambodia: Country-Specific Factor Differentials, University of Antwerp

Ek Madra (2010), China Signs Agreements with Cambodia to Boost Investment, March 18 (http://www.dap-news.com/en/news/582-china-signs-agreements-with-cambodia-to-boost-investment.html)

Hem, Socheth, Tong, Kimsun & Ker, Bopha (2009), Maximising Opportunities of Chinese Investment in Natural Resources in Cambodia (Phnom Penh: CDRI, forthcoming)

Hettige, Hemamala, Martin, Paul, Singh, Manjula & Wheeler, David (1995), The Industrial Pollution Projection System, World Bank Policy Research Working Paper No. 1431

Hing, Vutha & Hossein, Jalilian (2008), Environmental Impacts of the ASEAN-China Free Trade Agreement on the Greater Mekong Sub-Region (Canada: IISD)

Hing, Vutha & Nou, Keosothea (2006), The Early Harvest Programme: Implications for Cambodian Agriculture, Special Report No. 4 (Phnom Penh: CDRI)

Humphrey, John & Hubert Schmitz (2007), China: Its Impact on the Developing Asian Economies, Working Paper 295 (Brighton, UK: Institute of Development Studies)

Jenkins, Rhys & Chris Edwards (2004), How Does China's Growth Affect Poverty Reduction in Asia, Africa and Latin America? Expanded Report to DFID (Norwich: University of East Anglia)

Jenkins, Rhys, Enrique Dussel Peters & Mauricio Mesquita Moreira (2007), The Impact of China on Latin America and the Caribbean, *World Development*, Vol. 36, No.2, pp. 235-253

Kaplinsky, Raphael & Messner, Dirk (2007), Introduction: The Impact of Asian Drivers on the Developing World, *World Development*, Vol. 36, No. 2, pp.197-209

Kheang, Un (ND), China's Foreign Investment and Assistance: Implications for Cambodia's Development and Democratization

L. Alan, Neil & Andrew (2004), Trade Liberalisation and Poverty: The Evidence So Far, Journal of Economic Literature Vol. XLII, pp. 72-115

Ludo, Joseph, Reth & Daniel (2008), Determinants of Foreign Direct Investment in Cambodia: Country-Specific Factor Differentials, University of Antwerp

Ludo, Reth & Daniel (2006), Foreign Direct Investment and Development of Least Developed Countries: The Case of Cambodia's Textile, Garment, Furniture, Transportation and Tourism Industries, CAS Discussion Paper No.49, CAS & CIMDA

Ludo, Reth, Joseph & Daniel (2008), Productivity Spillovers from Foreign Direct Investment in the Cambodian Manufacturing Sector: Evidence from Establishment-Level Data, University of Antwerp

Martyn, Davies (2008), "How China Delivers Development Assistance to Africa", Centre for Chinese Studies, University of Stellenbosch

Matthew, Coghlan (2007), China's Poverty Footprint in Cambodia (Phnom Penh: OGB)

Menon, Jayant (2005), "Building Blocks or Stumbling Blocks? Regional Cooperation Arrangements in Southeast Asia", *ADB Institute Discussion Paper No.41* (Tokyo: Asian Development Bank Institute)

Neak, Samsen & Yem, Sokha (2006), Trade and Poverty Link: The Case of the Cambodian Garment Industry, (Phnom Penh: EIC)

Ngaire, Woods (2008), "Whose aid? Whose influence? China, Emerging Donors and the Silent Revolution in Development Assistance", The Royal Institute of International Affairs

Ngo, Ngoun Theary (2007), *Extractive Industry Transparency Initiative in Cambodia*, *Cambodia Development Watch*, Vol. 3, No. 2, pp.7-10 (Phnom Penh: NGO Forum on Cambodia)

Nuno, Crespo & Maria, Paula Fontoura (ND), Determinant Factors of FDI Spill-overs: What Do We Really Know? ISEG-Universidade Techica de Lisboa

OECD (2008), China's Outward Direct Investment, OECD Investment Policy Reviews: China 2008

Okamoto, Yumiko (2005), China and India: Challenges and Opportunities for ASEAN from Japanese Perspectives (Kyoto: Doshisha University)

Phou, Sambath (ND), "Cambodia-China Relation: Past, Present and Future", PhD Student, IIMBA

Raphael & Dirk (2008), Introduction: The Impact of Asian Drivers on the Developing World, World Development Vol. 36, No. 2, pp. 197-2009

Renato, Maria & Rogerio (2002), Foreign Direct Investment Spillovers: Additional Lessons from a Country Study

Rhys, Enrique & Mauricio (2008), The Impact of China on Latin America and the Caribbean, *World Development*, Vol. 36 No. 2, pp. 235-253

Rutherford, Jeff, Lazarus, Kate & Kelley, Shawn (2008), Rethinking Investment in Natural Resources: China's Emerging Role in the Mekong Region (Phnom Penh: HBSC)

Saing, Chan Hang (2009a), Export Competitiveness of the Cambodian Rubber Sector Relative to other Greater Mekong Sub-region Suppliers: A Simple Descriptive Analysis, ARTNeT-GMS Discussion Paper No.1

Saing, Chan Hang (2009b), Impacts of the Global Financial Crisis on Garment Workers and Remittances: Lesson from Cambodia, ARTNeT-GMS Notes No.3

Sandra, Poncet (2007), Inward and Outward FDI in China, (University Paris 1 CNRS and CEPII)

Saw, Sheng & Chin (2005), ASEAN-China Relations: Realities and Prospects, Institute of Southeast Asian Studies, Singapore

Sida (2007), Understanding Rural Poverty in Cambodia, Country Economic Report 2007:1 (Phnom Penh: Sida)

Setboonsarng, Sununtar (2006), Transport Infrastructure and Poverty Reduction, ADBI Research Policy Brief No.21 (ADBI: Tokyo)

SOFRECO & CEDAC (2005), Study on the Evolution of the Cambodian Rubber Sector, Draft report (Clichy-Cedex France and Phnom Penh)

Tong, Kimsun & Hem, Socheth (2009), China's Investment in Cambodia (Phnom Penh: CDRI)

UNDP & MOC (2007), Cambodia's 2007 Trade Integration Strategy: Executive Summary and Action Matrix (Phnom Penh: UNDP)

USAID (2007), Factory-Level Value Chain Analysis of Cambodia's Apparel Industry (Phnom Penh: USAID)

USAID (2006), Cambodia Garment Industry Workforce Assessment: Identifying Skill Needs and Sources of Supply (Phnom Penh: USAID)

USAID (2005), Measuring Competitiveness and Labor Productivity in Cambodia's Garment Industry (Phnom Penh: USAID)

Winters, L. Alan, McCulloch, Neil & McKey, Andrew (2004), Trade Liberalisation and Poverty: The Evidence So Far, Journal of Economic Literature Vol. XLII, pp. 72-115

World Bank (2009a), Sustaining Rapid Growth in a Challenging Environment, Cambodia Country Economic Memorandum (Phnom Penh: World Bank)

______ (2009b), Poverty Profile and Trend in Cambodia: Findings from the 2007 Cambodia Socio-Economic Survey (Washington: World Bank)

______ (2008), Handbook of Poverty Analysis (Washington: World Bank)

______ (2007), Cambodia: Sharing Growth, Equity and Development Report 2007 (Phnom Penh: World Bank)

______ (2006), Cambodia: Halving Poverty by 2015? (Phnom Penh: World Bank)

______ (2004), Cambodia at the Crossroads: Strengthening Accountability to Reduce Poverty (Phnom Penh: World Bank)

Wu, Hsiu-Ling & Chien-Hsun Chen (2001), "An Assessment of Outward Foreign Direct Investment from China's Transitional Economy", *Europe-Asia Studies*, Vol. 53, No. 8 (Glasgow: Central and East European Studies) pp. 1235-1254

Yamagata, Tatsufumi (2006), The Garment Industry in Cambodia: Its Role in Poverty Reduction Through Export-Oriented Development, IDE Discussion Paper No. 62 (Chiba: JETRO)

Yamagata, Tatsufumi (2007), Prospects for Development of the Garment Industry in Developing Countries: What Has Happened Since the MFA Phase-Out? IDE Discussion Paper No. 101 (Chiba: JETRO)

Yu, Ching Wong & Charles, Adams (2002), Trends in Global and Regional Foreign Direct Investment Flows, Regional Office for Asia and the Pacific International Monetary Fund

Zhu, Zhenming (ND), "China's Economic Aid to CLMV and Its Economic Cooperation with Them"

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១៖ ការបែងចែកផលិតផលលេខ ៣ខ្ទង់របស់ SITC ទៅតាមក្រុមអ្នកប្រើប្រាស់ និងក្រុមផលិតកម្ម* ( Jenkins and Edwards 2004:38 )

*ក្រុមផលិតកម្ម*

១. ផលិតផលកសិកម្មអតិពលកម្ម -- 037; 042; 05; 06; 07; 231; 232

២. ផលិតផលកសិកម្មផ្សេងទៀត -- 00; 01; 02; 034; 035; 036; 04 ( -042 ); 08; 09;12; 21; 22; 26

៣. ផលិតផលព្រៃឈើ -- 24; 25

៤. ឥន្ធនៈ និង រ៉ែ -- 233; 266; 27; 28; 32; 33; 34; 35; 68

៥. សម្លៀកបំពាក់ និងវាយនភណ្ឌអតិពលកម្ម -- 65; 84

៦. ទំនិញកម្មន្តសាលអតិពលកម្មផ្សេងទៀត -- 269; 61; 63; 665; 666; 821; 831; 851; 89 ( -896 និង 897 )

៧. ទំនិញកម្មន្តសាលផ្សេងទៀត -- 11; 51; 52; 53; 54; 55; 56; 58; 59; 62; 64; 66 ( -665 និង 666 ); 67; 69; 71; 72; 73; 74; 75; 76; 77; 78; 79; 812; 87; 88; 896; 897; 9

*ក្រុមផលិតផលប្រើប្រាស់*

ផលិតផល SITC ខាងក្រោមនេះ ត្រូវបានកំណត់ថាជាផលិតផលតែងប្រើប្រាស់ដោយក្រុមអ្នកមានចំណូលទាប។ ផលិតផលទាំងនេះ រួមមាន ម្ហូបអាហារ ភេសជ្ជៈ ថ្នាំជក់ សម្លៀកបំពាក់ និងស្បែកជើង។ 00; 01; 02; 03; 04; 05; 06; 07; 09; 11; 12; 269; 84; 851

* *ការប្រើចំណាត់ថ្នាក់លេខ ២ខ្ទង់ របស់ SITC មានន័យថា រាល់មុខផលិតផលលេខ ៣ខ្ទង់ដែលនៅក្នុងក្រុមចំណាត់ថ្នាក់លេខ២ខ្ទង់នោះ ត្រូវបានរាប់បញ្ចូលក្នុងក្រុមផលិតផលលេខ ២ខ្ទង់នោះ។*

ឧបសម្ព័ន្ធ ២៖ ចំណែកនៃផលិតផលនាំចេញនិងនាំចូលពីចិន (១៩៩២-២០០៨) នៅកម្រិតលេខ ៣ខ្ទង់

តារាង ២.១៖ ចំណែកនៃផលិតផលនាំចេញទៅចិន (១៩៩២-២០០៨) នៅកម្រិតលេខ ៣ខ្ទង់

| SITC 3 | ឈ្មោះផលិតផល | 1992 | 2000 | 2007 | 2008 |
|---|---|---|---|---|---|
| 001 | សត្វរស់ក្រៅពីត្រី | | 0.3522 | 2.0122 | 6.2231 |
| 012 | សាច់ ស្រស់/ត្រាំទឹកកក/បង្កក | | 0.001 | | |
| 034 | ត្រី រស់/ស្រស់/ត្រាំទឹកកក/បង្កក | | 0.7799 | 1.6226 | 1.2503 |
| 036 | សត្វវង្គ(ក្តាម បង្កង) សិប្បសត្វ (ខ្យង គ្រំ) ជាដើម | | 1.0249 | 0.672 | 0.9446 |
| 037 | ត្រី/ សត្វវង្គ(ក្តាម បង្កង) ឬសិប្បសត្វ (ខ្យង គ្រំ) កែច្នៃ/រក្សាទុក | | | 0.1935 | |
| 042 | ស្រូវ | | | | 0.0005 |
| 054 | បន្លែ ស្រស់/ត្រាំទឹកកក/បង្កក | | 0.0047 | | |
| 057 | ផ្លែឈើ/គ្រាប់ផ្លែឈើ ស្រស់/ស្ងួត | 16.833 | | | |
| 058 | ផ្លែឈើរក្សាទុក/ផ្លែឈើកែច្នៃ | | 0.0057 | | |
| 059 | ទឹកដមបន្លែ/ទឹកដមផ្លែឈើ | | | 0.0358 | 0.0248 |
| 112 | វត្ថុរាវមានជាតិស្រវឹង | | | | 0.0101 |
| 222 | គ្រាប់ដែលមានជាតិប្រេង ជាដើម-ប្រេងរាវ | | | 0.0381 | |
| 231 | កៅស៊ូធម្មជាតិ/ជ័រឈើ ជាដើម | 34.551 | 9.0992 | 21.569 | 29.606 |
| 246 | កាកសំណល់/ចំណាំងឈើ | | | | 0.7213 |
| 247 | ឈើមិនទាន់ច្នៃ/ឈើឡាំង | | 0.5677 | 31.605 | 13.027 |
| 248 | ឈើច្នៃធម្មតា | | 2.1666 | 15.452 | 13.669 |
| 269 | សម្លៀកបំពាក់ចាស់ៗ ជាដើម | | | 2.6466 | 3.1204 |
| 273 | ថ្ម/ដីខ្សាច់/ថ្មអាចម៍ផ្កាយ | | | 0.0141 | 0.066 |
| 282 | កំទេច/កាកសំណល់ដែលមានជាតិដែក | | | | 0.2571 |
| 287 | រ៉ែលោហធាតុធម្មតា | | | 0.0074 | |
| 292 | វត្ថុធាតុជាបន្លែឆៅ ដែលពុំបានចែងនៅកន្លែងផ្សេង | 14.455 | | 0.0803 | 0.0159 |
| 335 | ផលិតផលកាកសំណល់ប្រេង | | | 0.0001 | |
| 524 | ផលិតផលគីមីអសរីរាង្គផ្សេងៗ | | | | 0.0001 |
| 541 | ផលិតផលឱសថ និង សារជាតិឱសថ | | | 0.0001 | |
| 542 | ថ្នាំពេទ្យ រួមទាំងផ្នែកបសុពេទ្យ | | | 0.0125 | |
| 551 | ប្រេងចំរាញ់/ទឹកអប់/គ្រឿងទេស | | | 3.6379 | 0.3337 |
| 581 | ទីប ទុយោ ធ្វើពីប្លាស្ទិក | | | | 0.001 |
| 598 | ផលិតផលគីមីផ្សេងទៀត ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.0010 | | |
| 611 | ស្បែកសត្វ | | | 0.0042 | 0.0336 |
| 634 | សន្លឹករនៀរ/ក្តារបន្ទះ ជាដើម | | 79.439 | 0.0506 | |
| 635 | ផលិតផលឈើ ដែលពុំបានចែងនៅកន្លែងផ្សេង | | 2.3286 | 0.043 | 0.2263 |
| 641 | ក្រដាស/ក្រដាសកាតុង | | 0.0001 | | |

| | | | | | |
|---|---|---|---|---|---|
| 642 | ផលិតផលធ្វើពីម្សៅក្រដាស/ក្រដាសកាតុង/ក្រដាស ដែលកាត់រួច | | | 0.0003 | |
| 651 | អំបោះវាយនភណ្ឌ | | | 8.5324 | 1.2187 |
| 652 | ក្រណាត់ត្បាញពីកប្បាស ឬសំឡី | | | 0.843 | 0.0374 |
| 653 | ក្រណាត់ត្បាញសំយោគ ឬសិប្បនិម្មិត | | 0.003 | 0.2308 | 0.0458 |
| 654 | ក្រណាត់ត្បាញវាយនភណ្ឌ ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.0001 | 0.1738 | |
| 655 | ក្រណាត់ចាក់ ( ដោយម្ជុលមួយ ឬពីរ ) | | | 0.7581 | 0.2251 |
| 656 | គ្រឿងស្បៃ/គ្រឿងជរ/គ្រឿងប៉ាក់/គ្រឿងតម្រឹម | | | 0.0332 | 0.0076 |
| 657 | ក្រណាត់/សរសៃអំបោះពិសេស | | 0.0001 | 0.0196 | 0.0462 |
| 658 | របស់របរវាយនភណ្ឌដេរស្រាប់ | 3.2624 | | 0.0016 | |
| 661 | ផលិតផលស្បែកសម្លាប់ | | 0.0002 | 0.0014 | 0.0045 |
| 664 | កែវ | | | | 0.0003 |
| 665 | វត្ថុធ្វើអំពីកែវ | | | | 0.0005 |
| 666 | កុម្ភការភណ្ឌ | | | 0.0053 | 0.0277 |
| 667 | ត្បូងថ្មមានតម្លៃ/គុជ | | | 0.0016 | |
| 679 | ទីប ទុយោដែក/ដែកថែប ជាដើម | | | | 0.0004 |
| 694 | ដែកគោល/វីស/ទ្រនាប់ប៊ូឡុង/ប៊ូឡុង | | 0.0007 | | 0.0008 |
| 697 | ឧបករណ៍ទ្រ | | | | 0.0003 |
| 699 | ផលិតផលធ្វើពីលោហធាតុ | | 0.0003 | | 0.006 |
| 716 | គ្រឿងចក្រអគ្គិសនីដោយបង្វិល | | | 0.001 | |
| 718 | ឧបករណ៍ផលិតថាមពល | 6.3992 | | | |
| 723 | គ្រឿងចក្រសម្រាប់វិស្វកម្មស៊ីវិល | | | | 0.0144 |
| 724 | ម៉ាស៊ីនសម្រាប់វាយនភណ្ឌ/ស្បែកសម្លាប់ | | 0.0036 | | |
| 728 | ម៉ាស៊ីនសម្រាប់ឧស្សាហកម្មពិសេស | | | | 0.0009 |
| 742 | ស្នប់ ឬម៉ាស៊ីនមូលសម្រាប់វត្ថុរាវ | | | | 0.0022 |
| 744 | ឧបករណ៍មេកានិកសម្រាប់លើកដាក់ | 6.009 | | | |
| 747 | ក្បាលម៉ាស៊ីនទឹក/ក្បាលមាន់ ឬប្រដាប់បិទបើកទឹក/ស៊ូបាប់ ឬវ៉ាល់ | | | | 0.0007 |
| 752 | ឧបករណ៍កុំព្យូទ័រ | | | | 0.0045 |
| 763 | ម៉ាស៊ីនថតទូរទស្សន៍/សំឡេង ជាដើម | | | | 0.0002 |
| 764 | ឧបករណ៍ទូរគមនាគមន៍ ដែលពុំបានចែងនៅកន្លែងផ្សេង | | | 0.0102 | 0.0059 |
| 771 | ឧបករណ៍បញ្ជូនថាមពលអគ្គិសនី | | | | 0.0017 |
| 772 | ឧបករណ៍សៀគ្វីអគ្គិសនី | | | 0.0004 | 0.0405 |
| 776 | ស៊ូបាប់ ឬវ៉ាល់/គ្រង់ស៊ីស្ទ័រ ជាដើម | | | 0.0024 | 0.001 |
| 778 | ឧបករណ៍អគ្គិសនី ដែលពុំបានចែងនៅកន្លែងផ្សេង | 18.491 | | | 0.0015 |
| 784 | គ្រឿងបន្ទាប់បន្សំ/ភាគនៃរថយន្ត | | | 0.0001 | |

| | | | | | |
|---|---|---|---|---|---|
| 785 | ទោចក្រយានយន្ត/ទោចក្រយាន ជាដើម | | | 0.0016 | |
| 813 | គ្រឿងបំពាក់បំភ្លឺ ជាដើម | | | | 0.0002 |
| 821 | គ្រឿងសង្ហារឹម/វត្ថុប្រហាក់ប្រហែលផ្សេងទៀត | | | 0.1683 | 0.8679 |
| 831 | ហិប និងវ៉ាលី | | | 0.001 | |
| 841 | សម្លៀកបំពាក់ត្បាញសម្រាប់ក្មេងប្រុស/បុរស | | 4.1851 | 1.1544 | 5.0744 |
| 842 | សម្លៀកបំពាក់ត្បាញសម្រាប់ក្មេងស្រី/ស្ត្រី | | | 0.3848 | 0.6723 |
| 843 | អាវសឺមិសម្រាប់បុរសក្មេងប្រុស ដែលចាក់ដោយម្ជុល | | | 1.4856 | 1.793 |
| 844 | អាវសឺមិសម្រាប់ស្ត្រីក្មេងស្រី ដែលចាក់ដោយម្ជុល | | | 1.0931 | 2.0472 |
| 845 | សម្លៀកបំពាក់ប្រហាក់ប្រហែល ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.0000 | 4.6233 | 17.022 |
| 846 | គ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់ | | 0.0206 | 0.0031 | 0.004 |
| 848 | ក្រណាត់មិនមែនវាយនភណ្ឌ/គ្រឿងសម្រាប់ពាក់លើក្បាល | | 0.0003 | 0.0009 | 0.0007 |
| 851 | ស្បែកជើង | | | 0.5635 | 0.9043 |
| 874 | ឧបករណ៍សម្រាប់វាស់/ពិនិត្យមើល ដែលពុំមានចែងនៅកន្លែងផ្សេង | | | 0.0014 | 0.0016 |
| 885 | គ្រឿងនាឡិកា | | 0.0126 | | |
| 892 | ឯកសារបោះពុម្ព | | 0.0013 | 0.0328 | |
| 893 | វត្ថុធ្វើពីជាតិប្លាស្ទិក ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.001 | 0.0363 | 0.0575 |
| 894 | វត្ថុចាំបាច់សម្រាប់កីឡា/ល្បែង/ប្រដាប់ប្រដារក្មេងលេង/រទេះកូនក្មេង | | | | 0.0007 |
| 897 | គ្រឿងអលង្ការ | | | 0.0011 | |
| 898 | ឧបករណ៍ភ្លេង/ថាស | | | 0.0026 | |
| 899 | ស្នាដៃវត្ថុផ្សេងៗ ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.0007 | 0.135 | 0.3296 |

ប្រភព៖ UN ComTrade 2009

កំណត់សម្គាល់៖ ចំណែកនៃការនាំចេញទៅប្រទេសចិន ធៀបនឹងការនាំចូលសរុបទៅប្រទេសចិន

តារាង ២.២៖ ចំណែកនៃផលិតផលនាំចូលពីចិន (១៩៩២-២០០៨) នៅកម្រិតលេខ ៣ខ្ទង់

| SITC 3 | ឈ្មោះផលិតផល | 1992 | 2000 | 2007 | 2008 |
|---|---|---|---|---|---|
| 001 | សត្វរស់ លើកលែងត្រី | | | | 0.00952 |
| 016 | សាច់/សំណល់សាច់ រក្សាទុក | | 0.00055 | | |
| 017 | សាច់/សំណល់សាច់រក្សាទុក ដែលពុំបានចែងនៅកន្លែងផ្សេង | 0.08425 | | 0.00095 | |
| 022 | ទឹកដោះរៀបចំច្នៃ លើកលែងប៊ឺរ/ហ្ស្រម៉ាស | | 0.04319 | 0.00007 | |
| 025 | ស៊ុតសត្វស្លាប អាល់ប៊ុយមីន | | 0.00018 | | |
| 034 | ត្រី រស់/ស្រស់/ត្រាំទឹកកក/បង្កក | | 0.00007 | | |
| 036 | សត្វវង្គ(ក្តាម បង្កង) សិប្បសត្វ (ខ្យង គ្រុំ) ជាដើម | | 0.00005 | | |
| 037 | ត្រី/ សត្វវង្គ(ក្តាម បង្កង) ឬសិប្បសត្វ (ខ្យង គ្រុំ) កែច្នៃ/ រក្សាទុក | | 0.00236 | 0.02132 | 0.04885 |
| 042 | ស្រូវ | | 0.00827 | | |
| 048 | គ្រាប់ធញ្ញជាតិ/ម្សៅ | | 0.0134 | 0.09388 | 0.337 |
| 054 | បន្លែ ស្រស់/ត្រាំទឹកកក/បង្កក | | 0.00068 | 0.01321 | 0.00087 |
| 056 | មើម/ឬសបន្លែ កែច្នៃ/រក្សាទុក | 0.01262 | 0.14422 | 0.09495 | 0.03198 |
| 057 | ផ្លែឈើ/គ្រាប់ផ្លែឈើ ស្រស់/ស្ងួត | | 0.07736 | 0.0162 | 0.0539 |
| 058 | ផ្លែឈើរក្សាទុក/ផ្លែឈើកែច្នៃ | | 0.02109 | 0.03298 | |
| 061 | ជាតិស្ករ/រង្វូ/ទឹកឃ្មុំ | 1.84029 | 0.00543 | 0.01187 | 0.00014 |
| 062 | សារជាតិផ្អែម/ស្ករដុំ | 0.09468 | 0.023 | 0.10214 | 0.09587 |
| 071 | កាហ្វេ/វត្ថុជំនួសកាហ្វេ | | 0.00829 | | |
| 074 | តែ និង ម៉ាតេ | | | | 0.00323 |
| 075 | គ្រឿងទេស | | 0.00299 | | |
| 081 | ចំណីសត្វ | | 0.02587 | 0.00085 | 0.00591 |
| 091 | ម៉ាការីន/ប៊ឺរ | | | 0.00718 | 0.00416 |
| 098 | ផលិតផលសម្រាប់ហូប ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.31752 | 0.09061 | 0.04174 |
| 111 | វត្ថុរាវគ្មានជាតិស្រវឹង ដែលពុំបានចែងនៅកន្លែងផ្សេង | 0.66259 | 0.10683 | 0.03698 | 0.06718 |
| 112 | វត្ថុរាវមានជាតិស្រវឹង | 0.30194 | 0.09179 | 0.89364 | 1.03233 |
| 121 | ថ្នាំជក់ ឆៅ និងកាកសំណល់ | | 0.55311 | 0.34514 | 0.133 |
| 122 | ថ្នាំជក់ដែលផលិតរួច | | 3.83837 | 0.46196 | 0.28224 |
| 222 | គ្រាប់ដែលមានជាតិប្រេង ជាដើម-ប្រេងរាវ | | | 0.0023 | |
| 223 | គ្រាប់ដែលមានជាតិប្រេង ជាដើម-ប្រេងមិនរាវ | | | 0.001 | |
| 231 | ជ័រ/កៅស៊ូធម្មជាតិ ជាដើម | | 0.00197 | | |
| 232 | សំណល់កៅស៊ូសំយោគ ជាដើម | | 0.0003 | 0.00013 | 0.01169 |
| 248 | ឈើច្នៃធម្មតា | | 0.00011 | 0.00664 | 0.00406 |
| 251 | ម្សៅឈើ និងសំណល់ក្រដាស | | | 0.00281 | 0.00947 |

| | | | | | |
|---|---|---|---|---|---|
| 266 | សរសៃអំបោះសំយោគ | | | 0.00168 | 0.00855 |
| 269 | សម្លៀកបំពាក់ចាស់ៗ ជាដើម | | | 0.00372 | 0.009 |
| 272 | ជីមិនទាន់ច្នៃ | | | 0.0013 | 0.00021 |
| 273 | ថ្ម/ដីខ្សាច់/ថ្មអាចម៍ផ្កាយ | | 0.02655 | 0.07052 | 0.0179 |
| 277 | ថ្មសំលៀងធម្មជាតិ ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.00367 | 0.00094 | 0.00311 |
| 278 | សារធាតុខនិជមិនទាន់ច្នៃផ្សេងៗ | | 0.13092 | 0.00236 | 0.02637 |
| 281 | ល្បាយខាប់/រ៉ែដែក | | | | 0.00015 |
| 283 | ល្បាយខាប់/រ៉ែស្ពាន់ | | 0.00152 | | |
| 285 | ល្បាយខាប់/រ៉ែអាលុយមីញ៉ូម ជាដើម | | | 0.00016 | |
| 291 | ផលិតផលសត្វមិនទាន់ច្នៃ ដែលពុំបានចែងនៅកន្លែងផ្សេង | | | | 0.00373 |
| 292 | វត្ថុធាតុជាបន្លែឆៅ ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.01051 | 0.02274 | 0.00099 |
| 322 | ដុំធ្យូងថ្ម/ធ្យូងលីញីត/ធ្យូងភីត | | | 0.00068 | |
| 334 | ប្រេងដែលទទួលបានពីប៊ីទីមខនិជ/ ប្រេងតេលសិលាដែលមានទម្ងន់ធ្ងន់ | | 0.26001 | 0.36809 | 0.91359 |
| 335 | ផលិតផលកាកសំណល់ប្រេង | | | 0.00002 | 0.00314 |
| 342 | ប៊ុយតាន/ប្រប៉ានរាវ | | | | 0.51737 |
| 511 | ឧស្ម័នអ៊ីដ្រូកាបួរ/ដេរីវេ | | 0.00392 | 0.0159 | 0.03792 |
| 512 | ភេសជ្ជៈដែលមានជាតិស្រា/ហ្វេណុល/ ដេរីវេ | | 0.0073 | 0.00753 | 0.00075 |
| 513 | សមាសធាតុអាស៊ីដកាបុកស៊ីលិក | | 0.02104 | 0.01336 | 0.02302 |
| 514 | សមាសធាតុមុខងារអាហ្សូត | | 1.05954 | 0.16193 | 0.06416 |
| 515 | សមាសភាពសរីរាង្គ-អសរីរាង្គ | | 0.05858 | 0.03344 | 0.02539 |
| 516 | សមាសភាពសរីរាង្គដទៃទៀត | | 0.04296 | 0.01211 | 0.0137 |
| 522 | អំបិលអាឡូហ្សេណេ/អុកស៊ីទ/វត្ថុធាតុ | | 0.11811 | 0.0385 | 0.01659 |
| 523 | អំបិលលោហៈនៃអាស៊ីដអសរីរាង្គ | | 0.10523 | 0.09365 | 0.09607 |
| 524 | គីមីអសរីរាង្គផ្សេងៗ | | 0.03267 | 0.00003 | 0.00077 |
| 531 | ល័ក្ខជ្រលក់ពណ៌សិប្បនិម្មិត | | 0.02146 | 0.00237 | 0.0014 |
| 532 | សារជាតិសម្លាប់ស្បែក/ជ្រលក់ពណ៌ | | 0.00005 | | |
| 533 | ជាតិពណ៌/ថ្នាំលាប/វ៉ានីស | | 0.09016 | 0.06972 | 0.06407 |
| 541 | ផលិតផលឱសថ លើកលែងសារជាតិឱសថ | | 0.28184 | 0.21826 | 0.17008 |
| 542 | សារជាតិឱសថ រួមទាំងការផ្គត់ផ្គង់សម្រាប់បសុឱសថ | 0.03652 | 0.47826 | 0.86327 | 0.80181 |
| 551 | ប្រេងចំរាញ់/ទឹកអប់/គ្រឿងទេស | | 0.04672 | 0.10437 | 0.13017 |
| 553 | ទឹកអប់/ផលិតផលសំអាង/ផលិតផលថែរក្សាខ្លួន | | 0.00241 | 0.17828 | 0.10624 |
| 554 | សាប៊ូ/ផលិតផលសំអាត/ក្រមួនខាត់ | 0.16069 | 0.20416 | 0.08388 | 0.04197 |
| 562 | ជីកែច្នៃ | | 0.0068 | 0.02985 | 0.03688 |
| 571 | ប៉ូលីមែរអេទីឡែន ក្នុងទម្រង់ដើម | | 0.00922 | 0.04005 | 0.02612 |
| 572 | ប៉ូលីមែរស្ទីរ៉ែន ក្នុងទម្រង់ដើម | | | 0.01741 | 0.00086 |

| | | | | | |
|---|---|---|---|---|---|
| 573 | ប៉ូលីមែរ ក្លរៀវីនីល ក្នុងទម្រង់ដើម ជាដើម | | | 0.00145 | 0.01862 |
| 574 | ប៉ូលីអាសេតាល់/ប៉ូលីអេទែ | | 0.00107 | 0.00014 | 0.02518 |
| 575 | ប្លាស្ទិក ដែលពុំបានចែងនៅកន្លែងផ្សេង - ក្នុងទម្រង់ដើម | | 0.01034 | 0.01913 | 0.02286 |
| 581 | ទីប ទុយោ ធ្វើពីប្លាស្ទិក | | 0.00844 | 0.19971 | 0.14751 |
| 582 | សន្លឹក បង់ ជាដើម ដែលធ្វើពីប្លាស្ទិក | | 0.07706 | 0.15332 | 0.17389 |
| 583 | កង់/អង្កត់ ដែលមានសរសៃឆ្មារតែមួយដូចគ្នា | | 0.00455 | 0.00587 | 0.00562 |
| 591 | ផលិតផលគីមីសម្រាប់ថែសួន/សម្រាប់ប្រើប្រាស់ក្នុងផ្ទះ | | 0.04153 | 0.03352 | 0.03713 |
| 592 | បង្កីជាតិកែប្រែ/ការ ជាដើម | | 0.02345 | 0.05477 | 0.07511 |
| 593 | ម្សៅជាតិផ្ទុះ/ផលិតផលគ្រឿងរំសេវ | | | 0.03766 | 0.05766 |
| 597 | វត្ថុរាវ/វត្ថុធាតុបន្ថែមសម្រាប់ប្រេងរំអិល | | 0.00008 | 0.00168 | 0.00084 |
| 598 | ផលិតផលគីមីផ្សេងៗនៃឧស្សាហកម្មគីមី ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.01998 | 0.07384 | 0.16101 |
| 611 | ស្បែកសម្លាប់ | | 0.10046 | 0.22987 | 0.06989 |
| 612 | ផលិតផលស្បែកសម្លាប់ | | 0.00216 | 0.00165 | 0.00283 |
| 613 | ស្បែកមានជាប់រោម ដែលបានសម្លាប់/ជ្រលក់រួច | | | | 0.01637 |
| 621 | ផលិតផលកៅស៊ូ | | 0.04022 | 0.07521 | 0.05973 |
| 625 | សំបកកង់/បង់ដា ធ្វើពីកៅស៊ូ | | 0.76485 | 0.33168 | 0.30054 |
| 629 | វត្ថុផ្សេងៗធ្វើពីកៅស៊ូ ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.10853 | 0.06459 | 0.14593 |
| 633 | ផលិតផលត្បូក្បា | | | 0.00005 | |
| 634 | បន្ទះ វីនៀរ/ក្តារបន្ទះ ជាដើម | | 0.00356 | 0.02489 | 0.07754 |
| 635 | ផលិតផលឈើ ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.00328 | 0.04424 | 0.0194 |
| 641 | ក្រដាស/ក្រដាសកាតុង | | 0.60196 | 0.31687 | 0.25305 |
| 642 | ផលិតផលធ្វើពីម្សៅក្រដាស/ក្រដាសកាតុង/ក្រដាស ដែលកាត់រួច | | 0.62733 | 0.43079 | 0.42958 |
| 651 | អំបោះវាយនភណ្ឌ | | 1.42078 | 2.48547 | 2.58503 |
| 652 | ក្រណាត់ត្បាញពីកប្បាស ឬសំឡី | | 21.2794 | 15.6682 | 13.4696 |
| 653 | ក្រណាត់ត្បាញសំយោគ | | 6.55946 | 7.0439 | 5.38476 |
| 654 | ក្រណាត់ត្បាញវាយនភណ្ឌ ដែលពុំបានចែងនៅកន្លែងផ្សេង | | 2.94135 | 0.51125 | 0.69596 |
| 655 | ក្រណាត់ចាក់ដោយម្ជុលមួយ ឬពីរ | | 13.2108 | 28.5606 | 26.3276 |
| 656 | គ្រឿងស្បៃ/គ្រឿងជរ/គ្រឿងប៉ាក់/គ្រឿងតម្រឹម ជាដើម | | 0.28478 | 1.19186 | 0.94483 |
| 657 | ក្រណាត់/សរសៃអំបោះពិសេស | | 0.60757 | 0.68895 | 0.69375 |
| 658 | ផលិតផលវាយនភណ្ឌដេរស្រាប់ | | 0.02915 | 0.21196 | 0.20152 |
| 659 | កំរាល ជាដើម | | 0.01237 | 0.03993 | 0.03245 |
| 661 | សម្ភារៈសាងសង់/ស៊ីម៉ងត៍/ម្នាងសិលា | 40.3933 | 0.10128 | 0.2819 | 0.37723 |
| 662 | សម្ភារៈរឹងមាំមិនងាយរំលាយ/ដីឥដ្ឋ | 1.786 | 0.49292 | 2.69139 | 3.08905 |
| 663 | ផលិតផលខនិជ ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.06801 | 0.12127 | 0.07552 |

| | | | | | |
|---|---|---|---|---|---|
| 664 | កែវ | 1.23345 | 0.47847 | 0.32501 | 0.48312 |
| 665 | វត្ថុធ្វើពីកែវ | 3.08465 | 0.03021 | 0.14412 | 0.21236 |
| 666 | កុម្ភការភណ្ឌ | 0.63646 | 1.45092 | 0.537 | 0.35556 |
| 673 | ផលិតផលកិនសំប៉ែតពីដែក ឬពីដែកថែប | 0.25065 | 0.09859 | 0.13819 | 0.01279 |
| 674 | ដែកថែបស្រោបកិន | | 0.00542 | 0.62191 | 0.54692 |
| 675 | សំលោហៈដែកថែបដែលកិនសំប៉ែត | | 0.00064 | 0.00462 | 0.0722 |
| 676 | ដែកជាដើម ជាសរសៃ ធ្វើពីដែក ឬដែកថែប ជាដើម | 25.5067 | 6.9837 | 0.87978 | 2.25324 |
| 677 | គ្រឿងផ្លូវដែក ធ្វើពីដែក ឬដែកថែប | | | 0.00452 | |
| 678 | លួសពីដែក ឬដែកថែប | 0.07518 | 0.2353 | 0.04464 | 0.11492 |
| 679 | ទីប ទុយោ ធ្វើពីដែក ឬដែកថែប ជាដើម | | 0.54115 | 0.49922 | 0.36789 |
| 682 | ស្ពាន់ | | 0.00333 | 0.05492 | 0.02731 |
| 684 | អាលុយមីញ៉ូម | | 0.01236 | 0.22761 | 0.14167 |
| 685 | សំណ | | 0.00003 | | |
| 686 | សង្កសី | | 0.00004 | 0.00004 | |
| 691 | គ្រឿងសំណង់ ធ្វើពីអាលុយមីញ៉ូម/ដែកថែប/ដែក | | 1.72209 | 0.80198 | 1.14679 |
| 692 | ធុងដឹកជញ្ជូន/ស្តុក ធ្វើពីលោហធាតុ | | 0.00918 | 0.37736 | 0.08989 |
| 693 | ផលិតផលលួសសរសៃ លើកលែងខ្សែភ្លើង | | 0.04572 | 0.10745 | 0.6551 |
| 694 | ដែកសំរួច/វីស/ខ្ចៅកន្ទុយត្រី/ប៊ូឡុង | | 0.02194 | 0.10694 | 0.09939 |
| 695 | ឧបករណ៍ប្រើដោយដៃ | 1.9072 | 0.34065 | 0.24378 | 0.23708 |
| 696 | គ្រឿងឧបករណ៍ប្រភេទកាំបិត | | 0.20313 | 0.0196 | 0.01493 |
| 697 | សម្ភារៈប្រើប្រាស់ក្នុងផ្ទះ ធ្វើពីលោហធាតុធម្មតា | | 0.10399 | 0.04736 | 0.03666 |
| 699 | ផលិតផលធ្វើពីលោហធាតុធម្មតា ដែលពុំបានចែងនៅកន្លែងផ្សេង | 0.17153 | 0.51193 | 0.48182 | 0.43256 |
| 711 | ខ្ទះចំហាយ | | 0.08127 | 0.06753 | 0.87924 |
| 712 | ទួប៊ីនចំហាយ/ទួប៊ីនចំណាយទឹក | | | | 0.17038 |
| 713 | ម៉ាស៊ីនចំហេះដោយសម្ពាធ | 1.09634 | 1.89992 | 1.76467 | 2.16358 |
| 714 | ម៉ាស៊ីន មិនប្រើអគ្គិសនី ដែលពុំបានចែងនៅកន្លែងផ្សេង | | | 0.00001 | |
| 716 | គ្រឿងចក្រអគ្គិសនីដោយបង្វិល | 0.44833 | 0.65085 | 0.65028 | 1.07005 |
| 718 | ឧបករណ៍ផលិតអគ្គិសនីថាមពល ដែលពុំបានចែងនៅកន្លែងផ្សេង | 0.08661 | | 0.00042 | 0.05799 |
| 721 | ឧបករណ៍កសិកម្ម លើកលែងត្រាក់ទ័រ | 0.47872 | 0.00939 | 0.02756 | 0.11745 |
| 722 | ត្រាក់ទ័រ | 0.55781 | 0.06027 | 0.04352 | 0.10807 |
| 723 | គ្រឿងចក្រសម្រាប់វិស្វកម្មស៊ីវិល | 0.08035 | 0.02686 | 0.64169 | 0.54447 |
| 724 | ម៉ាស៊ីនសម្រាប់វាយនភណ្ឌ/ស្បែកសម្លាប់ | | 2.43813 | 1.58974 | 0.93542 |
| 725 | ម៉ាស៊ីនសម្រាប់ឧស្សាហកម្មក្រដាស | | 0.20473 | 0.06741 | 0.05693 |
| 726 | ម៉ាស៊ីនសម្រាប់ឧស្សាហកម្មបោះពុម្ព | | 0.02999 | 0.01022 | 0.02077 |

| | | | | | |
|---|---|---|---|---|---|
| 727 | ម៉ាស៊ីនកែច្នៃម្ហូបអាហារ | 0.49281 | 0.13988 | 0.08192 | 0.35903 |
| 728 | ម៉ាស៊ីនសម្រាប់ឧស្សាហកម្មពិសេស ដែលពុំបានចែងនៅកន្លែងផ្សេង | 7.8745 | 1.04036 | 0.58708 | 0.52136 |
| 731 | វត្ថុធាតុដោះដូរសម្រាប់គ្រឿងម៉ាស៊ីន | | 0.01896 | 0.01326 | 0.02226 |
| 733 | ម៉ាស៊ីនសម្រាប់ធ្វើការបំបែកលោហធាតុ | | 0.0161 | 0.00276 | 0.03128 |
| 735 | បណ្តាភាគនៃឧបករណ៍ម៉ាស៊ីនសម្រាប់បម្រើក្នុងការងារលោហធាតុ | | 0.00087 | | 0.00042 |
| 737 | ម៉ាស៊ីនសម្រាប់បម្រើក្នុងការងារលោហធាតុ ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.00273 | 0.02966 | 0.05484 |
| 741 | បរិក្ខារធ្វើឱ្យកក/ប្រព្រឹត្តកម្មកម្តៅសម្រាប់រោងចក្រ | 1.31248 | 0.31729 | 0.70361 | 0.57535 |
| 742 | ស្នប់ ឬម៉ាស៊ីនបូមសម្រាប់វត្ថុរាវ | 0.13706 | 0.15695 | 0.377 | 0.4076 |
| 743 | កង្ហារ/តម្រង់/ស្នប់ ឬម៉ាស៊ីនបូមឧស្ម័ន | 0.45103 | 0.13327 | 0.40265 | 0.29792 |
| 744 | ឧបករណ៍មេកានិកសម្រាប់លើកដាក់ | 1.34276 | 0.07906 | 0.61571 | 0.78082 |
| 745 | ម៉ាស៊ីនមិនប្រើអគ្គិសនី ដែលពុំបានចែងនៅកន្លែងផ្សេង | 1.21536 | 0.09557 | 0.13078 | 0.22769 |
| 746 | បាដាងគ្រាប់មូល និងគ្រាប់រាងស៊ីឡាំង | | 0.01415 | 0.02877 | 0.03141 |
| 747 | ក្បាលម៉ាស៊ីនទឹក/ក្បាលមាន់ ឬប្រដាប់បិទបើកទឹក/ស៊ូបាប់ ឬវ៉ាល់ | 0.00641 | 0.03689 | 0.07573 | 0.06458 |
| 748 | ឧបករណ៍បង្វិលមេកានិក | | 0.06318 | 0.03619 | 0.14016 |
| 749 | ម៉ាស៊ីនមានតំណ/បណ្តាភាគមិនប្រើអគ្គិសនី | | 0.0149 | 0.03835 | 0.03679 |
| 751 | ម៉ាស៊ីនការិយាល័យ | | 0.01061 | 0.10893 | 0.06364 |
| 752 | ឧបករណ៍កុំព្យូទ័រ | | 0.0192 | 0.08929 | 0.06227 |
| 759 | គ្រឿងបន្លាស់/បណ្តាភាគនៃឧបករណ៍ការិយាល័យ | | 0.00326 | 0.04715 | 0.03563 |
| 761 | បរិធានទទួលសម្រាប់ទូរទស្សន៍ | | 5.0272 | 0.13524 | 0.08937 |
| 762 | បរិធានទទួលនៃវិទ្យុផ្សាយសំឡេង | | 0.03094 | 0.00146 | 0.0023 |
| 763 | បរិធានថតទូរទស្សន៍/សំឡេង ជាដើម | | 0.00028 | 0.00067 | 0.05767 |
| 764 | ឧបករណ៍ទូរគមនាគមន៍ ដែលពុំបានចែងនៅកន្លែងផ្សេង | 0.21517 | 1.87375 | 5.71636 | 5.31392 |
| 771 | ឧបករណ៍បញ្ជូនថាមពលអគ្គិសនី | 0.02912 | 0.03766 | 0.18374 | 0.75807 |
| 772 | ឧបករណ៍សៀគ្វីអគ្គិសនី | 0.40462 | 0.12704 | 0.22214 | 0.62065 |
| 773 | ឧបករណ៍ចែកចាយអគ្គិសនី | 0.28229 | 0.01354 | 0.82665 | 1.2714 |
| 774 | ឧបករណ៍វិនិច្ឆ័យរោគផ្នែកវេជ្ជសាស្ត្រ ដោយប្រើអគ្គិសនី ជាដើម | | 0.01581 | 0.02645 | 0.04526 |
| 775 | ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ | 0.05246 | 0.02691 | 0.0283 | 0.04356 |
| 776 | ស៊ូបាប់ ឬវ៉ាល់/ត្រង់ស៊ីស្ទ័រ ជាដើម | 0.02527 | 0.00137 | 0.07706 | 0.0641 |
| 778 | ឧបករណ៍អគ្គិសនី ដែលពុំបានចែងនៅកន្លែងផ្សេង | 0.91781 | 0.57849 | 0.35895 | 0.58521 |
| 781 | រថយន្តសម្រាប់អ្នកដំណើរ | | 0.01048 | 0.04338 | 0.02239 |
| 782 | យានយន្តសម្រាប់សេវាកម្ម/ទំនិញ | 0.7972 | | 0.65014 | 0.65833 |

| | | | | | |
|---|---|---|---|---|---|
| 783 | រថយន្តសម្រាប់ដឹកជញ្ជូនមនុស្ស ដែលពុំបានចែងនៅកន្លែងផ្សេង | | | 0.05197 | 0.00321 |
| 784 | គ្រឿងបន្លាស់/ចំណែកនៃរថយន្តសម្រាប់ដឹកជញ្ជូនមនុស្ស | 0.03052 | 0.02185 | 0.1907 | 0.25128 |
| 785 | ទោចក្រយាន/ទោចក្រយានយន្ត ជាដើម | 0.37667 | 2.10005 | 1.44051 | 1.48437 |
| 786 | រថសណ្តោង/រថយន្តដឹកជញ្ជូនទំនិញ ជាដើម | 0.00424 | 0.00517 | 0.03102 | 0.01017 |
| 791 | ឧបករណ៍/យានយន្តផ្លូវដែក | | | 0.0045 | |
| 793 | ទូក/នាវា ជាដើម | | 0.01069 | 3.10741 | 2.01862 |
| 811 | សំណង់គ្រោងរួចជាមុន | | 0.00436 | 0.08251 | 0.11951 |
| 812 | បរិធានសម្រាប់ប្រព្រឹត្តកម្មកម្តៅ/ខ្សែប្រយោល/ការប្រើប្រាស់ខាងអនាម័យ | | 0.04137 | 0.06964 | 0.09925 |
| 813 | បរិធានបំពាក់បំភ្លឺ ជាដើម | 0.11955 | 0.20663 | 0.25854 | 0.33261 |
| 821 | គ្រឿងសង្ហារឹម/វត្ថុប្រហាក់ប្រហែលផ្សេងទៀត | | 0.07494 | 0.18578 | 0.30184 |
| 831 | ហិប និងវ៉ាលី | | 0.1649 | 0.04484 | 0.49168 |
| 841 | សម្លៀកបំពាក់ត្បាញសម្រាប់ក្មេងប្រុស/បុរស | | 0.00949 | 0.00789 | 0.04977 |
| 842 | សម្លៀកបំពាក់ត្បាញសម្រាប់ក្មេងស្រី/ស្ត្រី | | 0.09733 | 0.0005 | 0.00046 |
| 843 | អាវសឺមិសម្រាប់បុរសក្មេងប្រុស ដែលចាក់ដោយម្ជុល | | 0.26984 | 0.06986 | 0.65166 |
| 844 | អាវសឺមិសម្រាប់ស្ត្រីក្មេងស្រី ដែលចាក់ដោយម្ជុល | | 0.12894 | 0.16501 | 0.73263 |
| 845 | សម្លៀកបំពាក់ប្រហាក់ប្រហែល ដែលពុំបានចែងនៅកន្លែងផ្សេង | | 3.1879 | 2.44795 | 2.03402 |
| 846 | គ្រឿងបន្ទាប់បន្សំនៃសម្លៀកបំពាក់ | | 0.7803 | 0.95889 | 0.84454 |
| 848 | សម្លៀកបំពាក់មិនមែនវាយនភណ្ឌ/គ្រឿងសម្រាប់ពាក់លើក្បាល | 0.06452 | 0.50618 | 0.19031 | 0.11617 |
| 851 | ស្បែកជើង | 0.1705 | 3.90183 | 0.48847 | 0.42219 |
| 871 | ឧបករណ៍អុបទិក ដែលពុំបានចែងនៅកន្លែងផ្សេង | | 0.0001 | 0.00234 | 0.00175 |
| 872 | ឧបករណ៍បរិធានវេជ្ជសាស្ត្រវះកាត់ ជាដើម | 0.00507 | 0.04669 | 0.1053 | 0.19009 |
| 873 | កុងទ័រ ឬនាឡិកាវាស់ និងរាប់ ដែលពុំបានចែងនៅកន្លែងផ្សេង | 0.11508 | 0.02697 | 0.01176 | 0.01818 |
| 874 | ឧបករណ៍សម្រាប់វាស់/ពិនិត្យមើល ដែលពុំបានចែងនៅកន្លែងផ្សេង | 0.02464 | 0.04451 | 0.05894 | 0.06315 |
| 881 | ឧបករណ៍ថតរូប | | 0.00001 | 0.00081 | 0.00298 |
| 882 | សម្ភារៈផ្គត់ផ្គង់សម្រាប់ការថតរូប | | 0.02741 | 0.03857 | 0.02604 |
| 884 | សរសៃអុបទិក | | 0.04329 | 0.01215 | 0.03329 |
| 885 | នាឡិកា និងនាឡិកាដៃ | 0.0141 | 0.57079 | 0.00259 | 0.00186 |
| 891 | សាស្ត្រាវុធ និងគ្រាប់រំសេវ | 0.28472 | 0.00031 | 0.01246 | 0.02617 |
| 892 | ឯកសារបោះពុម្ព | | 0.0725 | 0.22723 | 0.18773 |
| 893 | វត្ថុធ្វើពីជាតិប្លាស្ទិក ដែលពុំបានចែងនៅកន្លែងផ្សេង | 2.2192 | 0.78243 | 0.47005 | 0.43092 |

| | | | | | |
|---|---|---|---|---|---|
| *894* | វត្ថុចាំបាច់សម្រាប់កីឡា/ល្បែង/ប្រដាប់ប្រដារក្មេងលេង/រទេះកូនក្មេង | 0.0183 | 0.08321 | 0.0448 | 0.07383 |
| *895* | សម្ភារៈការិយាល័យ | | 0.23431 | 0.06915 | 0.06686 |
| *896* | វត្ថុសិល្បៈ សមូហកម្ម និងបុរាណ | | 0.00078 | 0.00013 | |
| *897* | គ្រឿងអលង្ការកាឡៃ | | 0.00035 | 0.02157 | 0.03019 |
| *898* | ឧបករណ៍ភ្លេង/ថាស | | 0.00759 | 0.10048 | 0.35234 |
| *899* | ស្នាដៃវត្ថុផ្សេងៗ ដែលពុំបានចែងនៅកន្លែងផ្សេង | 0.00966 | 0.68267 | 0.56453 | 0.54788 |

ប្រភព៖ UN ComTrade 2009

កំណត់សម្គាល់៖ ចំណែកនៃការនាំចូលពីប្រទេសចិន ធៀបនឹងការនាំចូលសរុបពីប្រទេសចិន

ឧបសម្ព័ន្ធ ៣៖ ការពិភាក្សាតាមក្រុមស្នូល៖ ODA របស់ចិន លើការស្ថាបនាផ្លូវជាតិលេខ៧ ពីក្រចេះទៅត្រពាំងក្រៀល (ច្រកព្រំដែនទៅប្រទេសឡាវ)

*FGD ១៖ ភូមិស្រែរនាម ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ*

កាលបរិច្ឆេទ៖ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០
ពេលវេលា៖ ១០:១០-១១:១០
ទីតាំង៖ ភូមិស្រែរនាម ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ
អ្នកសម្របសម្រួល៖ ប៊ុន ដូរីណា
អ្នកកត់ត្រា៖ ផាន់ ដាលីស

តារាងរាយនាមអ្នកចូលរួម៧នាក់ជ្រើសចេញពីការពិភាក្សាតាមក្រុមស្នូល

| *លេខ* | *ឈ្មោះ* | *ភេទ* | *អាយុ* | *ការអប់រំ* | *មុខរបរ* | *ចំនួនសមាជិកគ្រួសារ* |
|---|---|---|---|---|---|---|
| ១ | ប៉ា ម៉ាលីស | ស | ៤៤ | 0 | កសិករ & អ្នកដើរលក់ភេសជ្ជៈ | ៧ |
| ២ | ហៀង អូន | ស | ៤៣ | 0 | លក់កម្លាំងពលកម្ម | ៦ |
| ៣ | ពុធ ភាន | ស | ២៣ | 0 | លក់កម្លាំងពលកម្ម | ៣ |
| ៤ | ចាន់ ហេង | ប | ៤៦ | ៧ | កសិករ & អ្នកដើរលក់ភេសជ្ជៈ | ៧ |
| ៥ | មឿន ស្រីអូន | ស | ៤៤ | ៣ | អ្នកលក់បបរ | ៣ |
| ៦ | យឹម សុខា | ប | ៥៦ | 0 | កសិករ | ២ |
| ៧ | ព្រំ នី | ស | ៥២ | ៣ | កសិករ | ៦ |

១. សាវតារសហគមន៍

ភូមិស្រែរនាម មានចម្ងាយ ៦០ គ.ម ពីខេត្តក្រចេះ។ ភូមិនេះ មាន ២៩៧គ្រួសារ មុនសាងសង់ផ្លូវ ហើយថ្មីៗនេះកើនដល់ ៣៦៧គ្រួសារ។ អ្នកភូមិថ្មី ភាគច្រើនមកពីខេត្តព្រៃវែង ស្វាយរៀង និងកំពង់ចាម។ អ្នកភូមិ ធ្វើស្រែ ដាំដំណាំ អារឈើ មើលហាងលក់គ្រឿងទេស ចិញ្ចឹមសត្វ ប្រមូលទ្រាំង និងលក់កម្លាំងពលកម្ម។ ពួកគេចាប់អារឈើតាំងពីឆ្នាំ១៩៩៥ សកម្មភាពនេះកាន់តែកើនឡើងក្រោយពេលមានផ្លូវល្អ។ ពួកគេក៏បានដឹកជញ្ជូនឈើឲ្យអ្នកដទៃផងដែរ ដោយយកតម្លៃ ១០០.០០០រៀល/រទេះគោ ក្នុងចម្ងាយប្រហែល ២០គ.ម។ ប៉ុន្តែពួកគេមិនរំពឹងថា អាចរកប្រាក់ច្រើនជាងនេះពីការអារឈើនោះទេ ព្រោះជាអំពើល្មើសច្បាប់។ ច្បាប់តឹងរ៉ឹងមានការរឹតបន្តឹង ហើយចំណូលដែលបានមក មិនសមថ្លៃក្នុងការប្រថុយឲ្យគេចាប់នោះទេ។ ដោយធ្វើតាមបទពិសោធន៍របស់អ្នកចំណូលថ្មី អ្នកភូមិប្រមាណ ៧០% បាននាំគ្នាដាំដំឡូងឈើក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ ព្រោះដំណាំនេះលក់បានថ្លៃ។ ជាភ័ព្វមិនល្អ ពួកគេមិនមានដីគ្រប់គ្រាន់សម្រាប់ដាំដំឡូងឈើឡើយ ដោយសារដីដាំដុះជាមធ្យមរបស់ពួកគេ គឺពី ០,៥-២ហិកតាប៉ុណ្ណោះ។ នៅតាមបណ្ដោយផ្លូវនោះ អ្នកភូមិបានបើកហាងលក់គ្រឿងទេស និងភោជនីយដ្ឋានតូចៗជាច្រើន រីឯដីសម្រាប់ដាំដុះវិញ មានទីតាំងនៅក្នុងព្រៃជ្រៅឆ្ងាយពីផ្លូវនោះ។

២. ផលប៉ះពាល់

<u>*ផលជាវិជ្ជមាន*</u>

នៅក្នុងការពិភាក្សានេះ មានការលើកឡើងពីអត្ថប្រយោជន៍ជាច្រើននៃផ្លូវថ្មីនេះ ទាក់ទងនឹងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ដែលមានជាអាទិ៍ ការសន្សំពេលវេលានិងប្រាក់កាស ការឡើងថ្លៃដី និងផលិតផលដាំដុះ ការទទួលបានអ្នកចូលមកទិញដល់កន្លែងច្រើនជាងមុន និងលទ្ធភាពទទួលបានសេវាសុខភាពប្រសើរជាងមុន (សាធារណៈ និងឯកជន) និងការអប់រំខ្ពស់ជាងមុនសម្រាប់កូនៗ។

*ពេលវេលា និងចំណាយលើការធ្វើដំណើរ៖* ផ្លូវនេះ កាត់បន្ថយពេលធ្វើដំណើរ និងសម្រួលដល់ការធ្វើដំណើរទៅទីឆ្ងាយនានា។ ពីមុន អ្នកភូមិត្រូវប្រើពេលពេញមួយថ្ងៃ និងចំណាយប្រាក់ ១០.០០០រៀល ក្នុងការធ្វើដំណើរទៅខេត្ត។ ឥឡូវ ពួកគាត់អាចជិះឡានក្រុង ឬតាក់ស៊ី ដោយចំណាយប្រាក់ ៥០០០រៀល និងប្រើពេលត្រឹមតែ ៣០-៦០នាទី ប៉ុណ្ណោះ ដើម្បីទៅកាន់កន្លែងដូចគ្នានោះ។

> *"ឥឡូវ យើងមិនចាំបាច់ចំណាយពេលមួយយប់នៅខេត្ត និងចំណាយលុយសម្រាប់ជួលកន្លែងស្នាក់នោះទេ។ យើងអាចជិះម៉ូតូផ្ទាល់ខ្លួនមកវិញពេលណាដែលយើងចង់មក។ ពីមុន យើងទៅផ្សារនៅទីរួមខេត្តតែ២ដងប៉ុណ្ណោះក្នុង១ឆ្នាំ តែឥឡូវ អ្នកខ្លះទៅស្ទើរតែរៀងរាល់ថ្ងៃ។ ឥឡូវ ប្រសិនបើយើងចង់បានទឹកកក គេនឹងដឹកមកឲ្យយើងភ្លាម ពេលយើងទូរស័ព្ទទៅ។"*

*លទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាព៖* ភូមិនេះ មានតែសាលាបឋមសិក្សាមួយទេ។ ជាលទ្ធផល ការសិក្សារបស់ក្មេងៗជាច្រើន នឹងបញ្ចប់ត្រឹមកម្រិតនេះ។ ដោយមានផ្លូវល្អ ក្មេងៗអាចបន្តទៅអនុវិទ្យាល័យ នៅស្រុកស្វាយជ្រុំ ឬស្រុកទួលប្រឡី ដោយធ្វើដំណើរចម្ងាយ ៨ ឬ ១០គ.ម និង ចំណាយ ៣០០០រៀលសម្រាប់ថ្លៃតាក់ស៊ីត្រលប់មកវិញ។

សេវាថែទាំសុខភាពនៅក្នុងភូមិអាចរកបាន តែប្រើសម្រាប់បញ្ហាសុខភាពស្រាលៗប៉ុណ្ណោះ។ ពេលឈឺធ្ងន់ អ្នកភូមិត្រូវទៅមណ្ឌលសុខភាពឃ្សឹម ឬស្នួល ឬត្រូវធ្វើដំណើរទៅខេត្ត។

> *"ពីមុន យើងប្រើថ្នាំបុរាណ ឬមើមរុក្ខជាតិដើម្បីព្យាបាលជំងឺ ហើយប្រសិនបើមិនអាចព្យាបាលបានទេនោះ យើងមានតែរង់ចាំស្លាប់ប៉ុណ្ណោះ។ ឥឡូវអ្វីៗ គឺល្អសម្រាប់ពួកយើង យើងអាចទៅកាន់មណ្ឌលសុខភាពល្អ បើទោះជាឆ្ងាយបន្តិចក្តី ក៏យើងមានលទ្ធភាពទៅដល់ទីនោះងាយស្រួលដែរ។"*

*ថ្លៃដី និងថ្លៃផលិតផលដំាដុះ៖* ថ្លៃដីនៅសងខាងផ្លូវ កើនឡើងដោយសារភាពងាយស្រួលចូលទៅកាន់ទីនោះ និងឱកាសអាជីវកម្មថ្មីៗក្នុងតំបន់ដែលបានទាញយកប្រយោជន៍ពីកំណើនយ៉ាងខ្លាំងនៃទីផ្សារដីនៅកម្ពុជា។ ដីឡើងថ្លៃពី ៧ដុល្លារ ទៅ ៤០០ដុល្លារ/ប្លង់ (១ម x ១៥០ម)។ ថ្លៃដីនេះបានធ្លាក់ចុះមកវិញបន្តិច ចាប់តាំងពីវិបត្តិសេដ្ឋកិច្ចសាកលលោក។

ភូមិនេះ មិនស្ងាត់ជ្រងំដូចពេលមិនទាន់មានផ្លូវនោះទេ។ ឡានធំៗ និងឈ្មួញកណ្តាល មកប្រមូលផលិតផលដំាដុះស្ទើររាល់ថ្ងៃ។ ដំណាំឡើងថ្លៃពី ៣០០រៀល/គីឡូក្រាម ដល់ ៧០០-៨០០រៀល/គីឡូក្រាម ដែលលើកទឹកចិត្តឲ្យអ្នកភូមិដាំ និងពង្រីកដីដាំដុះកាន់តែច្រើនឡើងថែមទៀត។

អត្ថប្រយោជន៍ផ្សេងទៀត៖

- *ប្រយោជន៍ទូទៅ៖* ផ្លូវនេះ លើកកម្ពស់ជីវភាពរស់នៅរបស់អ្នកភូមិ តាមរយៈការចរចាតម្លើងថ្លៃផលិតផលដាំដុះរបស់ពួកគេ។ កត្តានេះជំរុញឲ្យអ្នកភូមិអាចជួសជុល ឬសាងសង់ផ្ទះបានធំជាងមុន ទិញម៉ូតូ ម៉ាស៊ីនភ្លើង និងរហូតដល់ឡាន។
- *ការភ្ជាប់ទំនាក់ទំនងនឹងភ្នាក់ងារអភិវឌ្ឍន៍៖* ផ្លូវនេះបាននាំមកនូវភ្នាក់ងារមួយចំនួន ដូចជា CIVO (បង្រៀនពីសិប្បកម្ម) និងស្ថាប័នមីក្រូហិរញ្ញវត្ថុ-MFIs (អេស៊ីលីដា និង AMK) ឲ្យចូលមកដល់ភូមិ។ ភ្នាក់ងារទាំងនេះផ្តល់ឱកាសឲ្យអ្នកភូមិ ទទួលប្រាក់កម្ចី ដើម្បីវិនិយោគលើធាតុចូលសម្រាប់ការដាំដុះ។ មានប្រហែលជា ៩៨គ្រួសារ បានខ្ចីប្រាក់ពី MFIs ពី ៤-១៨លានរៀល ក្នុងអត្រាការប្រាក់ ២,៥% ក្នុង១ខែ ដើម្បីទិញគោ រទេះ និងធាតុចូលផ្សេងទៀត។ ពួកគេនឹងសងលុយនោះវិញ នៅឆ្នាំបន្ទាប់។

*ការព្រួយបារម្ភ*

*សុវត្ថិភាពផ្លូវ៖* ក្នុងការពិភាក្សានេះ ក៏មានលើកឡើងផងដែរពីឥទ្ធិពលមិនល្អមួយចំនួនតូចនៃផ្លូវនេះ។ អ្នកចូលរួមគ្រាន់តែសង្កត់ធ្ងន់ថា ផ្លូវល្អគួរមានផ្លាកសញ្ញាចរាចរណ៍គ្រប់គ្រាន់សម្រាប់ដាស់តឿនអ្នកបើកបរ ឲ្យមានការប្រុងប្រយ័ត្ន និងបញ្ចៀសពីគ្រោះថ្នាក់នានា។

៣. សេចក្តីសន្និដ្ឋាន

ផ្លូវនេះ ជួយលើកកម្ពស់ជីវភាពប្រជាជននៅតំបន់នោះ តាមរយៈលទ្ធភាពចូលទៅកាន់ទីផ្សារប្រសើរជាងមុន ដែលផ្តល់ឱកាសឲ្យពួកគេពង្រីកផលិតកម្មដាំដុះ។ អ្នកភូមិ អាចរៀនបច្ចេកទេសដាំដុះថ្មីៗពីបទពិសោធន៍របស់អ្នកចំណូលថ្មី ព្រមទាំងអ្នកដំណើរឆ្លងកាត់។ ពួកគេមានការរីករាយជាមួយនឹងផ្លូវថ្មី ទោះបីមានផលអវិជ្ជមានខ្លះៗក៏ដោយ។

*FGD ២៖ ភូមិអូរតាណឹង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ*

កាលបរិច្ឆេទ៖ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០
ពេលវេលា៖ ០៩:១០-១១:០០
ទីតាំង៖ ភូមិអូរតាណឹង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ
អ្នកសម្របសម្រួល៖ ប៉ុន ដូរីណា
អ្នកកត់ត្រា៖ ផាន់ ដាលីស

ដោយមានការជួយជ្រោមជ្រែងពីមេភូមិ ប្រជាជន៨នាក់ត្រូវបានជ្រើសរើស ដើម្បីចូលរួមការពិភាក្សា ស្តីពីផលប៉ះពាល់នៃវិនិយោគចិនក្នុងកំណាត់ផ្លូវជាតិលេខ៧ លើជីវភាពរស់នៅរបស់ប្រជាជននៅតាមបណ្តោយផ្លូវ និងនៅក្បែរៗនោះ (សូមមើលតារាងខាងក្រោម)។

| *លេខ* | *ឈ្មោះ* | *ភេទ* | *អាយុ* | *ការអប់រំ* | *មុខរបរ* | *ចំនួនសមាជិកគ្រួសារ* |
|---|---|---|---|---|---|---|
| ១ | រាជ សារ៉ាត់ | ប | ៥១ | មិនដឹង | មេភូមិ | ៦ |
| ២ | ផល អាត | ប | ៣៧ | ៨ | កសិករ | ៧ |
| ៣ | ញ៉ីវ យ៉ាត | ប | ៦០ | ១១ | កសិករ | ៤ |
| ៤ | ស អេង | ប | ៧០ | ៣ | កសិករ | ៧ |
| ៥ | ខន ធីម | ប | ៤១ | ២ | កសិករ & អ្នកលក់គ្រឿងទេស | ៥ |
| ៦ | មិន នា | ស | ៥៨ | ០ | កសិករ | ៥ |
| ៧ | ផុន ផានី | ស | ២៣ | ៤ | កសិករ | ៤ |
| ៨ | ទុយ សុភា | ស | ៣១ | ៤ | កសិករ | ៣ |

១. សាវតារសហគមន៍/អ្នកចូលរួម

ភូមិនេះ មានចម្ងាយ ៥៥គ.ម ពីទីរួមខេត្ត។ កាលពី៥ឆ្នាំមុន ភូមិអូរតាណឹង មានតែ ៧៨គ្រួសារប៉ុណ្ណោះ ហើយថ្មីៗនេះ កើនដល់ ១៤៣គ្រួសារ ដោយសារតែមានផ្លូវថ្មី។ អ្នកភូមិចាស់ និងថ្មី រកប្រាក់ចំណូលពីការដាំដុះ ដូចជា ធ្វើស្រែ ដាំដំណាំ កាប់ឈើ លក់កម្លាំងពលកម្ម ចិញ្ចឹមសត្វ និងបើកហាងលក់គ្រឿងទេស ជាដើម។ ភាគច្រើន ពួកគេដាំពោត សណ្តែក និងដំឡូងឈើ។ ពួកគាត់ក៏មានចិញ្ចឹមមាន់ ទា គោ និងក្របីសម្រាប់បរិភោគ សម្រាប់លក់ និងទុកភ្ជួររាស់ស្រែផងដែរ។

មានតែមួយគ្រួសារប៉ុណ្ណោះដែលបញ្ជូនកូនឲ្យទៅធ្វើការនៅម៉ាឡេស៊ី។ អ្នកភូមិដែលមិនមានដីដាំដុះ ស៊ីឈ្នួលកាប់ឈើ និងធ្វើស្រែចម្ការឲ្យអ្នកភូមិផ្សេងទៀត។ សរុបមក មានតែ២៧គ្រួសារប៉ុណ្ណោះដែលគ្មានដី អ្នកផ្សេងទៀតមានដីពី ១-៣ហិកតា ជាមធ្យម។ ការធ្វើស្រែជាប្រភពប្រាក់ចំណូលដ៏សំខាន់សម្រាប់កសិករ ហើយការធ្វើចម្ការ និងមុខរបរផ្សេងទៀត ជាប្រភពប្រាក់ចំណូលបន្ថែម។ មានតែអ្នកភូមិ ១០គ្រួសារប៉ុណ្ណោះដែលដាំដំណាំ។ គ្រួសារខ្លះ ស៊ីឈ្នួលដឹកឈើអាររួចឲ្យគេ ប៉ុន្តែពួកគាត់ត្រូវប្រើមធ្យោបាយដឹកជញ្ជូនដោយខ្លួនឯង។ ការកាប់ឈើ មានដំណើរការចាប់តាំងពីឆ្នាំ១៩៨៣មក ប៉ុន្តែវាមានសន្ទុះខ្លាំងក្នុងឆ្នាំ២០០៣ និងអំឡុងពេលបន្ទាប់ពីផ្លូវសាងសង់រួច។

២. ផលប៉ះពាល់

*ផលជាវិជ្ជមាន*

កិច្ចពិភាក្សា FGD បង្ហាញទំនោរសុទិដ្ឋិនិយមខ្លាំងអំពីផ្លូវថ្មី។ ប្រជាជន អាចចំណេញប្រាក់ និងពេលវេលាលើការធ្វើដំណើរ។ អ្នកខ្លះអាចរកប្រាក់ចំណូលពីការដឹកជញ្ជូនអ្នកភូមិទៅខេត្ត។ អ្នកទិញជាច្រើន នាំគ្នាមកដល់ភូមិ នៅរដូវដាំដុះ ហើយប្រជែងគ្នាទិញផលិតផលដាំដុះ ដែលនាំឲ្យផលដំណាំឡើងថ្លៃ។ ផ្លូវថ្មីបានទាក់ទាញគិលានុបដ្ឋាយិកាឯកជនម្នាក់ ក្រុមហ៊ុនមួយ និងស្ថាប័នមួយផ្សេងទៀត មកកាន់ភូមិ ហើយធ្វើឲ្យដីឡើងថ្លៃ។

*ពេលវេលានិងចំណាយលើការធ្វើដំណើរ៖* ផ្លូវនេះ បានបន្ថយចំណាយលើការធ្វើដំណើរទៅខេត្តពី ៧០០០រៀល មកត្រឹម ៤០០០រៀល។ អ្នកភូមិមិនចាំបាច់ព្រួយបារម្ភថាមិនមានមធ្យោបាយធ្វើដំណើរដូចពីមុននោះទេ ព្រោះឥឡូវ មានឡាននៅក្នុងភូមិ សម្រាប់បំរើពួកគាត់ពេលត្រូវការ និងមានរថយន្តឈ្នួលជាច្រើនបើកតាមផ្លូវ។ ឥឡូវនេះ គេចំណាយពេលតែ ១ម៉ោងប៉ុណ្ណោះ ដើម្បីទៅដល់ទីរួមខេត្ត ដែលពីមុនគេត្រូវចំណាយពេលពី ៣-៤ម៉ោង។

> *"អ្នកភូមិមួយចំនួនរហូតដល់ជិះកង់ទៅទីក្រុង......... ប្រជាជនដែលមានតូបលក់គ្រឿងទេស ទៅផ្សារក្នុងខេត្តស្ទើររាល់ថ្ងៃ ដើម្បីទិញទំនិញ។ អ្នកខ្លះ គ្រាន់តែចាំឈ្មួញកណ្តាលដឹកទំនិញមកឲ្យសម្រាប់ដាក់លក់។"*

*ការទទួលបានការអប់រំ និងការថែទាំសុខភាព៖* ភូមិនេះ មានសាលាបឋមសិក្សា និងវិទ្យាល័យ តាំងពីឆ្នាំ២០០៧ មុនពេលសាងសង់ផ្លូវនេះម្ល៉េះ។ ក្មេងៗភាគច្រើន (ប្រហែល៨០%) បានចូលសាលារៀន ប៉ុន្តែកង្វះគ្រូបង្រៀន ជាហេតុផលធ្វើឲ្យក្មេងៗមិនចង់ទៅសាលារៀន។ អ្នកដែលបញ្ចប់ថ្នាក់ក្នុងភូមិ អាចបន្តការសិក្សានៅស្រុកសណ្តាន់ (ចម្ងាយ ២៥គ.ម ពីភូមិ) ដោយធ្វើដំណើរទៅមករាល់ថ្ងៃ ឬជួលផ្ទះនៅទីនោះតែម្តង។

អ្នកភូមិ តែងទៅរកគ្រូពេទ្យឯកជនណាមួយនៅក្នុងភូមិ ដែលពួកគេបានចូលមកនៅទីនោះក្រោយពេលផ្លូវសាងសង់រួច។ នៅក្នុងភូមិ មានមណ្ឌលសុខភាពរដ្ឋមួយ ប៉ុន្តែមិនសូវមានប្រជាជន ទៅមណ្ឌលសុខភាពនោះទេ ដោយសារសេវាកម្មយឺត និងគ្មានគិលានុបដ្ឋាយិកាប្រចាំការនៅកន្លែង។ ពេលខ្លះ ប្រជាជនជនទៅគ្លីនិកនៅស្រុកសណ្តាន់ ឬមណ្ឌលសុខភាពសាធារណៈនៅស្រុកអូរគ្រៀង (ចម្ងាយ ៣៥គ.ម ពីភូមិ) ប្រសិនបើជំងឺរបស់ពួកគាត់មិនអាចព្យាបាលបាននៅកន្លែងថែទាំសុខភាពឯកជនក្នុងភូមិ។ លទ្ធភាពទទួលបានសេវាសុខាភិបាលប្រសើរឡើង ធ្វើឲ្យស្ត្រីមានគភ៌សម្រាលកូនប្រកបដោយសុវត្ថិភាពជាងមុន។ ស្ត្រីភាគច្រើន សម្រាលកូននៅផ្ទះដោយឆ្មបពីមណ្ឌលសុខភាព ឬឆ្មបតាមបែបបុរាណដែលទទួលការបណ្តុះបណ្តាលនៅមណ្ឌលសុខភាព។ មុនពេលមានផ្លូវថ្មីនេះ នៅក្នុងភូមិមានតែឆ្មបបុរាណដែលមិនបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈអ្វីឡើយ ហើយពួកគេជួយបង្កើតកូនឲ្យស្ត្រីមានគភ៌ដោយប្រើប្រាស់វិធីសាស្ត្របុរាណ។

*ថ្លៃដី និងថ្លៃផលិតផលដាំដុះ៖* ដីមួយប្លង់ទំហំ ១ម x ៣០០ម ឡើងថ្លៃពីសូន្យដល់ ១០០ដុល្លារ បន្ទាប់ពីផ្លូវសង់រួច។ អ្នកទិញដីទីនេះ ភាគច្រើនមកពីភ្នំពេញ ព្រៃវែង កំពង់ចាម ហើយពួកគេទិញដីទាំងនេះ ដើម្បីធ្វើការដាំដុះ ឬវិនិយោគ ដោយរំពឹងថាដីនឹងឡើងថ្លៃទៅថ្ងៃមុខ។

ថ្លៃផលដំណាំ ក៏កើនឡើងស្រដៀងនឹងថ្លៃដីផងដែរ ជាពិសេស ដំណាំស្រូវ ដែលកើនឡើងពី ៥០០រៀល/គ.ក. ដល់ ៨០០-១០០០រៀល/គ.ក. ដោយសារតឡូវមានឈ្មួញកណ្តាលត្រូវការផលិតផលច្រើន។

*"ឈ្មួញកណ្តាលមកផ្ទះយើងស្ទើរតែរាល់ថ្ងៃ មិនដូចពីមុនទេ ពួកគេមកមួយដងប៉ុណ្ណោះក្នុងមួយខែ... ប្រសិនបើពួកគេមិនមក យើងក៏អាចយកផលិតផលទៅកាន់ទីផ្សារខេត្តដោយខ្លួនឯងបានដែរ។"*

អត្ថប្រយោជន៍ផ្សេងទៀត

- *ឱកាសការងារ៖* អំឡុងពេលសាងសង់ផ្លូវអ្នកភូមិពី៤ទៅ១០នាក់បានធ្វើការនៅការដ្ឋានសំណង់។ពួកគេទទួលបានកម្រៃ ១០.០០០រៀល/ថ្ងៃ ប៉ុន្តែការងារនេះមានរយៈពេលពីរបីថ្ងៃប៉ុណ្ណោះ។ ក្រៅពីនេះ ចាប់តាំងពីផ្លូវសង់រួចមក នារីៗ អាចទៅស្រុកអូរឫស្សី ដើម្បីទទួលការបណ្តុះបណ្តាលសិប្បកម្ម ឬទៅកន្លែងផ្សេងទៀតដើម្បីរកការងារធ្វើ។
- *ការតភ្ជាប់ទៅនឹងភ្នាក់ងារអភិវឌ្ឍន៍៖* ផ្លូវល្អនាំផលប្រយោជន៍ជាច្រើនដល់ភូមិ។ផ្លូវនេះទាក់ទាញស្ថាប័នឬអង្គការជាច្រើនឲ្យមកជួយអភិវឌ្ឍន៍ភូមិ។ អ្នកភូមិបានបង្កើតជាក្រុមមួយមានសមាជិក ២៥នាក់ ដើម្បីទទួលមូលនិធិពីអង្គការនានា សម្រាប់ចិញ្ចឹមសត្វ ដាំដំណាំ និងបង្កើតអាជីវកម្មខ្នាតតូច។ ក្រុមនីមួយៗ ទទួលបានប្រាក់ ៧០ដុល្លារ ប៉ុន្តែពួកគេត្រូវសងប្រាក់នេះវិញនៅពេលអាជីវកម្មរបស់ខ្លួនមានដំណើរការល្អ។ Oxfam និង Danida ក៏មានវត្តមានក្នុងភូមិផងដែរ ដោយបានជួយជីកអណ្តូង សង់ផ្លូវ និងឲ្យប្រជាជនខ្ចីសត្វពាហនៈ។ ស្ថាប័នមីក្រូហិរញ្ញវត្ថុ ដូចជា អេស៊ីលីដា ធនាគារភូមិ និង AMK មាននៅក្នុងភូមិតាំងពីយូរមកហើយ ប៉ុន្តែពួកគេទើបតែបង្កើនសកម្មភាពរបស់ខ្លួនខ្លាំងនាពេលថ្មីៗនេះ។ យ៉ាងណាក្តី មានតែ ១៦គ្រួសារប៉ុណ្ណោះ ខ្ចីលុយពីស្ថាប័នទាំងនេះ ហើយទឹកប្រាក់ដែលខ្ចីមានមិនលើសពី ៥០០ដុល្លារទេ។

*<u>ការព្រួយបារម្ភ</u>*

ការសាងសង់ផ្លូវនេះ ក៏នាំមកនូវផលប៉ះពាល់ជាអវិជ្ជមានខ្លះផងដែរ។

*ការតាំងទីលំនៅជាថ្មី និងការស្តារនីតិសម្បទា៖* សំណង់នេះបានបំផ្លាញផ្ទះប្រជាជនមួយចំនួន។ ទោះមានសំណងក្តី ក៏វាមានបរិមាណតិចតួចប៉ុណ្ណោះ។ ផ្ទះមានលក្ខណៈល្អ (ដំបូលគ្រឿង) ទទួលបាន ១០០០-២៥០០ដុល្លារ ផ្ទះមានលក្ខណៈមធ្យមទទួលបានពី ៨០០-៩០០ដុល្លារ ហើយផ្ទះមានលក្ខណៈមិនសូវល្អ ទទួលបានពី ៧០០-៨០០ដុល្លារ។ អ្នកភូមិត្រូវផ្លាស់ទីទៅឆ្ងាយដល់ក្នុងព្រៃដើម្បីសង់លំនៅស្ថានថ្មី។

*សុវត្ថិភាពផ្លូវ និងសន្តិសុខសហគមន៍៖* ផ្លូវល្អបង្កគ្រោះថ្នាក់ច្រើនជាងមុន ជាពិសេសនៅកន្លែងដែលមិនមានផ្លាកសញ្ញាត្រឹមត្រូវ។ ដូចគ្នានេះដែរ ផ្លូវល្អអាចនាំឲ្យមានចោរកម្មកាន់តែច្រើន ដោយសារវាផ្តល់ភាពងាយស្រួលដល់ពួកចោរក្នុងការដឹកជញ្ជូនសត្វចិញ្ចឹមអ្នកភូមិទៅផ្សារនៅពេលយប់។

*"ពេលខ្លះ ចោរលួចសត្វពាហនៈរបស់យើងស្ទើរតែទាំងអស់ ហើយយើងគ្មានសត្វសម្រាប់ជួយការងារស្រែចម្ការទេ។"*

*ផលប៉ះពាល់លើបរិស្ថាន៖* ផ្លូវនេះទាក់ទាញក្រុមហ៊ុនជាច្រើន ដែលបំផ្លាញព្រៃឈើ ដោយបន្លំធ្វើជាវិនិយោគក្នុងផ្នែកអ្វីមួយ ហើយផ្តល់សំណងតិចតួចដល់អ្នកភូមិចំពោះការខូចខាតលើដីដាំដុះរបស់ពួកគាត់។ ក្រុមហ៊ុនទាំងនេះមានពិភាក្សានៅផ្នែកខាងក្រោម។

*ក្រុមហ៊ុននានាក្នុងភូមិ៖* ក្រុមហ៊ុន៤ គឺ Kamadyno, Asiavel (ចិន), NK Akree (ចិន) និង Tong Men (ចិន) បានបង្កើតឡើងក្នុងភូមិក្បាលដំរី ពេលផ្លូវបានសាងសង់រួច។ ក្រុមហ៊ុនមួយទៀត ឈ្មោះថា Global (ចិន) ដំណើរការនៅទីនោះរយៈពេលប្រហែល៥ឆ្នាំហើយ។ ក្រុមហ៊ុនភាគច្រើន កាប់ឆ្ការព្រៃដើម្បីដាំដើមម៉ៃសាក់។ គ្មានអ្នកភូមិណា ធ្វើការឲ្យក្រុមហ៊ុនទាំងនោះទេ ដោយសារបៀវត្សរ៍ដែលផ្តល់ឲ្យទាបពេក (១៧០.០០០-១៨០.០០០រៀល/ខែ)។ នេះជាហេតុធ្វើ

ឲ្យក្រុមហ៊ុនទាំងនេះ ជួលប្រជាជនពីខេត្តផ្សេងៗ ដូចជាកំពង់ធំ កំពង់ស្ពឺ កណ្តាល និងកំពង់ចាម។ ក្រុមហ៊ុនទាំងនេះ ត្រូវការដីទំហំធំសម្រាប់ចម្ការរបស់ពួកគេដែលប៉ះពាល់ដល់ការដាំដុះរបស់ប្រជាជន។

៣. សេចក្តីសន្និដ្ឋាន

ការធ្វើវិនិយោគលើផ្លូវថ្មីនេះ នាំមកនូវគុណប្រយោជន៍ច្រើនជាងគុណវិបត្តិដល់អ្នកភូមិ។ ប្រជាជនអាចបង្កើនប្រាក់ចំណូល ដោយសារផលិតផលដាំដុះរបស់ពួកគាត់ បានថ្លៃខ្ពស់ជាងមុន។ អ្នកភូមិអាចយកផលិតផលទៅទីផ្សារដោយខ្លួនឯងបាន។ កូនៗរបស់អ្នកភូមិ មានឱកាសទទួលបានការអប់រំខ្ពស់ និងធ្វើការងារនៅក្រៅភូមិបាន។ ទីភ្នាក់ងារអភិវឌ្ឍន៍ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អាចចូលមកដល់ក្នុងភូមិហើយជួយលើកស្ទួយជីវភាពអ្នកភូមិ និងដោះស្រាយតម្រូវការបន្ទាន់នានារបស់ពួកគាត់។

*FGD ៣៖ ភូមិកសាង ឃុំចង្រ្កង ស្រុកចិត្របុរី ខេត្តក្រចេះ*

កាលបរិច្ឆេទ៖ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០
ពេលវេលា៖ ១៥:១០-១៦:១០
ទីតាំង៖ ភូមិកសាង ឃុំចង្រ្កង ស្រុកចិត្របុរី ខេត្តក្រចេះ
អ្នកសម្របសម្រួល៖ ប៉ុន ដូរីណា
អ្នកកត់ត្រា៖ ស្រ៊ី បុប្ផារ័ត្ន

តារាងខាងក្រោមរាយនាមអ្នកចូលរួម ៧នាក់ ក្នុងការពិភាក្សាតាមក្រុមស្នូល ធ្វើឡើងដើម្បីស្វែងរកពីផលប៉ះពាល់នៃវិនិយោគចិនតាមបណ្តោយផ្លូវជាតិលេខ៧ (គេស្គាល់ក្នុងភូមិថាផ្លូវអាស៊ាន)។ អ្នកចូលរួមភាគច្រើន មករស់នៅក្នុងភូមិនេះបន្ទាប់ពីផ្លូវជាតិបានសាងសង់រួច។

| *លេខ* | *ឈ្មោះ* | *ភេទ* | *អាយុ* | *ការអប់រំ* | *មុខរបរ* | *ចំនួនសមាជិកគ្រួសារ* |
|---|---|---|---|---|---|---|
| ១ | សឹម ផល្លី | ស | ៤៦ | ៣ | កសិករ | ៥ |
| ២ | ពៅ ម៉ូ | ប | ៣៩ | ៨ | កសិករ | ៤ |
| ៣ | វង់ ព្រុំ | ប | ៥៩ | ៧ (ប្រព័ន្ធចាស់) | កសិករ | ១០ |
| ៤ | ងូវ ស៊ីគាង | ស | ៥២ | 3 (ប្រព័ន្ធចាស់) | កសិករ | ១១ |
| ៥ | ប៊ិន សឿន | ស | ៦០ | មត្តេយ្យ | កសិករ | ៧ |
| ៦ | ជួន ជាត | ប | ៤០ | ៤ | កសិករ | ៨ |
| ៧ | ចាន់ សុធា | ស | ៤៩ | ៧ (ប្រព័ន្ធចាស់) | កសិករ | ៦ |

១. សាវតារសហគមន៍/អ្នកចូលរួម

ភូមិកសាង មានចម្ងាយប្រហែល ២២គ.ម ពីខេត្តក្រចេះ។ មុខរបរសំខាន់របស់អ្នកភូមិ គឺបង្កបង្កើនផលស្រូវ ដំឡូងឈើ សណ្តែកសៀង សណ្តែកដី កាប់ឫស្សី និងស៊ីឈ្នួលជម្រះស្មៅក្នុងភូមិ និងភូមិក្បែរខាង។ អ្នកចាស់ក្នុងភូមិមានឱកាសច្រើន ព្រោះពួកគេមានដីសម្រាប់បង្កបង្កើនផលស្រូវ និងដំឡូងឈើ។ ៣គ្រួសារបើកតូបលក់គ្រឿងទេស។ អ្នកភូមិខ្លះ ធ្វើចំណាកស្រុកទៅខេត្តផ្សេងៗទៀត ដូចជា រតនគីរី កំពង់ចាម និងភ្នំពេញ ដើម្បីធ្វើការក្នុងរោងចក្រកាត់ដេរ ទៅប្រទេសម៉ាឡេស៊ី ធ្វើជាអ្នកថែទាំបោសសំអាតផ្ទះ ដោយសារតែគ្មានដីសម្រាប់ដាំដុះ និងគ្មានការងារធ្វើ។ ដូចដែលបុរសម្នាក់បាននិយាយថា "ហេតុផលសំខាន់ដែលខ្ញុំផ្លាស់ទីលំនៅ ដោយសារតែខ្ញុំគ្មានដី"។ ពេលដំណាលគ្នានោះ មនុស្សជា

ច្រើន បានចូលមករស់នៅក្នុងភូមិនេះ។ បន្ទាប់ពីផ្លូវសង់រួច អ្នកចំណូលថ្មី ទទួលពត៌មានតាមរយៈមេភូមិ ដែលផ្តល់ដីសម្បទានតាមគោលនយោបាយរបស់រដ្ឋាភិបាល។ អ្នកភូមិចាស់ ជាក្រុមជនជាតិភាគតិច ហើយមិនមានគ្រួសារច្រើនទេ ដែលរស់នៅក្នុងភូមិនេះពីមុនមក។ ហេតុដូច្នេះហើយបានជារដ្ឋាភិបាលផ្តល់ដីសម្បទានដល់ទាហាន។ បន្ទាប់ពីដីសម្បទាន បានផ្តល់ទៅឲ្យប្រជាជនដែលចូលមករស់នៅក្នុងភូមិនេះ ប្រជាជនកាន់តែច្រើនឡើងៗ បានចូលមករស់នៅទីនេះ។ ប្រជាជនជាង៤០០ គ្រួសារ បានដាក់ពាក្យសុំដីសម្បទានដែលមានតែ ១០០កន្លែងប៉ុណ្ណោះ។

២. ផលប៉ះពាល់

*ផលជាវិជ្ជមាន*

*ការភ្ជាប់ទំនាក់ទំនងនិងឱកាសការងារ៖* មានផ្លូវល្អ ធ្វើឲ្យប្រជាជនមានភាពងាយស្រួលជាងមុន ក្នុងការធ្វើដំណើរ និងស្វែងរកការងារក្រៅភូមិ និងដឹកជញ្ជូនផលិតផលដាំដុះទៅទីផ្សារ។ អ្នកភូមិភាគច្រើន ដែលលក់កម្លាំងពលកម្មនៅក្នុងភូមិមិនអាចផ្គត់ផ្គង់ជីវភាពបានទេ ដូច្នេះពួកគេត្រូវតែទៅភូមិដទៃទៀត។ បុរសម្នាក់បាននិយាយថា "ការលក់កម្លាំងពលកម្មនៅភូមិផ្សេងទៀត អាចរកប្រាក់ចំណូលបាន ២០០.០០០រៀល ដែលអាចទិញអង្ករមួយបាវ"។ ដូច្នេះផ្លូវនេះ ជួយឲ្យពួកគាត់អាចផ្គត់ផ្គង់ជីវភាពបាន។

*កាត់បន្ថយពេលវេលា និងចំណាយធ្វើដំណើរ៖* ពីភូមិទៅផ្លូវជាតិ មានចម្ងាយ ៤គ.ម។ អ្នកភូមិចំណាយប្រាក់តិចជាងមុនលើការធ្វើដំណើរ និងប្រើពេលតែមួយម៉ោងប៉ុណ្ណោះដើម្បីទៅដល់ខេត្តក្រចេះ។ អ្នកភូមិជារឿយៗ ទៅផ្សារកសាង ព្រោះវានៅជិត។ អ្នកភូមិទៅខេត្តក្រចេះដោយម៉ូតូ ហើយឥឡូវចំណាយពេលតែកន្លះម៉ោងប៉ុណ្ណោះ។

*ការទទួលបានការអប់រំ និង ការថែទាំសុខភាព៖* នៅក្នុងភូមិនេះ ក្មេងៗអាចរៀនពីត្រឹមថ្នាក់ទី១ ដល់ទី៦ប៉ុណ្ណោះ ប៉ុន្តែពួកគេអាចបន្តពីថ្នាក់ទី៧ ដល់ទី៩ នៅភូមិកសាង ដោយសារមានផ្លូវ។

មានមណ្ឌលសុខភាពមួយនៅក្បែរសាលាឃុំក្នុងភូមិ ប៉ុន្តែនៅទីនោះមានតែថ្នាំធម្មតាប៉ុន្មានមុខប៉ុណ្ណោះ។ ចាប់តាំងពីផ្លូវសង់រួច អ្នកភូមិតែងធ្វើដំណើរទៅខេត្តក្រចេះពេលពួកគេឈឺធ្ងន់។

*ថ្លៃផលិតផលដាំដុះ៖* មុនមានផ្លូវជាតិនេះ ឈ្មួញកណ្តាល មានការលំបាកនឹងចូលមកកាន់ភូមិនេះ ហើយប្រសិនបើពួកគេមកទិញផលិតផល ពួកគេឲ្យថ្លៃទាបប៉ុណ្ណោះដើម្បីបានចំណេញច្រើន។ បន្ទាប់ពីផ្លូវសង់រួចភ្លាម ឈ្មួញកណ្តាលជាច្រើនភាគច្រើនមកពីខេត្តក្រចេះ និងកំពង់ចាម បានចូលមកដល់ក្នុងភូមិ ដែលនេះជាការលើកទឹកចិត្តឲ្យកសិករដាំដំណាំច្រើនជាងមុន ជាពិសេសដំឡូងឈើ ដែលអ្នកចំណូលថ្មីនាំមក។ កំណើនតម្រូវការទីផ្សារ មានន័យថាគេអាចរកប្រាក់ចំណូលច្រើនជាងមុនពីការដាំដំឡូងឈើ។ យោងតាមកិច្ចពិភាក្សា FGD បានឲ្យដឹងថា ពួកគេលក់ដំឡូងឈើស្ងួតតម្លៃ ៦៥០រៀល/គីឡូក្រាម ធៀបនឹង ២០០រៀល/គីឡូក្រាម មុនផ្លូវសាងសង់ និងពេលមានតម្រូវការទាប។ លើសពីនេះទៀត ពួកគាត់អាចលក់ដំណាំដូចជា ត្រប់ និងល្ពៅ នៅផ្សារកសាងដែលមានចម្ងាយ ៤គ.មពីភូមិ ហើយពួកគាត់ទៅផ្សារពរាល់ពីរបីថ្ងៃម្តង។

អត្ថប្រយោជន៍ផ្សេងទៀត៖

- *ការភ្ជាប់ទំនាក់ទំនងនឹងភ្នាក់ងារអភិវឌ្ឍន៍៖* ក្រុមហ៊ុនចិនមកបង្រៀនអ្នកភូមិ ពីការដាំដំឡូងឈើ ដោយសារដំឡូងឈើ អាចកិនជាម្សៅមានសំណល់តិច ស្មើតែបាន ១០០%/គីឡូក្រាម។ លើសពីនេះ ស្ថាប័នមីក្រូហិរញ្ញវត្ថុរួមមាន អេស៊ីលីដា AMK ប្រសាក់ និង ធនាគារភូមិ បានមកក្នុងភូមិ បន្ទាប់ពីផ្លូវបានសាងសង់រួច។ ប្រជាជនភាគច្រើនខ្ចីលុយពីធនាគារភូមិ។ ប្រសិនបើគេខ្ចីជាបុគ្គល ពួកគាត់ត្រូវមានប្លង់ដីបញ្ចាំ។ ការខ្ចីជាក្រុម មានលក្ខណៈស្រួលជាង។ ប្រជាជនអាចខ្ចី ពី ៥០០.០០០រៀល ទៅ ១.០០០.០០០រៀល។ ជាធម្មតា ពួកគាត់សងសរុបទាំងការទាំងដើម រយៈពេល១០ខែក្រោយមក។ ការប្រាក់លើប្រាក់ដើម ១.០០០.០០០រៀល គឺ ៣០.០០០រៀល។

៣. សេចក្ដីសន្និដ្ឋាន

យើងមិនអាចទទួលពត៌មានច្រើនជាងនេះ ពីកម្រិតជីវភាពរស់នៅរបស់អ្នកភូមិទេ មុនពេលផ្លូវបានសាងសង់ ដោយសារអ្នកចូលរួមក្នុង FGD ជាអ្នកចំណូលថ្មីនៃភូមិនោះ។ ប៉ុន្តែយើងអាចដឹងព័ត៌មានច្រើនពីជីវភាពរស់នៅ ក្រោយការសាងសង់ផ្លូវ។ ប្រជាជនអាចទៅកាន់ទីផ្សារ មន្ទីរពេទ្យ និងសាលាស្រួលជាងមុន។ ទោះអ្នកភូមិមិនរស់តាមបណ្ដោយផ្លូវ ពួកគេក៏អាចទទួលប្រយោជន៍បានច្រើន ដូចជា មានឈ្មួញកណ្ដាលច្រើនជាងមុន មកទិញផលិតផល ហើយពួកគេមិនចាំបាច់ទៅផ្សារ ដើម្បីលក់ផលិតផលរបស់ខ្លួនឡើយ។ ដូច្នេះ ចំណាយលើការធ្វើដំណើរ និងដឹកជញ្ជូន បានកាត់បន្ថយ ហើយនៅពេលត្រូវការសេវាសុខភាព ដូចជា សេវាមាតុភាព អ្នកភូមិអាចទៅមន្ទីរពេទ្យខេត្តទាន់ពេលវេលា។ អ្នកភូមិមានផែនការរស់នៅក្នុងភូមិរហូត ដោយសារពួកគេមានដី និងអាចរកប្រាក់ចំណូលពីការដាំដុះដំណាំ។

*FGD ៤៖ ភូមិអូរឫស្សីកណ្ដាល ឃុំអូរឫស្សីកណ្ដាល ស្រុកសៀមបូក ខេត្តស្ទឹងត្រែង*

កាលបរិច្ឆេទ៖ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០
ពេលវេលា៖ ១៥:៣០-១៦:២៥
ទីតាំង៖ ភូមិអូរឫស្សីកណ្ដាល ឃុំអូរឫស្សីកណ្ដាល ស្រុកសៀមបូក ខេត្តស្ទឹងត្រែង
អ្នកសម្របសម្រួល៖ ប៊ុន ដូរីណា
អ្នកកត់ត្រា៖ ផាន់ ដាលីស

តារាងខាងក្រោម រាយនាមអ្នកភូមិ ៦នាក់ ដែលចូលរួមក្នុងក្រុមពិភាក្សាធ្វើឡើង ដើម្បីស្វែងរកផលប៉ះពាល់នៃវិនិយោគចិនក្នុងកំណាត់ផ្លូវជាតិលេខ៧ ទៅលើប្រជាជនរស់នៅតាមបណ្ដោយ និងក្បែរផ្លូវនោះ។ អ្នកចូលរួមភាគច្រើនជាស្ត្រី ដោយសារអ្នកភូមិជាបុរសកំពុងធ្វើការនៅចម្ការ ឬក្នុងព្រៃក្នុងអំឡុងពេលពិភាក្សា។

| *លេខ* | *ឈ្មោះ* | *ភេទ* | *អាយុ* | *ការអប់រំ* | *មុខរបរ* | *ចំនួនសមាជិកគ្រួសារ* |
|---|---|---|---|---|---|---|
| ១ | ស៊ូ កំអៀង | ប | ៣៥ | មិនដឹង | មេភូមិ | ៧ |
| ២ | អ៊ឹង កុសល | ប | ២៧ | ៥ | កសិករ | ៥ |
| ៣ | ពុធ យុន | ស | ៦០ | មិនដឹង | នាយិកាសាលាបឋម | ៧ |
| ៤ | ហួត សុភី | ស | ៤៨ | ៥ | កសិករ | ៧ |
| ៥ | អ៊ឹង ណារី | ស | ៣២ | ៤ | កសិករ | ៧ |
| ៦ | សឹម ចាន់ ថន | ស | ៥២ | ៨ | កសិករ | ៧ |

១. សាវតារសហគមន៍/អ្នកចូលរួម

ភូមិអូរឫស្សីកណ្ដាល មានចម្ងាយប្រហែល ២៨គ.ម ពីទីរួមខេត្ត។ ដំបូងឡើយ ភូមិនេះ មាន១០០គ្រួសារ តែចាប់តាំងពីផ្លូវលេខ៧នេះសង់រួចមក អ្នកចំណូលថ្មីបានចូលមកក្នុងភូមិ ហើយពេលកំពុងសិក្សា វាមានសរុប ១០០០គ្រួសារ ភាគច្រើនមកពីខេត្តកំពង់ចាម។ ប្រហែល២០គ្រួសារ រួមមាន គ្រួសារថ្មីចំនួន៦ មានតូបលក់គ្រឿងទេស។ យ៉ាងណាក្ដី អ្នកភូមិភាគច្រើនបង្កបង្កើនស្រូវ ធ្វើការនៅកសិដ្ឋាន ប្រមូលជ័រឈើ ពោត សណ្ដែក ស្វាយ ស្វាយចន្ទី និងដំណាំផ្សេងទៀត។ អ្នកភូមិប្រមាណ ៩០% បង្កបង្កើនផលស្រូវ និងស្វាយចន្ទីរយៈពេលយូរមកហើយ តែប្រមាណ ៧០% ដាំដំឡូងឈើ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ មានតែអ្នកភូមិ ៣% ប៉ុណ្ណោះ ដាំដំណាំផ្សេងទៀត។ លើសពីនេះ ១០គ្រួសារចាប់ផ្ដើមដាំកៅស៊ូ នៅចុងឆ្នាំ ២០០៩។ អ្នកភូមិ មានដីកសិដ្ឋានធំបំផុតទំហំត្រឹម ២-៣ហិកតា ដែលជាការលំបាកក្នុងការទាញយកផលប្រយោជន៍ឲ្យ

បានច្រើន។ ទោះគ្រួសារនីមួយៗ មានមុខរបរពីរបីក៏ដោយ ក៏ការផលិតស្រូវ និងដំណាំ នៅតែជាប្រភពប្រាក់ចំណូលចំបង។ ពួកគេផ្លាស់ប្តូរដាំដំណាំខុសៗគ្នាតាមរដូវលើដីកន្លែងដដែល។ ក្រៅពីនេះ អ្នកភូមិស៊ីឈ្នួលកាប់ឈើឲ្យអ្នកមានឧបករណ៍កាប់ឈើ។ ជាលទ្ធផល ពួកគេទទួលបានផលចំណេញតិចតួចប៉ុណ្ណោះពីព្រៃឈើ។

២.ផលប៉ះពាល់

*ផលជាវិជ្ជមាន*

ផ្លូវជាតិលេខ៧ សាងសង់ពីឆ្នាំ២០០៦-២០០៧។ ចាប់ពីការចាប់ផ្តើមសាងសង់ ប្រជាជនជាច្រើនទទួលបានប្រយោជន៍នានាពីផ្លូវនេះ។ អ្នកចូលរួម FGD បានឲ្យដឹងថា ផ្លូវបានជួយពួកគេតាមរយៈការបន្ថយថ្លៃ និងរយៈពេលធ្វើដំណើរ ការសម្រួលដល់ការចេញចូលភូមិ ជាពិសេសសម្រាប់អ្នកជំនួញ ការលើកកម្ពស់លទ្ធភាពចូលទៅមណ្ឌលសុខភាព ទទួលសេវាអប់រំ និងដឹកជញ្ជូនផលិតផលទៅទីផ្សារ ការតម្លើងថ្លៃដី ការតម្លើងថ្លៃផលិតផលកសិដ្ឋាន និងការភ្ជាប់ទំនាក់ទំនងអ្នកភូមិជាមួយទីក្រុង។

*កាត់បន្ថយចំណាយ និងពេលវេលាធ្វើដំណើរ៖* ពីមុន អ្នកភូមិត្រូវចំណាយពេលពេញមួយថ្ងៃ និងចំណាយប្រាក់ ២០.០០០រៀល ដើម្បីធ្វើដំណើរទៅទីរួមខេត្ត ប៉ុន្តែឥឡូវ ពួកគេចំណាយពេលតែ ១ម៉ោង តាមឡានក្រុង ឬតាក់ស៊ី ឬម៉ូតូ។ អ្នកភូមិនិយាយថា គ្រួសារប្រមាណ ៧០% ឥឡូវនេះមានម៉ូតូផ្ទាល់ខ្លួន ធ្វើឲ្យពួកគាត់អាចធ្វើដំណើរទៅខេត្តពេលណាដែលគេចង់។

> *"ពីមុន យើងគ្មានហេតុផលអ្វីត្រូវទិញម៉ូតូទេ ព្រោះមិនមានផ្លូវ។ ពេលដែលយើងចង់ទៅកន្លែងណា យើងត្រូវចាំរហូតដល់មានរថយន្តឈ្នួលមក ឬសុំឡានទាហានទៅដោយសារ។ តាំងពីយើងមានផ្លូវល្អមក យើងអាចសន្សំប្រាក់ពីការលក់ដី និងផលិតផលដាំដុះរបស់យើង ដើម្បីទិញម៉ូតូដែលធ្វើឲ្យការធ្វើដំណើរមានភាពងាយស្រួល និងឆាប់រហ័សជាងមុន.... អ្នកលក់គ្រឿងទេសមួយចំនួន ទៅផ្សារនៅឯខេត្តស្ទើររាល់ថ្ងៃ។"*

*លទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាព៖* សាលាបឋមសិក្សា និងវិទ្យាល័យ មាននៅក្នុងភូមិ ៣ឆ្នាំមុនការសិក្សារបស់យើង។ ប៉ុន្តែមិនមានក្មេងច្រើនចូលសាលារៀនទេ ដោយសារខ្វះគ្រូបង្រៀន និងព្រួយបារម្ភពីសន្តិសុខតាមផ្លូវទៅសាលារៀន។ ឥឡូវ ក្មេងច្រើនជាងមុន ចូលសាលារៀនរហូតដល់អ្នកខ្លះធ្វើដំណើរវិលល្ងាច ទៅរៀនវិទ្យាល័យ (មិនមានក្នុងភូមិ) នៅឯខេត្ត។

មានមណ្ឌលសុខភាពមួយ ក្នុងភូមិស្រែក្រសាំង មានចម្ងាយ ១៥គ.ម ពីភូមិ។ អ្នកភូមិតែងទៅមណ្ឌលសុខភាពនោះ ឬទៅខេត្តពេលត្រូវការសេវាសុខាភាព ដូចជា សេវាមាតុភាពជាដើម។ ពីមុន ស្ត្រីធ្លាប់តែសម្រាលកូនក្នុងភូមិដោយឆ្មបបុរាណ ដែលអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សុខុមាលភាពយ៉ាងខ្លាំង។

*ការឡើងថ្លៃដី និងថ្លៃផលិតផលកសិដ្ឋាន៖* ដីចាប់ផ្តើមឡើងថ្លៃស្ទើរភ្លាមៗបន្ទាប់ពីការសាងសង់ផ្លូវចាប់ផ្តើម ដោយសារប្រជាជនថ្មី ចូលមកចាប់យកដីដែលមានទំហំធំ និងតម្លៃថោកសម្រាប់ដាំដុះ។ ដីឡើងថ្លៃពី 0 ដល់ ១០០ដុល្លារ សម្រាប់ដីមួយឡូង៉ (៣ម x ៤០០ម) ដែលនៅតាមបណ្តោយផ្លូវ និងពី ២០០០-៣០០០ដុល្លារ/ហិកតា សម្រាប់ដីនៅឆ្ងាយពីផ្លូវ។ ស្រដៀងគ្នាដែរ ដំណាំដែលពីមុនលក់ថ្លៃ ២០០រៀល/គីឡូក្រាម ឬត្រូវគេទុករលួយចោលដោយសារកង្វះមធ្យោបាយយកទៅកាន់ទីផ្សារនោះ បានឡើងថ្លៃពី ៧០០រៀល ទៅ ៩០០រៀល/គីឡូក្រាម។

> *"អ្នកទិញមកដល់ភូមិ ហើយពួកគេប្រជែងគ្នាដើម្បីបានផលិតផលរបស់យើង។ យើងសប្បាយរីករាយណាស់ ព្រោះវាធ្វើឲ្យផលិតផលយើងឡើងថ្លៃ ហើយឈ្មួញអាចដឹកជញ្ជូនផលិតផលដោយខ្លួនគេបានទៀត។ ប្រសិនបើឈ្មួញមិនមក យើងក៏អាចយកផលិតផលទៅផ្សារផ្ទាល់ដែរ។"*

ជីវភាពប្រជាជន ប្រសើរជាងមុនដោយសារតែមានផ្លូវល្អ។ អ្នកជំនួញអាចចូលដល់ក្នុងភូមិ ដែលបង្កើតជាទីផ្សារមួយសម្រាប់ផលិតកម្មដាំដុះ។ ផ្លូវនេះនាំមកនូវភ្ញៀវទេសចរមកទស្សនាទឹកធ្លាក់ដ៏ស្រស់ស្អាត ហើយកម្មវិធីអភិរក្សបរិស្ថានក្នុងភូមិបង្កើតការងារសម្រាប់អ្នកភូមិផងដែរ។

*"យើងមានគណៈកម្មាធិការអេកូទេសចរណ៍ក្នុងភូមិសម្រាប់រក្សាទឹកធ្លាក់ដ៏ស្រស់ស្អាតរបស់យើង។ មនុស្សវ័យជំទង់ធ្វើការងារជាអ្នកមើលថែតំបន់នេះ។ ជនបរទេសត្រូវបង់ប្រាក់ ៤០០០រៀល ដើម្បីចូលទស្សនាតំបន់នេះ រីឯភ្ញៀវទេសចរជនជាតិខ្មែរ ត្រូវបង់ប្រាក់ ៥០០រៀល។ ចំណូល ១០% បានទៅឃុំ ២០% បានទៅមន្ទីរទេសចរណ៍ខេត្ត ៣៥% បានទៅគណៈកម្មាធិការ និងសល់ប៉ុន្មានរក្សាទុកក្នុងធនាគារសម្រាប់ការអភិវឌ្ឍផ្សេងៗទៀតក្នុងតំបន់។ ប្រជាជនអាចរកប្រាក់ពីការលក់អាហារក្នុងតំបន់នេះ។"*

*ការព្រួយបារម្ភ*

ផ្លូវនេះ បាននាំមកនូវគុណវិបត្តិមួយចំនួន ជាពិសេសអំឡុងពេលសាងសង់ ដោយសារផ្ទះមួយចំនួន ក្នុងតំបន់ដែលត្រូវសង់ផ្លូវកាត់នោះ ត្រូវបានវាយចោល។ យ៉ាងណាក្តី ក៏មានការផ្តល់ជាសំណងផងដែរ៖ ម្ចាស់ផ្ទះតូចៗ ទទួលបានប្រាក់ ៣០០ ដុល្លារ សម្រាប់ការផ្លាស់ទីលំនៅ។ លើសពីនេះទៀត អ្នកចូលរួមបានឲ្យដឹងថា មានគ្រោះថ្នាក់ច្រើនជាងមុនដោយសារផ្លូវល្អ ព្រោះអ្នកបើកម៉ូតូបើកលឿនហួស មិនមានផ្លាកសញ្ញាច្បាស់លាស់នៅពេលយប់ ឬមិនមានសញ្ញាដាស់តឿនត្រឹមត្រូវឡើយ។

៣. សេចក្តីសន្និដ្ឋាន

ផ្លូវល្អនេះ ជួយប្រជាជនឲ្យមានជីវភាពប្រសើរជាងមុន និងអាចឲ្យស្ថាប័នជាច្រើនចូលដល់ភូមិ ដើម្បីជួយអភិវឌ្ឍន៍ភូមិ។ តែផ្លូវល្អ គួរមានផ្លាកសញ្ញាសុវត្ថិភាពគ្រប់គ្រាន់ ដើម្បីដាស់តឿនដល់អ្នកបើកបរឲ្យមានការប្រុងប្រយ័ត្ន និងគួរមានគុណភាពល្អគ្រប់គ្រាន់ ដើម្បីឲ្យផ្ទៃថ្នល់មានភាពរឹងមាំ និងជាប់បានយូរ។

*FGD ៥៖ ភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង*

កាលបរិច្ឆេទ៖ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០
ពេល៖ ១០:០០-១៣:០០
ទីតាំង៖ ភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកថាឡាបរីវ៉ាត់ ខេត្តស្ទឹងត្រែង
អ្នកសម្របសម្រួល៖ ប៉ុន ដូរីណា
អ្នកកត់ត្រា៖ ស្រ៊ី បុប្ផារ័ត្ន

១. សាវតារសហគមន៍ និងអ្នកចូលរួម

ភូមិអូរស្វាយ មានចម្ងាយ ១២គ.ម ពីផ្លូវជាតិលេខ៧ ដែលស្គាល់ថាជាផ្លូវអាស៊ាន។ អ្នកភូមិភាគច្រើន ជាកសិករ ហើយដាំស្រូវ ពោត សណ្តែកសៀង និងល្ង។ ការងារបម្រុងរបស់ពួកគេ គឺការកាប់ឈើ។ ប៉ុន្តែថ្មីៗនេះ មិនមានអ្នកភូមិច្រើនទេ បន្តការកាប់ឈើ ព្រោះពួកគេមិនអាចរកប្រាក់បានច្រើន ហើយវាជាការងារមានហានិភ័យខ្ពស់។ ភូមិនេះមាន ២១១គ្រួសារ ភាគច្រើនធ្វើស្រូវវស្សាមួយដងក្នុង១ឆ្នាំ ហើយមានប្រមាណ ១០គ្រួសារ បើកតូបលក់គ្រឿងទេស។ ក្រៅពីដាំស្រូវ អ្នកភូមិស៊ីឈ្នួលប្រមូលផលពោត ធ្វើងាតត្រី និងធ្វើការងារសំណង់នៅក្នុងភូមិ។ ពួកគេក៏ចូលក្នុងព្រៃប្រមូលជ័រឈើ និងបរបាញ់សត្វព្រៃផងដែរ។

| *លេខ* | *ឈ្មោះ* | *ភេទ* | *អាយុ* | *ការអប់រំ* | *មុខរបរ* | *ចំនួនសមាជិកគ្រួសារ* |
|---|---|---|---|---|---|---|
| ១ | សានង នឿន | ស | ៦៤ | ការអប់រំក្រៅផ្លូវការ | កសិករ | ៥ |
| ២ | នង ពី | ស | ៣៤ | ៣ | កសិករ | ៥ |
| ៣ | នង ឡេង | ស | ២៩ | ៣ | មេផ្ទះ | ៥ |
| ៤ | ច្រឹក គន្ធា | ស | ៣៣ | ៥ | អ្នកលក់សាច់ជ្រូក | ៧ |
| ៥ | គាវ សុខគីម | ស | ២៧ | ៣ | អ្នកលក់គ្រឿងទេស | ៦ |
| ៦ | ស៊ិន ប៊ុនឡៃន | ស | ២៣ | ៨ | អ្នកលក់ (មី) | ៦ |
| ៧ | គីម សុខឃៀង | ប | ៤៨ | ៣ | កសិករ | ៧ |
| ៨ | ជា ចាន់ធឿន | ស | ៥៣ | ១០ | អ្នកលក់ (បង្អែម) | ៦ |
| ៩ | វ៉ាន សេណា | ប | ២៨ | 0 | កសិករ | ៦ |
| ១០ | នង ទៀង | ប | ៦៤ | N/A | កសិករ | ៤ |

២. ផលប៉ះពាល់

*ពេលវេលា និងចំណាយលើការធ្វើដំណើរ៖* មុនពេលមានផ្លូវជាតិនេះ អ្នកភូមិត្រូវធ្វើដំណើរដោយទូកម៉ាស៊ីន តាមទន្លេទៅខេត្តស្ទឹងត្រែង។ ក្នុងការធ្វើដំណើរទៅស្ទឹងត្រែង អ្នកភូមិត្រូវចំណាយយ៉ាងតិច ១០០.០០០រៀល៖ ៥០.០០០រៀលសម្រាប់ទូកម៉ាស៊ីនលឿន និងតិចបំផុត ២០.០០០រៀល សម្រាប់ទូកយឺត។ ការធ្វើដំណើរមិនត្រឹមតែចំណាយប្រាក់អស់ច្រើនប៉ុណ្ណោះទេ តែថែមទាំងប្រើពេលច្រើនទៀតផង ដោយសារពួកគេត្រូវស្នាក់នៅតាមផ្លូវទៅខេត្តស្ទឹងត្រែងមួយយប់។ ចាប់ពីពេលមានផ្លូវមក អ្នកភូមិចំណាយប្រាក់ និងពេលវេលាតិចជាងមុនក្នុងការធ្វើដំណើរ។

*"ពីមុន ពេលទៅស្ទឹងត្រែង ខ្ញុំត្រូវពិចារណាថាត្រូវទៅប៉ុន្មានដង ដោយសារខ្ញុំមិនមានលុយច្រើន ហើយខ្ញុំត្រូវចំណាយយ៉ាងច្រើនលើការធ្វើដំណើរ និងត្រូវស្នាក់នៅតាមផ្លូវមួយយប់ ឬពីរយប់។"*

*លទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាព៖* មុនពេលមានផ្លូវនេះ សិស្សភាគច្រើនរៀនត្រឹមថ្នាក់ទី៣។ ឥឡូវពួកគេអាចបន្តថ្នាក់ខ្ពស់ជាងមុននៅស្ទឹងត្រែង ដោយសារការធ្វើដំណើរ ចំណាយពេលពី ១ម៉ោងទៅមួយម៉ោងកន្លះប៉ុណ្ណោះ។

អ្នកភូមិឈឺធ្ងន់ ឬត្រូវការសម្រាលកូន អាចទៅមន្ទីរពេទ្យស្ទឹងត្រែងទាន់ពេលវេលា។

*"ប្រពន្ធខ្ញុំស្លាប់ ដោយសារការធ្លាក់ឈាមបន្ទាប់ពីសម្រាលកូនរួច ព្រោះមិនមានឧបករណ៍គ្រប់គ្រាន់។"*

*ថ្លៃដី និងថ្លៃផលិតផលដាំដុះ៖* ឥឡូវនេះ ដីមានថ្លៃខ្ពស់ខ្លាំង។ ដីមួយឡូង៍ (៥០ម x ៥០ម) ថ្លៃពី ៥.០០០ដុល្លារ ទៅ ៦.០០០ដុល្លារ។ ចាប់តាំងពីឆ្នាំ២០០៣មក មានអ្នកចំណូលថ្មីជាច្រើន មកពីខេត្តកំពង់ចាម តាកែវ និងកំពង់ធំ បានចូលមករស់នៅក្នុងភូមិ និងទិញដីដើម្បីដាំដុះ។

*"អ្នកភូមិធ្លាប់ត្រូវការប្រាក់ពី ០,១ ទៅ ០,២តម្លឹង ដើម្បីទិញដីមួយឡូង៍ទំហំ ២០ម x ៣០ម តែឥឡូវពួកគាត់ត្រូវការ ១ ទៅ ២ដំឡឹង។ បន្ទាប់ពីផ្លូវអាស៊ានសង់រួចមក អ្នកចំណូលថ្មីជាច្រើនបានចូលមករស់នៅក្នុងភូមិនេះ ដែលជាហេតុនាំឲ្យដីឡើងថ្លៃខ្ពស់។ ដីលំនៅស្ថាន និងដីដាំដុះ មានការឡើងថ្លៃ។"*

នៅតាមផ្លូវជាតិនេះ មានអ្នកលក់ដូរជាច្រើននាក់។ ឈ្មួញកណ្តាល អាចទិញផលិតផលពីអ្នកភូមិយ៉ាងស្រួល ដោយសារគាត់អាចទៅភូមិរាល់ថ្ងៃ ឬនៅពេលមានផលិតផល។ ដូច្នេះ ផលិតផលរបស់អ្នកភូមិ ទទួលបានថ្លៃខ្ពស់ជាងមុន។ ឧទាហរណ៍ សណ្តែកសៀង ឥឡូវលក់ថ្លៃពី ៤០០០ ទៅ ៥០០០រៀល/គីឡូក្រាម ជាហេតុនាំឲ្យអ្នកភូមិដាំសណ្តែកសៀងច្រើនជាងមុន។ បន្ទាប់ពីមានផ្លូវជាតិ ថ្លៃអាហារ ព្រមទាំងទំនិញប្រើប្រាស់ផ្សេងៗ ក៏ឡើងថ្លៃខ្ពស់ណាស់ដែរ។ មុនពេលមានផ្លូវ អ្នកភូមិ

ចំណាយប្រាក់ និងពេលវេលាច្រើនលើការដឹកជញ្ជូនផលិតផលទៅទីផ្សារដែលនៅឆ្ងាយ ហើយធ្វើឲ្យផលិតផលគាត់មិនអាចរក្សាភាពស្រស់ល្អពេលទៅដល់។ ដូច្នេះ ពួកគេមិនអាចចរចាសុំថ្លៃឲ្យបានខ្ពស់នោះទេ។ គ្មានឈ្មួញកណ្ដាលណាមកទិញផលិតផលដែលតែងតែសល់រលួយនោះទេ។

អត្ថប្រយោជន៍ផ្សេងទៀត៖

- *ប្រយោជន៍ទូទៅ៖* ពីមុន គ្មានសេវាកម្មរថយន្តឈ្នួល ក្នុងភូមិនេះទេ តែឥឡូវមានរថយន្តចំនួន ៦គ្រឿង រត់ពីភូមិទៅស្ទឹងត្រែង។ ថ្លៃដឹកជញ្ជូនផលិតផលពីភូមិទៅស្ទឹងត្រែងគឺ ៣០.០០០រៀល ធៀបនឹងពីមុន ៥០.០០០រៀល/តោន តាមទូកម៉ាស៊ីន។
- *ការភ្ជាប់ទំនាក់ទំនងនឹងភ្នាក់ងារអភិវឌ្ឍន៍៖* ធនាគារ អេស៊ីលីដា បានបង្កើតឡើងក្នុងភូមិនេះ ក្នុងឆ្នាំ២០០៥ ហើយ AMK មកដល់ក្នុងឆ្នាំ២០០៩។ អ្នកភូមិភាគច្រើនខ្ចីលុយពី AMK។ ក្នុងអំឡុងពេលសិក្សា អ្នកភូមិអាចខ្ចីប្រាក់រហូតដល់ ២០០០ដុល្លារ ក្នុងអត្រាការប្រាក់ ២,៨% ក្នុង១ខែ។ អ្នកភូមិត្រូវសងវិញក្នុងរយៈពេល១៨ខែបន្ទាប់។ AMK ប្រមូលការប្រាក់ជារៀងរាល់ខែ។ ប្រសិនបើប្រជាជនខ្ចីជាក្រុម ពួកគាត់មិនចាំបាច់ដាក់អ្វីបញ្ចាំនោះទេ។ ការខ្ចីជាក្រុមបែបនេះ ជួយ អ្នកភូមិឲ្យពង្រីកការដាំដុះរបស់ពួកគាត់ និងឆ្លើយតបនឹងសេចក្ដីត្រូវការបន្ទាន់។

*<u>ការព្រួយបារម្ភ</u>*

*សុវត្ថិភាពតាមផ្លូវ៖* គ្រោះថ្នាក់ចរាចរណ៍ជាច្រើនបានកើតឡើង ចាប់ពីមានផ្លូវថ្មីដោយសារអ្នកបើកបរ បើកក្នុងល្បឿនលឿនជាងមុនលើផ្លូវរលោង។

*ផលប៉ះពាល់ផ្សេងទៀត៖* ម្ចាស់ទូកម៉ាស៊ីនជាច្រើន បាត់បង់ការងារ ដោយសារអ្នកភូមិឈប់ធ្វើដំណើរតាមទូក។ មានតែអ្នកភូមិម្នាក់ប៉ុណ្ណោះ នៅប្រើទូករបស់គាត់សម្រាប់ដឹកជញ្ជូន និងទេសចរណ៍។ តាមធម្មតា អ្នកភូមិធ្លាប់បរបាញ់សត្វ និងប្រមូលជ័រឈើ ដែលទម្លាប់នេះមានការធ្លាក់ចុះ ចាប់តាំងពីផ្លូវថ្មីសង់រួច។ ផ្លូវនេះបានទាក់ទាញក្រុមហ៊ុនឯកជនដែលបានចូលមកធ្វើការកាប់ឈើ ធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍អ្នកភូមិពីព្រៃឈើ។

៣.សេចក្ដីសន្និដ្ឋាន

ជារួមមក អ្នកភូមិមានជីវភាពប្រសើរជាងមុន ដោយសារពួកគាត់ចំណាយពេលវេលា និងប្រាក់តិចជាងមុន លើការធ្វើដំណើរទៅស្ទឹងត្រែង និងរាជធានីភ្នំពេញ។ តែអ្នកភូមិមិនអាចទទួលបានប្រយោជន៍ច្រើនពីធនធានព្រៃឈើ ដូចមុនពេលមានផ្លូវថ្មីនោះទេ។

*FGD ៦៖ ភូមិរាជានុកូល ឃុំស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង*

កាលបរិច្ឆេទ៖ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០
ពេល៖ ១៧:០០-១៨:៣០
ទីតាំង៖ ភូមិរាជានុកូល ឃុំស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
អ្នកសម្របសម្រួល៖ ប៊ុន ដូរីណា
អ្នកកត់ត្រា៖ ស្រី បុប្ផារ័ត្ន

កិច្ចពិភាក្សា FGD ធ្វើឡើងក្នុងពេលល្ងាចបន្តិច។ អ្នកភូមិប្រហែលពាក់កណ្ដាលជាទាហាន ដូច្នេះ ទាហាន និងភរិយារបស់គាត់ អាចចូលរួមក្រុមពិភាក្សានេះបាន។ អ្នកចូលរួមសរុបមានចំនួន ១១នាក់។

| *លេខ* | *ឈ្មោះ* | *ភេទ* | *អាយុ* | *ការអប់រំ* | *មុខរបរ* | *ចំនួនសមាជិកគ្រួសារ* |
|---|---|---|---|---|---|---|
| ១ | ឱប សំអឿន | ស | ៥០ | 0 | មេផ្ទះ | ៥ |
| ២ | ឆយ ហួយ | ស | ៤៧ | 0 | មេផ្ទះ | ៩ |
| ៣ | សុខ មុំ | ស | ៤៥ | 0 | កសិករ | ៩ |
| ៤ | ខៀវ ចាន់ណា | ស | ២៣ | ៦ | មេផ្ទះ | ៥ |
| ៥ | វ៉ាន់ ណារី | ស | ៤៥ | ៣ | មេផ្ទះ | ៦ |
| ៦ | ចូវ សីសេងវៀន | ស | ៣១ | ២ | មេផ្ទះ | ៤ |
| ៧ | បិន សុភក្តិ | ប | ៣៣ | ៧ | កសិករ | N/A |
| ៨ | ហុង សារុន | ប | ៦៦ | ៩ | ជំនួយការមេភូមិ | ៣ |
| ៩ | អេង សារី | ប | ៤០ | ៩ | កសិករ | ៨ |
| ១០ | ឡាវ ឈន់ | ប | ៥៣ | ៩ | ទាហាន & កសិករ | ៧ |
| ១១ | ថន សុភាព | ស | ៤៦ | ២ | កសិករ | ៦ |

១. សាវតារសហគមន៍/អ្នកចូលរួម

ភូមិរាជានុកូល មានចម្ងាយ ២០គ.ម ពីស្ទឹងត្រែង (មាត់ទន្លេ) និងចម្ងាយ ១៤០គ.ម ពីអូរពងមាន់ ខេត្តក្រចេះ។ កាលពី ២ ឬ ៣ឆ្នាំមុន នៅមុនពេលដែលទាហានជាច្រើនទទួលបានដីនៅក្នុងភូមិ (ទំហំ ១០ម x ៣០ម ក្នុងទាហានម្នាក់ៗ) មានតែពីរបីគ្រួសារប៉ុណ្ណោះ ដែលរស់នៅក្នុងភូមិនេះ។ អ្នកភូមិប្រហែលពាក់កណ្តាល ជាទាហាន ហើយការដាំដុះជាមុខរបរបន្ទាប់បន្សំរបស់ពួកគេ។ អ្នកភូមិដាំដំឡូងឈើ និងស្វាយចន្ទី។ អ្នកភូមិដែលគ្មានដីធ្លី ធ្វើការជាកម្មករកាត់ស្មៅ និងឈើ រើសផ្លែស្វាយចន្ទី និងដើរចាំចម្ការឲ្យអ្នកដទៃ។ ប្រជាពលរដ្ឋមិនអាចបង្កបង្កើនផលក្នុងភូមិនេះទេ ដោយសារដីមិនអំណោយផល និងគ្មានប្រព័ន្ធធារាសាស្ត្រ។

២. ផលប៉ះពាល់

*ពេលវេលា និងចំណាយលើការធ្វើដំណើរ៖* ពីមុន ការធ្វើដំណើរពីភូមិទៅភ្នំពេញ ត្រូវចំណាយពេល២ថ្ងៃ២យប់ និងពីភូមិទៅស្ទឹងត្រែងចំណាយពេល២ម៉ោង។ ថ្លៃធ្វើដំណើរទៅភ្នំពេញគឺ ៥០.០០០រៀល ហើយ ៣០.០០០រៀលទៅស្ទឹងត្រែង។ ដោយសារចំណាយលើការធ្វើដំណើរខ្ពស់ អ្នកភូមិទៅស្ទឹងត្រែង ក្នុងគោលបំណងរកស៊ីប៉ុណ្ណោះ។ ពេលវេលា និងថ្លៃធ្វើដំណើរ បានថយចុះចាប់តាំងពីមានផ្លូវថ្មី។ ឥឡូវ គេចំណាយពេលតែ ២០នាទី ដើម្បីទៅស្ទឹងត្រែង និងរយៈពេល ១ថ្ងៃទៅដល់ភ្នំពេញ។ ផ្លូវថ្មីផ្តល់លទ្ធភាពឲ្យអ្នកភូមិក្មេងៗ រកការងារក្រៅភូមិបាន។

*លទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាព៖* មានសាលាបឋមសិក្សាមួយនៅក្នុងភូមិ ហើយអនុវិទ្យាល័យ ត្រូវបានបង្កើតឡើងកាលពី២ឆ្នាំមុន។ ក្មេងភាគច្រើនក្នុងភូមិ អាចទទួលបានការអប់រំ។ តែសម្រាប់ការសិក្សាថ្នាក់លើសនោះ សិស្សត្រូវធ្វើដំណើរទៅខេត្តស្ទឹងត្រែង។ សិស្សស្រីហាក់មានតិចជាងសិស្សប្រុស ដោយសារឪពុកម្តាយភាគច្រើន គិតថាកូនប្រុសគួរបានរៀនសូត្រខ្ពស់ជាងកូនស្រី។

ដោយសារមានផ្លូវថ្មីនេះ អ្នកភូមិអាចទៅមណ្ឌលសុខភាពខេត្តស្ទឹងត្រែង ហើយវេជ្ជបណ្ឌិត តែងមកភូមិ ដើម្បីផ្តល់ថ្នាំបង្ការមួយខែម្តង។ ដោយអាចជាប់រងលើសោហ៊ុយធ្វើដំណើរបាននោះ ស្ត្រីក្នុងភូមិតែងទៅកាន់មន្ទីរពេទ្យខេត្តស្ទឹងត្រែង ដើម្បីសម្រាលកូន ដែលជាការកាត់បន្ថយនូវហានិភ័យនៃផលវិបាកផ្សេងៗ ធៀបនឹងការបង្កើតកូនដោយឆ្មបបុរាណ។ មានឆ្មបបុរាណមួយចំនួននៅក្នុងភូមិ ដែលបានទទួលការបណ្តុះបណ្តាលពីអង្គការផ្នែកសុខាភិបាលមួយ ប៉ុន្តែអ្នកភូមិតែងទៅកាន់មន្ទីរពេទ្យខេត្តស្ទឹងត្រែងជាជាងនៅក្នុងភូមិ។

*ថ្លៃដី និងផលិតផលដាំដុះ៖* បន្ទាប់ពីផ្លូវបានសង់រួច ដីមួយប្លង់ (១ម x ៣០០ម) ក្បែរផ្លូវជាតិ ថ្លៃ ១០០០ដុល្លារ។ អ្នកទិញភាគច្រើនមកពីខេត្តកំពង់ចាម ភ្នំពេញ និងព្រៃវែង។

ផលិតផលដាំដុះ ក៏ឡើងថ្លៃផងដែរ។ ដំឡូងឈើ ឡើងថ្លៃពី ៣០០រៀល ដល់ ៧០០រៀល/គីឡូក្រាម។ ឈ្មួញកណ្ដាលជាច្រើន ចូលមកក្នុងភូមិ និងទិញផលិតផលរបស់អ្នកភូមិ។

អត្ថប្រយោជន៍ផ្សេងទៀត៖

- *អត្ថប្រយោជន៍ទូទៅ៖* ស្ថានភាពផ្ទះរបស់អ្នកភូមិ មានភាពប្រសើរជាងមុន។ មានគ្រួសារច្រើនជាងមុនរស់នៅក្នុងភូមិនេះ។ អ្នកភូមិ ៧០% មានម៉ូតូផ្ទាល់ខ្លួន។ លើសពីនេះទៀត ទំនិញប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃ អាចរកបាននៅក្នុងភូមិ ដូចជា សាច់គោ សាច់ជ្រូក សាំង ទឹកកក និងបន្លែ ដែលផលិតផលមួយចំនួនក្នុងនោះ មិនអាចដាំ ឬផលិតនៅក្នុងភូមិទេ ហេតុដូច្នេះ គេត្រូវនាំចូលពីភូមិ និងខេត្តដទៃទៀត។
- *ការភ្ជាប់ទំនាក់ទំនងនឹងភ្នាក់ងារអភិវឌ្ឍន៍៖* ស្ថាប័នមីក្រូហិរញ្ញវត្ថុជាច្រើនបានមកដល់ភូមិនេះបន្ទាប់ពីផ្លូវនេះសង់រួច មានជាអាទិ៍ AMK និង អេស៊ីលីដា ជាដើម។ ១៦គ្រួសារក្នុងភូមិនេះ បានបង្កើតជាក្រុម ដើម្បីខ្ចីប្រាក់ពីស្ថាប័នទាំងនោះ ស្របពេលដែល ១០ ទៅ ២០គ្រួសារ បានខ្ចីប្រាក់ជាលក្ខណៈបុគ្គល។ អ្នកភូមិអាចខ្ចីប្រាក់បានពី ៣០០.០០០រៀល ទៅ ២.០០០.០០០រៀល ដែលមានអត្រាការប្រាក់ ៣០.០០០រៀល គិតក្នុងប្រាក់ ១លានរៀល។ លទ្ធភាពងាយស្រួលជាងមុនក្នុងការចូលទៅកាន់ភូមិនេះ បាននាំមកនូវសកម្មភាពថ្មីៗជាច្រើននៅក្នុងភូមិ។ អ្នកភូមិបានគូសបញ្ជាក់ពីវត្តមានរបស់ក្រុមហ៊ុន អាន ម៉ារ៉ាឌី ដែលបានដាំកៅស៊ូលើដីសម្បទានផ្ដល់ដោយរដ្ឋាភិបាល។ បន្ថែមពីនេះទៀត ឈ្មួញកណ្ដាលមកភូមិ ដើម្បីប្រាប់ប្រជាជនអំពីឱកាសការងារនៅក្រៅប្រទេស ដូចជា ការងារផ្ទះនៅម៉ាឡេស៊ី ជាដើម។

<u>*ការព្រួយបារម្ភ*</u>

*សុវត្ថិភាពផ្លូវ និងលទ្ធភាពរកប្រាក់ចិញ្ចឹមជីវិត៖* ផ្លូវថ្មីនេះបណ្ដាលឲ្យមានគ្រោះថ្នាក់ចរាចរណ៍ច្រើន ដោយសារការបើកបរមិនប្រុងប្រយ័ត្ន និងកង្វះផ្លាកសញ្ញានៅតាមផ្លូវ។ អ្នកភូមិខ្លះ បានចូលធ្វើការឲ្យក្រុមហ៊ុនសំណង់ចិន ប៉ុន្តែពួកគេបានធ្វើតែពីរបីខែប៉ុណ្ណោះដោយទទួលបានប្រាក់ឈ្នួលពី១០.០០០ទៅ១៥.០០០រៀល/ថ្ងៃ។ការកាប់ឈើដោយក្រុមហ៊ុនវិនិយោគថ្មីៗ ធ្វើឲ្យថយចំណូលពីព្រៃឈើរបស់អ្នកភូមិ។

៣. សេចក្ដីសន្និដ្ឋាន

ក្រោយពីមានផ្លូវជាតិនេះ អ្នកភូមិមានលទ្ធភាពទទួលបានការងារ ការអប់រំ និងប្រាក់ចំណូលប្រសើរជាងមុន។

ឧបសម្ព័ន្ធ ៨៖ ការពិភាក្សាតាមក្រុមស្នូល៖ សំណង់ស្ពានព្រែកតាមាក់ក្រោមមូលនិធិ ODA របស់ចិន

*FGD ១៖ ភូមិកំពង់ដំរី ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល*

កាលបរិច្ឆេទ៖ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩
ទីតាំង៖ ភូមិកំពង់ដំរី ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល
អ្នកសម្របសម្រួល៖ ប៉ុន ដូរីណា
អ្នកកត់ត្រា៖ ស្រ៊ី បុប្ផារ័ត្ន

បញ្ជីរាយនាមអ្នកចូលរួម

| *លេខ* | *ឈ្មោះ* | *ភេទ* | *អាយុ* | *ចំនួនឆ្នាំបានសិក្សា* | *ចំនួនសមាជិកគ្រួសារ* | *តួនាទី* |
|---|---|---|---|---|---|---|
| ១ | មុំ ហឿន | ស | ៦០ | ០ | ១ | អ្នកចូលរួម |
| ២ | ណា វ៉ាន់ស៊ី | ស | ៤៥ | ២ | ៩ | អ្នកចូលរួម |
| ៣ | ពេជ្រ ពក | ស | ៣៤ | ០ | ៩ | អ្នកចូលរួម |
| ៤ | ម៉ុយ សុខជា | ស | ៣៨ | ៤ | ៩ | អ្នកចូលរួម |
| ៥ | ម៉ូ មុំ | ស | ៣០ | ៤ | ៦ | អ្នកចូលរួម |
| ៦ | ជា សិន | ស | ៥០ | ការអប់រំក្រៅផ្លូវការ | ៧ | អ្នកចូលរួម |
| ៧ | មុំ ចន្ទូរ | ស | ៣៦ | ២ | ៦ | អ្នកចូលរួម |
| ៨ | ហោ ជា | ប | ៥៥ | មិនដឹង | មិនដឹង | អ្នកចូលរួម |
| ៩ | យិន អុល | ប | ៥០ | មិនដឹង | មិនដឹង | សមាជិកក្រុមប្រឹក្សាឃុំ |
| ១០ | ហ៊ី តារារិទ្ធ | ប | ៥៥ | មិនដឹង | មិនដឹង | មេភូមិ |

១. សាវតារ

ភូមិកំពង់ដំរី មិនរងការប៉ះពាល់ដោយផ្ទាល់ពីស្ពានថ្មីនេះទេ ប៉ុន្តែសំណង់ស្ពាននេះ នាំឲ្យកម្រិតជីវភាពរស់នៅរបស់អ្នកភូមិមានការប្រែប្រួលជាច្រើន។ ភូមិនេះ មាន ២៧៤គ្រួសារ។ អ្នកចូលរួមក្នុងកិច្ចពិភាក្សានេះ មាន ៨នាក់ (ប្រុស ១នាក់ ស្រី ៧នាក់) ត្រូវបានជ្រើសរើសដោយមេភូមិ ផ្អែកលើកម្រិតជីវភាពរបស់ពួកគេ ដែលកំណត់ថាជាជនក្រីក្រ។ អ្នកចូលរួមម្នាក់ ជាសមាជិកក្រុមប្រឹក្សាឃុំ និងម្នាក់ទៀតជាមេភូមិ។

ក. ការងារចំបងរបស់អ្នកចូលរួម

អ្នកចូលរួម ៧នាក់ ជាអ្នកត្បាញកន្ទេល ហើយអ្នកចូលរួមតែម្នាក់ប៉ុណ្ណោះ ជាអ្នកដាំដុះ។ ការងារបន្ទាប់បន្សំរបស់អ្នកភូមិ គឺស៊ីឈ្នួលធ្វើស្រែ ឬចម្ការ នេសាទ រត់ម៉ូតូឌុប ជាងឈើ លក់ដូរក្បែរសាឡាង និង បញ្ជូនកូនឲ្យធ្វើការក្នុងវិស័យកាត់ដេរ។ អ្នកភូមិអាចរកប្រាក់បានពី ៣០០០រៀល ទៅ ៣៥០០រៀល/ថ្ងៃ ពីការត្បាញកន្ទេល ១៥.០០០រៀល ពីការស៊ីឈ្នួលស្ទូងស្រូវ ៥០០០រៀល ពីការងារដាំដុះ ១៥.០០០រៀល ទៅ ២០.០០០រៀល ពីការងារនេសាទ និង ៣០០០រៀល ពីការងារកាប់ឌស។ តម្បាញជាការងារពេញមួយឆ្នាំ តែការងារនៅស្រែចម្ការ និងនេសាទ ជាការងារតាមរដូវកាល។

ខ. មុខរបរចិញ្ចឹមជីវិតចំបងនៅសហគមន៍

ការងារចំបងរបស់អ្នកចូលរួម គឺការលក់កម្លាំងពលកម្ម ដោយសារពួកគេភាគច្រើន មិនមានដីផ្ទាល់ខ្លួន។ ពួកគេធ្វើការនៅវាលស្រែនៅរដូវច្រូតកាត់ និងធ្វើការនេសាទ នៅរដូវត្រីពង។ អ្នកស្រុកក៏ស៊ីឈ្នួលត្បាញកន្ទេល និងធ្វើការនៅចម្ការដំណាំផងដែរ។

គ. លទ្ធភាពទទួលបានសេវាសង្គមកិច្ច

ក្មេងៗជិះកង់ចម្ងាយ ១គ.ម ពីភូមិទៅសិក្សានៅវិទ្យាល័យព្រះសីហនុរាជ និងសាលាបឋមសិក្សា ហ៊ុន សែន ប៊ុនរ៉ានី។ ក្មេងៗភាគច្រើន អាចចូលសាលាបឋមសិក្សាដែលស្ថិតនៅក្នុងភូមិព្រះប្រសប់ ប៉ុន្តែជាធម្មតាមិនមានលទ្ធភាពផ្គត់ផ្គង់លើការរៀនសូត្រលើសពីថ្នាក់ទី៨ទេ។ ក្មេងៗ ២០% បោះបង់ការសិក្សានៅថ្នាក់បឋមសិក្សា ចំណែកឯការចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យ និងវិទ្យាល័យ មានលក្ខណៈថេរ។ ឆ្នាំទៅ សិស្ស ១៤នាក់ បញ្ចប់វិទ្យាល័យ មានតែសិស្ស ៤នាក់ប៉ុណ្ណោះបន្តការសិក្សាទៅមហាវិទ្យាល័យ។ មណ្ឌលសុខភាពនៅឃុំព្រែកតាមាក់ មានចម្ងាយ១២គ.ម ពីភូមិ។ ប្រជាពលរដ្ឋទៅមណ្ឌលសុខភាព ឬទិញថ្នាំពីផ្សារ បើសិនមានជំងឺស្រាល ប៉ុន្តែពួកគេតែងទៅមន្ទីរពេទ្យព្រះកេតុមាលានៅភ្នំពេញ ប្រសិនបើមានជំងឺធ្ងន់។

២.ផលប៉ះពាល់រំពឹងទុក

ក. ពេលវេលា និងការចំណាយលើការធ្វើដំណើរ

ការធ្វើដំណើរ មានភាពងាយស្រួលជាងមុន ដោយសារអ្នកភូមិមិនចាំបាច់រង់ចាំសាឡាងទៀតទេ ពួកគេអាចធ្វើដំណើរនៅពេលណាដែលចង់ និងចំណាយប្រាក់តិចជាងមុន។ ឧទាហរណ៍ ការធ្វើដំណើរទៅមកពីភូមិទៅភ្នំពេញ ត្រូវចំណាយអស់ ៤០.០០០រៀល។ សាឡាងគិតថ្លៃ ៥០០រៀល សម្រាប់ម៉ូតូមួយ និង ៣០០រៀលសម្រាប់មនុស្សម្នាក់។ ជិះរថយន្តឈ្នួលត្រលប់មកវិញ ត្រូវចំណាយប្រហែល ២០.០០០រៀល។ ជាធម្មតា គេត្រូវចាំ១ម៉ោង ទៅ១ម៉ោងកន្លះ ដើម្បីជិះសាឡាងឆ្លងទន្លេ។ ពេលដែលស្ពានបើកដំណើរការ អ្នកភូមិមិនចាំបាច់បង់ចំណាយទាំងនេះទៀតទេ។ សំខាន់បំផុតនោះ សាឡាងធ្វើការពីម៉ោង ៥ព្រឹក ត្រឹមម៉ោង ៥ល្ងាច ដូច្នេះការធ្វើដំណើរ គឺមានកម្រិត។ ក្នុងករណីបន្ទាន់ អ្នកភូមិត្រូវចំណាយលុយច្រើនជាងនេះលើសាឡាង។

